# សិក្សាអថេរភាព និងសង់ក្រាបនៃអនុគមន៍

STUDY OF FUNCTIONS AND GRAPH SKETCHING

ថ្នាក់ទី ១២ • GRADE 12

ទ្រឹស្តីសង្ខេប • វិធីសាស្ត្រគណនា • លំហាត់ និង ដំណោះស្រាយ

ត្រៀមប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ (បាក់ឌុប) និងប្រឡងសិស្សពូកែ




អ្នករៀបរៀង ៖ លោកគ្រូ ខែម ពុទ្ធី

បោះពុម្ពលើកទី១ ឆ្នាំ ២០២៦

# គណៈកម្មការរៀបរៀង និងត្រួតពិនិត្យ

| | |
|---|---|
| គណៈកម្មការរៀបរៀង | លោកគ្រូ ខែម ពុទ្ធី |
| | លោកគ្រូ ឡាយ ចាន់ហេន |
| ត្រួតពិនិត្យខ្លឹមសារ | លោកគ្រូ ឡាយ ចាន់ហេន |
| រៀបចំខ្លឹមសារ | លោកគ្រូ ខែម ពុទ្ធី |
| រចនាគម្រប និងទំព័រ | លោកគ្រូ ខែម ពុទ្ធី |
| រូបភាព និងតារាង | លោកគ្រូ ខែម ពុទ្ធី |
| កែសម្រួលអក្ខរាវិរុទ្ធ | លោកគ្រូ ខែម ពុទ្ធី |
| គណៈកម្មការពិនិត្យចុងក្រោយ | លោកគ្រូ ខែម ពុទ្ធី |
| | លោកគ្រូ ឡាយ ចាន់ហេន |

សៀវភៅនេះត្រូវបានរៀបចំឡើងយ៉ាងសម្រិតសម្រាំង សម្រាប់សិស្សានុសិស្សថ្នាក់ទី១២ ក្នុងការស្វ័យសិក្សា និងត្រៀមប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ (បាក់ឌុប) ព្រមទាំងការប្រឡងសិស្សពូកែទូទាំងប្រទេស។

**ព័ត៌មានសៀវភៅ**

កំណែសាកល្បង © ២០២៦

# សិក្សាអថេរភាព និងសង់ក្រាបនៃអនុគមន៍ ថ្នាក់ទី១២

**STUDY OF FUNCTIONS - GRADE 12**

រៀបរៀងដោយ **លោកគ្រូ ខែម ពុទ្ធី**

សម្រាប់បោះពុម្ពផ្សាយ៖ **បណ្ណាគារអង្គរ**

# សេចក្តីឧទ្ទិស

សៀវភៅ «**សិក្សាអថេរភាព និងសង់ក្រាបនៃអនុគមន៍**» នេះ
សូមឧទ្ទិសជូនចំពោះ៖

ភរិយាជាទីស្រឡាញ់

**ថៃ៉ត សុគន្ធា**

និង

កូនស្រីជាទីស្រឡាញ់

**ខែម សោភា**

ដែលជាកម្លាំងចិត្ត និងជាប្រភពនៃសុភមង្គលដ៏កក់ក្តៅ
ក្នុងដំណើរជីវិត និងការស្រាវជ្រាវរបស់ខ្ញុំបាទជានិច្ចនិរន្តរ៍។

**លោកគ្រូ ខែម ពុទ្ធី**

# អារម្ភកថា

គណិតវិទ្យា គឺជាមូលដ្ឋានគ្រឹះដ៏មានសារៈសំខាន់បំផុត ក្នុងការអភិវឌ្ឍការគិតបែបសមហេតុផល វិភាគស៊ីជម្រៅ និងការដោះស្រាយបញ្ហាក្នុងវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងជីវភាពរស់នៅជាក់ស្តែង។ ក្នុងចំណោមប្រធានបទគណិតវិទ្យាថ្នាក់ទី១២ «**ការសិក្សាអថេរភាព និងសង់ក្រាបនៃអនុគមន៍**» គឺជាស្នូលដ៏សំខាន់បំផុតនៃគណិតវិភាគ (Calculus) ដែលសិស្សានុសិស្សគ្រប់រូបត្រូវតែក្តាប់ឱ្យបានច្បាស់លាស់ ទាំងទ្រឹស្តី ទាំងវិធីសាស្ត្រគណនា និងការអនុវត្តជាក់ស្តែង សម្រាប់ត្រៀមខ្លួនប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ (បាក់ឌុប) ព្រមទាំងការប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេស។

សៀវភៅ «**សិក្សាអថេរភាព និងសង់ក្រាបនៃអនុគមន៍ ថ្នាក់ទី១២**» មួយក្បាលនេះ ត្រូវបានរៀបចំឡើងយ៉ាងហ្មត់ចត់ និងសម្បូរបែប ដោយបែងចែកខ្លឹមសារជា ៣ មេរៀនចម្បងៗ៖

- **មេរៀនទី១ ៖ អនុគមន៍សនិទាន** — ផ្តោតលើដែនកំណត់ សញ្ញាទ្វេធានិងត្រីធា ទិសដៅអថេរភាព អតិបរមាធៀបនិងអប្បបរមាធៀប ចំណុចរបត់ សិក្សាទីតាំងធៀប អនុគមន៍គូ-សេស អ័ក្សឆ្លុះ-ផ្ចិតឆ្លុះ បន្ទាត់ប៉ះ អាស៊ីមតូតឈរ-ដេក-ទ្រេត ព្រមទាំងប្លង់សិក្សាអថេរភាព និងសង់ក្រាបនៃអនុគមន៍សនិទានគ្រប់ទម្រង់ ព្រមជាមួយលំហាត់អនុវត្តន៍យ៉ាងក្បោះក្បាយ។
- **មេរៀនទី២ ៖ អនុគមន៍អិចស្ប៉ូណង់ស្យែល** — ពន្យល់ពីនិយមន័យ លក្ខណៈគ្រឹះ សមីការនិងវិសមីការអ៊ិចស្ប៉ូណង់ស្យែល រូបមន្តដេរីវេ លីមីតសំខាន់ៗ វិធីសាស្ត្រសិក្សាអថេរភាព និងសង់ក្រាបតាងអនុគមន៍អ៊ិចស្ប៉ូណង់ស្យែល ព្រមទាំងកម្រងលំហាត់អនុវត្តន៍កម្រិតខ្ពស់។
- **មេរៀនទី៣ ៖ អនុគមន៍លោការីត** — ពិភាក្សាលម្អិតលើនិយមន័យ លក្ខណៈនៃលោការីតនេពែ ដេរីវេ លីមីត សមីការ វិសមីការ និងប្រព័ន្ធសមីការលោការីត ដំណើរការសិក្សាអថេរភាព និងសង់ក្រាប ព្រមទាំងកម្រងលំហាត់សរុបជំពូកទី៤ សម្រាប់វាស់ស្ទង់សមត្ថភាពសិស្ស។

សៀវភៅនេះត្រូវបានរចនាឡើងយ៉ាងយកចិត្តទុកដាក់ មានក្រឡាសៀវភៅសរសេរ (Seyes Grid) សម្រាប់សិស្សអនុវត្តដោះស្រាយដោយផ្ទាល់ដៃ និងមានរូបភាពគំនូសក្រាហ្វិកគណិតវិទ្យា TikZ យ៉ាងច្បាស់លាស់។

ខ្ញុំបាទសង្ឃឹមយ៉ាងមុតមាំថា សៀវភៅនេះនឹងក្លាយជាមគ្គុទេសក៍ និងជាកម្រងឯកសារជំនួយស្មារតីដ៏មានតម្លៃបំផុតសម្រាប់លោកគ្រូ អ្នកគ្រូ និងប្អូនៗសិស្សានុសិស្សក្នុងការបង្រៀននិងរៀន។ ទោះបីជាមានការខិតខំប្រឹងប្រែងយ៉ាងណាក្តី ក៏សៀវភៅនេះប្រាកដជាមិនអាចជៀសផុតពីកំហុសអចេតនាណាមួយឡើយ។ ខ្ញុំបាទរង់ចាំទទួលនូវរាល់មតិរិះគន់ស្ថាបនាពីសំណាក់លោកគ្រូ អ្នកគ្រូ និងមិត្តអ្នកអានដោយក្តីរីករាយជានិច្ច។

រាជធានីភ្នំពេញ ថ្ងៃទី.......... ខែ.......... ឆ្នាំ២០២៦

**លោកគ្រូ ខែម ពុទ្ធី**

# សេចក្ដីដឹងគុណ

ជាបឋម ខ្ញុំបាទ **លោកគ្រូ ខែម ពុទ្ធី** សូមលំឱនកាយវាចាចិត្ត ថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ជូនចំពោះលោកអ្នកមានគុណទាំងពីរ គឺមាតា និងបិតារបស់ខ្ញុំ ដែលលោកទាំងពីរបានពលិកម្មគ្រប់បែបយ៉ាង ចិញ្ចឹមបីបាច់ថែរក្សា ផ្ដល់ភាពកក់ក្ដៅ និងអប់រំទូន្មានប្រៀនប្រដៅខ្ញុំបាទតាំងពីកុមារភាព រហូតធ្វើឱ្យខ្ញុំអាចឈរយ៉ាងរឹងមាំនៅលើវិថីជីវិតមួយនេះ។ បើគ្មានការលះបង់ និងសេចក្ដីស្រឡាញ់ដ៏មហាសាលពីលោកទាំងពីរទេ នោះខ្ញុំបាទក៏ប្រហែលជាគ្មានថ្ងៃនេះឡើយ។

ជាបន្តបន្ទាប់ ខ្ញុំបាទសូមសម្ដែងនូវសេចក្ដីគោរពដឹងគុណយ៉ាងស្មោះស្ម័គ្រ ជូនចំពោះលោកគ្រូ អ្នកគ្រូ និងសាស្ត្រាចារ្យគ្រប់លំដាប់ថ្នាក់ តាំងពីកម្រិតបឋមសិក្សា រហូតដល់ថ្នាក់សាកលវិទ្យាល័យ ដែលបានខិតខំចំណាយកម្លាំងកាយចិត្តក្នុងការផ្ទេរនូវចំណេះដឹង និងបណ្ដុះបណ្ដាលរូបខ្ញុំឱ្យក្លាយជាធនធានមនុស្សមួយរូបប្រកបដោយសមត្ថភាព។ រាល់ដំបូន្មានដែលទទួលបានពីលោកគ្រូ អ្នកគ្រូ គឺជាប្រទីបបំភ្លឺផ្លូវដែលតែងតែចង្អុលបង្ហាញឱ្យខ្ញុំបាទដើរលើកន្លងដ៏ត្រឹមត្រូវ។

ជាពិសេសលើសពីនេះទៅទៀត ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងផ្ញើជូននូវសេចក្ដីស្រឡាញ់ដ៏ធំធេងមិនអាចកាត់ថ្លៃបាន ជូនចំពោះភរិយាជាទីស្រឡាញ់របស់ខ្ញុំ គឺលោកស្រី **ង៉ែត សុគន្ធា** ព្រមទាំងកូនស្រីជាទីស្រឡាញ់ **ខែម សោភា** ដែលតែងតែនៅក្បែរ ផ្ដល់ភាពកក់ក្ដៅ មើលថែទាំ លើកទឹកចិត្ត និងលះបង់គ្រប់បែបយ៉ាង ដើម្បីឱ្យខ្ញុំបាទមានពេលវេលាពេញលេញក្នុងការស្រាវជ្រាវ និងចងក្រងសៀវភៅមួយក្បាលនេះឡើងរហូតទទួលបានជោគជ័យ។

សៀវភៅ «**សិក្សាអថេរភាព និងសង់ក្រាបនៃអនុគមន៍**» មួយក្បាលនេះ មិនអាចលេចចេញជារូបរាងឡើងបានឡើយ ប្រសិនបើគ្មានការលើកទឹកចិត្តពីមនុស្សជាច្រើនជុំវិញខ្លួនខ្ញុំ។ ខ្ញុំបាទសូមអរគុណដល់មិត្តភក្តិ បងប្អូន និងសហការីទាំងអស់ ដែលតែងតែផ្ដល់មតិយោបល់ ជួយកែសម្រួល និងជួយជំរុញទឹកចិត្តខ្ញុំនៅក្នុងដំណើរការនៃការចងក្រងសៀវភៅនេះជាភាសា LaTeX។ ជាចុងបញ្ចប់ ខ្ញុំបាទសូមប្រសិទ្ធពរជ័យ សិរីសួស្ដី ជ័យមង្គល ជូនដល់លោកអ្នកមានគុណ លោកគ្រូ អ្នកគ្រូ ភរិយា កូនស្រី ព្រមទាំងមិត្តអ្នកសិក្សាទាំងអស់ សូមប្រកបដោយសុខភាពល្អបរិបូរណ៍ ប្រាជ្ញាភ្លឺថ្លា ជោគជ័យគ្រប់ភារកិច្ច និងសម្រេចបាននូវរាល់បំណងប្រាថ្នាក្នុងជីវិតជានិរន្តរ៍។

ថ្ងៃទី.......... ខែ.......... ឆ្នាំ២០២៦

**លោកគ្រូ ខែម ពុទ្ធី**

# តារាងនិមិត្តសញ្ញាគណិតវិទ្យា

| និមិត្តសញ្ញា | អត្ថន័យ | អានថា / ការប្រើប្រាស់ |
|---|---|---|
| $f(x), y$ | អនុគមន៍នៃ $x$ | អនុគមន៍ $f$ កំណត់លើចន្លោះ $I$ |
| $\Delta x, \Delta y$ | កំណើននៃ $x$ និងកំណើននៃ $y$ | $\Delta x = x - x_0,\ \Delta y = f(x) - f(x_0)$ |
| $f'(x_0)$ | ចំនួនដេរីវេនៃ $f$ ត្រង់ $x_0$ | $f$ ព្រីមនៃ $x_0$ ឬ ដេរីវេត្រង់ $x_0$ |
| $f'(x), y'$ | អនុគមន៍ដេរីវេទីមួយនៃ $f(x)$ | ដេរីវេទីមួយនៃអនុគមន៍ |
| $\dfrac{df}{dx}, \dfrac{dy}{dx}$ | និមិត្តសញ្ញាឡាយប្និស (Leibniz) | ដេរីវេនៃ $y$ ធៀបនឹង $x$ |
| $f''(x), y''$ | អនុគមន៍ដេរីវេទីពីរ | $f$ ព្រីមពីរដងនៃ $x$ |
| $\dfrac{d^2y}{dx^2}$ | និមិត្តសញ្ញាឡាយប្និសដេរីវេទីពីរ | ដេរីវេទីពីរនៃ $y$ ធៀបនឹង $x$ |
| $f^{(n)}(x)$ | ដេរីវេលំដាប់ $n$ នៃ $f(x)$ | ដេរីវេទី $n$ នៃអនុគមន៍ $(n \geq 1)$ |
| $dy$ | ឌីផេរ៉ង់ស្យែលនៃអនុគមន៍ $y$ | $dy = f'(x)dx$ |
| $m$ | មេគុណប្រាប់ទិសនៃបន្ទាត់ប៉ះ | $m = f'(x_0) = \tan\alpha$ |
| $\approx$ | តម្លៃប្រហែល | ស្មើប្រហែល (Approximation) |
| $v(t), a(t)$ | ល្បឿន និងសំទុះនៃចលនា | $v(t) = s'(t),\ a(t) = v'(t) = s''(t)$ |
| $C(x), R(x), P(x)$ | ថ្លៃដើម ចំណូល និងចំណេញ | អនុគមន៍ក្នុងសេដ្ឋកិច្ច |
| $C'(x), R'(x), P'(x)$ | ម៉ាជីណាលនៃថ្លៃដើម ចំណូល ចំណេញ | អត្រាបម្រែបម្រួលមួយឯកតា |
| $\overline{C}(x)$ | ថ្លៃដើមមធ្យម | $\overline{C}(x) = \dfrac{C(x)}{x}$ |
| $\mathbb{R}, \mathbb{N}^*$ | សំណុំចំនួនពិត និងគត់វិជ្ជមាន | $x \in \mathbb{R},\ n \in \mathbb{N}^*$ |
| $\in, \notin$ | ជាធាតុនៃ, មិនមែនជាធាតុនៃ | សញ្ញាជាសមាជិកក្នុងសំណុំ |
| $[a,b], ]a,b[$ | ចន្លោះបិទ និងចន្លោះបើក | $a \leq x \leq b,\ a < x < b$ |

# មាតិកា


**មេរៀនទី ១ : អនុគមន៍សនិទាន** **9**

១ ដែនកំណត់ 9

២ សញ្ញាទ្វេធា 10

៣ ទិសដៅអថេរភាពនៃអនុគមន៍ 11

៤ អតិបរមាធៀប និង អប្បបរមាធៀបនៃអនុគមន៍ 12

៥ សិក្សាទីតាំងធៀប 14

៦ អនុគមន៍គូ និងអនុគមន៍សេស 14

៧ អ័ក្សឆ្លុះ និងផ្ចិតឆ្លុះ 15

៨ បន្ទាត់ប៉ះនឹងក្រាបតាងអនុគមន៍ 16

៩ អាស៊ីមតូត 16

១០ ប្លង់សិក្សាអថេរភាព និងសង់ខ្សែកោង $C: y=f(x)$ 21

១១ អនុគមន៍ $y=f(x)=\frac{ax^2+bx+c}{px+q}$ 22

១២ អនុគមន៍ $y=f(x)=\frac{ax^2+bx+c}{px^2+qx+r}$ 23

**មេរៀនទី ២ : អនុគមន៍អិចស្ប៉ូណង់ស្យែល** **179**

១ និយមន័យ 179

២ លក្ខណៈ 179

៣ សមីការនៃអនុគមន៍អ៊ិចស្ប៉ូណង់ស្យែល 179

៤ ដេរីវេនៃអនុគមន៍អ៊ិចស្ប៉ូណង់ស្យែល 180

៥ លីមីតនៃអនុគមន៍ 182

៦ សិក្សាអនុគមន៍ 183

**មេរៀនទី ៣ : អនុគមន៍លោការីត** **237**

១ និយមន័យ 237

២ លក្ខណៈ 237

៣ ដេរីវេនៃអនុគមន៍ 238

៤ លីមីតនៃអនុគមន៍ 242

៥ សមីការ និងវិសមីការ 242

៦ សិក្សាអនុគមន៍ 246

**មេរៀនទី ៤ ៖ ផ្នែកដំណោះស្រាយ** **415**

ដំណោះស្រាយ មេរៀនទី ១ ៖ អនុគមន៍សនិទាន 415

ដំណោះស្រាយ មេរៀនទី ២ ៖ អនុគមន៍អិចស្ប៉ូណង់ស្យែល 520

ដំណោះស្រាយ មេរៀនទី ៣ ៖ អនុគមន៍លោការីត 571

លំហាត់កិច្ចការផ្ទះ សិក្សាអនុគមន៍ថ្នាក់ទី១២ 718

**ឧបសម្ព័ន្ធ ៖ តារាងរូបមន្ត និងវិធីសាស្ត្រគន្លឹះ** **723**

ក ៖ តារាងរូបមន្តដេរីវេ (Table of Derivatives) 723

ខ ៖ តារាងរូបមន្តព្រីមីទីវ និងអាំងតេក្រាលគ្រឹះ (Primitives & Integrals) 725

គ ៖ លីមីតនៃអនុគមន៍ និងវិធីសាស្ត្រគណនារាងមិនកំណត់ 727

ឃ ៖ ជំហានទាំងស្រុងនៃការសិក្សាអថេរភាព និងសង់ក្រាប (ភាគ ១) 729

ឃ ៖ ជំហានទាំងស្រុងនៃការសិក្សាអថេរភាព និងសង់ក្រាប (ភាគ ២) 730

ង ៖ ធរណីមាត្រវិភាគ និងបន្ទាត់ប៉ះក្រាប (Tangents & Analytic Geometry) 731

ច ៖ រូបមន្តត្រីកោណមាត្រ និងតារាងតម្លៃមុំពិសេស 732

**ឯកសារយោង** **733**



# មេរៀនទី ១

# អនុគមន៍សនិទាន

## ១ ដែនកំណត់

**និយមន័យ ១**

ដែនកំណត់នៃអនុគមន៍ $f$ ជាសំណុំអថេរ $x$ ដែលបណ្ដាលឱ្យអនុគមន៍ $y=f(x)$ មានតម្លៃ។

**ជាទូទៅ ១**

រំលឹកដែនកំណត់នៃអនុគមន៍

- ចំពោះអនុគមន៍ពហុធា $f(x)=a_nx^n+a_{n-1}x^{n-1}+\ldots+a_1x+a_0$ មានន័យចំពោះ $\forall x\in\mathbb{R}$
- អ៊ិចស្ប៉ូណង់ស្យែល $f(x)=e^{U(x)}$ មានន័យចំពោះគ្រប់ $U(x)$ ជារបស់ $\mathbb{R}$
- លោការីតនេពែរ $f(x)=\ln[g(x)]$ មានន័យកាលណា $g(x)>0$
- អនុគមន៍សនិទាន $f(x)=\frac{P(x)}{Q(x)}$ មានន័យកាលណា $Q(x)\neq 0$
- អសនិទាន $f(x)=\sqrt{g(x)}$ មានន័យកាលណា $Q(x)\geq 0$

**លំហាត់គំរូ ១**

រកដែនកំណត់នៃអនុគមន៍ខាងក្រោម៖

ក. $f(x)=\sqrt{x+5}$

ខ. $f(x)=\sqrt{7x-14}$

គ. $f(x)=\sqrt{2x^2-8x+6}$

ឃ. $f(x)=\sqrt{16-4x^2}$

ង. $f(x)=\sqrt{x^2+4x+4}$

ច. $f(x)=\sqrt{4-(x+1)^2}$

**ចម្លើយ:**

## ២ សញ្ញាទ្វេធា

### ២.១ សញ្ញាទ្វេធា $f(x) = ax + b$

បើ $ax + b = 0$ គេបាន $x = -\frac{b}{a}$

| $x$ | $-\infty$ | | $-b/a$ | | $+\infty$ |
|---|---|---|---|---|---|
| $f(x)$ | | សញ្ញាផ្ទុយ $a$ | $0$ | សញ្ញាដូច $a$ | |

### ២.២ សញ្ញាត្រីធា $f(x) = ax^2 + bx + c$

បើ $ax^2 + bx + c = 0$ ប្រើ ឌីសគ្រីមីណង់ $\Delta = b^2 - 4ac$

- បើ $\Delta > 0$ សមីការមានឫសពីរផ្សេងគ្នា $x_{1,2} = \frac{-b \pm \sqrt{\Delta}}{2a}$
  ដោយ $x_1, x_2$ ជាឫស (សន្មត $x_1 < x_2$) គេបានតារាងសញ្ញា

| $x$ | $-\infty$ | $x_1$ | | $x_2$ | | $+\infty$ |
|---|---|---|---|---|---|---|
| $f(x)$ | សញ្ញាដូច $a$ | 0 | សញ្ញាផ្ទុយ $a$ | 0 | សញ្ញាដូច $a$ | |

- បើ $\Delta = 0$ សមីការមានឬសឌុប $x_1 = x_2 = -\frac{b}{2a}$
  ដោយ $x_1 = x_2 = \alpha$ ជាឬស គេបានតារាងសញ្ញា

| $x$ | $-\infty$ | $\alpha$ | | $+\infty$ |
|---|---|---|---|---|
| $ax^2+bx+c$ | សញ្ញាដូច $a$ | 0 | សញ្ញាដូច $a$ | |

- បើ $\Delta < 0$ សមីការគ្មានឬស(ដោយសារតែយើងសិក្សាក្នុងសំណុំចំនួនពិត $\mathbb{R}$)
  គេបានតារាងសញ្ញា

| $x$ | $-\infty$ | $+\infty$ |
|---|---|---|
| $f(x)$ | សញ្ញាដូច $a$ | |

ចំពោះពហុធាដឺក្រេទី២ $f(x) = ax^2+bx+c = 0$ បើ $b$ ជាចំនួនគត់គូ គេអាចប្រើប្រាស់ $\Delta'$ ជំនួសឱ្យ $\Delta$ បានដែល $\Delta' = (b')^2 - ac$ ដែល $b' = \frac{b}{2}$

- បើ $\Delta' > 0$ សមីការមានឬសពីរផ្សេងគ្នា $x_{1,2} = \frac{-b' \pm \sqrt{\Delta'}}{a}$
- បើ $\Delta' = 0$ សមីការមានឬសឌុប $x_1 = x_2 = -\frac{b'}{a}$
- បើ $\Delta' < 0$ សមីការគ្មានឬស(ដោយសារតែយើងសិក្សាក្នុងសំណុំចំនួនពិត $\mathbb{R}$)

នៅក្នុងលក្ខខណ្ឌឬសទាំងបីខាងលើ យើងនឹងសិក្សាតារាងសញ្ញាដូចគ្នាទៅនឹង តារាងសញ្ញារបស់ $\Delta$ តាមលក្ខខណ្ឌនីមួយៗផងដែរ។

## ៣ ទិសដៅអថេរភាពនៃអនុគមន៍

### ៣.១ អនុគមន៍កើន-អនុគមន៍ចុះ

**ជាទូទៅ ២**

- $f$ ជាអនុគមន៍កើននៅចន្លោះ $I$ មួយកាលណា $\forall x_1, x_2 \in I, x_1 < x_2$ នាំឱ្យ $f(x_1) < f(x_2)$ ។
- $f$ ជាអនុគមន៍ចុះនៅចន្លោះ $I$ មួយកាលណា $\forall x_1, x_2 \in I, x_1 < x_2$ នាំឱ្យ $f(x_1) > f(x_2)$ ។

## ៣.២ ដេរីវេនិងទិសដៅអថេរភាពនៃអនុគមន៍

**ជាទូទៅ ៣**

- $f$ ជាអនុគមន៍កើន លើចន្លោះ $x \in (a,b)$ លុះត្រាតែ $f'(x) > 0$ គ្រប់ $x \in (a,b)$
- $f$ ជាអនុគមន៍ចុះ លើចន្លោះ $x \in (a,b)$ លុះត្រាតែ $f'(x) < 0$ គ្រប់ $x \in (a,b)$
- $f$ ជាអនុគមន៍ថេរ លើចន្លោះ $x \in (a,b)$ លុះត្រាតែ $f'(x) = 0$ គ្រប់ $x \in (a,b)$

# ៤ អតិបរមាធៀប និង អប្បបរមាធៀបនៃអនុគមន៍

## ៤.១ អតិបរមាធៀប អប្បបរមាធៀប និងដេរីវេទី 1

**ជាទូទៅ ៤**

- $f$ មានអតិបរមាធៀបត្រង់ $x_0$ កាលណា $\begin{cases} f'(x) > 0 & \text{ចំពោះ} \quad x < x_0 \\ f'(x) = 0 & \text{ចំពោះ} \quad x = x_0 \\ f'(x) < 0 & \text{ចំពោះ} \quad x > x_0 \end{cases}$
- $f$ មានអប្បបរមាធៀបត្រង់ $x_0$ កាលណា $\begin{cases} f'(x) < 0 & \text{ចំពោះ} \quad x < x_0 \\ f'(x) = 0 & \text{ចំពោះ} \quad x = x_0 \\ f'(x) > 0 & \text{ចំពោះ} \quad x > x_0 \end{cases}$

## ៤.២ អតិបរមាធៀប អប្បបរមាធៀប និងដេរីវេទី 2

**ជាទូទៅ ៥**

អនុគមន៍ $y = f(x)$ មានដេរីវេពីរដង លើចន្លោះមួយដែលមាន $x_0$

- $f$ មានអតិបរមាធៀបត្រង់ $x_0$ កាលណា $\begin{cases} f'(x_0) = 0 \\ f''(x_0) < 0 \end{cases}$
- $f$ មានអប្បបរមាធៀបត្រង់ $x_0$ កាលណា $\begin{cases} f'(x_0) = 0 \\ f''(x_0) > 0 \end{cases}$

**ជាទូទៅ ៦ : សម្គាល់**

បើ $f''(x_0) = 0$ នោះគេត្រូវត្រឡប់ទៅសិក្សាសញ្ញានៃដេរីវេទី 1 វិញ ដើម្បីឈានទៅរកតម្លៃអតិបរមា និងអប្បបរមាធៀប។

## ៤.៣ ចំណុចរបត់នៃខ្សែកោង

**ជាទូទៅ ៧**

ចំណុច $I(x_0, y_0)$ ជាចំណុចរបត់នៃខ្សែកោង។ តាងអនុគមន៍ កាលណាខ្សែកោងប៉ោង ឬផតនៅលើ $[a, x_0]$ ហើយផត ឬប៉ោងនៅលើ $[x_0, b]$ ។ របៀបរកចំណុចរបត់នៃខ្សែកោងតាងអនុគមន៍ $f$ :

- ជំហានទី១៖ រក $f''(x)$
- ជំហានទី២ ៖ ដោះស្រាយសមីការ $f''(x) = 0$
- ជំហានទី ៣៖ សិក្សាសញ្ញានៃ $f''(x)$ ។
  - បើ $f''(x)$ ដូរសញ្ញានៅសងខាង $x_0$ នោះខ្សែកោងមានចំណុចរបត់ $I(x_0, f(x_0))$
  - បើ $f''(x)$ មិនដូរសញ្ញា នោះខ្សែកោងគ្មានចំណុចរបត់ទេ។




# ៥ សិក្សាទីតាំងធៀប

**ជាទូទៅ ៨**

បើគេមានក្រាប $(C): f(x) = \cdots$ និងបន្ទាត់ $(D): y = \cdots$ យើងត្រូវៈ

- យក $f(x) - y$
- សិក្សាសញ្ញានៃ $f(x) - y$
  - បើ $f(x) - y > 0$ នោះក្រាប $(C)$ ស្ថិតនៅលើបន្ទាត់ $(D)$
  - បើ $f(x) - y = 0$ នោះក្រាប $(C)$ កាត់បន្ទាត់ $(D)$ នៅត្រង់ចំណុច មួយគឺ $(x, y)$ ដែល $y = f(x)$
  - បើ $f(x) - y < 0$ នោះក្រាប $(C)$ ស្ថិតនៅក្រោមន្ទាត់ $(D)$

# ៦ អនុគមន៍គូ និងអនុគមន៍សេស

**ជាទូទៅ ៩**

- ចំពោះ $\forall x \in \mathbb{D}, \exists -x \in \mathbb{D}$ បើ $f(-x) = f(x)$ នោះគេថា $f$ ជាអនុគមន៍គូ
- ចំពោះ $\forall x \in \mathbb{D}, \exists -x \in \mathbb{D}$ បើ $f(-x) = -f(x)$ នោះគេថា $f$ ជាអនុគមន៍សេស

# ៧ អ័ក្សឆ្លុះ និងផ្ចិតឆ្លុះ

**ជាទូទៅ ១០**

- បើបន្ទាត់ $x=a$ ជាអ័ក្សឆ្លុះនៃក្រាប $C$ លុះត្រាតែ $f(2a-x)=f(x)$
- បើចំណុច $I(a,b)$ ជាផ្ចិតឆ្លុះនៃក្រាប $C$ លុះត្រាតែ $f(2a-x)+f(x)=2b$
- បើ $f$ ជាអនុគមន៍ គូ នោះគេបាន $x=0$ ជាអ័ក្សឆ្លុះនៃក្រាប $(C)$
- បើ $f$ ជាអនុគមន៍សេសនោះគេបានចំណុច $O(0,0)$ ជាផ្ចិតឆ្លុះនៃក្រាប $(C)$។

**ជាទូទៅ ១១**

ការរកផ្ចិតឆ្លុះ ឬអ័ក្សឆ្លុះតាមរូបមន្តប្តូរអ័ក្ស

- បើបន្ទាត់ $x=a$ ជាអ័ក្សឆ្លុះ គេកំណត់សរសេរ $\begin{cases} x=a+X \\ y=Y \end{cases}$
  យក $x,y$ ទៅជួសអនុគមន៍ដើមហើយទាញរក $Y$ រួចស្រាយថា $Y=F(X)$ ជាអនុគមន៍គូ
- បើបន្ទាត់ $I(a,b)$ ជាអ័ក្សឆ្លុះ គេកំណត់សរសេរ $\begin{cases} x=a+X \\ y=b+Y \end{cases}$
  យក $x,y$ ទៅជួសអនុគមន៍ដើមហើយទាញរក $Y$ រួចស្រាយថា $Y=F(X)$ ជាអនុគមន៍សេស

# ៨ បន្ទាត់ប៉ះនឹងក្រាបតាងអនុគមន៍

**ជាទូទៅ ១២**

មេគុណប្រាប់ទិសនៃបន្ទាត់ប៉ះនឹងក្រាបតាងអនុគមន៍ $f$ នៅត្រង់ $x_0$ ជាដេរីវេ $f$ នៅត្រង់ $x_0$ គឺ $m = f'(x_0)$ ។




**ជាទូទៅ ១៣**

សមីការនៃបន្ទាត់ប៉ះក្រាបតាងអនុគមន៍ $f$ ត្រង់ចំណុច $(x_0, y_0)$ កំណត់ដោយ៖
$y - y_0 = f'(x_0)(x - x_0)$ ដែល $f'(x_0)$ ជាមេគុណប្រាប់ទិសបន្ទាត់ប៉ះ និង $(x_0, y_0)$ កូអរដោនេចំណុចប៉ះ។

# ៩ អាស៊ីមតូត

## ៩.១ អាស៊ីមតូតឈរ

**ជាទូទៅ ១៤**

បន្ទាត់ $x = a$ ជាអាស៊ីមតូតឈរនៃអនុគមន៍ $y = f(x)$ កាលណា $\lim\limits_{x\to a} f(x) = \pm\infty$



**ជាទូទៅ ១៥ : សម្គាល់**

ចំពោះអនុគមន៍ប្រភាគសនិទាន អាស៊ីមតូតឈរមានក្នុងករណីភាគបែងមានឫស

## ៩.២ អាស៊ីមតូតដេក

**ជាទូទៅ ១៦**

បន្ទាត់ $y=b$ ជាអាស៊ីមតូតដេកនៃក្រាប $C$ កាលណា $\lim_{x\to\pm\infty} f(x)=b$ ដែល $b\in\mathbb{R}$



# ៩.៣ អាស៊ីមតូតទ្រេត

**ជាទូទៅ ១៧**

បើអនុគមន៍ $f(x)=ax+b+\varphi(x)$ ដែល $\lim\limits_{x\to\pm\infty} f(x)=0$ នោះបន្ទាត់ $L: y=ax+b$ ជាអាស៊ីមតូតទ្រេតនៃក្រាប $C$។




**ជាទូទៅ ១៨**

បង្ហាញថា $L: y=ax+b$ ជាអាស៊ីមតូតទ្រេតនៃក្រាប $C$ បន្ទាត់ $L: y=ax+b$ ជាអាស៊ីមតូតទ្រេតនៃក្រាប $C$ តាង $y=f(x)$ លុះត្រាតែ $\lim\limits_{x\to\pm\infty}[f(x)-(ax+b)]=0$

**ជាទូទៅ ១៩ : សម្គាល់**

នៅក្នុងអនុគមន៍ដែលយើងសិក្សានៅកម្រិតវិទ្យាល័យនេះ បើសិនណាជាមានអាស៊ីមតូតដេក នោះមិនមានអាស៊ីមតូតទ្រេតទេ។ មានន័យថា បើមាន៖

- អាស៊ីមតូតឈរ $x=a$ និង អាស៊ីមតូតដេក $y=b$
- អាស៊ីមតូតឈរ $x=a$ និងអាស៊ីមតូតទ្រេត $y=ax+b$

**លំហាត់គំរូ ២**

រកអាស៊ីមតូតនៃក្រាបតាងអនុគមន៍ខាងក្រោម៖

ក. $f(x)=-x+3+\frac{3}{x-1}$

គ. $f(x)=\frac{x^2-1}{x-3}$

ង. $f(x)=\frac{x}{x^2+1}$

ខ. $f(x)=\frac{2x^2+3x+4}{x-1}$

ឃ. $f(x)=\frac{x^2-4x+1}{x+2}$

ច. $f(x)=\frac{x-1}{(x-1)^2}$

**ចម្លើយ:**

## ប្រតិបត្តិ ១

រកអាស៊ីមតូតនៃក្រាបតាងអនុគមន៍ខាងក្រោម៖

ក. $f(x)=\frac{x^2-2x+2}{(x-1)^2}$

ខ. $f(x)=\frac{x^2-4x}{x^2-4x+3}$

គ. $f(x)=\frac{4x^2+4x-9}{4x^2-4}$

**ចម្លើយ:**

## ប្រតិបត្តិ ២

រកអាស៊ីមតូតនៃក្រាបតាងអនុគមន៍ខាងក្រោម៖

ក. $y = x + 1 + \frac{2}{x-1}$ ខ. $y = \frac{x^2+4x+1}{x+2}$ គ. $y = \frac{x^2+3x+1}{x^2-1}$

**ចម្លើយ:**

# ១០ ប្លង់សិក្សាអថេរភាព និងសង់ខ្សែកោង $C: y = f(x)$

**ជាទូទៅ ២០**

ដើម្បីសិក្សាអនុគមន៍មួយគេត្រូវ៖

- ដែនកំណត់
- ទិសដៅអថេរភាព
  - រកដេរីវេទី 1: $f'(x)$
  - រកឫសរបស់ដេរីវេទី 1 : $f'(x) = 0$ (បើមាន )
  - សិក្សាសញ្ញា $f'(x)$
  - ចំណុចបរមា (បើមាន )
  - លីមីតចុងដែន និងអាស៊ីមតូត
  - អាស៊ីមតូត
  - តារាងអថេរភាព
- ក្រាប
  - ចំណុចប្រសព្វរវាងក្រាប $C$ និងអ័ក្ស $x'x$ (ឱ្យ $y = 0$ ) បើមាន
  - ចំណុចប្រសព្វរវាងក្រាប $C$ និងអ័ក្ស $y'y$ (ឱ្យ $x = 0$ ) បើមាន
  - ចំណុចប្រសព្វរវាងក្រាប $C$ និងអាស៊ីមតូតដេក បើមាន

# ១១ អនុគមន៍ $y = f(x) = \frac{ax^2+bx+c}{px+q}$

## ជាទូទៅ ២១ : សម្គាល់

$f(x)$ មានន័យកាលណា $px+q \neq 0 \Rightarrow x \neq -\frac{q}{p}$

គេបាន $\mathbb{D}_f = \mathbb{R} - \left\{-\frac{q}{p}\right\}$ ឬ $\mathbb{D}_f = \left(-\infty, -\frac{q}{p}\right) \cup \left(-\frac{q}{p}, +\infty\right)$

## លំហាត់គំរូ ៣

សិក្សាអថេរភាព និងសង់ក្រាបនៃអនុគមន៍ខាងក្រោម៖

ក. $f(x) = \frac{x^2+3x+3}{x+2}$

គ. $f(x) = \frac{x^2-1}{x-3}$

ខ. $f(x) = \frac{2x^2+3x+4}{x-1}$

ឃ. $f(x) = -x+3+\frac{3}{x-1}$

**ចម្លើយ:**

# ១២ អនុគមន៍ $y=f(x)=\frac{ax^2+bx+c}{px^2+qx+r}$

## ១២.១ ដែនកំណត់

**ជាទូទៅ ២២ : សម្គាល់**

អនុគមន៍ $f(x)$ មានន័យកាលណា $px^2+qx+r\neq 0$ ឱ្យ $px^2+qx+r=0$
ប្រើឌីសគ្រីមីណង់ $\Delta=b^2-4ac$

- $\Delta>0$ សមីការមានឫសពីរ $x_1=\alpha, x_2=\beta$ នោះ $\mathbb{D}_f=\mathbb{R}-\{\alpha,\beta\}$
- $\Delta=0$ សមីការមានឫសឌុប $x_1=x_2=\alpha$ នោះ $\mathbb{D}_f=\mathbb{R}-\{\alpha\}$
- $\Delta<0$ សមីការគ្មានឫស នោះ $\mathbb{D}_f=\mathbb{R}$

**លំហាត់គំរូ ៤**

សិក្សាអថេរភាព និងសង់ក្រាបនៃអនុគមន៍ $f(x)=\frac{2x^2-9x+4}{x^2+x-12}$។

**ចម្លើយ:**

## លំហាត់គំរូ ៥

សិក្សាអថេរភាព និងសង់ក្រាបនៃអនុគមន៍ $y=f(x)=\frac{3x^2-18x+25}{x^2-6x+8}$ ។

**ចម្លើយ:**

មេរៀនទី ១ អនុគមន៍សនិទាន

# វិញ្ញាសាពហុជ្រើសរើស៖ ការសិក្សាអថេរភាព និងសង់ក្រាប (១០០ លំហាត់)

## សម្រាប់ត្រៀមប្រឡងបាក់ឌុប និងពង្រឹងសមត្ថភាព

១. ដែនកំណត់នៃអនុគមន៍ $f(x)=\frac{x-1}{x+2}$ គឺ៖

ក. $\mathbb{R}$ ខ. $\mathbb{R}\setminus\{1\}$ គ. $\mathbb{R}\setminus\{-2\}$ ឃ. $(-2,+\infty)$

២. អនុគមន៍ $f(x)=\sqrt{2x-6}$ មានន័យកាលណា៖

ក. $x\geq 3$ ខ. $x>3$ គ. $x\leq 3$ ឃ. $x\neq 3$

៣. ដែនកំណត់នៃ $f(x)=\ln(x-4)$ គឺ៖

ក. $\mathbb{R}$ ខ. $x>4$ គ. $x\geq 4$ ឃ. $x\neq 4$

៤. បើ $f(x)=\frac{P(x)}{Q(x)}$ មានន័យកាលណា៖

ក. $P(x)\neq 0$ គ. $Q(x)\neq 0$
ខ. $Q(x)>0$ ឃ. $P(x)=Q(x)$

៥. សញ្ញានៃ $f(x)=-3x+6$ វិជ្ជមានលើចន្លោះ៖

ក. $(2,+\infty)$ ខ. $(-\infty,2)$ គ. $\{2\}$ ឃ. $\mathbb{R}$

៦. ត្រីធា $x^2-5x+6$ មានសញ្ញាផ្ទុយពី $a$ ក្នុងចន្លោះ៖

ក. $(2,3)$ ខ. $(-\infty,2)$ គ. $(3,+\infty)$ ឃ. គ្មានចម្លើយ

៧. ដែនកំណត់នៃ $f(x)=\frac{x}{x^2+1}$ គឺ៖

ក. $\mathbb{R}\setminus\{-1,1\}$ ខ. $\mathbb{R}$ គ. $(0,+\infty)$ ឃ. $x\neq -1$

៨. បើ $\Delta<0$ នោះត្រីធាដឺក្រេទី ២ មានសញ្ញា៖

ក. ដូរសញ្ញា ២ ដង គ. អវិជ្ជមានជានិច្ច
ខ. ដូច $a$ ជានិច្ច ឃ. សូន្យ

៩. ដែនកំណត់នៃ $f(x)=\sqrt{x^2-4}$ គឺ៖

ក. $[-2,2]$ គ. $\mathbb{R}$
ខ. $(-\infty,-2]\cup[2,+\infty)$ ឃ. $x>2$

១០. អនុគមន៍ $f(x)=e^{2x+1}$ មានដែនកំណត់៖

ក. $x>-1/2$ ខ. $x\neq 0$ គ. $\mathbb{R}$ ឃ. $(0,+\infty)$

១១. បើ $f(x)=\frac{1}{\sqrt{x}}$ នោះដែនកំណត់គឺ៖

ក. $x \geq 0$ ខ. $x \neq 0$ គ. $x > 0$ ឃ. $\mathbb{R}$

១២. សញ្ញានៃ $f(x) = x^2 + 1$ គឺ៖

ក. វិជ្ជមានជានិច្ច
គ. វិជ្ជមានកាលណា $x > 1$
ខ. អវិជ្ជមានជានិច្ច
ឃ. សូន្យ

១៣. ដែនកំណត់នៃ $f(x) = \frac{x+2}{x^2-9}$ គឺ៖

ក. $x \neq 3$
គ. $x \neq \pm 3$
ខ. $x \neq -3$
ឃ. $\mathbb{R}$

១៤. បើ $f(x) = \ln(-x)$ មានន័យកាលណា៖

ក. $x > 0$ ខ. $x < 0$ គ. $x = 0$ ឃ. $x \neq 0$

១៥. ឫសនៃទ្វេធា $2x + 8 = 0$ គឺ៖

ក. $4$ ខ. $-4$ គ. $2$ ឃ. $-8$

១៦. ដែនកំណត់នៃ $f(x) = \sqrt{x^2 + x + 1}$ គឺ៖

ក. $\mathbb{R}$ ខ. $\emptyset$ គ. $x > 0$ ឃ. $x \geq -1$

១៧. ចំពោះ $f(x) = \frac{1}{x^2 - x}$ តម្លៃដែលមិនស្ថិតក្នុងដែនកំណត់គឺ៖

ក. $0$ ខ. $1$ គ. $0$ និង $1$ ឃ. $-1$

១៨. $f(x) = \sqrt{4 - x^2}$ មានដែនកំណត់៖

ក. $x \in [-2, 2]$ ខ. $x > 2$ គ. $x < -2$ ឃ. $\mathbb{R}$

១៩. ឫសឌុបនៃ $x^2 - 4x + 4 = 0$ គឺ៖

ក. $x = 2$ ខ. $x = -2$ គ. $x = 0$ ឃ. $x = 4$

២០. បើ $f(x) = \frac{x-1}{(x-2)(x-3)}$ នោះដែនកំណត់គឺ៖

ក. $x \neq 2$
គ. $x \neq 2$ និង $x \neq 3$
ខ. $x \neq 3$
ឃ. $x \neq 1$

២១. ដែនកំណត់នៃ $f(x) = \tan x$ គឺ៖

ក. $\mathbb{R}$
គ. $x \neq k\pi$
ខ. $x \neq \frac{\pi}{2} + k\pi$
ឃ. $x > 0$

២២. សញ្ញានៃ $x - 5$ ប្តូរសញ្ញាត្រង់៖

ក. $x=0$ ខ. $x=5$ គ. $x=-5$ ឃ. មិនប្តូរសញ្ញា

២៣. ដែនកំណត់ $f(x)=\sqrt{x}+\sqrt{1-x}$ គឺ៖

ក. $[0,1]$ ខ. $\mathbb{R}$ គ. $x\geq 0$ ឃ. $x\leq 1$

២៤. ត្រីធា $x^2+x-6$ មានឫស៖

ក. $2,3$ ខ. $-2,3$ គ. $2,-3$ ឃ. $-2,-3$

២៥. អនុគមន៍ $f(x)=\frac{1}{e^x-1}$ មិនមានន័យត្រង់៖

ក. $x=1$ ខ. $x=e$ គ. $x=0$ ឃ. $x=-1$

២៦. បើ $f'(x)=0$ លើចន្លោះ $I$ នោះ $f$ ជាអនុគមន៍៖

ក. កើន ខ. ចុះ គ. ថេរ ឃ. គ្មានចម្លើយ

២៧. ដេរីវេនៃ $f(x)=\frac{x-1}{x+1}$ គឺ $f'(x)=$ ៖

ក. $\frac{2}{(x+1)^2}$ ខ. $\frac{-2}{(x+1)^2}$ គ. $1$ ឃ. $0$

២៨. បើ $f'(x)<0$ លើ $(a,b)$ នោះ $f$ ជាអនុគមន៍៖

ក. កើន ខ. ចុះ គ. មិនប្រែប្រួល ឃ. អវិជ្ជមាន

២៩. តម្លៃបរមាធៀបកើតមានកាលណា $f'(x)$ ៖

ក. វិជ្ជមានជានិច្ច គ. ស្មើ 0 ជានិច្ច

ខ. ប្តូរសញ្ញាឆ្លងកាត់ឫស ឃ. មិនមានឫស

៣០. $f(x)=x^2-6x+8$ មានចំណុចអប្បបរមាត្រង់៖

ក. $x=3$ ខ. $x=6$ គ. $x=0$ ឃ. $x=-3$

៣១. បើ $f''(x_0)>0$ និង $f'(x_0)=0$ នាំឱ្យ $f$ មាន៖

ក. អតិបរមាធៀប គ. ចំណុចរបត់

ខ. អប្បបរមាធៀប ឃ. អាស៊ីមតូត

៣២. ដេរីវេនៃ $f(x)=\frac{1}{x}$ គឺ៖

ក. $\ln x$ ខ. $1/x^2$ គ. $-1/x^2$ ឃ. $1$

៣៣. អនុគមន៍ $f(x)=x^3$ ជាអនុគមន៍៖

ក. កើនជានិច្ច ខ. ចុះជានិច្ច គ. ថេរ ឃ. មានអតិបរមា

៣៤. ចំណុចរបត់នៃ $f(x)=x^3-3x$ គឺ៖

ក. $(1,-2)$ ខ. $(-1,2)$ គ. $(0,0)$ ឃ. $(0,-3)$

៣៥. បើ $f'(x)=x^2-4$ នោះ $f$ កើនលើ៖

ក. $(-2,2)$ គ. $\mathbb{R}$
ខ. $(-\infty,-2)\cup(2,+\infty)$ ឃ. $\{2,-2\}$

៣៦. មេគុណប្រាប់ទិសនៃបន្ទាត់ប៉ះក្រាប $y=x^2$ ត្រង់ $x=1$ គឺ៖

ក. 1 ខ. 2 គ. 0 ឃ. $-2$

៣៧. សមីការបន្ទាត់ប៉ះក្រាប $f$ ត្រង់ $x_0$ គឺ $y=$ ៖

ក. $f'(x_0)(x-x_0)+f(x_0)$ គ. $f'(x_0)x$
ខ. $f(x_0)(x-x_0)+f'(x_0)$ ឃ. $f(x_0)$

៣៨. បើ $f(x)=\frac{2x+3}{x-1}$ នោះ $f'(x)=$ ៖

ក. $\frac{5}{(x-1)^2}$ ខ. $\frac{-5}{(x-1)^2}$ គ. $\frac{-1}{(x-1)^2}$ ឃ. 2

៣៩. អនុគមន៍ $f(x)=-x^2+4x$ មានតម្លៃអតិបរមាគឺ៖

ក. 2 ខ. 4 គ. 0 ឃ. $-4$

៤០. បើ $f''(x)$ ប្ដូរសញ្ញាឆ្លងកាត់ $x_0$ នោះក្រាបមាន៖

ក. អាស៊ីមតូត គ. បន្ទាត់ប៉ះដេក
ខ. ចំណុចរបត់ ឃ. ចំណុចដាច់

៤១. $f(x)=\frac{x^2}{x-1}$ មានដេរីវេ $f'(x)=$ ៖

ក. $\frac{x(x-2)}{(x-1)^2}$ ខ. $\frac{x^2-2x}{(x-1)^2}$ គ. ទាំង a និង b ត្រូវ ឃ. 1

៤២. បើ $f'(x)=\frac{-3}{(x-2)^2}$ នោះ $f$ ជាអនុគមន៍៖

ក. កើន ខ. ចុះ គ. ថេរ ឃ. កើនផងចុះផង

៤៣. អនុគមន៍ $f(x)=|x|$ គ្មានដេរីវេត្រង់៖

ក. $x=1$ ខ. $x=-1$ គ. $x=0$ ឃ. គ្រប់ $x$

៤៤. $f(x)=\frac{x+1}{x}$ ចុះជានិច្ចលើដែនកំណត់ ព្រោះ $f'(x)=$ ៖

ក. $1/x^2$ ខ. $-1/x^2$ គ. 1 ឃ. $-1$

៤៥. តម្លៃអប្បបរមានៃ $f(x)=x+\frac{1}{x}$ ចំពោះ $x>0$ គឺ៖

ក. 0 ខ. 1 គ. 2 ឃ. 4

៤៦. បើ $f(x)=x^4$ នោះ $f''(x)=0$ ត្រង់ $x=0$ តើ $(0,0)$ ជាចំណុចរបត់ឬទេ?

ក. បាទ/ចាស ខ. ទេ គ. មិនដឹង ឃ. អាស្រ័យលើ $y$

៤៧. អនុគមន៍ $f(x)=ax+b$ ជាអនុគមន៍ចុះកាលណា៖

ក. $a>0$ ខ. $a<0$ គ. $a=0$ ឃ. $b<0$

៤៨. ដេរីវេទី ២ នៃ $f(x)=\sin x$ គឺ៖

ក. $\cos x$ ខ. $-\sin x$ គ. $-\cos x$ ឃ. $\sin x$

៤៩. $f(x)=\frac{x^2+1}{x}$ មានចំណុចបរមាធៀបចំនួន៖

ក. 0 ខ. 1 គ. 2 ឃ. 3

៥០. ដើម្បីសិក្សាអថេរភាព ជំហានដំបូងគេត្រូវរក៖

ក. ដេរីវេ ខ. ដែនកំណត់ គ. លីមីត ឃ. ក្រាប

៥១. បន្ទាត់ $x=a$ ជាអាស៊ីមតូតឈរកាលណា៖

ក. $\lim_{x\to a} f(x)=\pm\infty$ គ. $f(a)=0$

ខ. $\lim_{x\to\infty} f(x)=a$ ឃ. $f'(a)=\infty$

៥២. អនុគមន៍ $f(x)=\frac{x}{x-3}$ មានអាស៊ីមតូតឈរគឺ៖

ក. $x=0$ ខ. $x=3$ គ. $y=1$ ឃ. $y=3$

៥៣. បន្ទាត់ $y=b$ ជាអាស៊ីមតូតដេកកាលណា៖

ក. $\lim_{x\to b} f(x)=\infty$ គ. $f(b)=\infty$

ខ. $\lim_{x\to\pm\infty} f(x)=b$ ឃ. $f(0)=b$

៥៤. អាស៊ីមតូតដេកនៃ $y=\frac{3x+1}{x-2}$ គឺ៖

ក. $y=2$ ខ. $y=3$ គ. $x=2$ ឃ. $x=3$

៥៥. បើ $f(x)=ax+b+\frac{k}{Q(x)}$ នោះអាស៊ីមតូតទ្រេតគឺ៖

ក. $y=ax$ ខ. $y=ax+b$ គ. $y=b$ ឃ. $x=-q/p$

៥៦. $f(x)=\frac{x^2-3x+2}{x-1}$ មានអាស៊ីមតូតឈរដែរឬទេ?

ក. មាន $x=1$ គ. មាន $x=-1$

ខ. គ្មានទេ (ព្រោះសម្រួលដាច់) ឃ. គ្មានព្រោះ $x\neq 1$

៥៧. អាស៊ីមតូតទ្រេតនៃ $f(x)=\frac{x^2+x+1}{x}$ គឺ៖

ក. $y=x$ ខ. $y=x+1$ គ. $y=1$ ឃ. $x=0$

៥៨. បើដឺក្រេភាគយក ស្មើដឺក្រេភាគបែង នោះអនុគមន៍សនិទានមាន៖

ក. អាស៊ីមតូតដេក
ខ. អាស៊ីមតូតទ្រេត
គ. គ្មានអាស៊ីមតូត
ឃ. អាស៊ីមតូតប៉ារ៉ាបូល

៥៩. បើដឺក្រេភាគយក ធំជាងដឺក្រេភាគបែង ១ ដឺក្រេ នោះមាន៖

ក. អាស៊ីមតូតដេក
ខ. អាស៊ីមតូតទ្រេត
គ. អាស៊ីមតូតឈរតែមួយគត់
ឃ. គ្មានទេ

៦០. អាស៊ីមតូតឈរនៃ $f(x)=\frac{x+1}{x^2-4}$ គឺ៖

ក. $x=2$ ខ. $x=-2$ គ. $x=2$ និង $x=-2$ ឃ. $x=4$

៦១. អាស៊ីមតូតដេកនៃ $f(x)=\frac{5}{x+1}$ គឺ៖

ក. $y=5$ ខ. $y=0$ គ. $y=1$ ឃ. គ្មានទេ

៦២. ដើម្បីរកអាស៊ីមតូតទ្រេត គេអាចប្រើវិធី៖

ក. ចែកពហុធា
ខ. រកលីមីត
គ. ទាំង a និង b ត្រូវ
ឃ. ដេរីវេ

៦៣. បើ $\lim_{x\to\infty}[f(x)-(2x-3)]=0$ នោះអាស៊ីមតូតទ្រេតគឺ៖

ក. $y=2x$ ខ. $y=2x-3$ គ. $y=-3$ ឃ. $y=0$

៦៤. $f(x)=\frac{x^2}{x+2}$ មានអាស៊ីមតូតទ្រេត $y=ax+b$ ដែល $a$ ស្មើ៖

ក. $1$ ខ. $-2$ គ. $0$ ឃ. $2$

៦៥. ក្នុងសំណួរ ៦៤ តម្លៃ $b$ ស្មើ៖

ក. $1$ ខ. $-2$ គ. $2$ ឃ. $0$

៦៦. អនុគមន៍ $f(x)=\frac{1}{x}$ មានអាស៊ីមតូតចំនួន៖

ក. ១ ខ. ២ គ. ៣ ឃ. ០

៦៧. អាស៊ីមតូតដេកនៃ $y=\frac{x^2+1}{2x^2-3}$ គឺ៖

ក. $y=1/2$ ខ. $y=2$ គ. $y=1$ ឃ. $y=-1/3$

៦៨. តើអាស៊ីមតូតដេក អាចកាត់ជាមួយក្រាបបានដែរឬទេ ?

ក. មិនអាចដាច់ខាត
គ. អាចជានិច្ច
ខ. អាចក្នុងករណីខ្លះ
ឃ. គ្មានចម្លើយ

៦៩. តើអាស៊ីមតូតឈរ អាចកាត់ជាមួយក្រាបបានដែរឬទេ ?

ក. អាច ខ. មិនអាច គ. អាចត្រង់ 0 ឃ. មិនដឹង

៧០. $f(x)=e^{-x}$ មានអាស៊ីមតូតដេក $y=0$ ក្នុងករណី $x\to$ ៖

ក. $0$ ខ. $+\infty$ គ. $-\infty$ ឃ. $1$

៧១. អាស៊ីមតូតឈរនៃ $f(x)=\frac{\ln x}{x-1}$ គឺ៖

ក. $x=1$ ខ. $x=0$ គ. គ្មានទេ ឃ. $x=e$

៧២. បើ $f(x)=\frac{x^2-x-2}{x-2}$ នោះក្រាបជា៖

ក. ខ្សែកោងមានអាស៊ីមតូត
គ. ប៉ារ៉ាបូល
ខ. បន្ទាត់ត្រង់ដែលមានចំណុចដាច់
ឃ. រង្វង់

៧៣. អាស៊ីមតូតឈរ និងអាស៊ីមតូតដេកនៃ $y=\frac{2x}{x+1}$ ប្រសព្វគ្នាត្រង់៖

ក. $(-1,2)$ ខ. $(1,2)$ គ. $(2,-1)$ ឃ. $(0,0)$

៧៤. ចំណុចប្រសព្វនៃអាស៊ីមតូតទាំងពីររបស់ $f(x)=\frac{ax+b}{cx+d}$ ជា៖

ក. ចំណុចរបត់ ខ. ផ្ចិតឆ្លុះ គ. គល់តម្រុយ ឃ. ចំណុចអតិបរមា

៧៥. បើ $f(x)=\sqrt{x^2+1}$ តើមានអាស៊ីមតូតដេកទេ ?

ក. មាន ខ. គ្មាន គ. មានតែ $x\to 0$ ឃ. មិនដឹង

៧៦. បើ $f$ ជាអនុគមន៍គូ នោះ $f$ ឆ្លុះធៀបនឹង៖

ក. អ័ក្សអាប់ស៊ីស ខ. អ័ក្សអរដោនេ គ. គល់ $O$ ឃ. បន្ទាត់ $y=x$

៧៧. បើ $f$ ជាអនុគមន៍សេស នោះ $f$ ឆ្លុះធៀបនឹង៖

ក. អ័ក្សអរដោនេ ខ. គល់តម្រុយ $O$ គ. អ័ក្សអាប់ស៊ីស ឃ. បន្ទាត់ $y=1$

៧៨. លក្ខខណ្ឌអនុគមន៍សេសគឺ $f(-x)=$ ៖

ក. $f(x)$ ខ. $-f(x)$ គ. $1/f(x)$ ឃ. $0$

៧៩. បន្ទាត់ $x=a$ ជាអ័ក្សឆ្លុះកាលណា $f(2a-x)=$ ៖

ក. $b$ ខ. $f(x)$ គ. $-f(x)$ ឃ. $2b-f(x)$

៨០. ចំណុច $I(a,b)$ ជាផ្ចិតឆ្លុះកាលណា $f(2a-x)+f(x)=$ ៖

ក. $b$ ខ. $2b$ គ. $0$ ឃ. $a$

៨១. ផ្ចិតឆ្លុះនៃ $f(x)=\frac{x+3}{x-1}$ គឺ៖

ក. $(1,1)$ ខ. $(-1,1)$ គ. $(1,3)$ ឃ. $(3,-1)$

៨២. អនុគមន៍ $f(x)=\cos x$ ជាអនុគមន៍៖

ក. សេស ខ. គូ គ. មិនគូមិនសេស ឃ. ថេរ

៨៣. ផ្ចិតឆ្លុះនៃ $f(x)=x^3-3x^2+4$ គឺ៖

ក. $(0,4)$ ខ. $(1,2)$ គ. $(2,0)$ ឃ. $(1,0)$

៨៤. បើ $f(x)=\frac{x^2-2x+2}{x-1}$ នោះផ្ចិតឆ្លុះស្ថិតនៅលើអាស៊ីមតូតឈរ៖

ក. $x=1$ ខ. $x=2$ គ. $x=0$ ឃ. $x=-1$

៨៥. ការរកចំណុចប្រសព្វរវាងក្រាប និងអ័ក្សអាប់ស៊ីស ត្រូវឱ្យ៖

ក. $x=0$ ខ. $y=0$ គ. $x=1$ ឃ. $y=1$

៨៦. ការរកចំណុចប្រសព្វរវាងក្រាប និងអ័ក្សអរដោនេ ត្រូវឱ្យ៖

ក. $x=0$ ខ. $y=0$ គ. $x=1$ ឃ. $y=1$

៨៧. បើ $f(x)-y_{asym}>0$ នោះក្រាបស្ថិតនៅ៖

ក. ខាងក្រោមអាស៊ីមតូត គ. លើអ័ក្សអាប់ស៊ីស

ខ. ខាងលើអាស៊ីមតូត ឃ. គ្មានចម្លើយ

៨៨. អ័ក្សឆ្លុះនៃប៉ារ៉ាបូល $y=x^2-4x+5$ គឺ៖

ក. $x=4$ ខ. $x=2$ គ. $x=0$ ឃ. $x=-2$

៨៩. អនុគមន៍ $f(x)=\frac{x^2+1}{x}$ ជាអនុគមន៍៖

ក. គូ ខ. សេស គ. មិនគូមិនសេស ឃ. ថេរ

៩០. ចំណុចប្រសព្វនៃ $y=\frac{x-1}{x+1}$ ជាមួយអ័ក្សអរដោនេគឺ៖

ក. $(1,0)$ ខ. $(0,-1)$ គ. $(0,1)$ ឃ. $(-1,0)$

៩១. ក្នុងអនុគមន៍ $f(x)=\frac{ax^2+bx+c}{px+q}$ បើ $f'(x)$ គ្មានឫស នោះក្រាប៖

ក. គ្មានចំណុចបរមា
គ. កាត់អ័ក្សអាប់ស៊ីស
ខ. មានអតិបរមាតែមួយ
ឃ. គ្មានអាស៊ីមតូត

៩២. បើ $I(a,b)$ ជាផ្ចិតឆ្លុះ នោះ $f(x)=b+F(x-a)$ ដែល $F$ ជា៖

ក. អនុគមន៍គូ ខ. អនុគមន៍សេស គ. អនុគមន៍ថេរ ឃ. គ្មានចម្លើយ

៩៣. ក្រាបនៃ $f(x)=\frac{x^2+1}{x^2-1}$ ឆ្លុះធៀបនឹង៖

ក. គល់ $O$ ខ. អ័ក្ស $y'y$ គ. អ័ក្ស $x'x$ ឃ. បន្ទាត់ $y=x$

៩៤. ដើម្បីសង់ក្រាបបានត្រឹមត្រូវ គេត្រូវដឹងពី៖

ក. តារាងអថេរភាព
គ. ចំណុចពិសេស
ខ. អាស៊ីមតូត
ឃ. គ្រប់ចំណុចខាងលើ

៩៥. បើ $x\to\pm\infty$ ហើយ $f(x)\to 2$ នោះក្រាបខិតជិតបន្ទាត់៖

ក. $x=2$ ខ. $y=2$ គ. $y=2x$ ឃ. $y=0$

៩៦. អនុគមន៍ $f(x)=\frac{|x|}{x}$ ចំពោះ $x\neq 0$ ជាអនុគមន៍៖

ក. គូ ខ. សេស គ. កើន ឃ. ចុះ

៩៧. ចំណុច $I(1,2)$ ជាផ្ចិតឆ្លុះនៃ $f$ មានន័យថា $f(2-x)+f(x)=$ ៖

ក. 2 ខ. 4 គ. 1 ឃ. 0

៩៨. បើ $f(x)=\frac{x^2+4}{x}$ តម្លៃអប្បបរមាធៀបគឺ៖

ក. 2 ខ. 4 គ. $-4$ ឃ. 0

៩៩. ក្នុងតារាងអថេរភាព បើសញ្ញា $f'(x)$ គឺ $+|+$ មានន័យថា៖

ក. មានបរមាធៀប
គ. មានចំណុចរបត់
ខ. អនុគមន៍កើនជានិច្ចលើដែនកំណត់
ឃ. អនុគមន៍ចុះ

១០០. ក្រាបនៃអនុគមន៍សនិទាន $y=\frac{ax+b}{cx+d}$ ហៅថា៖

ក. ប៉ារ៉ាបូល ខ. អ៊ីពែបូល គ. រង្វង់ ឃ. អេលីប

# លំហាត់អនុវត្តន៍

១. រកដែនកំណត់នៃអនុគមន៍ $y = f(x)$ខាងក្រោម៖

ក. $f(x) = 2x + 3$

ខ. $f(x) = \sqrt{x+1}$

គ. $f(x) = \sqrt{x^2 - 1}$

ឃ. $f(x) = \dfrac{x-1}{x+2}$

ង. $f(x) = \dfrac{x^2-1}{x-3}$

ច. $f(x) = \dfrac{1}{\sqrt{x-2}}$

**ចម្លើយ:**

២. រកដែនកំណត់នៃអនុគមន៍ $y=f(x)$ខាងក្រោម៖

ក. $f(x)=\dfrac{\sqrt{x^2-1}}{x-2}$

ខ. $f(x)=\dfrac{\sqrt{x^2-1}}{x+3}$

គ. $f(x)=\dfrac{x^2-3x+4}{x-1}$

ឃ. $f(x)=\sqrt{x^2-4x+3}$

ង. $f(x)=\sqrt{x^2-4}+\dfrac{\sqrt{x^2-9}}{x-1}$

ច. $f(x)=\dfrac{\sqrt{x^2-4}}{x-2}$

**ចម្លើយ:**

៣. រកដេរីវេនៃអនុគមន៍ $y = f(x)$ខាងក្រោម៖

ក. $f(x) = e^x$

ខ. $f(x) = e^x - 1$

គ. $f(x) = \dfrac{e^x}{x-1}$

ឃ. $f(x) = \ln(x^2 - 4x + 3)$

ង. $f(x) = x + 1 + \dfrac{\ln x}{x}$

ច. $f(x) = \ln\left(\dfrac{x-1}{x}\right)$

**ចម្លើយ:**

៤. រកសមីការអាស៊ីមតូតឈរនៃក្រាបតាងអនុគមន៍ $y=f(x)$ ខាងក្រោម៖

ក. $f(x)=\dfrac{2x+1}{x-2}$ គ. $f(x)=\dfrac{2-3x}{x+1}$ ង. $f(x)=\dfrac{x+1}{x^2+2x+1}$

ខ. $f(x)=\dfrac{1-x}{x-2}$ ឃ. $f(x)=\dfrac{2+3x}{1-x}$ ច. $f(x)=\dfrac{\sqrt{x^2+1}}{x^2+3x+2}$

**ចម្លើយ:**

៥. រកសមីការអាស៊ីមតូតឈរនៃក្រាបតាងអនុគមន៍ $y=f(x)$ ខាងក្រោម៖

ក. $f(x)=\dfrac{1-x}{2x-1}$

គ. $f(x)=\dfrac{2+3x}{x^2-1}$

ង. $f(x)=\dfrac{x+1}{x^2+3x-4}$

ខ. $f(x)=\dfrac{3x+1}{x+1}$

ឃ. $f(x)=\dfrac{2+3x}{2-x+x^2}$

ច. $f(x)=\dfrac{\sqrt{x^2+1}}{x^2-3x+2}$

**ចម្លើយ:**

៦. រកសមីការអាស៊ីមតូតឈរនៃក្រាបតាងអនុគមន៍ $y=f(x)$ ខាងក្រោម៖

ក. $f(x)=\dfrac{3-x}{(2x-1)^2}$

គ. $f(x)=\dfrac{2+3x}{x^2-5x+6}$

ង. $f(x)=\dfrac{x+1}{x^2-3x-4}$

ខ. $f(x)=\dfrac{3x+1}{x^2-4x+3}$

ឃ. $f(x)=\dfrac{1}{2-x+x^2}$

ច. $f(x)=\dfrac{\sqrt{x^2-1}}{x^2-3x-4}$

**ចម្លើយ:**

៧. រកសមីការអាស៊ីមតូតដេកនៃក្រាបតាងអនុគមន៍ $y = f(x)$ ខាងក្រោម៖

ក. $f(x) = \frac{2x+1}{x-2}$

គ. $f(x) = \frac{2-3x}{x+1}$

ង. $f(x) = \frac{x^2+1}{x^2+2x+1}$

ខ. $f(x) = \frac{1-x}{x-2}$

ឃ. $f(x) = \frac{2+3x}{1-x}$

ច. $f(x) = \frac{x^2+1}{x^2+3x+2}$

**ចម្លើយ:**

៨. រកសមីការអាស៊ីមតូតដេកនៃក្រាបតាងអនុគមន៍ $y=f(x)$ ខាងក្រោម៖

ក. $f(x)=\dfrac{x^2+3x+2}{x^2+4x+5}$

គ. $f(x)=\dfrac{2x^2+3x+2}{-x^2+4x}$

ង. $f(x)=\dfrac{x^2-3x-2}{-2x^2+4x+5}$

ខ. $f(x)=\dfrac{x^2-3x+2}{x^2+4x+11}$

ឃ. $f(x)=\dfrac{3x^2+3x+2}{-2x^2+5}$

ច. $f(x)=\dfrac{11x^2+3x+2}{x^2+8x+1}$

**ចម្លើយ:**

៩. រកសមីការអាស៊ីមតូតដេកនៃក្រាបតាងអនុគមន៍ $y=f(x)$ ខាងក្រោម៖

ក. $f(x)=\dfrac{3x+2}{x^2+4x+5}$

គ. $f(x)=\dfrac{2x^2+3x+2}{-x^3+4x}$

ង. $f(x)=\dfrac{x^2+23x-12}{-2x^2+4x+5}$

ខ. $f(x)=\dfrac{x^2+2}{x^2+4x+11}$

ឃ. $f(x)=\dfrac{x^2-3x+12}{-2x^2+5}$

ច. $f(x)=\dfrac{-4x^2+3x+2}{3x^2+8x+1}$

**ចម្លើយ:**

១០. រកសមីការអាស៊ីមតូតទ្រេតនៃក្រាបតាងអនុគមន៍ $y=f(x)$ ខាងក្រោម៖

ក. $f(x)=\dfrac{x^2+3x+1}{x-2}$ គ. $f(x)=\dfrac{2-3x+x^2}{x+1}$ ង. $f(x)=\dfrac{x^2+4x+1}{2x+1}$

ខ. $f(x)=\dfrac{1-x-x^2}{x-2}$ ឃ. $f(x)=\dfrac{2+3x-2x^2}{1-x}$ ច. $f(x)=\dfrac{x^2+3x+8}{3x+2}$

**ចម្លើយ:**

១១. រកសមីការអាស៊ីមតូតទ្រេតនៃក្រាបតាងអនុគមន៍ $y=f(x)$ ខាងក្រោម៖

ក. $f(x)=\dfrac{x^2+3x+2}{4x+5}$

ខ. $f(x)=\dfrac{x^2-3x+2}{4x+11}$

គ. $f(x)=\dfrac{x^2+3x+2}{4x+1}$

ឃ. $f(x)=\dfrac{3x^2+x+2}{2x+5}$

ង. $f(x)=\dfrac{x^2-3x-2}{4x+5}$

ច. $f(x)=\dfrac{11x^2+3x+2}{2x+1}$

**ចម្លើយ:**

១២. រកសមីការអាស៊ីមតូតទ្រេតនៃក្រាបតាងអនុគមន៍ $y=f(x)$ ខាងក្រោម៖

ក. $f(x)=\dfrac{x^2+4x+5}{3x+2}$

គ. $f(x)=\dfrac{2x^2+3x+2}{4x-1}$

ង. $f(x)=\dfrac{x^2+23x-12}{4x+5}$

ខ. $f(x)=\dfrac{x^2+2x+3}{x+1}$

ឃ. $f(x)=\dfrac{x^2-3x+12}{2+5x}$

ច. $f(x)=\dfrac{-4x^2+3x+2}{8x+1}$

**ចម្លើយ:**

មេរៀនទី ១ អនុគមន៍សនិទាន

១៣. រកសមីការអាស៊ីមតូតទ្រេតនៃក្រាបតាងអនុគមន៍ $y=f(x)$ ខាងក្រោម៖

ក. $f(x)=\dfrac{x^2-4x+5}{-3x+2}$

ខ. $f(x)=\dfrac{2x^2+2x+3}{x+1}$

គ. $f(x)=\sqrt{x^2+x+1}$

ឃ. $f(x)=\sqrt{4x^2+x+3}$

ង. $f(x)=\sqrt{9x^2+x+2}$

ច. $f(x)=\sqrt{8x^2+x-5}$

ឆ. $f(x)=\sqrt{x^2+x-1}$

**ចម្លើយ:**

១៤. គណនាដេរីវេនៃអនុគមន៍ $y=f(x)$ ខាងក្រោម៖

ក. $f(x)=\dfrac{2x+1}{x-2}$

ខ. $f(x)=\dfrac{1-x}{x-2}$

គ. $f(x)=\dfrac{2-3x}{x+1}$

ឃ. $f(x)=\dfrac{2+3x}{1-x}$

ង. $f(x)=\dfrac{x^2+1}{x^2+2x+1}$

ច. $f(x)=\dfrac{x^2+1}{x^2+3x+2}$

**ចម្លើយ:**

មេរៀនទី ១ អនុគមន៍សនិទាន

១៥. គណនាដេរីវេនៃអនុគមន៍ $y=f(x)$ ខាងក្រោម៖

ក. $f(x)=\dfrac{x^2+3x+2}{x^2+4x+5}$

គ. $f(x)=\dfrac{2x^2+3x+2}{-x^2+4x}$

ង. $f(x)=\dfrac{x^2-3x-2}{-2x^2+4x+5}$

ខ. $f(x)=\dfrac{x^2-3x+2}{x^2+4x+11}$

ឃ. $f(x)=\dfrac{3x^2+3x+2}{-2x^2+5}$

ច. $f(x)=\dfrac{11x^2+3x+2}{x^2+8x+1}$

**ចម្លើយ:**

១៦. គណនាដេរីវេនៃអនុគមន៍ $y=f(x)$ ខាងក្រោម៖

ក. $f(x)=\dfrac{3x+2}{x^2+4x+5}$

គ. $f(x)=\dfrac{2x^2+3x+2}{-x^3+4x}$

ង. $f(x)=\dfrac{x^2+23x-12}{-2x^2+4x+5}$

ខ. $f(x)=\dfrac{x^2+2}{x^2+4x+11}$

ឃ. $f(x)=\dfrac{x^2-3x+12}{-2x^2+5}$

ច. $f(x)=\dfrac{-4x^2+3x+2}{3x^2+8x+1}$

**ចម្លើយ:**

១៧. គណនាដេរីវេនៃអនុគមន៍ $y=f(x)$ ខាងក្រោម៖

ក. $f(x)=\dfrac{x^2+3x+1}{x-2}$ គ. $f(x)=\dfrac{2-3x+x^2}{x+1}$ ង. $f(x)=\dfrac{x^2+4x+1}{2x+1}$

ខ. $f(x)=\dfrac{1-x-x^2}{x-2}$ ឃ. $f(x)=\dfrac{2+3x-2x^2}{1-x}$ ច. $f(x)=\dfrac{x^2+3x+8}{3x+2}$

**ចម្លើយ:**

១៨. គណនាដេរីវេនៃអនុគមន៍ $y=f(x)$ ខាងក្រោម៖

ក. $f(x)=\dfrac{x^2+3x+2}{4x+5}$ គ. $f(x)=\dfrac{x^2+3x+2}{4x+1}$ ង. $f(x)=\dfrac{x^2-3x-2}{4x+5}$

ខ. $f(x)=\dfrac{x^2-3x+2}{4x+11}$ ឃ. $f(x)=\dfrac{3x^2+x+2}{2x+5}$ ច. $f(x)=\dfrac{11x^2+3x+2}{2x+1}$

**ចម្លើយ:**

មេរៀនទី ១ អនុគមន៍សនិទាន

១៩. គណនាដេរីវេនៃអនុគមន៍ $y=f(x)$ ខាងក្រោម៖

ក. $f(x)=\dfrac{x^2+4x+5}{3x+2}$

គ. $f(x)=\dfrac{2x^2+3x+2}{4x-1}$

ង. $f(x)=\dfrac{x^2+23x-12}{4x+5}$

ខ. $f(x)=\dfrac{x^2+2x+3}{x+1}$

ឃ. $f(x)=\dfrac{x^2-3x+12}{2+5x}$

ច. $f(x)=\dfrac{-4x^2+3x+2}{8x+1}$

**ចម្លើយ:**

២០. សិក្សាសញ្ញានៃអនុគមន៍ $y=f(x)$ ខាងក្រោម៖

ក. $f(x)=2x-3$

ខ. $f(x)=3x+2$

គ. $f(x)=-x+1$

ឃ. $f(x)=-2x+1$

ង. $f(x)=4-3x$

ច. $f(x)=-5x+10$

**ចម្លើយ:**

២១. សិក្សាសញ្ញានៃអនុគមន៍ $y = f(x)$ ខាងក្រោម៖

ក. $f(x) = x^2 - 2x - 3$
គ. $f(x) = x^2 - 2x + 1$
ង. $f(x) = 4 - 3x + x^2$
ខ. $f(x) = x^2 - 3x + 2$
ឃ. $f(x) = 2x^2 - 2x + 1$
ច. $f(x) = x^2 - 5x + 10$

**ចម្លើយ:**

២២. សិក្សាសញ្ញានៃអនុគមន៍ $y=f(x)$ ខាងក្រោម៖

ក. $f(x)=\dfrac{2x+1}{x-2}$

គ. $f(x)=\dfrac{2-3x}{x+1}$

ង. $f(x)=\dfrac{x^2+1}{x^2+2x+1}$

ខ. $f(x)=\dfrac{1-x}{x-2}$

ឃ. $f(x)=\dfrac{2+3x}{1-x}$

ច. $f(x)=\dfrac{x^2+1}{x^2+3x+2}$

**ចម្លើយ:**

២៣. សិក្សាសញ្ញានៃអនុគមន៍ $y = f(x)$ ខាងក្រោម៖

ក. $f(x) = \dfrac{x^2+3x+2}{x^2+4x+5}$

ខ. $f(x) = \dfrac{x^2-3x+2}{x^2+4x+11}$

គ. $f(x) = \dfrac{2x^2+3x+2}{-x^2+4x}$

ឃ. $f(x) = \dfrac{3x^2+3x+2}{-2x^2+5}$

ង. $f(x) = \dfrac{x^2-3x-2}{-2x^2+4x+5}$

ច. $f(x) = \dfrac{11x^2+3x+2}{x^2+8x+1}$

**ចម្លើយ:**

២៤. សិក្សាសញ្ញានៃអនុគមន៍ $y=f(x)$ ខាងក្រោម៖

ក. $f(x)=\dfrac{3x+2}{x^2+4x+5}$

គ. $f(x)=\dfrac{2x^2+3x+2}{-x^3+4x}$

ង. $f(x)=\dfrac{x^2+23x-12}{-2x^2+4x+5}$

ខ. $f(x)=\dfrac{x^2+2}{x^2+4x+11}$

ឃ. $f(x)=\dfrac{x^2-3x+12}{-2x^2+5}$

ច. $f(x)=\dfrac{-4x^2+3x+2}{3x^2+8x+1}$

**ចម្លើយ:**

២៥. សិក្សាសញ្ញានៃអនុគមន៍ $y=f(x)$ ខាងក្រោម៖

ក. $f(x)=\dfrac{x^2+3x+1}{x-2}$ 　 គ. $f(x)=\dfrac{2-3x+x^2}{x+1}$ 　 ង. $f(x)=\dfrac{x^2+4x+1}{2x+1}$

ខ. $f(x)=\dfrac{1-x-x^2}{x-2}$ 　 ឃ. $f(x)=\dfrac{2+3x-2x^2}{1-x}$ 　 ច. $f(x)=\dfrac{x^2+3x+8}{3x+2}$

**ចម្លើយ:**

២៦. សិក្សាសញ្ញានៃអនុគមន៍ $y = f(x)$ ខាងក្រោម៖

ក. $f(x) = \dfrac{x^2+3x+2}{4x+5}$

គ. $f(x) = \dfrac{x^2+3x+2}{4x+1}$

ង. $f(x) = \dfrac{x^2-3x-2}{4x+5}$

ខ. $f(x) = \dfrac{x^2-3x+2}{4x+11}$

ឃ. $f(x) = \dfrac{3x^2+x+2}{2x+5}$

ច. $f(x) = \dfrac{11x^2+3x+2}{2x+1}$

**ចម្លើយ:**

២៧. សិក្សាសញ្ញានៃអនុគមន៍ $y=f(x)$ ខាងក្រោម៖

ក. $f(x)=\dfrac{x^2+4x+5}{3x+2}$ គ. $f(x)=\dfrac{2x^2+3x+2}{4x-1}$ ង. $f(x)=\dfrac{x^2+23x-12}{4x+5}$

ខ. $f(x)=\dfrac{x^2+2x+3}{x+1}$ ឃ. $f(x)=\dfrac{x^2-3x+12}{2+5x}$ ច. $f(x)=\dfrac{-4x^2+3x+2}{8x+1}$

**ចម្លើយ:**

២៨. ស្រាយបញ្ជាក់ថា $y=f(x)$ ខាងក្រោមជាអនុគមន៍កើនជានិច្ចលើដែនកំណត់របស់វានីមួយៗ៖

ក. $f(x)=\dfrac{x-2}{x-1}$ ខ. $f(x)=\dfrac{2x-1}{x+2}$ គ. $f(x)=\dfrac{x^2-4x}{x-2}$

**ចម្លើយ:**

២៩. ស្រាយបញ្ជាក់ថា $y=f(x)$ខាងក្រោមជាអនុគមន៍ចុះជានិច្ចលើដែនកំណត់របស់វានីមួយៗ៖

ក. $f(x)=\dfrac{-x+2}{x-1}$ ខ. $f(x)=\dfrac{-2x+3}{x+1}$ គ. $f(x)=\dfrac{-x^2+x+3}{x+1}$

**ចម្លើយ:**

៣០. រកតម្លៃ$m$ដើម្បីឲ្យអនុគមន៍$f(x)=(2m-1)x^2+m+1$ ចំពោះ $x>0$ជាអនុគមន៍កើន។

**ចម្លើយ:**

៣១. កំណត់តម្លៃ$k$ដើម្បីឲ្យអនុគមន៍ $f(x)=(k+3)x^2-k+2$ចំពោះ $x<0$ជា៖

ក. ជាអនុគមន៍ចុះ
ខ. ជាអនុគមន៍ថេរ

**ចម្លើយ:**

៣២. រកតម្លៃបរមាធៀបនៃអនុគមន៍ $y=f(x)$ ខាងក្រោម៖

ក. $f(x)=-x^2+4x-1$

គ. $f(x)=-x^2+9x-3$

ង. $f(x)=x^2+4x+3$

ខ. $f(x)=-2x^2+3x+6$

ឃ. $f(x)=-3x^2-9x+8$

ច. $f(x)=-x^2+3x-2$

**ចម្លើយ:**

មេរៀនទី ១ អនុគមន៍សនិទាន

៣៣. រកតម្លៃបរមាធៀបនៃអនុគមន៍ $y=f(x)$ ខាងក្រោម៖

ក. $f(x)=-x^2+4x+4$

ខ. $f(x)=-x^2+3x+2$

គ. $f(x)=-x^2+4x-3$

ឃ. $f(x)=x^2-4x+8$

ង. $f(x)=x^2-x+3$

ច. $f(x)=x^2+3x+2$

**ចម្លើយ:**

មេរៀនទី ១ អនុគមន៍សនិទាន

៣៤. គេឲ្យអនុគមន៍$h(x)=mx^2+nx+1$ ក្រាប$H$។ ចូររកចំនួនពិត$m$ និង $n$ដើម្បីឲ្យ$h$មានតម្លៃអប្បបរមាត្រង់$x=1$ ហើយមាន$h(3)=2$។

**ចម្លើយ:**

៣៩. កំណត់តម្លៃ$a$ដើម្បីឲ្យអនុគមន៍$f(x)=x^2+\frac{a}{x}$។

ក. អប្បបរមាត្រង់$x=2$ ខ. អប្បបរមាត្រង់$x=-3$ គ. មានចំណុចរបត់ត្រង់$x=1$

ឃ. បង្ហាញថាគ្មានតម្លៃ$a$ដែលធ្វើឲ្យ$f$មានអតិបរិមាទេ?

**ចម្លើយ:**

៣៦. អនុគមន៍ $f(x)=x^3+3ax^2+3bx+2$ចំពោះ$x\in\mathbb{R}$។

ក. រកតម្លៃ$a$ និង $b$ដើម្បីឲ្យ $f$មានអតិបរិមាធៀបត្រង់$x=1$ និង មានអប្បបរមាធៀបត្រង់$x=2$។

ខ. រកផលដករវាងតម្លៃអតិបរមា និង អប្បបរមាធៀបនៃ$f$។

**ចម្លើយ:**

៣៧. រកតម្លៃ $a$ និង $b$ ដើម្បីឲ្យ $f(x)=x^3+ax^2+bx+1$ មាន៖

ក. អតិបរមាត្រង់ $x=-1$ និង អប្បបរមាត្រង់ $x=3$។

ខ. អប្បបរមាត្រង់ $x=4$ និងចំណុចរបត់ $x=-1$។

**ចម្លើយ:**

៣៨. សិក្សាអថេរភាពនៃអនុគមន៍ $y=f(x)$ ខាងក្រោម៖

ក. $f(x)=2x^2-8x+5$ ខ. $f(x)=x^3-3x+3x+2$ គ. $f(x)=x^4-2x^2+2$

**ចម្លើយ:**

៣៩. សិក្សាអថេរភាពនៃអនុគមន៍ $y=f(x)$ខាងក្រោម៖

ក. $f(x)=\dfrac{x^2-4x}{x^2+3x}$

ខ. $f(x)=\dfrac{2x^2-2x-1}{(x-1)^2}$

គ. $f(x)=\dfrac{x^2-4x}{x^2-4x+3}$

ឃ. $f(x)=\dfrac{3x^2-18x+25}{x^2-6x+8}$

ង. $f(x)=\dfrac{x^2-4}{x^2+1}$

ច. $f(x)=\dfrac{x^2-1}{x^2+2}$

ឆ. $f(x)=\dfrac{x^2-2x+3}{x^2-1}$

ជ. $f(x)=\dfrac{-x^2+3x+5}{x^2-2x-3}$

ឈ. $f(x)=\dfrac{2x^2-x+3}{1-x^2}$

**ចម្លើយ:**

មេរៀនទី ១ អនុគមន៍សនិទាន

៤០. គេឱ្យអនុគមន៍ $f$ កំណត់ចំពោះ $x \neq 2$ ដោយ $y = \frac{2x^2+x-1}{x-2}$ និងមានក្រាប $C$។

ក. រកចំនួនពិត $a, b, c$ ដែលគ្រប់ $x \neq 2$ គេបាន $f(x) = ax + b + \frac{c}{x-2}$

ខ. រកអាស៊ីមតូតឈរ និងអាស៊ីមតូតទ្រេតនៃក្រាប $C$។

គ. សិក្សាទីតាំងនៃ $C$ ធៀបទៅនឹងអាស៊ីមតូតទ្រេតរបស់វា។

**ចម្លើយ:**

៤១. គេឱ្យ $f$ កំណត់លើ $(-\infty,2)\cup(2,+\infty)$ ដោយ $f(x)=\frac{x^2-4x+8}{x-2}$ ហើយ $C$ ជាខ្សែកោងតាង $f$ ក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j})$។

ក. កំណត់ចំនួនពិត $a,b,c$ ដើម្បីបាន $f(x)=ax+b+\frac{c}{x-2}\quad,\quad x\neq 2$

ខ. កំណត់អាស៊ីមតូតឈរ និងទ្រេតនៃក្រាប $C$

គ. សិក្សាអថេរភាពនៃ $f$ និងសង់ក្រាប $C$

**ចម្លើយ:**

៤២. គេមានអនុគមន៍ $f$ ដែល $f(x)=\frac{x^2-x-3}{x+1}$ និងគេតាងដោយ $C$ ក្រាបនៃអនុគមន៍ $f$ ។

ក. រកដែនកំណត់នៃ $f$

ខ. បង្ហាញថា $f(x)=x-2-\frac{1}{x+1}$

គ. បង្ហាញថា បន្ទាត់ដែលមានសមីការ $y=x-2$ ជាអាស៊ីមតូតទ្រេតនៃក្រាប $C$

ឃ. សិក្សាអថេរភាព និងសង់ក្រាបនៃ $f$ ។

**ចម្លើយ:**

៤៣. អនុគមន៍ $f$ កំណត់ចំពោះ $x\neq 1$ ដោយ $f(x)=\frac{x^2+x-1}{x-1}$ និងមានក្រាប $C$ ។

ក. រកចំនួនពិត $a,b$ និង $c$ ដើម្បីឱ្យ $f(x)=ax+b+\frac{c}{x-1}$ ចំពោះ $x\neq 1$ ។

ខ. គណនាលីមីតត្រង់គោលនៃដែនកំណត់ រួចកំណត់អាស៊ីមតូតឈរ និងអាស៊ីមតូតទ្រេតនៃ $C$ ។

គ. គណនា $f'(x)$ រួចសិក្សាសញ្ញារបស់វា។ សង់តារាងអថេរភាពនៃ $f$ ។

ឃ. បង្ហាញថា $I(1,3)$ ជាផ្ចិតឆ្លុះនៃ $C$ ។ សង់ខ្សែកោង $C$ ក្នុងអរតូណរម៉ាល់

ង. សិក្សាតាមក្រាភិច ចំនួនឬសនៃសមីការ $x^2+(1-m)x+m-1=0$

**ចម្លើយ:**

៤៤. គេមានអនុគមន៍ $f$ កំណត់លើ $\mathbb{R}-\{2\}$ ដោយ $f(x)=\frac{x^2-x-1}{x-2}$ ។
យើងតាង $C$ ជាក្រាបរបស់វាលើតម្រុយអរតូណរម៉ាល់ $\left(0,\vec{i},\vec{j}\right)$ ។

ក. សិក្សាលីមីតនៃអនុគមន៍ $f$ ត្រង់ $-\infty$ និងត្រង់ $+\infty$ ។

ខ. សិក្សាអថេរភាព និងសង់តារាងអថេរភាពនៃអនុគមន៍ $f$ ។

គ. ⓐ. រកចំនួនពិត $a,b,c$ ដែលគ្រប់ $x\neq 2;\quad f(x)=ax+b+\frac{c}{x-2}$ ។

ⓑ. គេតាង d ដែលមានសមីការ $y=x+1$ ។ បង្ហាញថា $d$ ជាអាស៊ីមតូតនៃ $C$ ត្រង់ $+\infty$ និង $-\infty$ ។ សិក្សាទីតាំងនៃក្រាប $C$ ធៀបនឹងបន្ទាត់ d ។

ⓒ. សង់ក្រាប $C$ និង បន្ទាត់ $d$ ។

**ចម្លើយ:**

៤៥. គេមានអនុគមន៍ $f$ ដែល $f(x)=\frac{x^2-x-3}{x+1}$ និង គេតាងដោយ $(C)$ ក្រាបនៃអនុគមន៍ $f$ ។

ក. រកដែនកំណត់នៃអនុគន៍ $f$ ។

ខ. បង្ហាញថា $f(x)=x-2-\frac{1}{x+1}$ ។

គ. បង្ហាញថាបន្ទាត់ដែលមានសមីការ $y=x-2$ ជាអាស៊ីមតូតទ្រេតនៃក្រាប $(C)$ ។

ឃ. សិក្សាអថេរភាព និងសង់ក្រាបនៃ $f$ ។

**ចម្លើយ:**

៤៦. គេមានអនុគមន៍ $f(x)=\frac{(x+2)(x-2)}{(1-x)}$ ។

ក. រកដែនកំណត់ $f(x)$ ។

ខ. បង្ហាញថា $f(x)=-x-1+\frac{3}{x-1}$ ។

គ. សិក្សាអថេរភាពនិង សង់ក្រាប $C$ នៃអនុគមន៍ $f(x)=\frac{(x+2)(x-2)}{(1-x)}$ ។

**ចម្លើយ:**

៤៧. គេឲ្យអនុគមន៍ $f$ កំណត់ដោយ $f(x)=\frac{x^2+x+4}{x+1}$ ហើយមានក្រាប $C$ ។

ក. រកដែនកំណត់ និង សិក្សាសញ្ញាដេរីវេ $f'(x)$ នៃអនុគមន៍ $f$ ។

ខ. សរសេរសមីការអាស៊ីមតូតឈរ និង អាស៊ីមតូតទ្រេតនៃក្រាប $C$ ។

គ. សង់តារាងអថេរភាព អាស៊ីមតូត និង ក្រាប $C$ នៃអនុគមន៍ $f$ ។

**ចម្លើយ:**

៤៨. គេមានអនុគមន៍ $f(x)=\frac{x^2+3x+6}{x+2}$ កំណត់ចំពោះគ្រប់ $x\neq -2$ និងមានខ្សែកោង $C$។

ក. គណនា $f'(x)$។ រកតម្លៃបរមានៃ $f$។ រកសមីការអាស៊ីមតូតនៃខ្សែកោង $C$។ គណនាលីមីតនៃ $f$ កាលណា $x$ ខិតទៅ $+\infty$, $-\infty$។ សង់តារាងអថេរភាពនៃ $f$។

ខ. រកសមីការបន្ទាត់ប៉ះនឹងខ្សែកោង $C$ ត្រង់ចំណុច $x_0=1$។ គណនាកូអរដោនេនៃចំណុចប្រសព្វ $A$ រវាងសមីការបន្ទាត់ប៉ះនឹងអាស៊ីមតូតទ្រេតនៃខ្សែកោង $C$។

គ. សង់ខ្សែកោង $C$ បន្ទាត់ប៉ះនៃខ្សែកោង $C$ និងអាស៊ីមតូត នៅក្នុងតម្រុយអរតូណរម៉ាល់តែមួយ។
គណនាផ្ទៃក្រឡាខណ្ឌដោយខ្សែកោង $C$ អ័ក្សអាប់ស៊ីស និងបន្ទាត់ $x=1$, $x=2$។

**ចម្លើយ:**

៤៩. គេមានអនុគមន៍ $f$ កំណត់ដោយ $y=f(x)=\frac{x^2-5x+7}{x-2}$ មានក្រាបតំណាង $(C)$។

ក. រកដែនកំណត់នៃអនុគមន៍ $f$។

ខ. គណនាលីមីត៖ $\lim_{x\to 2} f(x)$ ; $\lim_{x\to\pm\infty} f(x)$ ។

គ. រកតម្លៃនៃចំនួនពិត $a$ ; $b$ និង $c$ ដើម្បីឲ្យ $f(x)=ax+b+\frac{c}{x-2}$ ។

ឃ. រកសមីការអាស៊ីមតូតឈរ និងសមីការអាស៊ីមតូតទ្រេត។

ង. សិក្សាអថេរភាព និងសង់តារាងអថេរភាពនៃអនុគមន៍ $f$ រួចសង់ក្រាប $(C)$។

**ចម្លើយ:**

៥០. គេឲ្យអនុគមន៍ $f$ មួយកំណត់គ្រប់តម្លៃ $x \neq 2$ ដែល $y = f(x) = \frac{x^2-3x-4}{x-2}$ មានក្រាបតំណាង $(C)$។

ក. សិក្សាលីមីតនៃអនុគមន៍ $f$ ត្រង់ $2$ និង $\pm\infty$ ។ រួចទាញរកសមីការអាស៊ីមតូតឈរ។

ខ. កំណត់តម្លៃ $a, b$ និង $c$ ដើម្បីឲ្យ $f(x) = ax + b + \frac{c}{x-2}$។ រួចបង្ហាញថាបន្ទាត់ $(d): y = x - 1$ ជាអាស៊ីមតូតទ្រេតនៃក្រាប $(C)$ ត្រង់ $\pm\infty$។

គ. គណនាដេរីវេ $f'(x)$ និងសិក្សាសញ្ញាដេរីវេ។

ឃ. សង់តារាងអថេរភាពនៃអនុគមន៍ $f$។

ង. បង្ហាញថាចំណុច $I(2, 1)$ ជាផ្ចិតឆ្លុះនៃក្រាប $(C)$ រួចសង់ក្រាប $(C)$។

**ចម្លើយ:**

៥១. គេមានអនុគមន៍ $f$ កំណត់ដោយ $y=f(x)=\frac{x^2-4}{x-1}$ មានក្រាបតំណាង $(C)$។

ក. ចូររកដែនកំណត់នៃអនុគមន៍ $f$។

ខ. គណនា $\lim\limits_{x\to1} f(x)$ ; $\lim\limits_{x\to-\infty} f(x)$ ; $\lim\limits_{x\to+\infty} f(x)$ ។ រួចទាញរកសមីការអាស៊ីមតូតឈរ។

គ. បង្ហាញថា $f(x)=x+1-\frac{3}{x-1}$ ។ រួចបង្ហាញថា $(d): y=x+1$ ជាអាស៊ីមតូតទ្រេតនៃក្រាប$(C)$ ត្រង់ $\pm\infty$ ។

ឃ. បង្ហាញថា $f'(x)=\frac{x^2-2x+4}{(x-1)^2}$ ចំពោះគ្រប់ $x\in D_f$ ។ រួចសិក្សាសញ្ញា $f'(x)$ ។

ង. សង់តារាងអថេរភាពនៃអនុគមន៍ $f$។

ច. រកចំណុចប្រសព្វរវាងក្រាប $(C)$ នឹងអ័ក្សទាំងពីរ ហើយ រកផ្ចិតឆ្លុះនៃក្រាប រួចសង់ក្រាប$(C)$។

**ចម្លើយ:**

៥២. គេមានអនុគមន៍ $f$ មួយកំណត់លើ $\mathbb{R}-\{1\}$ ដោយ $y=f(x)=\frac{x^2-x+9}{x-1}$ មានក្រាបតំណាង$(C)$។

ក. ចូរគណនាលីមីតនៃអនុគមន៍ $f$ ត្រង់ $-\infty$ ; $+\infty$

ខ. ចូរសរសេរសមីការអាស៊ីមតូតឈរនៃក្រាប$(C)$។

គ. សិក្សាសញ្ញាដេរីវេ $f'(x)$ រួចបង្ហាញថា អនុគមន៍ $f$ មានអតិបរមាធៀបមួយត្រង់ $x=-2$ និង អប្បបរមាធៀបមួយត្រង់ $x=4$ ព្រមទាំងរកតម្លៃបរមាធៀបទាំងនេះ។

ឃ. សង់តារាងអថេរភាពនៃអនុគមន៍ $f$ ។

ង. កំណត់តម្លៃនៃចំនួនពិត $a;b$ និង $c$ ដែលធ្វើឲ្យ $f(x)=ax+b+\frac{c}{x-1}$។ រួចបង្ហាញថា $(d):y=x$ ជាសមីការអាស៊ីមតូតទ្រេតនៃក្រាប $C$។

ច. រកចំណុចប្រសព្វរវាង អាស៊ីមតូតឈរ និងអាស៊ីមតូតទ្រេត រួចសង់ក្រាប $(C)$ និងបន្ទាត់ $(d)$ ក្នុងតម្រុយតែមួយ។

**ចម្លើយ:**

៥៣. គេមានអនុគមន៍ $f$ មួយ ដែលកំណត់ដោយ $y = f(x) = \frac{x^2+3x-3}{x-1}$ មានក្រាបតំណាង $(C)$។

ក. ចូររកដែនកំណត់នៃអនុគមន៍$f$។

ខ. ចូរគណនា $\lim\limits_{x\to\pm\infty} f(x)$; $\lim\limits_{x\to1} f(x)$។

គ. រកសមីការអាស៊ីមតូតឈរ និង សមីការអាស៊ីមតូតទ្រេត។

ឃ. គណនាដេរីវេ $f'(x)$ និង សិក្សាសញ្ញាដេរីវេ $f'(x)$ ។ រួចរកតម្លៃបរមាធៀប បើមាន។

ង. សង់តារាងអថេរភាពនៃអនុគមន៍ $f$ ។

ច. សិក្សាទីតាំងធៀបរវាងក្រាប $(C)$ និងអាស៊ីមតូតទ្រេត រួចសង់ក្រាប$(C)$ ។

**ចម្លើយ:**

មេរៀនទី ១ អនុគមន៍សនិទាន

៥៤. ក. សិក្សាអថេរភាព និងសង់ក្រាបនៃអនុគមន៍ $y=\frac{x^2-4x+8}{x-2}$

ខ. សិក្សាទៅតាមតម្លៃ $m$ អត្ថិភាព និងសញ្ញានៃឫសសមីការ $x^2-(m+4)x+2m+8=0$ ដោយប្រើក្រាបតាង $y$ ។

**ចម្លើយ:**

៥៥. គេឱ្យអនុគមន៍ $y=\frac{mx^2+3mx+2m+1}{x+2}$ ។

ក. ស្រាយបញ្ជាក់ថា អាស៊ីមតូតទ្រេតកាត់តាមចំណុចនឹងមួយចំពោះគ្រប់ប៉ារ៉ាម៉ែត្រ $m$ ដែល ត្រូវកំណត់កូអរដោនេ។

ខ. រកតម្លៃ $m$ ដើម្បីឱ្យបន្ទាត់ $y=m$ ប៉ះនឹងក្រាប។

គ. សិក្សាអថេរភាព និងសង់ក្រាប ចំពោះ $m=-1$ ។

**ចម្លើយ:**

៥៦. គេអោយអនុគមន៍ $f(x)=\dfrac{x^2+2x-2}{x-1}$ មានក្រាប$(C)$។ ហើយមានបន្ទាត់ពីរ$(L_1): y=2x+1$ និង $(L_2): y=x+3$។

ក. រកដែនកំណត់នៃ $f(x)$។ រកលីមីតនៃ$f$ត្រង់ចុងដែនកំណត់។

ខ. តើបន្ទាត់មួយណាជាអាស៊ីមតូតទ្រេតនៃ$(C)$?

គ. បញ្ជាក់ទីតាំងនៃ $(C)$ ធៀបនិងអាស៊ីមតូតទ្រេតនោះ។

ឃ. គណនា $f'(x)$។ សិក្សាសញ្ញានៃ$f'(x)$។ សង់តារាងអថេរភាពនៃ$f$។

ង. សង់ក្រាប$(C)$ក្នុងតម្រុយអរតូណរមេមួយ។

**ចម្លើយ:**

៥៧. គេអោយអនុគមន៍ $f(x)=\dfrac{x^2+3x+1}{x+1}$ មានក្រាប $(C)$។

ក. កំណត់ចំនួនពិត $a,b$ និង $c$ ចំពោះគ្រប់ $x\neq -1$ បើ $f(x)=ax+b+\dfrac{c}{x+1}$។

ខ. គណនា $\lim\limits_{x\to -1} f(x)$ និង $\lim\limits_{x\to\infty} f(x)$។ រកសមីការអាស៊ីមតូតទាំងអស់នៃក្រាប $(C)$។

គ. បញ្ជាក់ទីតាំងនៃ $(C)$ ធៀបនិងអាស៊ីមតូតទ្រេតនោះ។

ឃ. គណនា $f'(x)$។ សិក្សាសញ្ញានៃ $f'(x)$។ សង់តារាងអថេរភាពនៃ $f$។

ង. សង់ក្រាប $(C)$ ក្នុងតម្រុយអរតូណរមេមួយ។

**ចម្លើយ:**

៥៨. គេអោយអនុគមន៍ $f(x)=\dfrac{x^2+x+1}{x+3}$ មានក្រាប $(C)$។

ក. កំណត់ចំនួនពិត $a,b$ និង $c$ ចំពោះគ្រប់ $x\neq-1$ បើ $f(x)=ax+b+\dfrac{c}{x+3}$។

ខ. គណនា $\lim\limits_{x\to-3} f(x)$ និង $\lim\limits_{x\to\infty} f(x)$។ រកសមីការអាស៊ីមតូតទាំងអស់នៃក្រាប $(C)$។

គ. បញ្ជាក់ទីតាំងនៃ $(C)$ ធៀបនិងអាស៊ីមតូតទ្រេតនោះ។

ឃ. គណនា $f'(x)$។ សិក្សាសញ្ញានៃ $f'(x)$។ សង់តារាងអថេរភាពនៃ $f$។

ង. សង់ក្រាប $(C)$ ក្នុងតម្រុយអរតូណរមេមួយ។

**ចម្លើយ:**

៥៩. គេអោយអនុគមន៍ $f(x)=\dfrac{x^2+2x+3}{x+1}$ មានក្រាប $(C)$។

ក. រកដែនកំណត់នៃ $f$។ រកលីមីតនៃ $f$ ត្រង់ចុងដែនកំណត់។

ខ. កំណត់ $a,b$ និង $c$ ដែលធ្វើឲ្យ $f(x)=ax+b+\dfrac{c}{x+1}$។

គ. រកសមីការអាស៊ីមតូតទាំងអស់នៃ $(C)$។ ចូរបញ្ជាក់ថាទីតាំងរវាងក្រាប $(C)$ និង អាស៊ីមតូតទ្រេត។

ឃ. គណនា $f'(x)$។ សិក្សាសញ្ញានៃ $f'(x)$។ រួចរកតម្លៃបរិមានៃ $f$។

ង. សង់តារាងអថេរភាពនៃ $f$។ សង់ក្រាប $(C)$ និងអាស៊ីមតូតក្នុងតម្រុយកូអរដោនេមួយ។

**ចម្លើយ:**

៦០. គេអោយអនុគមន៍ $f(x)=\dfrac{x^2-2x}{x-1}$ ចំពោះ $x\neq 1$ មានក្រាប $(C)$។

ក. កំណត់ $a,b$ និង $c$ ដែលធ្វើឲ្យ $f(x)=ax+b+\dfrac{c}{x-1}$។

ខ. គណនា $\lim\limits_{x\to 1} f(x)$ និង $\lim\limits_{x\to\infty} f(x)$។ រកសមីការអាស៊ីមតូតទាំងអស់នៃក្រាប $(C)$។

គ. គណនា $f'(x)$។ ហើយទាញថា $f'(x)>0$ ចំពោះ $x\neq 1$។

ឃ. សង់តារាងអថេរភាពនៃ $f$។ ចូរស្រាយបញ្ជាក់ថាចំណុច $I(1,0)$ ជាផ្ចិតឆ្លុះនៃ $(C)$។

ង. សង់អាស៊ីមតូត និងក្រាប $(C)$ ក្នុងតម្រុយ $(O,\vec{i},\vec{j})$ តែមួយ។

ច. ដោយប្រើតាមក្រាហ្វិក សិក្សាអថេរភាព និងសញ្ញាឫសនៃសមីការ $x^2-(2+m)x+m=0$ ទៅតាមតម្លៃប៉ារ៉ាម៉ែត $m$។

**ចម្លើយ:**

មេរៀនទី ១ អនុគមន៍សនិទាន

៦១. គេអោយអនុគមន៍ $f(x)=\dfrac{-x^2+4x}{x-1}$ ចំពោះ $x\neq 1$ មានក្រាប $(C)$។

ក. កំណត់ចំនួនពិត $a,b$ និង $c$ ដែលធ្វើឲ្យ $f(x)=ax+b+\dfrac{c}{x-1}$។

ខ. គណនាលីមីត $\lim\limits_{x\to\pm\infty} f(x)$ និង $\lim\limits_{x\to 1} f(x)$។ រកសមីការអាស៊ីមតូតទាំងអស់នៃក្រាប $(C)$។

គ. បញ្ជាក់ទីតាំងធៀបរវាងក្រាប $(C)$ និងអាស៊ីមតូតទ្រេត។

ឃ. បញ្ជាក់ថា $f$ ជាអនុគមន៍ចុះលើ $\mathbb{R}\setminus\{1\}$។ សង់តារាងអថេរភាពនៃ $f$។

ង. ស្រាយបញ្ជាក់ថាចំនុច $I(1,2)$ ជាផ្ចិតឆ្លុះនៃ $(C)$។

ច. សង់អាស៊ីមតូត និងក្រាប $(C)$ នៅក្នុងតម្រុយ $(O,\vec{i},\vec{j})$ តែមួយ។

ឆ. ដោយប្រើតាមក្រាប ចូរពិភាក្សាអត្ថិភាព និង សញ្ញាឫសនៃសមីការ $-x^2+(4-m)x+m=0$ ទៅតាមតម្លៃប៉ារ៉ាម៉ែត $m$។

**ចម្លើយ:**

៦២. គេអោយអនុគមន៍ $f(x)=\dfrac{x^2+4x+1}{x+2}$ ចំពោះ$x\neq -2$ មានក្រាប$(C)$។

ក. កំណត់ចំនួនពិត$a,b$ និង $c$ដែលធ្វើឲ្យ $f(x)=ax+b+\dfrac{c}{x+2}$។

ខ. គណនាលីមីត $\lim\limits_{x\to\pm\infty} f(x)$ និង $\lim\limits_{x\to-2} f(x)$។ រកសមីការអាស៊ីមតូតទាំងអស់នៃក្រាប$(C)$។

គ. បង្ហាញថាបន្ទាត់$(L):y=x+2$ ជាសមីការអាស៊ីមតូតទ្រេតនៃក្រាប$(C)$។ បញ្ជាក់ទីតាំងរវាងក្រាប$(C)$ធៀបនឹងបន្ទាត់$(L)$។

ឃ. ចូរស្រាយបញ្ជាក់ថា$f$ជាអនុគមន៍កើនលើ $\mathbb{R}\setminus\{-2\}$។ សង់តារាងអថេរភាពនៃ$f$។

ង. ស្រាយថា$I(-2,0)$ ជាផ្ចិតឆ្លុះនៃក្រាប់$(C)$។

ច. សង់អាស៊ីមតូត និងក្រាប$(C)$នៅក្នុងតម្រុយ$(O,\vec{i},\vec{j})$តែមួយ។

ឆ. ដោយប្រើតាមក្រាប ចូរពិភាក្សាអត្ថិភាព និង សញ្ញាឬសនៃសមីការ $x^2+(4-m)x-(2m-1)=0$ទៅតាមតម្លៃប៉ារ៉ាម៉ែត$m$។

**ចម្លើយ:**

៦៣. គេអោយអនុគមន៍ $f(x)=\dfrac{x^2-2x+6}{x+1}$ ចំពោះ$x\neq-1$ មានក្រាប$(C)$។

ក. កំណត់ចំនួនពិត$a,b$ និង $c$ដែលធ្វើឲ្យ $f(x)=ax+b+\dfrac{c}{x+1}$។

ខ. គណនាលីមីត $\lim\limits_{x\to\pm\infty} f(x)$ និង $\lim\limits_{x\to-1} f(x)$។ រកសមីការអាស៊ីមតូតទាំងអស់នៃក្រាប$(C)$។

គ. គណនា$f'(x)$ និង រកតម្លៃបរមានៃ$f$។ សង់តារាងអថេរភាពនៃ$f$។

ឃ. ស្រាយថា$I(-1,-4)$ ជាផ្ចិតឆ្លុះនៃក្រាប់$(C)$។

ង. សង់អាស៊ីមតូត និងក្រាប$(C)$នៅក្នុងតម្រុយ$(O,\vec{i},\vec{j})$តែមួយ។

ច. ដោយប្រើតាមក្រាប ចូរពិភាក្សាអត្ថិភាព និង សញ្ញាឫសនៃសមីការ $x^2-(2+m)x-(m-6)=0$ទៅតាមតម្លៃប៉ារ៉ាម៉ែត$m$។

**ចម្លើយ:**

៦៤. គេអោយអនុគមន៍ $f(x)=\frac{x^2+2x+5}{x+1}$ ចំពោះ$x\neq -1$ មានក្រាប$(C)$។

ក. កំណត់ចំនួនពិត$m,n$ និង $p$ដែលធ្វើឲ្យ $f(x)=mx+n+\frac{p}{x+1}$។

ខ. គណនាលីមីត $\lim_{x\to\pm\infty} f(x)$ និង $\lim_{x\to-1} f(x)$។ រកសមីការអាស៊ីមតូតទាំងអស់នៃក្រាប$(C)$។

គ. បង្ហាញថា$f$មានតម្លៃអតិបរមាមួយ និង អប្បបរមាធៀបមួយ។រួចរកតម្លៃរបស់វា។ សង់តារាងអថេរភាពនៃ$f$។

ឃ. គណនា$f(-3), f(-2), f\left(-\frac{3}{2}\right), f\left(-\frac{1}{2}\right), f(0), f(1)$ និង $f(2)$។

ង. សង់អាស៊ីមតូត និងក្រាប$(C)$នៅក្នុងតម្រុយ$(O,\vec{i},\vec{j})$តែមួយ។

ច. ដោយប្រើតាមក្រាប ចូរពិភាក្សាអត្ថិភាព និង សញ្ញាឫសនៃសមីការ $x^2+(2-k)x+3-k=0$ទៅតាមតម្លៃប៉ារ៉ាម៉ែត$k$។

**ចម្លើយ:**

៦៥. គេអោយអនុគមន៍ $f(x)=\dfrac{x^2+x+2}{x-1}$ ចំពោះ $x\neq 1$ មានក្រាប $(C)$។

ក. គណនាលីមីត $\lim\limits_{x\to\pm\infty} f(x)$ និង $\lim\limits_{x\to 1} f(x)$។ រកសមីការអាស៊ីមតូតទាំងអស់នៃក្រាប $(C)$។

ខ. បង្ហាញថាចំណុច $I(1,3)$។ ជាផ្ចិតឆ្លុះនៃក្រាប $(C)$។

គ. គណនា និង សិក្សាសញ្ញានៃ $f'(x)$។ បង្ហាញថា $f$ មានតម្លៃអតិបរមាមួយ និង អប្បបរមាមួយ។ រួចគណនាតម្លៃបរមានេះ។ រួចសង់តារាងអថេរភាពនៃ $(C)$។

ឃ. សង់អាស៊ីមតូត និងក្រាប $(C)$ នៅក្នុងតម្រុយ $(O,\vec{i},\vec{j})$ តែមួយ។

ង. រកតម្លៃ $a$ ដើម្បីឲ្យសមីការ $f(x)=a$ មានឫសពីរផ្សេងគ្នាគឺ $x_1$ និង $x_2$ ដែល $1<x_1<x_2$ ដោយប្រើក្រាប $(C)$។

**ចម្លើយ:**

៦៦. គេអោយអនុគមន៍ $f(x)=x+\dfrac{4}{x-1}$ ចំពោះ $x\neq 1$ មានក្រាប $(C)$។

ក. គណនាលីមីត $\lim\limits_{x\to\pm\infty} f(x)$ និង $\lim\limits_{x\to 1} f(x)$។ រកសមីការអាស៊ីមតូតទាំងអស់នៃក្រាប $(C)$។

ខ. គណនា $f(0)$ និង $f'(0)$។ បង្ហាញថា $f$ មានអតិបរមាមួយ និង អប្បបរមាមួយរួចរកតម្លៃរបស់វា។

គ. សង់តារាងអថេរភាពនៃ $f$ រួចសង់អាស៊ីមតូត និងក្រាប $(C)$ នៅក្នុងតម្រុយ $(O,\vec{i},\vec{j})$ តែមួយ។

ឃ. រកចំនួនពិត $m$ ដើម្បីឲ្យសមីការ $x^2-(m+1)x+m+4=0$ គ្មានឫសដោយប្រើក្រាប $(C)$។

**ចម្លើយ:**

៦៧. គេអោយអនុគមន៍ $f(x)=\dfrac{ax^2+bx+c}{x+1}$ ចំពោះ $x\neq -1$ មានក្រាប $(C)$។

ក. រកចំនួនពិត $a,b$ និង $c$ ដើម្បីឲ្យក្រាប $(C)$ កាត់តាមចំណុច $A(0,1)$ ហើយ $f$ មានបរិមាធៀបត្រង់ចំណុច $B(1,0)$។

ខ. គណនាលីមីត $\lim\limits_{x\to\pm\infty} f(x)$ និង $\lim\limits_{x\to -1} f(x)$។ រកសមីការអាស៊ីមតូតទាំងអស់នៃក្រាប $(C)$។

គ. ចូរសិក្សាអថេរភាពនៃអនុគមន៍ $f$ និងសង់ក្រាប $f$។

ឃ. កំណត់តម្លៃ $m$ ដើម្បីឲ្យសមីការ $x^2-(2+m)x+1-m=0$ មានឫសពីរជាចំនួនពិតផ្សេងគ្នា ដោយប្រើក្រាប $(C)$។

**ចម្លើយ:**

៦៨. គេអោយអនុគមន៍ $f(x)=\dfrac{ax^2+bx+c}{x+2}$ ចំពោះ $x\neq -2$ មានក្រាប $(C)$។

ក. រកចំនួនពិត $a,b$ និង $c$ ដើម្បីឲ្យក្រាប $(C)$ កាត់តាមចំណុច $A\left(0,\dfrac{3}{2}\right)$ ហើយ $f$ មានបរិមាធៀបត្រង់ចំណុច $B(-1,0)$។

ខ. គណនាលីមីត $\lim\limits_{x\to\pm\infty} f(x)$ និង $\lim\limits_{x\to-2} f(x)$។ រកសមីការអាស៊ីមតូតទាំងអស់នៃក្រាប $(C)$។

គ. ចូរសិក្សាអថេរភាពនៃអនុគមន៍ $f$ និងសង់ក្រាប $f$។

ឃ. កំណត់តម្លៃ $m$ ដើម្បីឲ្យសមីការ $f(x)=m$ មានឫសពីរជាចំនួនពិតផ្សេងគ្នាដោយប្រើក្រាប $(C)$។

**ចម្លើយ:**

៦៩. គេអោយអនុគមន៍ $f(x)=\dfrac{ax^2+bx+c}{x+2}$ ចំពោះ $x\neq -2$ មានក្រាប $(C)$ ។

ក. រកចំនួនពិត $a,b$ និង $c$ ដើម្បីឲ្យក្រាប $(C)$ កាត់តាមចំណុច $A\left(0,\dfrac{3}{2}\right)$ ហើយ $f$ មានបរិមាធៀបត្រង់ចំណុច $B(-1,1)$ ។

ខ. គណនាលីមីត $\lim\limits_{x\to\pm\infty} f(x)$ និង $\lim\limits_{x\to -2} f(x)$ ។ រកសមីការអាស៊ីមតូតទាំងអស់នៃក្រាប $(C)$ ។

គ. ចូរសិក្សាអថេរភាពនៃអនុគមន៍ $f$ និងសង់ក្រាប $f$ ។

ឃ. កំណត់តម្លៃ $m$ ដើម្បីឲ្យ $f(x)=m$ មានឫសពីរជាចំនួនពិតផ្សេងគ្នា $x_1,x_2$ ដែល $x_1<x_2<-2$ ដោយប្រើក្រាប $(C)$ ។

**ចម្លើយ:**

៧០. គេអោយអនុគមន៍ $f(x)=\dfrac{x^2+ax+b}{x-1}$ ចំពោះ$x\neq 1$ មានក្រាប$(C)$។

ក. កំណត់ចំនួនពិត$a$ និង$b$ដើម្បីឲ្យ$f$មានតម្លៃអតិបរមាត្រង់$x=0$ស្មើនឹង$1$។

ខ. ចំពោះតម្លៃ$a$ និង$b$ដែលរកឃើញក្នុងសំណួរទី១៖

ⓐ. គណនាលីមីត $\lim\limits_{x\to\pm\infty} f(x)$ និង $\lim\limits_{x\to 1} f(x)$។ រកសមីការអាស៊ីមតូតទាំងអស់នៃក្រាប$(C)$។

ⓑ. គណនា $f'(x)$ និងសិក្សាសញ្ញារបស់វា។ រួចសង់តារាងអថេរភាពនៃ$f$។

ⓒ. សង់ក្រាប$(C)$នៅក្នុងតម្រុយ$(O,\vec{i},\vec{j})$។

ⓓ. ប្រើតាមក្រាហ្វិក ចូរសិក្សានូវអត្ថិភាព និងសញ្ញាឫសតាមតម្លៃប៉ារ៉ាម៉ែត$m$ ចំពោះ$x^2+(a-m)x+(b+m)=0$។

**ចម្លើយ:**

៧១. គេឱ្យ $f$ ជាអនុគមន៍កំណត់ដោយ $f(x)=\frac{x^2-6x}{x^2-6x+5}$ ហើយ $C$ ជាក្រាបនៃ $f$ ក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j})$។

ក. គណនាលីមីតត្រង់គោលនៃដែនកំណត់ រួចទាញឱ្យបានថា $C$ មានអាស៊ីមតូតឈរពីរ និងអាស៊ីមតូតដេកមួយដែលត្រូវកំណត់។

ខ. គណនា $f'(x)$ រួចសិក្សាសញ្ញារបស់វា។ ទាញថា $f$ មានអប្បបរមាធៀបមួយ រួចគណនាតម្លៃអប្បបរមាធៀបនោះ។ សង់តារាងអថេរភាពនៃ $f$។

គ. សង់ខ្សែកោង $C$ និងអាស៊ីមតូតរបស់វា។

**ចម្លើយ:**

៧២. អនុគមន៍ $f$ កំណត់ចំពោះ $x \neq 2$ ដោយ $y = f(x) = \frac{ax^2+bx+c}{(x-2)^2}$ ហើយ $C$ ជាក្រាបនៃ $f$ ក្នុងតម្រុយអរតូណរម៉ាល់ $(O, \vec{i}, \vec{j})$។

ក. រក $a,b,c$ ដោយដឹងថាក្រាប $C$ កាត់អ័ក្សអាប់ស៊ីសត្រង់ $x = 1$ និង $x = -3$ ហើយមានអាស៊ីមតូតដេកជាបន្ទាត់ $y = 1$។

ខ. រកសមីការអាស៊ីមតូតឈរនៃក្រាប $C$ និងសង់តារាងអថេរភាពនៃ $f$ ដែលកំណត់បានក្នុងសំណួរទី 1។

គ. សង់ក្រាប $C$ នៃអនុគមន៍ $f$ ។

**ចម្លើយ:**

៧៣. $f$ ជាអនុគមន៍កំណត់លើ $I = \mathbb{R} - \{-2, 2\}$ ដោយ $f(x) = \frac{2x^2}{x^2-4}$ ។

ក. សិក្សាលីមីតនៃ $f$ ត្រង់ $-\infty$, $-2$, $2$ និង $+\infty$ ។
ទាញរកសមីការអាស៊ីមតូតដេក និង អាស៊ីមតូតឈរនៃក្រាបតាងអនុគមន៍ $f$ ។

ខ. សិក្សាអថេរភាព និង សង់តារាងអថេរភាពនៃ $f$ ។

គ. សង់នៅក្នុងតម្រុយអរតូណរម៉ាល់ $\left(o, \vec{i}, \vec{j}\right)$ ក្រាបតាង $f$ ។

**ចម្លើយ:**

៧៤. អនុគមន៍ $f$ កំណត់ចំពោះ $x \neq -2,\ \ x \neq 2$ ដោយ $y = f(x) = \frac{x^2}{4-x^2}$ និងមានក្រាប $C$ ។

ក. គណនា $\lim_{x \to -2} f(x),\ \lim_{x \to 2} f(x)$ និង $\lim_{x \to \pm\infty} f(x)$ ។
ទាញរកសមីការអាស៊ីមតូតឈរ និង អាស៊ីមតូតដេកនៃក្រាប $C$ ។

ខ. សិក្សាសញ្ញានៃដេរីវេ $f'(x)$ និងសង់តារាងអថេរភាពនៃ $f$ ។

គ. គណនា $f(-3)$ និង $f(3)$ ហើយសង់ក្រាប $C$ នៃអនុគមន៍ $f$ ។

**ចម្លើយ:**

៧៥. អនុគមន៍ $f$ មួយកំណត់ដោយ $y=f(x)=\frac{2x^2-9x+4}{x^2+x-12}$ មានក្រាបតំណាង $(C)$ ។

ក. ចូររកដែនកំណត់នៃអនុគមន៍ $f$ ។

ខ. ចូរគណនាលីមីត៖ $\lim\limits_{x\to -4} f(x)$ ; $\lim\limits_{x\to 3} f(x)$ និង $\lim\limits_{x\to\pm\infty} f(x)$ ។

គ. កំណត់សមីការអាស៊ីមតូតឈរ និងអាស៊ីមតូតដេកនៃក្រាប$(C)$ ។

ឃ. គណនាដេរីវេនៃអនុគមន៍ $f$ រួចសិក្សាសញ្ញាដេរីវេ។

ង. សង់តារាងអថេរភាពនៃអនុគមន៍ $f$ និងសង់ក្រាប$(C)$ ។

**ចម្លើយ:**

៧៦. គេមានអនុគមន៍ $f$ មួយកំណត់ដោយ $y=f(x)=\frac{3x^2-18x+25}{x^2-6x+8}$ មានក្រាបតំណាង$(C)$។

ក. រកដែនកំណត់នៃអនុគមន៍$f$។

ខ. គណនាលីមីតនៃអនុគមន៍$f$ ត្រង់ $\pm\infty$ ; 2 និង 4 ។ រួចទាញរកសមីការអាស៊ីមតូតឈរ និងដេក។

គ. ចូរបង្ហាញថា $f'(x)=\frac{-2x+6}{\left(x^2-6x+8\right)^2}$ ចំពោះគ្រប់ $x\in\mathbb{R}-\{2,4\}$។

ឃ. សិក្សាសញ្ញាដេរីវេ$f'(x)$ និងសង់តារាងអថេរភាពនៃអនុគមន៍$f$។

ង. សង់ក្រាប $(C)$។

**ចម្លើយ:**

៧៧. គេឲ្យអនុគមន៍ $f$មួយ កំណត់ដោយ $y=f(x)=\frac{x^2+2x}{x^2+4}$ មានក្រាបតំណាង$(C)$ ។

ក. រកដែនកំណត់នៃអនុគមន៍$f$។

ខ. រកសមីការអាស៊ីមតូតដេកនៃក្រាប$(C)$។

គ. សិក្សាអថិរភាព និងសង់តារាងអថិរភាពនៃអនុគមន៍$f$ ។

ឃ. សង់ក្រាប $(C)$ ក្នុងតម្រុយ$\left(O,\vec{i},\vec{j}\right)$។

**ចម្លើយ:**

៧៨. គេមានអនុគមន៍ $f$ មួយ កំណត់ដោយលើ $\mathbb{R}-\{-2\}$ ដែល $y=f(x)=\frac{x^2-1}{(x+2)^2}$។ តាង $(C)$ ជាក្រាបតំណាងនៃអនុគមន៍ $f$។

ក. គណនា $\lim\limits_{x\to-2} f(x)$ ; $\lim\limits_{x\to\pm\infty} f(x)$។ រួចទាញរកសមីការអាស៊ីមតូតទាំងអស់ដែលមាន។

ខ. គណនាដេរីវេ $f'(x)$ រួចបង្ហាញថា $f$ មានតម្លៃអប្បបរមាធៀបមួយស្មើ $-\frac{1}{3}$ ត្រង់ $x=-\frac{1}{2}$។

គ. សង់តារាងអថេរភាព រួចសង់ក្រាប $(C)$។

**ចម្លើយ:**

៧៩. អនុគមន៍ $f$ មួយកំណត់ដោយ $y=f(x)=\frac{-x^2-2x+3}{x^2+3x+2}$ មានក្រាបតំណាង $(C)$។

ក. រកដែនកំណត់នៃអនុគមន៍ $f$ ។

ខ. សិក្សាលីមីតនៃ $f$ ត្រង់ $-1,\ -2$ និង $\pm\infty$។ ទាញរកអាស៊ីមតូតដេក និងអាស៊ីមតូតឈរទាំងពីរ។

គ. ចំពោះគ្រប់ $x\in\mathbb{R}\setminus\{-1,-2\}$ ចូរគណនាដេរីវេ $f'(x)$។

ឃ. សិក្សាសញ្ញាដេរីវេ $f'(x)$ រួចសង់តារាងអថេរភាពនៃអនុគមន៍ $f$ ។

ង. ចូរសង់ក្រាប $(C)$ ក្នុងតម្រុយ $(O,\vec{i},\vec{j})$

**ចម្លើយ:**

៨០. គេអោយអនុគមន៍ $f(x)=\dfrac{3x^2-18x+25}{x^2-6x+8}$ និង មានក្រាប $(C)$។

ក. រកដែនកំណត់នៃ $f$។ រកលីមីតនៃ $f$ ត្រង់ចុងដែនកំណត់ និង ទាញរកសមីការអាស៊ីមតូតនៃក្រាប $(C)$។

ខ. គណនា $f'(x)$ រួចសិក្សាសញ្ញារបស់វាព្រមទាំងកំណត់តម្លៃបរិមាធៀបផង។

គ. រកកូអរដោនេចំណុចប្រសព្វរវាងក្រាប $(C)$ នឹងអ័ក្សអាប់ស៊ីស។

ឃ. សង់តារាងអថេរភាពនៃ $f$។ គណនា $f(-1), f(0), f(1)$ និង $f(5)$។សង់ក្រាប $(C)$។

ង. ប្រើក្រាហ្វិកចូរសិក្សាអថេរភាព និងសញ្ញាឫសនៃសមីការ
$(3-m)x^2-(18-6m)x+25-8m=0$ តាមប៉ារ៉ាម៉ែត $m$។

**ចម្លើយ:**

៨១. គេអោយអនុគមន៍ $f(x)=\dfrac{3x^2-12x+10}{x^2-4x+3}$ កំណត់ដោយ $\mathbb{R}\setminus\{1,3\}$ និង មានក្រាប $(C)$។

ក. រកលីមីតនៃ $f$ ត្រង់ចុងដែនកំណត់ និង ទាញរកសមីការអាស៊ីមតូតនៃក្រាប $(C)$។

ខ. រកកូអរដោនេចំណុចប្រសព្វរវាងក្រាប $(C)$ នឹងអ័ក្សអាប់ស៊ីស។

គ. បង្ហាញថា $f$ មានតម្លៃបរិមាធៀបមួយត្រង់ $x=2$។ រួចរកតម្លៃវា។

ឃ. សិក្សាអថេរភាពនៃអនុគមន៍ $f$។

ង. សង់ក្រាប $(C)$។ ដោយប្រើក្រាប $(C)$ ចូរកំណត់តម្លៃ $k$ ដើម្បីឲ្យសមីការ $f(x)=k$ គ្មានឫស។

**ចម្លើយ:**

៨២. គេអោយអនុគមន៍ $f(x)=\dfrac{x^2-1}{(x+2)^2}$ កំណត់ដោយ $\mathbb{R}\setminus\{-2\}$ និង មានក្រាប $(C)$។

ក. រកលីមីតនៃ $f$ ត្រង់ចុងដែនកំណត់ និង ទាញរកសមីការអាស៊ីមតូតនៃក្រាប $(C)$។

ខ. គណនា $f'(x)$ និងសិក្សាសញ្ញារបស់វា។ សង់តារាងអថេរភាពនៃ $f$។

គ. រកកូអរដោនេចំណុចប្រសព្វរវាងក្រាប $(C)$ និងអ័ក្សនៃតម្រុយហើយអាស៊ីមតូតដេក។

ឃ. សង់ក្រាប $(C)$។

**ចម្លើយ:**

៨៣. គេអោយអនុគមន៍ $f(x)=\dfrac{3x^2-6x}{x^2+x-2}$ និង មានក្រាប $(C)$។

ក. រកដែនកំណត់នៃ $f$។ ស្រាយបញ្ជាក់ថាអនុគមន៍ $f$ កើនជានិច្ចលើដែនកំណត់។

ខ. រកលីមីតនៃ $f$ ត្រង់ចុងដែនកំណត់ និង ទាញរកសមីការអាស៊ីមតូតនៃក្រាប $(C)$។

គ. រកសមីការបន្ទាត់ $(L)$ ប៉ះក្រាប $(C)$ ត្រង់ចំណុចដែលមានអាប់ស៊ីស $x_0=3$។

ឃ. គូសតារាងអថេរភាពនៃ $f$។ សង់ខ្សែកោង $(C)$។

ង. តាមក្រាប $(C)$ ចូរសិក្សាអត្ថិភាព និង សញ្ញាឫសនៃសមីការ $(3-k)x^2-(6+k)x+2k=0$ ទៅតាមប៉ារ៉ាម៉ែត $k$។

**ចម្លើយ:**

៨៤. គេអោយអនុគមន៍ $f(x)=\frac{x^2}{x^2+x-2}$ និង មានក្រាប $(C)$។

ក. រកដែនកំណត់នៃ $f$។ រកលីមីតនៃ $f$ ត្រង់ចុងដែនកំណត់ និង ទាញរកសមីការអាស៊ីមតូតនៃក្រាប $(C)$។

ខ. គណនា $f'(x)$ និងសិក្សាសញ្ញារបស់វា។

គ. កំណត់តម្លៃបរិមានៃ $f$។ សង់តារាងអថេរភាពនៃ $f$។

ឃ. រកកូអរដោនេចំណុច $A$ ដែលជាប្រសព្វរវាង $(C)$ និង អាស៊ីមតូតដេក។

ង. តាមក្រាប $(C)$ ចូរសិក្សាអត្ថិភាព និង សញ្ញាឫសនៃសមីការ $(1-m)x^2-mx+2m=0$ ទៅតាមប៉ារ៉ាម៉ែត $m$។

**ចម្លើយ:**



# មេរៀនទី ២
# អនុគមន៍អិចស្ប៉ូណង់ស្យែល

## ១ និយមន័យ

**និយមន័យ ១**

អនុគមន៍អ៊ិចស្ប៉ូណង់ស្យែល មានរាង $y = f(x) = e^x$ មានន័យគ្រប់ $x \in \mathbb{R}$

## ២ លក្ខណៈ

**ជាទូទៅ ១**

ចំពោះគ្រប់ចំនួនពិត $m, n$ គេបាន

ក. $e^{m+n} = e^m \cdot e^n$

គ. $e^{m-n} = \frac{e^m}{e^n}$

ខ. $e^{-n} = \frac{1}{e^n}$

ឃ. $(e^m)^n = e^{mn}$

## ៣ សមីការនៃអនុគមន៍អ៊ិចស្ប៉ូណង់ស្យែល

**ជាទូទៅ ២**

ចំពោះអនុគមន៍ អ៊ិចស្បូមានលក្ខណៈមួយចំនួនដូចខាងក្រោម៖

- $e^x = a \Leftrightarrow e^x = e^{\ln a} \Rightarrow x = \ln a$

- $e^x > a \Leftrightarrow e^x > e^{\ln a} \Rightarrow x > \ln a$
- $e^x < a \Leftrightarrow e^x < e^{\ln a} \Rightarrow x < \ln a$

## ៤ ដេរីវេនៃអនុគមន៍អិចស្ប៉ូណង់ស្យែល

**ជាទូទៅ ៣**

- បើ $f(x) = e^x$ នោះ $f'(x) = e^x$
- បើ $f(x) = e^{u(x)}$ នោះ $f'(x) = u'(x) \cdot e^{u(x)}$

**លំហាត់គំរូ ១**

គណនាដេរីវេនៃអនុគមន៍ខាងក្រោម៖

ក. $y = e^{4x}$

ខ. $y = e^{x^2-3x+1}$

គ. $y = xe^x$

ឃ. $y = (x^2-3)e^x$

ង. $y = x^2e^{-2x}$

ច. $y = \frac{\sqrt{x}}{e^x}$

ឆ. $y = xe^{-x}$

ជ. $f(x) = x^2e^x$

ឈ. $g(x) = \frac{e^x-e^{-x}}{e^x+e^{-x}}$

ញ. $y = \frac{e^x+e^{-x}}{2}$

ដ. $f(x) = \frac{e^x(1+\cos x)}{1-\cos x}$

ឋ. $g(x) = e^{\frac{x-1}{x+1}}$

**ចម្លើយ:**

# ៩ លីមីតនៃអនុគមន៍

**ជាទូទៅ ៤**

រូបមន្តលីមីតនៃអនុគមន៍អ៊ិចស្ប៉ូណង់ស្យែល

- $\lim\limits_{x \to -\infty} e^x = 0$
- $\lim\limits_{x \to +\infty} e^x = +\infty$
- $\lim\limits_{x \to +\infty} \frac{e^x}{x^n} = +\infty$
- $\lim\limits_{x \to +\infty} \frac{x^n}{e^x} = 0$
- $\lim\limits_{x \to -\infty} x^n e^x = 0$
- $\lim\limits_{x \to 0} \frac{e^x - 1}{x} = 1$
- $\lim\limits_{x \to 0} \frac{e^{ax} - 1}{ax} = 1$
- $\lim\limits_{x \to +\infty} \left(1 + \frac{1}{x}\right)^x = e$
- $\lim\limits_{x \to +\infty} \left(1 + \frac{a}{x}\right)^{\frac{x}{a}} = e$
- $\lim\limits_{x \to 0} (1 + x)^{\frac{1}{x}} = e$
- $\lim\limits_{x \to 0} \left(1 + \frac{x}{a}\right)^{\frac{a}{x}} = e$

**លំហាត់គំរូ ២**

គណនាលីមីតនៃអនុគមន៍ខាងក្រោម៖

ក. $\lim\limits_{x \to +\infty} e^{3x}$

ខ. $\lim\limits_{x \to -\infty} e^{5x}$

គ. $\lim\limits_{x \to +\infty} 6e^{2x}$

ឃ. $\lim\limits_{x \to +\infty} xe^{x+1}$

ង. $\lim\limits_{x \to -\infty} x^2 e^{4x}$

ច. $\lim\limits_{x \to +\infty} \left(1 + \frac{n}{x}\right)^x$

ឆ. $\lim\limits_{x \to +\infty} \frac{3e^{x-2}}{x^3}$

ជ. $\lim\limits_{x \to +\infty} \left(\frac{x+3}{x-1}\right)^{x+2}$

ឈ. $\lim\limits_{x \to 0} \left(\frac{e^x - e^{-x}}{x}\right)$

**ចម្លើយ:**

# ៦ សិក្សាអនុគមន៍

**លំហាត់គំរូ ៣**

សិក្សាអថេរភាព និងសង់ក្រាបនៃអនុគមន៍ $f(x)=xe^{x}$

**ចម្លើយ:**

## លំហាត់គំរូ ៤

សិក្សាអថេរភាព និងសង់ក្រាបនៃអនុគមន៍ $f(x) = x^2e^{-x}$

**ចម្លើយ:**

# វិញ្ញាសាពហុជ្រើសរើស៖ អនុគមន៍អិចស្ប៉ូណង់ស្យែល (១០០ លំហាត់)

## សម្រាប់ត្រៀមប្រឡងបាក់ឌុប និងពង្រឹងសមត្ថភាព

១. ដែនកំណត់នៃអនុគមន៍ $f(x)=e^x$ គឺ៖

ក. $\mathbb{R}$ ខ. $(0,+\infty)$ គ. $[0,+\infty)$ ឃ. $\mathbb{R}^*$

២. ដែនកំណត់នៃអនុគមន៍ $f(x)=e^{\frac{1}{x}}$ គឺ៖

ក. $\mathbb{R}$ ខ. $\mathbb{R}\setminus\{0\}$ គ. $(0,+\infty)$ ឃ. $x>1$

៣. អនុគមន៍ $f(x)=\frac{1}{e^x-1}$ មានន័យកាលណា៖

ក. $x\neq 0$ ខ. $x>0$ គ. $x\neq 1$ ឃ. $x\geq 0$

៤. ដែនកំណត់នៃអនុគមន៍ $f(x)=\sqrt{e^x-1}$ គឺ៖

ក. $[0,+\infty)$ ខ. $(0,+\infty)$ គ. $\mathbb{R}$ ឃ. $(-\infty,0]$

៥. ដែនកំណត់នៃអនុគមន៍ $f(x)=e^{\sqrt{x}}$ គឺ៖

ក. $[0,+\infty)$ ខ. $\mathbb{R}$ គ. $(0,+\infty)$ ឃ. $\mathbb{R}\setminus\{0\}$

៦. អនុគមន៍ $f(x)=\frac{1}{e^x+1}$ មានដែនកំណត់៖

ក. $\mathbb{R}$ ខ. $\mathbb{R}\setminus\{-1\}$ គ. $x>0$ ឃ. $x\neq 0$

៧. ដែនកំណត់នៃអនុគមន៍ $f(x)=\frac{e^x+1}{e^x-2}$ គឺ៖

ក. $\mathbb{R}\setminus\{\ln 2\}$ ខ. $\mathbb{R}\setminus\{2\}$ គ. $(0,+\infty)$ ឃ. $x>\ln 2$

៨. ចំពោះគ្រប់ចំនួនពិត $a,b$ រូបមន្ត $e^{a+b}$ ស្មើនឹង៖

ក. $e^a\cdot e^b$ ខ. $e^a+e^b$ គ. $(e^a)^b$ ឃ. $e^a-e^b$

៩. ចំពោះគ្រប់ចំនួនពិត $a,b$ រូបមន្ត $e^{a-b}$ ស្មើនឹង៖

ក. $\frac{e^a}{e^b}$ ខ. $e^a-e^b$ គ. $e^b-e^a$ ឃ. $\frac{e^b}{e^a}$

១០. រូបមន្ត $(e^a)^b$ ស្មើនឹង៖

ក. $e^{ab}$ ខ. $e^{a+b}$ គ. $e^{a/b}$ ឃ. $ae^b$

១១. តម្លៃនៃ $e^0$ ស្មើនឹង៖

ក. $1$ ខ. $0$ គ. $e$ ឃ. $+\infty$

១២. បើ $a>0$ នោះតម្លៃនៃ $e^{\ln a}$ ស្មើនឹង៖

ក. $a$ ខ. $\ln a$ គ. $e^a$ ឃ. $1$

១៣. ចំពោះគ្រប់ចំនួនពិត $a$ តម្លៃនៃ $\ln(e^a)$ ស្មើនឹង៖

ក. $a$ ខ. $e^a$ គ. $1$ ឃ. $0$

១៤. សញ្ញានៃ $e^x$ ចំពោះគ្រប់ $x \in \mathbb{R}$ គឺ៖

ក. $e^x > 0$ ខ. $e^x \geq 0$ គ. $e^x < 0$ ឃ. ដូរសញ្ញាតាម $x$

១៥. កន្សោម $e^{-x}$ ស្មើនឹង៖

ក. $\frac{1}{e^x}$ ខ. $-e^x$ គ. $(-e)^x$ ឃ. $1-e^x$

១៦. តម្លៃនៃ $e^{\ln 3+\ln 2}$ ស្មើនឹង៖

ក. $6$ ខ. $5$ គ. $e^5$ ឃ. $e^6$

១៧. តម្លៃនៃ $\frac{e^5}{e^2}$ ស្មើនឹង៖

ក. $e^3$ ខ. $e^{2.5}$ គ. $e^7$ ឃ. $e^{10}$

១៨. តម្លៃនៃ $(e^2)^3$ ស្មើនឹង៖

ក. $e^6$ ខ. $e^5$ គ. $e^8$ ឃ. $6e$

១៩. អនុគមន៍ $f(x)=\sqrt{1-e^x}$ មានន័យកាលណា៖

ក. $x \leq 0$ ខ. $x \geq 0$ គ. $x < 1$ ឃ. $x \leq 1$

២០. ដែនកំណត់នៃ $f(x)=e^{\frac{x+1}{x-2}}$ គឺ៖

ក. $\mathbb{R}\setminus\{2\}$ ខ. $\mathbb{R}\setminus\{-1,2\}$ គ. $x > 2$ ឃ. $\mathbb{R}$

២១. ដេរីវេនៃ $f(x)=e^x$ គឺ៖

ក. $f'(x)=e^x$ ខ. $f'(x)=xe^{x-1}$ គ. $f'(x)=\frac{e^x}{x}$ ឃ. $f'(x)=1$

២២. ដេរីវេនៃ $f(x)=e^{2x}$ គឺ៖

ក. $2e^{2x}$ ខ. $e^{2x}$ គ. $\frac{1}{2}e^{2x}$ ឃ. $2xe^{2x-1}$

២៣. ដេរីវេនៃ $f(x)=e^{-x}$ គឺ៖

ក. $-e^{-x}$ ខ. $e^{-x}$ គ. $e^x$ ឃ. $-e^x$

២៤. ដេរីវេនៃ $f(x)=e^{3x-1}$ គឺ៖

ក. $3e^{3x-1}$ ខ. $e^{3x-1}$ គ. $(3x-1)e^{3x-1}$ ឃ. $\frac{1}{3}e^{3x-1}$

២៥. ដេរីវេនៃ $f(x)=e^{x^2}$ គឺ៖

ក. $2xe^{x^2}$ ខ. $x^2e^{x^2}$ គ. $e^{2x}$ ឃ. $2e^{x^2}$

២៦. ដេរីវេនៃ $f(x)=e^{-x^2}$ គឺ៖

ក. $-2xe^{-x^2}$ ខ. $2xe^{-x^2}$ គ. $-x^2e^{-x^2}$ ឃ. $-2e^{-x^2}$

២៧. ដេរីវេនៃ $f(x)=xe^x$ គឺ៖

ក. $(x+1)e^x$ ខ. $e^x$ គ. $xe^x$ ឃ. $(x-1)e^x$

២៨. ដេរីវេនៃ $f(x)=x^2e^x$ គឺ៖

ក. $(x^2+2x)e^x$ ខ. $2xe^x$ គ. $(x^2+x)e^x$ ឃ. $x^2e^x$

២៩. ដេរីវេនៃ $f(x)=(x-1)e^x$ គឺ៖

ក. $xe^x$ ខ. $(x-2)e^x$ គ. $e^x$ ឃ. $(x+1)e^x$

៣០. ដេរីវេនៃ $f(x)=\frac{e^x}{x}$ គឺ៖

ក. $\frac{(x-1)e^x}{x^2}$ ខ. $\frac{(x+1)e^x}{x^2}$ គ. $\frac{e^x}{x^2}$ ឃ. $\frac{e^x}{1}$

៣១. ដេរីវេនៃ $f(x)=e^{\sqrt{x}}$ ចំពោះ $x>0$ គឺ៖

ក. $\frac{e^{\sqrt{x}}}{2\sqrt{x}}$ ខ. $\frac{e^{\sqrt{x}}}{\sqrt{x}}$ គ. $2\sqrt{x}e^{\sqrt{x}}$ ឃ. $\frac{1}{2}e^{\sqrt{x}}$

៣២. ដេរីវេនៃ $f(x)=e^{\sin x}$ គឺ៖

ក. $\cos x\cdot e^{\sin x}$ ខ. $-\cos x\cdot e^{\sin x}$ គ. $\sin x\cdot e^{\sin x}$ ឃ. $e^{\cos x}$

៣៣. ដេរីវេនៃ $f(x)=e^{\cos x}$ គឺ៖

ក. $-\sin x\cdot e^{\cos x}$ ខ. $\sin x\cdot e^{\cos x}$ គ. $\cos x\cdot e^{\cos x}$ ឃ. $e^{-\sin x}$

៣៤. ដេរីវេនៃ $f(x)=\frac{1}{e^x+1}$ គឺ៖

ក. $-\frac{e^x}{(e^x+1)^2}$ ខ. $\frac{e^x}{(e^x+1)^2}$ គ. $-\frac{1}{(e^x+1)^2}$ ឃ. $\frac{1}{e^x}$

៣៥. ដេរីវេនៃ $f(x)=(x^2-2x+2)e^x$ គឺ៖

ក. $x^2e^x$ ខ. $(x^2-2)e^x$ គ. $(2x-2)e^x$ ឃ. $(x^2+2)e^x$

៣៦. ដេរីវេទី ២ នៃ $f(x)=e^{2x}$ គឺ៖

ក. $4e^{2x}$ ខ. $2e^{2x}$ គ. $8e^{2x}$ ឃ. $e^{2x}$

៣៧. ដេរីវេទី ២ នៃ $f(x)=xe^x$ គឺ៖

ក. $(x+2)e^x$ ខ. $(x+1)e^x$ គ. $xe^x$ ឃ. $2e^x$

៣៨. បើ $f(x)=e^{-x}$ នោះ $f''(x)=$៖

ក. $e^{-x}$ ខ. $-e^{-x}$ គ. $e^x$ ឃ. $-e^x$

៣៩. បើ $f(x)=e^{3x}$ នោះដេរីវេទី $n$ គឺ $f^{(n)}(x)=$៖

ក. $3^n e^{3x}$ ខ. $3e^{3x}$ គ. $n\cdot 3e^{3x}$ ឃ. $3^{n-1}e^{3x}$

៤០. ចំណុចរបត់នៃក្រាបតាង $f(x)=xe^x$ មានអាប់ស៊ីស $x$ ស្មើនឹង៖

ក. $-2$ ខ. $-1$ គ. $0$ ឃ. $1$

៤១. តម្លៃនៃ $\lim\limits_{x\to+\infty} e^x$ គឺ៖

ក. $+\infty$ ខ. $0$ គ. $-\infty$ ឃ. $1$

៤២. តម្លៃនៃ $\lim\limits_{x\to-\infty} e^x$ គឺ៖

ក. $0$ ខ. $-\infty$ គ. $+\infty$ ឃ. $1$

៤៣. តម្លៃនៃ $\lim\limits_{x\to+\infty} e^{-x}$ គឺ៖

ក. $0$ ខ. $+\infty$ គ. $-\infty$ ឃ. $-1$

៤៤. តម្លៃនៃ $\lim\limits_{x\to-\infty} e^{-x}$ គឺ៖

ក. $+\infty$ ខ. $0$ គ. $-\infty$ ឃ. $1$

៤៥. តម្លៃនៃ $\lim\limits_{x\to+\infty} \frac{e^x}{x}$ គឺ៖

ក. $+\infty$ ខ. $0$ គ. $1$ ឃ. $e$

៤៦. តម្លៃនៃ $\lim\limits_{x\to+\infty} \frac{e^x}{x^2}$ គឺ៖

ក. $+\infty$ ខ. $0$ គ. $1$ ឃ. $2$

៤៧. តម្លៃនៃ $\lim\limits_{x\to+\infty} \frac{x}{e^x}$ គឺ៖

ក. $0$ ខ. $+\infty$ គ. $1$ ឃ. $e$

៤៨. តម្លៃនៃ $\lim\limits_{x\to-\infty} xe^x$ គឺ៖

ក. $0$ ខ. $-\infty$ គ. $+\infty$ ឃ. $-1$

៤៩. តម្លៃនៃ $\lim\limits_{x\to-\infty} x^2e^x$ គឺ៖

ក. $0$ ខ. $+\infty$ គ. $-\infty$ ឃ. $1$

៥០. តម្លៃនៃ $\lim\limits_{x\to0} \frac{e^x-1}{x}$ គឺ៖

ក. 1　ខ. 0　គ. $e$　ឃ. $+\infty$

៥១. តម្លៃនៃ $\lim_{x\to 0}\frac{e^{2x}-1}{x}$ គឺៈ

ក. 2　ខ. 1　គ. 0　ឃ. $\frac{1}{2}$

៥២. តម្លៃនៃ $\lim_{x\to 0}\frac{e^{kx}-1}{x}$ $(k\neq 0)$ គឺៈ

ក. $k$　ខ. 1　គ. 0　ឃ. $\frac{1}{k}$

៥៣. តម្លៃនៃ $\lim_{x\to 0}\frac{e^{x}-e^{-x}}{x}$ គឺៈ

ក. 2　ខ. 1　គ. 0　ឃ. $-2$

៥៤. តម្លៃនៃ $\lim_{x\to +\infty}\frac{2e^{x}+1}{e^{x}-3}$ គឺៈ

ក. 2　ខ. $-\frac{1}{3}$　គ. 1　ឃ. $+\infty$

៥៥. តម្លៃនៃ $\lim_{x\to -\infty}\frac{2e^{x}+1}{e^{x}-3}$ គឺៈ

ក. $-\frac{1}{3}$　ខ. 2　គ. 0　ឃ. 1

៥៦. តម្លៃនៃ $\lim_{x\to +\infty}(x-e^{x})$ គឺៈ

ក. $-\infty$　ខ. $+\infty$　គ. 0　ឃ. 1

៥៧. តម្លៃនៃ $\lim_{x\to 0}\frac{e^{x^2}-1}{x^2}$ គឺៈ

ក. 1　ខ. 0　គ. 2　ឃ. $+\infty$

៥៨. តម្លៃនៃ $\lim_{x\to +\infty}\frac{e^{2x}}{e^{x}+1}$ គឺៈ

ក. $+\infty$　ខ. 1　គ. 0　ឃ. 2

៥៩. តម្លៃនៃ $\lim_{x\to -\infty}(x^2+1)e^{x}$ គឺៈ

ក. 0　ខ. $+\infty$　គ. $-\infty$　ឃ. 1

៦០. តម្លៃនៃ $\lim_{x\to 0}\frac{e^{\sin x}-1}{x}$ គឺៈ

ក. 1　ខ. 0　គ. $\cos 1$　ឃ. $+\infty$

៦១. ឫសនៃសមីការ $e^{x}=1$ គឺៈ

ក. $x=0$　ខ. $x=1$　គ. $x=e$　ឃ. គ្មានឫស

៦២. ឫសនៃសមីការ $e^{x}=e^{3}$ គឺៈ

ក. $x=3$　ខ. $x=\ln 3$　គ. $x=e^{3}$　ឃ. $x=1$

៦៣. ឫសនៃសមីការ $e^{2x-1}=1$ គឺៈ

ក. $x=\frac{1}{2}$ ខ. $x=1$ គ. $x=0$ ឃ. $x=-\frac{1}{2}$

៦៤. ឫសនៃសមីការ $e^x=5$ គឺ៖

ក. $x=\ln 5$ ខ. $x=e^5$ គ. $x=5$ ឃ. $x=\frac{5}{e}$

៦៥. ឫសនៃសមីការ $e^{2x}=4$ គឺ៖

ក. $x=\ln 2$ ខ. $x=\ln 4$ គ. $x=2$ ឃ. $x=2\ln 2$

៦៦. ឫសនៃសមីការ $e^x=-2$ គឺ៖

ក. គ្មានឫសក្នុង $\mathbb{R}$ គ. $x=\ln(-2)$

ខ. $x=-\ln 2$ ឃ. $x=-2$

៦៧. សំណុំឫសនៃសមីការ $e^{x^2-4}=1$ គឺ៖

ក. $\{-2,2\}$ ខ. $\{2\}$ គ. $\{0,4\}$ ឃ. $\{4\}$

៦៨. សំណុំឫសនៃសមីការ $e^{2x}-3e^x+2=0$ គឺ៖

ក. $\{0,\ln 2\}$ ខ. $\{1,2\}$ គ. $\{0,1\}$ ឃ. $\{\ln 2\}$

៦៩. សំណុំឫសនៃសមីការ $e^{2x}-4e^x+3=0$ គឺ៖

ក. $\{0,\ln 3\}$ ខ. $\{1,3\}$ គ. $\{0,3\}$ ឃ. $\{\ln 3\}$

៧០. ឫសនៃសមីការ $e^x+e^{-x}=2$ គឺ៖

ក. $x=0$ ខ. $x=1$ គ. $x=-1$ ឃ. $x=\pm 1$

៧១. ឫសនៃសមីការ $e^{2x}-e^x=0$ គឺ៖

ក. $x=0$ ខ. $x=1$ គ. $x=e$ ឃ. គ្មានឫស

៧២. ឫសនៃសមីការ $e^{x+1}\cdot e^{x-1}=1$ គឺ៖

ក. $x=0$ ខ. $x=1$ គ. $x=-1$ ឃ. $x=\pm 1$

៧៣. វិសមីការ $e^x>1$ មានសំណុំចម្លើយ៖

ក. $(0,+\infty)$ ខ. $[0,+\infty)$ គ. $(1,+\infty)$ ឃ. $\mathbb{R}$

៧៤. វិសមីការ $e^x\leq 1$ មានសំណុំចម្លើយ៖

ក. $(-\infty,0]$ ខ. $([-\infty,0)$ គ. $(-\infty,1]$ ឃ. $\emptyset$

៧៥. វិសមីការ $e^{2x-4}>1$ មានសំណុំចម្លើយ៖

ក. $(2,+\infty)$ ខ. $(4,+\infty)$ គ. $[2,+\infty)$ ឃ. $(0,+\infty)$

៧៦. វិសមីការ $e^x > -5$ មានសំណុំចម្លើយ៖

ក. $\mathbb{R}$ ខ. $(-\ln 5,+\infty)$ គ. $(0,+\infty)$ ឃ. $\emptyset$

៧៧. វិសមីការ $e^x < 0$ មានសំណុំចម្លើយ៖

ក. $\emptyset$ ខ. $\mathbb{R}$ គ. $(-\infty,0)$ ឃ. $\{0\}$

៧៨. វិសមីការ $e^{x^2-1} \leq 1$ មានសំណុំចម្លើយ៖

ក. $[-1,1]$ ខ. $(-\infty,1]$ គ. $[0,1]$ ឃ. $\{-1,1\}$

៧៩. សំណុំចម្លើយនៃវិសមីការ $e^{2x}-5e^x+6<0$ គឺ៖

ក. $(\ln 2,\ln 3)$ ខ. $(2,3)$ គ. $(0,\ln 3)$ ឃ. $(-\infty,\ln 2)$

៨០. ចំនួនឫសពិតនៃសមីការ $e^x = x+1$ គឺ៖

ក. មានឫសតែមួយ $x=0$

គ. គ្មានឫស

ខ. មានឫសពីរ

ឃ. មានឫសរាប់មិនអស់

៨១. អនុគមន៍ $f(x)=e^x$ ជាអនុគមន៍៖

ក. កើនជានិច្ចលើ $\mathbb{R}$

គ. កើនផងចុះផង

ខ. ចុះជានិច្ចលើ $\mathbb{R}$

ឃ. ជាអនុគមន៍ថេរ

៨២. អនុគមន៍ $f(x)=e^{-x}$ ជាអនុគមន៍៖

ក. ចុះជានិច្ចលើ $\mathbb{R}$

គ. កើនលើ $(0,+\infty)$

ខ. កើនជានិច្ចលើ $\mathbb{R}$

ឃ. ចុះលើ $(-\infty,0)$

៨៣. អនុគមន៍ $f(x)=xe^x$ មានដេរីវេ $f'(x)=0$ ត្រង់៖

ក. $x=-1$ ខ. $x=0$ គ. $x=1$ ឃ. $x=-2$

៨៤. តម្លៃអប្បបរមាធៀបនៃអនុគមន៍ $f(x)=xe^x$ គឺ៖

ក. $-\frac{1}{e}$ ខ. $0$ គ. $-1$ ឃ. $-e$

៨៥. ដេរីវេនៃ $f(x)=x^2e^{-x}$ ស្មើ 0 ត្រង់តម្លៃ $x$ ណាខ្លះ?

ក. $x=0, x=2$ ខ. $x=0, x=-2$ គ. $x=1, x=2$ ឃ. $x=0, x=1$

៨៦. តម្លៃអតិបរមាធៀបនៃអនុគមន៍ $f(x)=x^2e^{-x}$ គឺ៖

ក. $\frac{4}{e^2}$ ខ. $\frac{2}{e}$ គ. $4e^2$ ឃ. $0$

៨៧. សមីការអាស៊ីមតូតដេកនៃក្រាប $y=e^x$ កាលណា $x\to-\infty$ គឺ៖

ក. $y=0$ ខ. $x=0$ គ. $y=1$ ឃ. $y=-1$

៨៨. សមីការអាស៊ីមតូតដេកនៃក្រាប $y=\frac{e^x}{e^x+1}$ កាលណា $x\to+\infty$ គឺ៖

ក. $y=1$ ខ. $y=0$ គ. $y=-1$ ឃ. $x=0$

៨៩. សមីការអាស៊ីមតូតដេកនៃក្រាប $y=\frac{e^x}{e^x+1}$ កាលណា $x\to-\infty$ គឺ៖

ក. $y=0$ ខ. $y=1$ គ. $y=-1$ ឃ. $x=1$

៩០. សមីការបន្ទាត់ប៉ះនឹងក្រាប $y=e^x$ ត្រង់ចំណុច $x=0$ គឺ៖

ក. $y=x+1$ ខ. $y=x$ គ. $y=2x+1$ ឃ. $y=x-1$

៩១. សមីការបន្ទាត់ប៉ះនឹងក្រាប $y=e^{-x}$ ត្រង់ចំណុច $x=0$ គឺ៖

ក. $y=-x+1$ ខ. $y=-x$ គ. $y=x+1$ ឃ. $y=-x-1$

៩២. ក្រាបនៃអនុគមន៍ $y=e^x$ កាត់អ័ក្សអរដោនេ $y'y$ ត្រង់ចំណុច៖

ក. $(0,1)$ ខ. $(1,0)$ គ. $(0,0)$ ឃ. $(0,e)$

៩៣. ក្រាបនៃអនុគមន៍ $y=e^x$ កាត់អ័ក្សអាប់ស៊ីស $x'x$ ត្រង់ចំណុច៖

ក. មិនកាត់អ័ក្ស $x'x$ ទេ គ. $(1,0)$
ខ. $(0,0)$ ឃ. $(-1,0)$

៩៤. ក្រាបនៃអនុគមន៍ $y=(x-2)e^x$ កាត់អ័ក្ស $x'x$ ត្រង់ចំណុច៖

ក. $(2,0)$ ខ. $(0,-2)$ គ. $(-2,0)$ ឃ. $(1,0)$

៩៥. សមីការអាស៊ីមតូតទ្រេតនៃក្រាប $y=x+e^{-x}$ កាលណា $x\to+\infty$ គឺ៖

ក. $y=x$ គ. $y=0$
ខ. $y=-x$ ឃ. គ្មានអាស៊ីមតូតទ្រេត

៩៦. សមីការអាស៊ីមតូតទ្រេតនៃក្រាប $y=2x-1+e^x$ កាលណា $x\to-\infty$ គឺ៖

ក. $y=2x-1$ ខ. $y=2x$ គ. $y=2x+1$ ឃ. $y=-1$

៩៧. មេគុណប្រាប់ទិសនៃបន្ទាត់ប៉ះនឹងក្រាប $y=e^{2x}$ ត្រង់ $x=0$ គឺ៖

ក. $2$ ខ. $1$ គ. $0$ ឃ. $4$

៩៨. ក្រាបនៃអនុគមន៍ $y=e^x$ និង $y=e^{-x}$ ឆ្លុះគ្នាធៀបនឹង៖

ក. អ័ក្សអរដោនេ $y'y$

ខ. អ័ក្សអាប់ស៊ីស $x'x$

គ. គល់កូអរដោនេ $O$

ឃ. បន្ទាត់ $y=x$

៩៩. អនុគមន៍ $f(x)=\frac{e^x-e^{-x}}{2}$ ជាអនុគមន៍៖

ក. សេស

ខ. គូ

គ. មិនគូមិនសេស

ឃ. ជាអនុគមន៍ថេរ

១០០. អនុគមន៍ $f(x)=\frac{e^x+e^{-x}}{2}$ ជាអនុគមន៍៖

ក. គូ

ខ. សេស

គ. មិនគូមិនសេស

ឃ. ជាអនុគមន៍កើនជានិច្ច

# លំហាត់អនុវត្តន៍

១. គេឱ្យអនុគមន៍ $f$ កំណត់លើ $\mathbb{R}$ ដោយ $f(x) = e^x - x - 1$ និងមានក្រាប $C$ ។

ក. គណនា $\lim_{x\to+\infty} f(x)$ និង $\lim_{x\to-\infty} f(x)$

ខ. គណនា $f'(x)$ រួចសិក្សាសញ្ញារបស់វា ទាញថា $f$ មានអប្បបរមាធៀបមួយ រួចគណនាតម្លៃបរមាធៀបនោះ។ ចូរគូសតារាងអថេរភាពនៃ $f$ ។

គ. បង្ហាញថា បន្ទាត់ $d : y = -x - 1$ ជាអាស៊ីមតូតទ្រេតនៃខ្សែកោង $C$ កាលណា $x \to -\infty$

ឃ. កំណត់កូអរដោនេនៃចំណុច $P$ នៃ $C$ ដែលបន្ទាត់ប៉ះនឹង $C$ ត្រង់ចំណុចនេះស្របទៅនឹងបន្ទាត់ $y = x$ ។

ង. សង់ $C$ និងបន្ទាត់ $d$ និងបន្ទាត់ប៉ះត្រង់ $P$ ។ $(\ln 2 \approx 0.7)$

**ចម្លើយ:**

២. គេឱ្យអនុគមន៍ $f$ កំណត់លើ $\mathbb{R}$ ដោយ $f(x)=x-1+\frac{2}{e^x}$ និង មានក្រាប $C$។

ក. កំណត់លីមីតនៃ $f(x)$ កាលណា $x$ ខិតទៅ $+\infty$ ។ បង្ហាញថា បន្ទាត់ $d$ ដែលមានសមីការ $y=x-1$ ជាអាស៊ីមតូតទ្រេតនៃ $C$ ។

ខ. បង្ហាញថា $f(x)$ អាចសរសេរខាងក្រោមទម្រង់ $f(x)=\frac{xe^x-e^x+2}{e^x}$ ទាញរកលីមីតនៃ $f(x)$ កាលណា $x$ ខិតទៅ $-\infty$ ។

គ. គណនា $f'(x)$ រួចសិក្សាសញ្ញារបស់វា។ សង់តារាងអថេរភាពនៃ $f$ ។

ឃ. សរសេរសមីការបន្ទាត់ប៉ះ $T$ ទៅនឹង $C$ ត្រង់ចំណុចដែលមានអាប់ស៊ីស $0$។

ង. តាមក្រាភិច កំណត់ចំនួនឫសនៃសមីការ $f(x)=2$ រួចអមឫសទាំងនោះដោយចំនួនគត់ពីរតគ្នា។

**ចម្លើយ:**

៣. $f$ ជាអនុគមន៍កំណត់លើ $\mathbb{R}-\{0\}$ ដោយ $f(x)=\frac{e^x}{x}$ និងក្រាប $C$ ។

ក. គណនាលីមីត $\lim\limits_{x\to+\infty} f(x)$, $\lim\limits_{x\to-\infty} f(x)$ និង $\lim\limits_{x\to 0} f(x)$ ។ ទាញរកអាស៊ីមតូតនៃក្រាប $C$ ។

ខ. គណនា និងសិក្សាសញ្ញាដេរីវេ $f'(x)$ ។ បង្ហាញថាអនុគមន៍ $f$ មានអប្បបរមាមួយ។ គណនាតម្លៃអប្បបរមានេះ ហើយសង់តារាងអថេរភាពនៃ $f$ ។

គ. បង្ហាញថា បន្ទាត់ប៉ះនឹងក្រាប $C$ ត្រង់អាប់ស៊ីស $x_0=1$ ជាបន្ទាត់ស្របនឹងអ័ក្សអាប់ស៊ីស។

ឃ. សង់ក្រាប $C$ ។ប្រើក្រាប $C$ ចូរកំណត់តម្លៃ $m$ ដើម្បីឱ្យសមីការ $e^x-mx=0$ មានឫស។

**ចម្លើយ:**

មេរៀនទី ២ អនុគមន៍អិចស្ប៉ូណង់ស្យែល

៤. អនុគមន៍ $f$ កំណត់លើ $\mathbb{R}$ ដោយ $f(x)=(2x+1)e^{-2x}$ ហើយមានក្រាប $C$ តាងក្នុងតម្រុយ $(O,\vec{i},\vec{j})$ ។

ក. ចូរគណនាលីមីតកាលណា $x$ ខិតជិត $-\infty$ និង $+\infty$ រួចទាញសមីការអាស៊ីមតូតដេកនៃ $C$។

ខ. គណនាដេរីវេ $f'(x)$ និងសិក្សាសញ្ញា រួចគូសតារាងអថេរភាព។

គ. រកចំណុចប្រសព្វ $A$ រវាងក្រាប $C$ និងអ័ក្ស $x'ox$ ។ សិក្សាសញ្ញានៃ $f$ ។

ឃ. សរសេរសមីការបន្ទាត់ប៉ះ $T$ ទៅនឹងក្រាប $C$ ត្រង់ចំណុច $A$ ។ សង់ក្រាប $C$ បន្ទាត់អាស៊ីមតូត និងបន្ទាត់ប៉ះ $T$ ក្នុងតម្រុយតែមួយ។

ង. ដោយប្រើក្រាប $C$ ចូរកំណត់តម្លៃ $m$ ដើម្បីឱ្យសមីការ $(2x+1)e^{-2x}=m$ មានឫសពីរផ្សេងគ្នា។

**ចម្លើយ:**

៥. គេកំណត់អនុគមន៍ $f$ លើ $\mathbb{R}-\{0\}$ ដោយ $f(x)=\frac{e^x}{e^x-1}$ មានក្រាប $C$ ជាក្រាបតាង $f$ ក្នុងតម្រុយ $(O,\vec{i},\vec{j})$ ។

ក. កំណត់ ចំនួនពិត $a$ និង $b$ ដែលអនុគមន៍ $f$ អាចសរសេរ $f(x)=a+\frac{b}{e^x-1}$ ចំពោះគ្រប់ $x\in\mathbb{D}$ ។ ដោយប្រើទម្រង់នេះ ចូរគណនាលីមីត $\lim\limits_{x\to+\infty} f(x)$ រួចទាញរកសមីការអាស៊ីមតូតដេកនៃ $C$។

ខ. បង្ហាញថា $f$ មានដេរីវេចំពោះ គ្រប់ចំណុចនៃ $\mathbb{D}$ ហើយគណនាដេរីវេនៃ $f'$ នៃ $f$។ សិក្សាទិសដៅអថេរភាពនៃ $f$ រួចគូសតារាងអថេរភាព ហើយគណនាលីមីតត្រង់ចុងដែនកំណត់នៃ $\mathbb{D}$ ។

គ. រកអាស៊ីមតូតនៃក្រាប $C$ និងសមីការបន្ទាត់ $T$ ប៉ះទៅនឹងក្រាប $C$ ត្រង់ចំណុចអាប់ស៊ីស $1$ ។

ឃ. សង់ក្រាប $C$ បន្ទាត់ អាស៊ីមតូត និងបន្ទាត់ប៉ះ $T$ ក្នុងតម្រុយតែមួយ។

**ចម្លើយ:**

៦. ក. តាង $g(x)=(x-1)e^x+1$ ចំពោះ $x\in\mathbb{R}$ ។ គណនា $g'(x)$ ។ គូសតារាងអថេរភាពនៃ $g$ ដោយមិនចាំបាច់គណនាលីមីត រួចទាញរកសញ្ញានៃ $g(x)$ លើ $\mathbb{R}$

ខ. អនុគមន៍ $f$ កំណត់ដោយ $f(x)=(x-2)e^x+x$ កំណត់លើ $\mathbb{R}$ ហើយមានក្រាប $C$ តំណាងក្នុងតម្រុយអរតូណរមេ $(O,\vec{i},\vec{j})$ ។

ⓐ. គណនាលីមីត $\lim\limits_{x\to-\infty} f(x)$ និង $\lim\limits_{x\to+\infty} f(x)$ ។

ⓑ. រកអាស៊ីមតូតទ្រេតនៃក្រាប $C$ ។ សិក្សាទីតាំងធៀបនៃ $C$ធៀបនឹងអាស៊ីមតូតទ្រេតវា។

ⓒ. គណនា $f'(x)$ ។ ប្រើលទ្ធផលសំណួរ (ក) សិក្សាសញ្ញានៃ $f'(x)$ រួចគូសតារាងអថេរភាពនៃ $f$ ។

ⓓ. បង្ហាញថា ក្រាប $C$ តាងអនុគមន៍ $f$ មានចំណុចរបត់មួយដែលត្រូវគណនាកូអរដោនេ ហើយត្រង់ចំណុចរបត់នេះ ក្រាប $C$ មានបន្ទាត់ប៉ះស្របនឹងអ័ក្សអាប់ស៊ីស។

ⓔ. សង់ក្រាប $C$ អាស៊ីមតូតទ្រេត និងបន្ទាត់ប៉ះត្រង់ចំណុចរបត់នោះ ក្នុងតម្រុយតែមួយ។

**ចម្លើយ:**

៧. គេឲ្យ អនុគមន៍ $y=f(x)=\frac{e^x-1}{e^x+1}$ មានក្រាប $C$ ។

ក. គណនាលីមីតចុងដែនកំណត់ និង អាស៊ីមតូត។

ខ. រកដេរីវេ សិក្សាសញ្ញា $f'(x)$ និងបរមាធៀបនៃ $f$ ។

គ. បង្ហាញថា $f$ ជាអនុគមន៍ សេស និងបញ្ជាក់ផ្ចិតឆ្លុះ។

ឃ. គូសតារាងអថេរភាពនៃ $f$ រួចរកសមីការបន្ទាត់ប៉ះ $T$ ប៉ះក្រាប $C$ ត្រង់ផ្ចិតឆ្លុះនោះ។

ង. សង់ក្រាប $C$ គេឲ្យ $e=2.7$ និង $e^{-1}=0.36$ ។

**ចម្លើយ:**

៨. គេឲ្យ អនុគមន៍ $y = f(x) = \frac{e^x+1}{e^x-1}$ មានក្រាប $C$ ។

ក. រកដែនកំណត គណនាលីមីតចុងដែនកំណត់ និង អាស៊ីមតូត។

ខ. រកដេរីវេ សិក្សាសញ្ញា $f'(x)$ និងបរមាធៀបនៃ $f$ ។

គ. បង្ហាញថា $f$ ជាអនុគមន៍ សេស និងបញ្ជាក់ផ្ចិតឆ្លុះ។

ឃ. បន្ទាត់ $(T): y = 3$ កាត់ខ្សែកោង $C$ ត្រង់ $M$ ។ គណនាកូអរដោនេនៃ $M$ និងសមីការបន្ទាត់ប៉ះខ្សែកោង $C$ ត្រង់ចំណុច $M$ ។

ង. គូសតារាងអថេរភាពនៃ $f$ រួចរកសមីការបន្ទាត់ប៉ះ $T$ ប៉ះក្រាប $C$ ត្រង់ផ្ចិតឆ្លុះនោះ។

ច. សង់ក្រាប $C$ គេឲ្យ $e = 2.7$ និង $e^{-1} = 0.36$ ។

**ចម្លើយ:**

៩. គេឲ្យអនុគមន៍ $f$ ដែល $y = f(x) = x^2e^{-x}$ មានក្រាប $C$ ។

ក. រកដែនកំណត់នៃ $f$ ។

ខ. គណនាលីមីតចុងដែនកំណត់និងអាស៊ីមតូត ។

គ. បង្ហាញថាសមីការបន្ទាត់ $(L)$ ប៉ះខ្សែកោង $C$ ត្រង់អាប់ស៊ីស $x = 2$ ស្របនឹងអ័ក្សអាប់ស៊ីស។

ឃ. រកដេរីវេ សិក្សាសញ្ញា $f'(x)$ និង បរមាធៀបនៃ $f$ ។

ង. គូសតារាងអថេរភាព និងសង់ក្រាប។

**ចម្លើយ:**

១០. គេឲ្យអនុគមន៍ $f$ កំណត់ដោយ $y=f(x)=x-2+e^{1-x}$ តាងដោយក្រាប $C$ ។

ក. រកដែនកំណត់ $D_f$ និង គណនាលីមីតចុងដែនកំណត់ រួចបញ្ជាក់សមីការអាស៊ីមតូត។

ខ. រកដេរីវេ សិក្សាសញ្ញា $f'(x)$ និងបរមាធៀប នៃ $f$ ។

គ. សិក្សាទីតាំងធៀបរវាងខ្សែកោង $C$ ជាមួយបន្ទាត់ $L$ កាត់តាមគល់តម្រុយ ហើយស្របនឹងអាស៊ីមតូតទ្រេត។

ឃ. គូសតារាងអថេរភាពនិងសង់ក្រាប។

**ចម្លើយ:**

មេរៀនទី ២ អនុគមន៍អិចស្ប៉ូណង់ស្យែល

១១. គេអោយអនុគមន៍ $f$ កំណត់លើ $\mathbb{R}$ ដែល $f(x)=x+2-\frac{4e^x}{1+e^x}$ មានក្រាប $C$ ក្នុងតម្រុយ $(o,\vec{i},\vec{j})$ ។

ក. គណនាលីមីត $f$ កាលណា $x\to-\infty$ និង $x\to+\infty$ ។

ខ. បង្ហាញថាបន្ទាត់ $(d_1): y=x+2$ ជាអាស៊ីមតូតទ្រេតនៃក្រាប $C$ កាលណា $x\to-\infty$ ។ រួចសិក្សាទីតាំងក្រាប $C$ ធៀបនឹងបន្ទាត់ $(d_1)$។

គ. ផ្ទៀងផ្ទាត់ថាចំពោះគ្រប់ចំនួនពិត $x$ គេបាន $f(x)=x-1+\frac{4}{1+e^x}$ ។

ឃ. បង្ហាញថាបន្ទាត់ $(d_2): y=x-2$ ជាអាស៊ីមតូតទ្រេតនៃ $C$ កាលណា $x\to+\infty$ ។ រួចសិក្សាទីតាំងក្រាប $C$ ធៀបនឹងបន្ទាត់ $(d_2)$ ។

ង. សិក្សាអថេរភាពនៃ $f$ លើ $\mathbb{R}$ ។ សរសេរសមីការបន្ទាត់ $(L)$ ប៉ះក្រាបត្រង់ចំណុចមានអាប់ស៊ីស $x=0$ ។

ច. សង់ក្រាប $C$ បន្ទាត់ $(d_1),(d_2)$ និង $(L)$ ។

**ចម្លើយ:**

១២. គេឲ្យអនុគមន៍ $f$ កំណត់ចំពោះគ្រប់ចំនួនពិត $x$ ដែល $f(x)=x-\frac{e^x-1}{e^x+1}$ មានក្រាបក្នុងតម្រុយ $(O,\vec{i},\vec{j})$ ឯកតាលើអ័ក្សយក $2cm$ ។

ក. ⓐ. ផ្ទៀងផ្ទាត់ថាចំពោះគ្រប់ចំនួនពិត $x; f(x)=x-1+\frac{2}{1+e^x}=x+1-\frac{2e^x}{1+e^x}$ ។

ⓑ. គណនាលីមីត $\lim\limits_{x\to-\infty} f(x)$ និង $\lim\limits_{x\to+\infty} f(x)$ ។

ⓒ. បង្ហាញថាបន្ទាត់ $(d_1): y=x+1$ និង $(d_2): y=x-1$ ជាអាស៊ីមតូតទ្រេតនៃ $(C)$ ។

ⓓ. សិក្សាទីតាំងធៀបរវាងក្រាប $(C)$ និង បន្ទាត់ $(d_1),(d_2)$ ។

ខ. បង្ហាញថាអនុគមន៍ $f$ ជាអនុគមន៍សេស ។ សិក្សាអថេរភាពនៃ $f$ ។

គ. សរសេរសមីការបន្ទាត់ $(L)$ ប៉ះក្រាបត្រង់ចំណុច មានអាប់ស៊ីសស្មើសូន្យ។ សង់ក្រាប $(C),(d_1),(d_2),(L)$ ក្នុងតម្រុយតែមួយ។

**ចម្លើយ:**

១៣. គេឲ្យអនុគមន៍ $f$ កំណត់លើ $\mathbb{R}$ ដែល $f(x)=x+2-\frac{4e^x}{e^x+2}$ មានក្រាប $C$ ។

ក. គណនាលីមីត $\lim\limits_{x\to-\infty} f(x)$ និង $\lim\limits_{x\to+\infty} f(x)$ ។

ខ. បង្ហាញថាបន្ទាត់ $(d_1): y=x+2$ និង $(d_2): y=x-2$ ជាអាសុីមតូតទ្រេតនៃក្រាប $C$។សិក្សាទីតាំងក្រាប $C$ ធៀបនឹងបន្ទាត់ $(d_1),(d_2)$ ។

គ. សិក្សាអថេរភាពនៃ $f$ ។ គូសតារាងអថេរភាពនៃ $f$ ។ សរសេរសមីការបន្ទាត់ $L$ ប៉ះក្រាប $C$ ត្រង់ចំណុច $A(\ln 2,\ln 2)$ ។

ឃ. សង់ក្រាប $C,(d_1),(d_2)$ និង $L$ ។

**ចម្លើយ:**

១៤. **A**. អនុគមន៍ $h(x)=1+e^{x}(1-x)$ កំណត់ $\forall x\in\mathbb{R}$ ។ ដោយពុំបាច់គណនាលីមីតចុងដែនកំណត់ចូរសិក្សាសញ្ញា នៃ $h(x)$ លើ $\mathbb{R}$ ។

**B**. អនុគមន៍ $y=f(x)=2+x(1+e^{x})$ មានក្រាប $C$ ។

ក. គណនាលីមីតចុងដែនកំណត់។

ខ. បំភ្លឺថា $y=x+2$ ជាអាស៊ីមតូតទ្រេតខាង $+\infty$។

គ. សិក្សាអថេរភាពនៃ $f$ ោដយប្រើលទ្ធផល $A$ ។

ឃ. សិក្សាទីតាំងធៀបនៃ ខ្សែកោង $C$ ជាមួយអាស៊ីមតូតទ្រេត $y=x+2$ ។

ង. សង់ក្រាប $C$ លើតម្រុយអរតូណរមេ។

**ចម្លើយ:**

១៥. ក. អនុគមន៍ $h$ កំណត់ចំពោះគ្រប់ចំនួនពិត $x$ ដោយ $h(x) = e^{2x} - 2x - 1$ ហើយមានតារាងអថេរភាពដូចខាងក្រោម៖

| $x$ | $-\infty$ | | $0$ | | $+\infty$ |
|---|---|---|---|---|---|
| $h'(x)$ | | $-$ | $0$ | $+$ | |
| $h(x)$ | $+\infty$ | $\searrow$ | $0$ | $\nearrow$ | $+\infty$ |

ដោយប្រើតារាងអថេរភាពនៃអនុគមន៍ $h$ ចូរបញ្ជាក់ថា $e^{2x} \geq 2x + 1$ ចំពោះគ្រប់ចំនួនពិត $x$ ។

ខ. $f$ ជាអនុគមន៍កំណត់ដោយ $f(x) = (x+1)(e^{-2x} + 1)$ ចំពោះគ្រប់ចំនួនពិត $x$ និង មានក្រាប $(C)$។

a. គណនា $f'(x)$ និង $f'(0)$ ។ បញ្ជាក់ថាដេរីវេ $f'(x)$ និងអនុគមន៍ $h(x)$ មាន សញ្ញាដូចគ្នាចំពោះគ្រប់ $x \neq 0$ ។

b. គណនា $f(0)$, $\lim\limits_{x \to -\infty} f(x)$ និង $\lim\limits_{x \to +\infty} f(x)$ ។ សង់តារាងអថេរភាពរបស់អនុគមន៍ $f$ ។

c. បង្ហាញថា $f(x) = x + 1 + \left(\frac{x}{e^x}\right)\left(\frac{1}{e^x}\right) + \left(\frac{1}{e^x}\right)^2$ ។ បង្ហាញថាបន្ទាត់ $(D)$ មានសមីការ $y = x + 1$ ជាអាស៊ីមតូតទ្រេតនៃ $(C)$ នៅខាង $+\infty$ ។

d. សិក្សាទីតាំងរវាងក្រាប $(C)$ និងបន្ទាត់ $(D)$ ។

e. បន្ទាត់ $(\Delta)$ មួយស្របនឹងបន្ទាត់ $(D)$ ហើយប៉ះក្រាប $(C)$ ត្រង់ $M$ ។ កំណត់កូអរដោនេនៃចំណុច $M$ និង សរសេរសមីការនៃបន្ទាត់ $(\Delta)$ ។

f. សង់បន្ទាត់ $(D),(\Delta)$ និងក្រាប $(C)$ នៅក្នុងតម្រុយអរតូណរម៉ាល់ $(o,\vec{i}.\vec{j})$ តែមួយ។ (គេឲ្យ $e = 2.7$)

**ចម្លើយ:**

មេរៀនទី ២ អនុគមន៍អិចស្ប៉ូណង់ស្យែល

១៦. **A**. $f$ ជាអនុគមន៍កំណត់លើ $\mathbb{R}$ ដោយ $f(x)=(1-x)e^x-1$ ។ គណនា $f'(x)$ ។ សង់តារាងអថេរភាពនៃអនុគមន៍ $f$ (ដោយមិនចាំបាច់គណនាលីមីតត្រង់ $-\infty$ និង $+\infty$ ) ។ទាញរកសញ្ញានៃ $f(x)$ ។

**B**. $g$ ជាអនុគមន៍កំណត់លើ $\mathbb{R}$ ដោយ $g(x)=(2-x)e^x+2-x$ ។

ក. គណនា $\lim_{x\to-\infty} g(x)$ និង $\lim_{x\to+\infty} g(x)$ ។ គណនា $g'(x)$ ។ ដោយប្រើលទ្ធផលដែលបាននៅសំណួរទី (១) ចូរសិក្សាសញ្ញានៃ $g'(x)$ រួចសង់តារាងអថេរភាពនៃ $g$ ។

ខ. បង្ហាញថាខ្សែកោង $(C)$ តាងអនុគមន៍ $g$ មានបន្ទាត់ $(D): y=2-x$ ជាអាស៊ីមតូតទ្រេតកាលណា $x$ ខិតទៅ $-\infty$ ។ បញ្ជាក់ទីតាំងនៃខ្សែកោង $(C)$ ធៀបនឹង $(D)$ ។

គ. កំណត់សមីការបន្ទាត់ប៉ះនឹងខ្សែកោង $(C)$ ដែលស្របនឹង $(D)$ ។

ឃ. រកកូអរដោនេនៃចំណុចរបត់របស់ខ្សែកោង $(C)$ ។

ង. សង់ខ្សែកោង $(C)$ ក្នុងតម្រុយអរតូណរម៉ាល់ $(o,\vec{i},\vec{j})$ ។ (ឯកតាលើអ័ក្សស្មើ $1cm$ ) ។

**ចម្លើយ:**

១៧. អនុគមន៍ $f$ កំណត់ដោយ $y=f(x)=x-1+2e^{-x}$ ហើយមានក្រាប $(C)$ ។

ក. រក $\lim_{x\to\pm\infty} f(x)$ ។ រកសមីការអាស៊ីមតូតទ្រេត $L_1$ នៃក្រាប $C$ ។ បង្ហាញថា $f$ មានអប្បបរមាត្រង់ $x=\ln 2$ ។

ខ. សង់តារាងអថេរភាពនៃ $f$ ។ រកសមីការបន្ទាត់ $L_2$ ដែលប៉ះក្រាប $C$ ត្រង់ចំណុច $A(0,1)$ ។

គ. សង់បន្ទាត់ $L_1, L_2$ នៅក្នុងតម្រុយអរតូណរម៉ាល់តែមួយ។ គេឲ្យ $\ln 2=0.7$ ។

ឃ. គណនាក្រលាផ្ទៃផ្នែកប្លង់កំណត់ដោយអាស៊ីមតូតទ្រេត $L_1$ ក្រាប $C$ បន្ទាត់ $x=0$ និង $x=1$ ។

**ចម្លើយ:**

មេរៀនទី ២ អនុគមន៍អិចស្ប៉ូណង់ស្យែល

១៨. គេឲ្យ $f(x)=e^x$ និង $g(x)=\ln(x+1)+1$ ។

ក. ផ្ទៀងផ្ទាត់ថាខ្សែកោង $(C_1): y=f(x)$ និង $(C_2): y=g(x)$ មានចំណុចរួម $A(0,1)$ ។

ខ. គណនា $f'(0)$ និង $g'(0)$ រួចទាញថា $(C_1)$ និង $(C_2)$ ប៉ះគ្នាត្រង់ $A$ ។

គ. សរសេរសមីការបន្ទាត់រួមរវាង $(C_1)$ និង $(C_2)$ ។

**ចម្លើយ:**

១៩. $f$ ជាអនុគមន៍ កំណត់លើ $\mathbb{R}$ ដោយ $f(x)=4-x-e^{-x}$ ។ គេតាងដោយ $C$ ជាក្រាបរបស់វា។

**A**. ក. រក $\lim\limits_{x\to+\infty} f(x)$

ខ. បង្ហាញថាបន្ទាត់ $D$ មានសមីការ $y=-x+4$ ជាអាស៊ីមតូតនៃខ្សែកោង $C$ ។

គ. តើខ្សែកោង $C$ នៅលើ ឬក្រោមបន្ទាត់ $D$ ។ ចូរបញ្ជាក់។

ឃ. ផ្ទៀងផ្ទាត់ថាគ្រប់ចំនួនពិត $x, f(x)=\frac{4e^x-xe^x-2}{e^x}$

ង. រក $\lim\limits_{x\to-\infty} f(x)$ (ប្រើលទ្ធផល $\lim\limits_{x\to-\infty} xe^x=0$ )

**B**. ក. គណនា $f'(x)$ ។ សិក្សាអថេរភាពនៃ $f$ ។ កំណត់តម្លៃពិតនៃអតិបរមារបស់ $f$ ។

ខ. $A$ ជាចំណុចនៅលើខ្សែកោង $C$ ដែលមានអាប់ស៊ីស $0$ ។ កំណត់សមីការបន្ទាត់ប៉ះខ្សែកោង $C$ ត្រង់ $A$ ។

គ. បង្ហាញថាសមីការ $f(x)=0$ មានចម្លើយតែមួយគត់ដែលគេតាងដោយ $\beta$ នៅក្នុងចន្លោះ $[-1,0]$ ។

**ចម្លើយ:**

២០. គេមានអនុគមន៍ $f$ កំណត់លើ $\mathbb{R}$ ដោយ $f(x)=x+2-\frac{4e^x}{e^x+3}$ ។ គេតាងដោយក្រាបរបស់វានៅក្នុងប្លង់ប្រដាប់ដោយតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j})$ ។

ក. ⓐ. គណនាលីមីតនៃ $f$ ត្រង់ $-\infty$ និង $+\infty$ ។

ⓑ. សិក្សាទីតាំងធៀបនៃក្រាប $C$ ធៀបនឹងបន្ទាត់ $d_1$ ដែលមានសមីការ $y=x+2$ ។

ខ. ⓐ. ស្រាយបំភ្លឺថាចំពោះគ្រប់ចំនួនពិត $x$ , $f'(x)=\left(\frac{e^x-3}{e^x+3}\right)^2$ ។

ⓑ. សិក្សាអថេរភាពនៃ $f$ លើ $\mathbb{R}$ និង សង់តារាងអថេរភាពនៃ $f$ ។

គ. ⓐ. តើគេអាចថាយ៉ាងណាចំពោះបន្ទាត់ប៉ះ $d_2$ នឹងក្រាប $C$ ត្រង់ចំណុច $I$ ដែលមានអាប់ស៊ីស $ln(3)$ ។

ⓑ. សិក្សាទីតាំងនៃក្រាប $C$ ធៀបនឹងបន្ទាត់ប៉ះ $d_2$ ។

ឃ. ⓐ. បង្ហាញថាបន្ទាត់ប៉ះ $d_3$ ទៅនឹងក្រាប $C$ ត្រង់ចំណុចមានអាប់ស៊ីសសូន្យមានសមីការ $y=\frac{1}{4}x+1$ ។

ⓑ. ដោយសន្មត់ថាចំណុច $I$ ជាផ្ចិតឆ្លុះនៃក្រាប $C$ និង ក្នុងតម្លៃប្រហែលនៃ $ln(3)$ ចូរសង់ក្រាប $C$ និងបន្ទាត់ប៉ះ $d_1,d_2,d_3$ ។ (នៅលើតម្រុយនេះមួយឯកតាស្មើ $2cm$) ។

**ចម្លើយ:**

២១. គេមានអនុគមន៍ $f$ កំណត់លើ $\mathbb{R}$ ដោយ $f(x) = x + \frac{1-3e^x}{1+e^x}$ ។ គេតាងដោយ $C$ ក្រាបរបស់វានៅក្នុងប្លង់ប្រដាប់ដោយតម្រុយអរតូណរម៉ាល់ $(O;\vec{i};\vec{j})$ ។

ក. បង្ហាញថា $f(x) = x + 1 - \frac{4e^x}{1+e^x}$ និង គណនាលីមីតនៃ $f$ ត្រង់ $-\infty$ ។ ស្រាយបំភ្លឺថាបន្ទាត់ $d_1$ ដែលមានសមីការ $y = x+1$ ជាអាស៊ីមតូតទៅនឹង $C$ ត្រង់ $-\infty$ ។ សិក្សាទីតាំងនៃ $C$ ធៀបនឹងបន្ទាត់ $d_1$ ។

ខ. គណនាលីមីត $f$ ត្រង់ $+\infty$ ។ ស្រាយបំភ្លឺថាបន្ទាត់ $d_2$ មានសមីការ $y = x-3$ ជាអាស៊ីមតូតទៅនឹងក្រាប $C$ ត្រង់ $+\infty$ ។សិក្សាទីតាំងនៃក្រាប $C$ ធៀបនឹងបន្ទាត់ $d_2$ ។

គ. ⓐ. គណនាដេរីវេ $f'(x)$ និង បង្ហាញថាគ្រប់ចំនួនពិត$x$, $f(x) = \left(\frac{e^x-1}{e^x+1}\right)^2$ ។

ⓑ. សិក្សាអថេរភាពនៃ $f$ រួចសង់តារាងអថេរភាពនៃ $f$ ។ សង់ក្រាប $C$ និង អាស៊ីតតូត $d_1$ និង $d_2$ របស់វា ។

**ចម្លើយ:**



# មេរៀនទី ៣
# អនុគមន៍លោការីត

## ១ និយមន័យ

**និយមន័យ ១**

អនុគមន៍លោការីតនេពែ កំណត់ដោយ $y = \ln x$ មានន័យចំពោះ $x > 0$

## ២ លក្ខណៈ

**ជាទូទៅ ១**

ចំពោះ $k > 0, a > 0, b > 0$

- $e^x = k \Rightarrow x = \ln k$
- $\ln(ab) = \ln a + \ln b$
- $e^{\ln k} = k$
- $\ln \frac{a}{b} = \ln a - \ln b$
- $\ln e^k = k$

**លំហាត់គំរូ ១**

គណនាតម្លៃនៃកន្សោមខាងក្រោម៖

ក. $e^{\ln 5}$ គ. $e^{\ln 0.2}$ ង. $e^{\ln 7}$

ខ. $\ln e^{3x+4}$ ឃ. $\ln e^{-4x}$ ច. $\ln e^{x-2}$

**ចម្លើយ:**

## ៣ ដេរីវេនៃអនុគមន៍

**ជាទូទៅ ២**

- $y = \ln x$ នោះ $y' = \frac{1}{x}$
- $y = \ln u$ នោះ $y' = \frac{u'}{u}$

**លំហាត់គំរូ ២**

គណនាដេរីវេនៃអនុគមន៍ខាងក្រោម៖

ក. $y = x^3 + \ln x$ ខ. $y = x^2 \ln x$ គ. $y = x + 2\ln x$ ឃ. $y = x^4 \ln x$

**ចម្លើយ:**

មេរៀនទី ៣ អនុគមន៍លោការីត

## លំហាត់គំរូ ៣

គណនាដេរីវេនៃអនុគមន៍ខាងក្រោម៖

ក. $f(x)=\ln(x^2+3x)$

ខ. $f(x)=\ln(\cos x)$

គ. $f(x)=\ln(x^2-4)^3$

ឃ. $y=\sqrt{x}\cdot\ln x$

ង. $y=\sqrt[3]{\ln x}$

ច. $y=\ln(x+\sqrt{1+x^2})$

ឆ. $y=\ln\frac{e^x}{e^x+1}$

ជ. $y=x\ln x-x$

ឈ. $y=x^2\ln\frac{1}{x^2}$

**ចម្លើយ:**

**ប្រតិបត្តិ ១**

គណនាដេរីវេនៃអនុគមន៍ $f(x)=\frac{x^2\sqrt{5x+1}}{(3x-2)^3}$

**ចម្លើយ:**

## ប្រតិបត្តិ ២

គណនាដេរីវេនៃអនុគមន៍ខាងក្រោម៖

ក. $f(x)=\sqrt{x}\cdot\ln x$

ខ. $f(x)=x\sqrt[3]{\ln x}$

គ. $f(x)=\ln(x+\sqrt{1+x^2})$

ឃ. $y=\ln\frac{e^x}{e^x+1}$

ង. $f(x)=\ln x+e^x$

ច. $y=\ln^2 x+\frac{1}{\ln^2 x+2}$

ឆ. $y=x-1-\ln x$

ជ. $y=\ln\left(\frac{x-3}{x+2}\right)$

ឈ. $y=x^2\ln x-\frac{x^2}{2}$

**ចម្លើយ:**

# ៤ លីមីតនៃអនុគមន៍

**ប្រតិបត្តិ ៣**

ក. $\lim_{x\to+\infty} x^{-5}\ln x$ ខ. $\lim_{x\to+\infty} \frac{(1+\ln x)}{x^2}$ គ. $\lim_{x\to 0}(x\ln x)$

**ចម្លើយ:**

# ៥ សមីការ និងវិសមីការ

## ៥.១ សមីការ

**ជាទូទៅ ៣**

បើ $\ln a = \ln b$ នោះ $a = b$

មេរៀនទី ៣ អនុគមន៍លោការីត

## លំហាត់គំរូ ៤

ដោះស្រាយសមីការក្នុង $\mathbb{R}$

ក. $\ln(x-2)+\ln(x+2)=\ln 45$

ខ. $3e^{2x}+e^{x}-10=0$

គ. $\ln(1-x)+\ln(2x+3)-\ln(x+1)=\ln 3$

ឃ. $\frac{e^{x}-2}{e^{x}-3}=4$

**ចម្លើយ:**

# ៥.២ វិសមីការ

**ជាទូទៅ ៤**

- $\ln a \leq \ln b$ នោះ $a \leq b$
- $\ln a \geq \ln b$ នោះ $a \geq b$

**លំហាត់គំរូ ៥**

ដោះស្រាយវិសមីការក្នុង $\mathbb{R}$

ក. $\ln(x+3)+\ln(x+5) \leq \ln 15$

ខ. $\ln(x^2-4e^2) < 1+\ln 3x$

គ. $3e^x - 10e^{-x} + 1 \geq 0$

**ចម្លើយ:**

# ៥.៣ ប្រព័ន្ធសមីការ

## លំហាត់គំរូ ៦

ដោះស្រាយប្រព័ន្ធសមីការក្នុង $\mathbb{R}$

ក. $\begin{cases} \ln y = \ln x + 2 \\ xy = 9e^2 \end{cases}$

ខ. $\begin{cases} e^x + 2e^y = 1 \\ -3e^x + e^y = 4 \end{cases}$

គ. $\begin{cases} x + y = 65 \\ \ln x + \ln y = \ln 1000 \end{cases}$

**ចម្លើយ:**

# ៦ សិក្សាអនុគមន៍

**លំហាត់គំរូ ៧**

សិក្សាអថេរភាព និងសង់ក្រាបនៃអនុគមន៍ $f(x)=x-\ln x$

**ចម្លើយ:**

## លំហាត់គំរូ ៨

សិក្សាអថេរភាព និងសង់ក្រាបនៃអនុគមន៍ $f(x)=\frac{lnx}{x}$

**ចម្លើយ:**

## លំហាត់គំរូ ៩

សិក្សាអថេរភាព និងសង់ក្រាបនៃអនុគមន៍ $f(x)=e^x\ln x$

**ចម្លើយ:**

**ប្រតិបត្តិ ៤**

គេឱ្យ $f$ ជាអនុគមន៍កំណត់លើ $(0,+\infty)$ ដោយ $f(x)=ax+b+\frac{\ln x}{x}$ ។ កំណត់ $a$ និង $b$ ដើម្បីឱ្យខ្សែកោង $C$ តាង $f$ កាត់តាមចំណុច $A(1,0)$ ហើយបន្ទាត់ប៉ះនឹង $C$ ត្រង់ $A$ ស្របនឹងបន្ទាត់ $y=2x$ ។

**ចម្លើយ:**

## ប្រតិបត្តិ ៥

អនុគមន៍ $f$ កំណត់លើ $(0,+\infty)$ ដោយ $f(x)=x+1+\frac{-1+\ln x}{x}$ ហើយ $C$ ជាក្រាបរបស់វា។

ក. អនុគមន៍ $g$ កំណត់ដោយ $g(x)=1+x^2-\ln x$ ។ សង់តារាងអថេរភាពនៃ $g$ (មិនបាច់គណនាលីមីតទេ) រួចទាញរកសញ្ញានៃ $g(x)$ លើ $(0,+\infty)$ ។

ខ. គណនា $\lim\limits_{x\to 0^+} f(x), \lim\limits_{x\to+\infty}$ ទាញឱ្យបានថា $C$ មានអាស៊ីមតូតឈរមួយដែលគេនឹងកំណត់សមីការ។

គ. សិក្សាទំនាក់ទំនង $f'(x)=\frac{g(x)}{x^2}$ ។ សង់តារាងអថេរភាពនៃ $f$ ។

ឃ. បង្ហាញថាបន្ទាត់ $\Delta: y=x+1$ ជាអាស៊ីមតូតទ្រេតនៃ $C$ ។

ង. រកកូអរដោនេនៃចំណុចប្រសព្វនស $C$ ជាមួយ $\Delta$ រួចបញ្ជាក់ឱ្យបានច្បាស់ទីតាំងនៃ $C$ ធៀបទៅនឹង $\Delta$ ។

ច. សង់ខ្សែកោង $C$ និងអាស៊ីមតូតរបស់វាក្នុងតម្រុយកូអរដោនេតែមួយ។

**ចម្លើយ:**

# វិញ្ញាសាពហុជ្រើសរើស៖ អនុគមន៍លោការីត (១០០ លំហាត់)

## សម្រាប់ត្រៀមប្រឡងបាក់ឌុប និងពង្រឹងសមត្ថភាព

១. ដែនកំណត់នៃអនុគមន៍ $f(x)=\ln x$ គឺ៖

ក. $(0,+\infty)$ ខ. $[0,+\infty)$ គ. $\mathbb{R}$ ឃ. $\mathbb{R}^*$

២. ដែនកំណត់នៃអនុគមន៍ $f(x)=\ln(x-3)$ គឺ៖

ក. $(3,+\infty)$ ខ. $[3,+\infty)$ គ. $(-\infty,3)$ ឃ. $x\neq 3$

៣. ដែនកំណត់នៃអនុគមន៍ $f(x)=\ln(2-x)$ គឺ៖

ក. $(-\infty,2)$ ខ. $(2,+\infty)$ គ. $(-\infty,2]$ ឃ. $x\neq 2$

៤. ដែនកំណត់នៃអនុគមន៍ $f(x)=\ln(x^2-1)$ គឺ៖

ក. $(-\infty,-1)\cup(1,+\infty)$ គ. $[-1,1]$

ខ. $(-1,1)$ ឃ. $\mathbb{R}\setminus\{-1,1\}$

៥. ដែនកំណត់នៃអនុគមន៍ $f(x)=\ln(x^2+1)$ គឺ៖

ក. $\mathbb{R}$ ខ. $(0,+\infty)$ គ. $[-1,1]$ ឃ. $\mathbb{R}^*$

៦. ដែនកំណត់នៃអនុគមន៍ $f(x)=\ln|x|$ គឺ៖

ក. $\mathbb{R}^*$ ខ. $\mathbb{R}$ គ. $(0,+\infty)$ ឃ. $x>1$

៧. ដែនកំណត់នៃអនុគមន៍ $f(x)=\sqrt{\ln x}$ គឺ៖

ក. $[1,+\infty)$ ខ. $(0,+\infty)$ គ. $(1,+\infty)$ ឃ. $[0,+\infty)$

៨. អនុគមន៍ $f(x)=\frac{1}{\ln x}$ មានន័យកាលណា៖

ក. $x>0$ និង $x\neq 1$ គ. $x\neq 1$

ខ. $x>0$ ឃ. $x>1$

៩. ដែនកំណត់នៃអនុគមន៍ $f(x)=\ln\left(\frac{x+1}{x-1}\right)$ គឺ៖

ក. $(-\infty,-1)\cup(1,+\infty)$ គ. $\mathbb{R}\setminus\{1\}$

ខ. $(-1,1)$ ឃ. $x>1$

១០. តម្លៃនៃ $\ln 1$ ស្មើនឹង៖

ក. $0$ ខ. $1$ គ. $e$ ឃ. មិនកំណត់

១១. តម្លៃនៃ $\ln e$ ស្មើនឹង៖

ក. 1 ខ. 0 គ. $e$ ឃ. 10

១២. តម្លៃនៃ $\ln(e^2)$ ស្មើនឹង៖

ក. 2 ខ. $e^2$ គ. $2e$ ឃ. 1

១៣. តម្លៃនៃ $e^{\ln 5}$ ស្មើនឹង៖

ក. 5 ខ. $\ln 5$ គ. $e^5$ ឃ. 1

១៤. បើ $a>0, b>0$ នោះរូបមន្ត $\ln(ab)$ ស្មើនឹង៖

ក. $\ln a+\ln b$ ខ. $\ln a\cdot\ln b$ គ. $\ln a-\ln b$ ឃ. $a\ln b$

១៥. បើ $a>0, b>0$ នោះរូបមន្ត $\ln\left(\frac{a}{b}\right)$ ស្មើនឹង៖

ក. $\ln a-\ln b$ ខ. $\frac{\ln a}{\ln b}$ គ. $\ln b-\ln a$ ឃ. $\ln(a-b)$

១៦. បើ $a>0$ និង $n\in\mathbb{R}$ នោះរូបមន្ត $\ln(a^n)$ ស្មើនឹង៖

ក. $n\ln a$ ខ. $\ln(na)$ គ. $(\ln a)^n$ ឃ. $\frac{\ln a}{n}$

១៧. បើ $a>0$ នោះរូបមន្ត $\ln\sqrt{a}$ ស្មើនឹង៖

ក. $\frac{1}{2}\ln a$ ខ. $2\ln a$ គ. $\sqrt{\ln a}$ ឃ. $\ln\left(\frac{a}{2}\right)$

១៨. តម្លៃនៃ $\ln 6-\ln 2$ ស្មើនឹង៖

ក. $\ln 3$ ខ. $\ln 4$ គ. $\frac{\ln 6}{\ln 2}$ ឃ. 3

១៩. តម្លៃនៃ $\ln 2+\ln 5$ ស្មើនឹង៖

ក. $\ln 10$ ខ. $\ln 7$ គ. 10 ឃ. $\ln 2.5$

២០. ដែនកំណត់នៃអនុគមន៍ $f(x)=\ln(4-x^2)$ គឺ៖

ក. $(-2,2)$ គ. $(-\infty,-2)\cup(2,+\infty)$

ខ. $[-2,2]$ ឃ. $x<2$

២១. ដេរីវេនៃ $f(x)=\ln x$ ចំពោះ $x>0$ គឺ៖

ក. $f'(x)=\frac{1}{x}$ ខ. $f'(x)=-\frac{1}{x}$ គ. $f'(x)=\frac{1}{x^2}$ ឃ. $f'(x)=1$

២២. ដេរីវេនៃ $f(x)=\ln(2x)$ ចំពោះ $x>0$ គឺ៖

ក. $\frac{1}{x}$ ខ. $\frac{2}{x}$ គ. $\frac{1}{2x}$ ឃ. $2\ln x$

២៣. ដេរីវេនៃ $f(x)=\ln(x+3)$ ចំពោះ $x>-3$ គឺ៖

ក. $\frac{1}{x+3}$ ខ. $\frac{3}{x+3}$ គ. $-\frac{1}{x+3}$ ឃ. $\frac{1}{x}$

២៤. ដេរីវេនៃ $f(x)=\ln(3-2x)$ ចំពោះ $x<\frac{3}{2}$ គឺ៖

ក. $\frac{-2}{3-2x}$ ខ. $\frac{2}{3-2x}$ គ. $\frac{1}{3-2x}$ ឃ. $-2\ln(3-2x)$

២៥. ដេរីវេនៃ $f(x)=\ln(x^2+1)$ គឺ៖

ក. $\frac{2x}{x^2+1}$ ខ. $\frac{1}{x^2+1}$ គ. $\frac{x}{x^2+1}$ ឃ. $\frac{2}{x}$

២៦. ដេរីវេនៃ $f(x)=\ln(x^2-4)$ ចំពោះ $|x|>2$ គឺ៖

ក. $\frac{2x}{x^2-4}$ ខ. $\frac{1}{x^2-4}$ គ. $\frac{x}{x^2-4}$ ឃ. $\frac{2}{x-2}$

២៧. ដេរីវេនៃ $f(x)=x\ln x$ ចំពោះ $x>0$ គឺ៖

ក. $\ln x+1$ ខ. $\ln x$ គ. $1$ ឃ. $\frac{1}{x}+1$

២៨. ដេរីវេនៃ $f(x)=x^2\ln x$ ចំពោះ $x>0$ គឺ៖

ក. $2x\ln x+x$ ខ. $2x\ln x$ គ. $x^2+2x$ ឃ. $x\ln x+x$

២៩. ដេរីវេនៃ $f(x)=\frac{\ln x}{x}$ ចំពោះ $x>0$ គឺ៖

ក. $\frac{1-\ln x}{x^2}$ ខ. $\frac{1+\ln x}{x^2}$ គ. $\frac{\ln x-1}{x^2}$ ឃ. $\frac{1}{x^2}$

៣០. ដេរីវេនៃ $f(x)=\ln^2 x$ ចំពោះ $x>0$ គឺ៖

ក. $\frac{2\ln x}{x}$ ខ. $\frac{\ln x}{x}$ គ. $2\ln x$ ឃ. $\frac{2}{x}$

៣១. ដេរីវេនៃ $f(x)=\ln^3 x$ ចំពោះ $x>0$ គឺ៖

ក. $\frac{3\ln^2 x}{x}$ ខ. $3\ln^2 x$ គ. $\frac{\ln^2 x}{x}$ ឃ. $\frac{3}{x}$

៣២. ដេរីវេនៃ $f(x)=\ln|x|$ ចំពោះ $x\neq 0$ គឺ៖

ក. $\frac{1}{x}$ ខ. $\frac{1}{|x|}$ គ. $-\frac{1}{x}$ ឃ. $\frac{x}{|x|}$

៣៣. ដេរីវេនៃ $f(x)=x-x\ln x$ គឺ៖

ក. $-\ln x$ ខ. $\ln x$ គ. $1-\ln x$ ឃ. $-x\ln x$

៣៤. ដេរីវេនៃ $f(x)=\ln\sqrt{x}$ ចំពោះ $x>0$ គឺ៖

ក. $\frac{1}{2x}$ ខ. $\frac{1}{x}$ គ. $\frac{1}{\sqrt{x}}$ ឃ. $\frac{1}{2\sqrt{x}}$

៣៥. ដេរីវេនៃ $f(x)=\ln(\ln x)$ ចំពោះ $x>1$ គឺ៖

ក. $\frac{1}{x\ln x}$ ខ. $\frac{1}{\ln x}$ គ. $\frac{1}{x}$ ឃ. $\frac{\ln x}{x}$

៣៦. ដេរីវេទី ២ នៃ $f(x)=\ln x$ គឺ៖

ក. $-\frac{1}{x^2}$ ខ. $\frac{1}{x^2}$ គ. $-\frac{1}{x}$ ឃ. $\frac{2}{x^2}$

៣៧. ដេរីវេទី ២ នៃ $f(x)=x\ln x$ គឺ៖

ក. $\frac{1}{x}$ ខ. $-\frac{1}{x^2}$ គ. $\ln x$ ឃ. $1$

៣៨. ដេរីវេទី ៣ នៃ $f(x)=\ln x$ គឺ៖

ក. $\frac{2}{x^3}$ ខ. $-\frac{2}{x^3}$ គ. $\frac{6}{x^4}$ ឃ. $-\frac{1}{x^3}$

៣៩. ដេរីវេនៃ $f(x)=\ln(x+\sqrt{x^2+1})$ គឺ៖

ក. $\frac{1}{\sqrt{x^2+1}}$ ខ. $\frac{1}{x+\sqrt{x^2+1}}$ គ. $\frac{x}{\sqrt{x^2+1}}$ ឃ. $\sqrt{x^2+1}$

៤០. ចំណុចរបត់នៃក្រាបតាង $f(x)=x^2\ln x$ មានអាប់ស៊ីស $x$ ស្មើនឹង៖

ក. $e^{-3/2}$ ខ. $e^{-1/2}$ គ. $e^{-1}$ ឃ. $1$

៤១. តម្លៃនៃ $\lim\limits_{x\to+\infty}\ln x$ គឺ៖

ក. $+\infty$ ខ. $0$ គ. $-\infty$ ឃ. $1$

៤២. តម្លៃនៃ $\lim\limits_{x\to0^+}\ln x$ គឺ៖

ក. $-\infty$ ខ. $0$ គ. $+\infty$ ឃ. $-1$

៤៣. តម្លៃនៃ $\lim\limits_{x\to+\infty}\frac{\ln x}{x}$ គឺ៖

ក. $0$ ខ. $+\infty$ គ. $1$ ឃ. $e$

៤៤. តម្លៃនៃ $\lim\limits_{x\to+\infty}\frac{\ln x}{x^2}$ គឺ៖

ក. $0$ ខ. $+\infty$ គ. $1$ ឃ. $\frac{1}{2}$

៤៥. តម្លៃនៃ $\lim\limits_{x\to0^+}x\ln x$ គឺ៖

ក. $0$ ខ. $-\infty$ គ. $+\infty$ ឃ. $-1$

៤៦. តម្លៃនៃ $\lim\limits_{x\to0^+}x^2\ln x$ គឺ៖

ក. $0$ ខ. $-\infty$ គ. $1$ ឃ. $+\infty$

៤៧. តម្លៃនៃ $\lim\limits_{x\to0}\frac{\ln(1+x)}{x}$ គឺ៖

ក. $1$ ខ. $0$ គ. $e$ ឃ. $+\infty$

៤៨. តម្លៃនៃ $\lim\limits_{x\to1}\frac{\ln x}{x-1}$ គឺ៖

ក. 1 ខ. 0 គ. $e$ ឃ. $-1$

៤៩. តម្លៃនៃ $\lim_{x\to 0}\frac{\ln(1+2x)}{x}$ គឺ៖

ក. 2 ខ. 1 គ. 0 ឃ. $\frac{1}{2}$

៥០. តម្លៃនៃ $\lim_{x\to 0}\frac{\ln(1+kx)}{x}$ $(k\neq 0)$ គឺ៖

ក. $k$ ខ. 1 គ. 0 ឃ. $\frac{1}{k}$

៥១. តម្លៃនៃ $\lim_{x\to +\infty}\frac{\ln x}{\sqrt{x}}$ គឺ៖

ក. 0 ខ. $+\infty$ គ. 1 ឃ. 2

៥២. តម្លៃនៃ $\lim_{x\to 0^+}\sqrt{x}\ln x$ គឺ៖

ក. 0 ខ. $-\infty$ គ. $+\infty$ ឃ. $-1$

៥៣. តម្លៃនៃ $\lim_{x\to +\infty}(x-\ln x)$ គឺ៖

ក. $+\infty$ ខ. 0 គ. $-\infty$ ឃ. 1

៥៤. តម្លៃនៃ $\lim_{x\to +\infty}\frac{2\ln x+3}{\ln x-1}$ គឺ៖

ក. 2 ខ. $-3$ គ. 1 ឃ. $+\infty$

៥៥. តម្លៃនៃ $\lim_{x\to 1}\frac{\ln x}{x^2-1}$ គឺ៖

ក. $\frac{1}{2}$ ខ. 1 គ. 0 ឃ. 2

៥៦. តម្លៃនៃ $\lim_{x\to 0^+}x^3\ln x$ គឺ៖

ក. 0 ខ. $-\infty$ គ. $+\infty$ ឃ. 1

៥៧. តម្លៃនៃ $\lim_{x\to +\infty}\frac{\ln(x+1)}{x}$ គឺ៖

ក. 0 ខ. 1 គ. $+\infty$ ឃ. $e$

៥៨. តម្លៃនៃ $\lim_{x\to +\infty}\ln\left(\frac{x+1}{x}\right)$ គឺ៖

ក. 0 ខ. 1 គ. $+\infty$ ឃ. $e$

៥៩. តម្លៃនៃ $\lim_{x\to +\infty}x\ln\left(1+\frac{1}{x}\right)$ គឺ៖

ក. 1 ខ. 0 គ. $e$ ឃ. $+\infty$

៦០. តម្លៃនៃ $\lim_{x\to 0}\frac{\ln(1+\sin x)}{x}$ គឺ៖

ក. 1 ខ. 0 គ. $\cos 1$ ឃ. $+\infty$

៦១. ឫសនៃសមីការ $\ln x = 0$ គឺ៖

ក. $x=1$ ខ. $x=0$ គ. $x=e$ ឃ. គ្មានឫស

៦២. ឫសនៃសមីការ $\ln x=1$ គឺ៖

ក. $x=e$ ខ. $x=0$ គ. $x=1$ ឃ. $x=e^2$

៦៣. ឫសនៃសមីការ $\ln x=2$ គឺ៖

ក. $x=e^2$ ខ. $x=2e$ គ. $x=2$ ឃ. $x=\sqrt{e}$

៦៤. ឫសនៃសមីការ $\ln(x-1)=0$ គឺ៖

ក. $x=2$ ខ. $x=1$ គ. $x=0$ ឃ. $x=e+1$

៦៥. ឫសនៃសមីការ $\ln(2x-3)=0$ គឺ៖

ក. $x=2$ ខ. $x=\frac{3}{2}$ គ. $x=1$ ឃ. $x=\frac{e+3}{2}$

៦៦. ឫសនៃសមីការ $\ln x=-1$ គឺ៖

ក. $x=\frac{1}{e}$ ខ. $x=-e$ គ. $x=1$ ឃ. គ្មានឫស

៦៧. ឫសនៃសមីការ $\ln(x+2)=\ln(2x-1)$ គឺ៖

ក. $x=3$ ខ. $x=1$ គ. $x=-3$ ឃ. គ្មានឫស

៦៨. ឫសនៃសមីការ $\ln(x-2)+\ln(x+2)=\ln 5$ គឺ៖

ក. $x=3$ ខ. $x=\pm 3$ គ. $x=9$ ឃ. $x=5$

៦៩. សំណុំឫសនៃសមីការ $\ln^2 x-3\ln x+2=0$ គឺ៖

ក. $\{e,e^2\}$ ខ. $\{1,2\}$ គ. $\{0,\ln 2\}$ ឃ. $\{e\}$

៧០. សំណុំឫសនៃសមីការ $\ln^2 x-\ln x=0$ គឺ៖

ក. $\{1,e\}$ ខ. $\{0,1\}$ គ. $\{0,e\}$ ឃ. $\{e\}$

៧១. សំណុំឫសនៃសមីការ $\ln(x^2-3)=0$ គឺ៖

ក. $\{-2,2\}$ ខ. $\{2\}$ គ. $\{0,4\}$ ឃ. $\{\pm 3\}$

៧២. ឫសនៃសមីការ $\ln x+\ln(x-3)=\ln 4$ គឺ៖

ក. $x=4$ ខ. $x=-1$ គ. $x=4, x=-1$ ឃ. $x=1$

៧៣. វិសមីការ $\ln x>0$ មានសំណុំចម្លើយ៖

ក. $(1,+\infty)$ ខ. $[1,+\infty)$ គ. $(0,+\infty)$ ឃ. $(0,1)$

៧៤. វិសមីការ $\ln x<0$ មានសំណុំចម្លើយ៖

ក. $(0,1)$ ខ. $(-\infty,1)$ គ. $(-\infty,0)$ ឃ. $[0,1)$

៧៥. វិសមីការ $\ln x \geq 1$ មានសំណុំចម្លើយ៖

ក. $[e,+\infty)$ ខ. $(e,+\infty)$ គ. $[1,+\infty)$ ឃ. $(0,e]$

៧៦. វិសមីការ $\ln(x-1)>0$ មានសំណុំចម្លើយ៖

ក. $(2,+\infty)$ ខ. $(1,+\infty)$ គ. $[2,+\infty)$ ឃ. $(0,+\infty)$

៧៧. វិសមីការ $\ln(2x+1)\leq 0$ មានសំណុំចម្លើយ៖

ក. $(-\frac{1}{2},0]$ ខ. $(-\infty,0]$ គ. $[0,+\infty)$ ឃ. $(-\frac{1}{2},+\infty)$

៧៨. សំណុំចម្លើយនៃវិសមីការ $\ln^2 x-4\leq 0$ គឺ៖

ក. $[e^{-2},e^2]$ ខ. $[-2,2]$ គ. $(0,e^2]$ ឃ. $[1,e^2]$

៧៩. សំណុំចម្លើយនៃវិសមីការ $\ln x>\ln(2x-1)$ គឺ៖

ក. $(\frac{1}{2},1)$ ខ. $(1,+\infty)$ គ. $(0,1)$ ឃ. $(-\infty,1)$

៨០. ចំនួនឫសពិតនៃសមីការ $\ln x=-x$ លើចន្លោះ $(0,+\infty)$ គឺ៖

ក. មានឫសតែមួយ
ខ. មានឫសពីរ
គ. គ្មានឫស
ឃ. មានឫសរាប់មិនអស់

៨១. អនុគមន៍ $f(x)=\ln x$ ជាអនុគមន៍៖

ក. កើនជានិច្ចលើ $(0,+\infty)$
ខ. ចុះជានិច្ចលើ $(0,+\infty)$
គ. កើនផងចុះផង
ឃ. ជាអនុគមន៍ថេរ

៨២. សមីការអាស៊ីមតូតឈរនៃក្រាប $y=\ln x$ គឺ៖

ក. $x=0$ ខ. $y=0$ គ. $x=1$ ឃ. $y=1$

៨៣. ក្រាបនៃអនុគមន៍ $y=\ln x$ កាត់អ័ក្សអាប់ស៊ីស $x'x$ ត្រង់ចំណុច៖

ក. $(1,0)$ ខ. $(0,1)$ គ. $(0,0)$ ឃ. $(e,0)$

៨៤. មេគុណប្រាប់ទិសនៃបន្ទាត់ប៉ះនឹងក្រាប $y=\ln x$ ត្រង់ $x=1$ គឺ៖

ក. $1$ ខ. $0$ គ. $e$ ឃ. $-1$

៨៥. សមីការបន្ទាត់ប៉ះនឹងក្រាប $y=\ln x$ ត្រង់ចំណុច $x=1$ គឺ៖

ក. $y=x-1$ ខ. $y=x+1$ គ. $y=x$ ឃ. $y=-x+1$

៨៦. សមីការបន្ទាត់ប៉ះនឹងក្រាប $y=\ln x$ ត្រង់ចំណុច $x=e$ គឺ៖

ក. $y=\frac{1}{e}x$ ខ. $y=\frac{1}{e}x+1$ គ. $y=x-e$ ឃ. $y=\frac{1}{e}x-1$

៨៧. ដេរីវេនៃអនុគមន៍ $f(x)=\frac{\ln x}{x}$ ស្មើ 0 ត្រង់៖

ក. $x=e$ ខ. $x=1$ គ. $x=0$ ឃ. $x=e^2$

៨៨. តម្លៃអតិបរមាធៀបនៃអនុគមន៍ $f(x)=\frac{\ln x}{x}$ គឺ៖

ក. $\frac{1}{e}$ ខ. $e$ គ. $1$ ឃ. $0$

៨៩. សមីការអាស៊ីមតូតដេកនៃក្រាប $y=\frac{\ln x}{x}$ កាលណា $x\to+\infty$ គឺ៖

ក. $y=0$ ខ. $y=1$ គ. $x=0$ ឃ. $y=\frac{1}{e}$

៩០. តម្លៃអប្បបរមាធៀបនៃអនុគមន៍ $f(x)=x\ln x$ គឺ៖

ក. $-\frac{1}{e}$ ខ. $0$ គ. $-1$ ឃ. $-e$

៩១. តម្លៃអប្បបរមាធៀបនៃអនុគមន៍ $f(x)=x-\ln x$ គឺ៖

ក. $1$ ខ. $0$ គ. $e$ ឃ. $-1$

៩២. ក្រាបនៃអនុគមន៍ $y=\ln x$ និង $y=e^x$ ឆ្លុះគ្នាធៀបនឹង៖

ក. បន្ទាត់ពុះទី ១ $y=x$
គ. អ័ក្ស $x'x$
ខ. អ័ក្ស $y'y$
ឃ. គល់កូអរដោនេ $O$

៩៣. ចំណុចរបត់នៃក្រាប $y=\frac{\ln x}{x}$ មានអាប់ស៊ីស $x$ ស្មើនឹង៖

ក. $e^{3/2}$ ខ. $e^{1/2}$ គ. $e^2$ ឃ. $e$

៩៤. សមីការអាស៊ីមតូតឈរនៃក្រាប $y=\ln(x-2)$ គឺ៖

ក. $x=2$ ខ. $x=0$ គ. $y=2$ ឃ. $x=-2$

៩៥. សមីការអាស៊ីមតូតឈរនៃក្រាប $y=\frac{1}{\ln x}$ គឺ៖

## លំហាត់ទី ៣៣

រកតម្លៃបរមាធៀបនៃអនុគមន៍ $y=f(x)$ ខាងក្រោម ៖

ក. $f(x)=-x^2+4x+4$  គ. $f(x)=-x^2+4x-3$  ង. $f(x)=x^2-x+3$

ខ. $f(x)=-x^2+3x+2$  ឃ. $f(x)=x^2-4x+8$  ច. $f(x)=x^2+3x+2$

## ដំណោះស្រាយ

ក. $f(x)=-x^2+4x+4$ ៖

$f'(x)=-2x+4=0 \iff x=2$ ។ ដោយ $a=-1<0$ នាំឱ្យ $f$ មានអតិបរមាធៀបត្រង់ $x=2$ ៖

$$f_{\max}=f(2)=-(2)^2+4(2)+4=-4+8+4=\boxed{8}$$

ដូចនេះ តម្លៃអតិបរមាធៀបស្មើ 8 ត្រង់ $x=2$ ។

ខ. $f(x)=-x^2+3x+2$ ៖

$f'(x)=-2x+3=0 \iff x=\frac{3}{2}$ ។ ដោយ $a=-1<0$ នាំឱ្យ $f$ មានអតិបរមាធៀបត្រង់ $x=\frac{3}{2}$ ៖

$$f_{\max}=f\left(\frac{3}{2}\right)=-\frac{9}{4}+\frac{9}{2}+2=-\frac{9}{4}+\frac{18}{4}+\frac{8}{4}=\boxed{\frac{17}{4}}$$

ដូចនេះ តម្លៃអតិបរមាធៀបស្មើ $\frac{17}{4}$ ត្រង់ $x=\frac{3}{2}$ ។

គ. $f(x)=-x^2+4x-3$ ៖

$f'(x)=-2x+4=0 \iff x=2$ ។ ដោយ $a=-1<0$ នាំឱ្យ $f$ មានអតិបរមាធៀបត្រង់ $x=2$ ៖

$$f_{\max}=f(2)=-(2)^2+4(2)-3=-4+8-3=\boxed{1}$$

ដូចនេះ តម្លៃអតិបរមាធៀបស្មើ 1 ត្រង់ $x=2$ ។

ឃ. $f(x)=x^2-4x+8$ ៖

$f'(x)=2x-4=0 \iff x=2$ ។ ដោយ $a=1>0$ នាំឱ្យ $f$ មានអប្បបរមាធៀបត្រង់ $x=2$ ៖

$$f_{\min}=f(2)=2^2-4(2)+8=4-8+8=\boxed{4}$$

ដូចនេះ តម្លៃអប្បបរមាធៀបស្មើ 4 ត្រង់ $x=2$ ។

ង. $f(x) = x^2 - x + 3$ ៖

$f'(x) = 2x - 1 = 0 \iff x = \frac{1}{2}$ ។ ដោយ $a = 1 > 0$ នាំឱ្យ $f$ មានអប្បបរមាធៀបត្រង់ $x = \frac{1}{2}$ ៖

$$f_{\min} = f\left(\frac{1}{2}\right) = \frac{1}{4} - \frac{1}{2} + 3 = \frac{1 - 2 + 12}{4} = \boxed{\frac{11}{4}}$$

ដូចនេះ តម្លៃអប្បបរមាធៀបស្មើ $\frac{11}{4}$ ត្រង់ $x = \frac{1}{2}$ ។

ប. $f(x) = x^2 + 3x + 2$ ៖

$f'(x) = 2x + 3 = 0 \iff x = -\frac{3}{2}$ ។ ដោយ $a = 1 > 0$ នាំឱ្យ $f$ មានអប្បបរមាធៀបត្រង់ $x = -\frac{3}{2}$ ៖

$$f_{\min} = f\left(-\frac{3}{2}\right) = \frac{9}{4} - \frac{9}{2} + 2 = \frac{9 - 18 + 8}{4} = \boxed{-\frac{1}{4}}$$

ដូចនេះ តម្លៃអប្បបរមាធៀបស្មើ $-\frac{1}{4}$ ត្រង់ $x = -\frac{3}{2}$ ។

---

## លំហាត់ទី ៣៤

គេឱ្យអនុគមន៍ $h(x) = mx^2 + nx + 1$ មានក្រាប $(H)$ ។ ចូររកចំនួនពិត $m$ និង $n$ ដើម្បីឱ្យ $h$ មានតម្លៃអប្បបរមាត្រង់ $x = 1$ ហើយមាន $h(3) = 2$ ។

## ដំណោះស្រាយ

គណនាដេរីវេនៃអនុគមន៍ $h(x)$ ៖

$$h'(x) = 2mx + n$$

អនុគមន៍ $h$ មានតម្លៃអប្បបរមាត្រង់ $x = 1$ លុះត្រាតែ ៖

$$h'(1) = 0 \quad \text{និង} \quad h''(1) = 2m > 0 \iff m > 0$$

សមីការ $h'(1) = 0$ នាំឱ្យ ៖

$$2m(1) + n = 0 \iff 2m + n = 0 \implies n = -2m \quad (1)$$

ម្យ៉ាងទៀត តាមប្រធាន $h(3) = 2$ ៖

$$h(3) = m(3)^2 + n(3) + 1 = 2 \iff 9m + 3n + 1 = 2 \iff 9m + 3n = 1 \quad (2)$$

ជំនួស (1) ចូលក្នុង (2) ៖

$$9m + 3(-2m) = 1 \iff 9m - 6m = 1 \iff 3m = 1 \implies m = \frac{1}{3}$$

ដោយ $m = \frac{1}{3} > 0$ នោះលក្ខខណ្ឌអប្បបរមាផ្ទៀងផ្ទាត់ត្រឹមត្រូវ ។

ទាញរក $n$ ពីសមីការ (1) ៖

$$n = -2\left(\frac{1}{3}\right) = -\frac{2}{3}$$

ដូចនេះ ចំនួនពិតដែលត្រូវរកគឺ $\boxed{m=\frac{1}{3},\quad n=-\frac{2}{3}}$ ។

---

## លំហាត់ទី ៣៥

គេឱ្យអនុគមន៍ $f(x)=x^2+\frac{a}{x}$ ដែលមានដែនកំណត់ $D=\mathbb{R}^*=\mathbb{R}\setminus\{0\}$ ។

ក. កំណត់តម្លៃ $a$ ដើម្បីឱ្យ $f$ មានអប្បបរមាត្រង់ $x=2$ ។

ខ. កំណត់តម្លៃ $a$ ដើម្បីឱ្យ $f$ មានអប្បបរមាត្រង់ $x=-3$ ។

គ. កំណត់តម្លៃ $a$ ដើម្បីឱ្យ $f$ មានចំណុចរបត់ត្រង់ $x=1$ ។

ឃ. បង្ហាញថាគ្មានតម្លៃ $a$ ណាដែលធ្វើឱ្យ $f$ មានតម្លៃអតិបរិមាឡើយ ។

## ដំណោះស្រាយ

គណនាដេរីវេទីមួយ និងដេរីវេទីពីរ ៖

$$f'(x)=2x-\frac{a}{x^2}=\frac{2x^3-a}{x^2},\qquad f''(x)=2+\frac{2a}{x^3}=\frac{2(x^3+a)}{x^3}$$

ក. $f$ មានអប្បបរមាត្រង់ $x=2$ ៖
លក្ខខណ្ឌចាំបាច់គឺ $f'(2)=0$ ៖

$$2(2)-\frac{a}{2^2}=0 \iff 4-\frac{a}{4}=0 \implies a=16$$

ផ្ទៀងផ្ទាត់ដេរីវេទីពីរ ៖ $f''(2)=2+\frac{2(16)}{2^3}=2+4=6>0$ (ពិតជាចំណុចអប្បបរមា) ។
**ដូចនេះ តម្លៃដែលត្រូវរកគឺ** $\boxed{a=16}$ ។

ខ. $f$ មានអប្បបរមាត្រង់ $x=-3$ ៖
លក្ខខណ្ឌចាំបាច់គឺ $f'(-3)=0$ ៖

$$2(-3)-\frac{a}{(-3)^2}=0 \iff -6-\frac{a}{9}=0 \iff \frac{a}{9}=-6 \implies a=-54$$

ផ្ទៀងផ្ទាត់ដេរីវេទីពីរ ៖ $f''(-3)=2+\frac{2(-54)}{(-3)^3}=2+\frac{-108}{-27}=2+4=6>0$ (ពិតជាចំណុចអប្បបរមា) ។
**ដូចនេះ តម្លៃដែលត្រូវរកគឺ** $\boxed{a=-54}$ ។

គ. $f$ មានចំណុចរបត់ត្រង់ $x=1$ ៖
ក្រាបនៃអនុគមន៍មានចំណុចរបត់ត្រង់ $x=1$ លុះត្រាតែ $f''(1)=0$ ហើយ $f''(x)$ ប្តូរសញ្ញាកាត់តាម $x=1$ ៖

$$f''(1)=2+\frac{2a}{1^3}=2+2a=0 \implies a=-1$$

នៅពេល $a=-1$ គេបាន $f''(x)=\frac{2(x^3-1)}{x^3}$ ដែលប្តូរសញ្ញាពី $-$ ទៅ $+$ កាត់តាម $x=1$ ។
**ដូចនេះ តម្លៃដែលត្រូវរកគឺ** $\boxed{a=-1}$ ។

ឃ. បង្ហាញថាគ្មានតម្លៃ $a$ ដែលធ្វើឱ្យ $f$ មានតម្លៃអតិបរិមា ៖
ដើម្បីឱ្យ $f$ មានបរមាធៀបត្រង់ $x_0$ លុះត្រាតែ $f'(x_0)=0$ ៖

$$2x_0-\frac{a}{x_0^2}=0 \iff 2x_0^3=a \iff x_0^3=\frac{a}{2} \quad (a\neq 0)$$

ពិនិត្យដេរីវេទីពីរត្រង់ចំណុច $x_0$ នេះ ៖

$$f''(x_0)=2+\frac{2a}{x_0^3}=2+\frac{2a}{\frac{a}{2}}=2+4=6>0$$

ដោយ $f''(x_0)=6>0$ ជានិច្ច គ្រប់ចំណុចស្ថានីយ $x_0$ សុទ្ធតែជាចំណុចអប្បបរមាធៀបទាំងអស់ មិនអាចជាចំណុចអតិបរមាឡើយ ។
ចំពោះករណី $a=0$ គេបាន $f(x)=x^2$ ដែលជាប៉ារ៉ាបូលមានតែអប្បបរមាត្រង់កំពូល គ្មានអតិបរិមាឡើយ ។
**ដូចនេះ គ្មានតម្លៃ $a$ ណាដែលអាចធ្វើឱ្យអនុគមន៍ $f$ មានតម្លៃអតិបរិមាឡើយ ។ (បញ្ជាក់រួច)**

---

## លំហាត់ទី ៣៦

គេឱ្យអនុគមន៍ $f(x)=x^3+3ax^2+3bx+2$ កំណត់ចំពោះគ្រប់ $x\in\mathbb{R}$ ។
ក. រកតម្លៃ $a$ និង $b$ ដើម្បីឱ្យ $f$ មានអតិបរមាធៀបត្រង់ $x=1$ និងមានអប្បបរមាធៀបត្រង់ $x=2$ ។
ខ. រកផលដករវាងតម្លៃអតិបរមា និងអប្បបរមាធៀបនៃ $f$ ។

## ដំណោះស្រាយ

ក. រកតម្លៃ $a$ និង $b$ ៖
គណនាដេរីវេទីមួយនៃអនុគមន៍ ៖

$$f'(x)=3x^2+6ax+3b$$

អនុគមន៍ $f$ មានអតិបរមាធៀបត្រង់ $x=1$ និងអប្បបរមាធៀបត្រង់ $x=2$ លុះត្រាតែ $x=1$ និង $x=2$ ជាឫសនៃ $f'(x)=0$ ៖

$$\begin{cases} f'(1)=3(1)^2+6a(1)+3b=0 \\ f'(2)=3(2)^2+6a(2)+3b=0 \end{cases} \iff \begin{cases} 3+6a+3b=0 \\ 12+12a+3b=0 \end{cases} \iff \begin{cases} 2a+b=-1 & (1) \\ 4a+b=-4 & (2) \end{cases}$$

យកសមីការ $(2)$ ដកសមីការ $(1)$ អង្គនឹងអង្គ ៖

$$(4a+b)-(2a+b)=-4-(-1) \iff 2a=-3 \implies a=-\frac{3}{2}$$

ជំនួសតម្លៃ $a=-\frac{3}{2}$ ចូលក្នុងសមីការ $(1)$ ៖

$$2\left(-\frac{3}{2}\right)+b=-1 \iff -3+b=-1 \implies b=2$$

ពិនិត្យដេរីវេទីពីរ ៖ $f''(x)=6x+6a=6x-9$ ៖

- $f''(1) = 6(1) - 9 = -3 < 0 \implies x = 1$ ពិតជាចំណុចអតិបរមាធៀប ។
- $f''(2) = 6(2) - 9 = 3 > 0 \implies x = 2$ ពិតជាចំណុចអប្បបរមាធៀប ។

**ដូចនេះ តម្លៃដែលត្រូវរកគឺ** $\boxed{a = -\frac{3}{2}, \quad b = 2}$ ។

ខ. រកផលដករវាងតម្លៃអតិបរមា និងអប្បបរមាធៀបនៃ $f$ ៖
ជំនួស $a = -\frac{3}{2}$ និង $b = 2$ ចូលក្នុងកន្សោមអនុគមន៍ ៖

$$f(x) = x^3 - \frac{9}{2}x^2 + 6x + 2$$

គណនាតម្លៃអតិបរមាធៀប ៖

$$f_{\max} = f(1) = 1^3 - \frac{9}{2}(1)^2 + 6(1) + 2 = 1 - \frac{9}{2} + 8 = 9 - 4.5 = \frac{9}{2}$$

គណនាតម្លៃអប្បបរមាធៀប ៖

$$f_{\min} = f(2) = 2^3 - \frac{9}{2}(2)^2 + 6(2) + 2 = 8 - 18 + 12 + 2 = 4$$

ផលដករវាងតម្លៃអតិបរមា និងអប្បបរមាធៀប ៖

$$f_{\max} - f_{\min} = \frac{9}{2} - 4 = \frac{9-8}{2} = \frac{1}{2}$$

**ដូចនេះ ផលដកដែលត្រូវរកគឺ** $\boxed{f(1) - f(2) = \frac{1}{2}}$ ។

---

**លំហាត់ទី ៣៧**

រកតម្លៃ $a$ និង $b$ ដើម្បីឱ្យអនុគមន៍ $f(x) = x^3 + ax^2 + bx + 1$ មាន ៖

ក. អតិបរមាត្រង់ $x = -1$ និងអប្បបរមាត្រង់ $x = 3$ ។

ខ. អប្បបរមាត្រង់ $x = 4$ និងចំណុចរបត់ត្រង់ $x = -1$ ។

## ដំណោះស្រាយ

គណនាដេរីវេទីមួយ និងដេរីវេទីពីរ ៖

$$f'(x) = 3x^2 + 2ax + b, \qquad f''(x) = 6x + 2a$$

ក. $f$ មានអតិបរមាត្រង់ $x = -1$ និងអប្បបរមាត្រង់ $x = 3$ ៖
លក្ខខណ្ឌចាំបាច់ ៖

$$\begin{cases} f'(-1) = 3(-1)^2 + 2a(-1) + b = 0 \\ f'(3) = 3(3)^2 + 2a(3) + b = 0 \end{cases} \iff \begin{cases} 3 - 2a + b = 0 \\ 27 + 6a + b = 0 \end{cases} \iff \begin{cases} -2a + b = -3 & (1) \\ 6a + b = -27 & (2) \end{cases}$$

យក (2) ដក (1) អង្គនឹងអង្គ ៖

$$(6a+b)-(-2a+b)=-27-(-3) \iff 8a=-24 \implies a=-3$$

ជំនួស $a=-3$ ចូល (1) ៖

$$-2(-3)+b=-3 \iff 6+b=-3 \implies b=-9$$

ពិនិត្យដេរីវេទីពីរ ៖ $f''(x)=6x+2(-3)=6x-6$ ៖

- $f''(-1)=6(-1)-6=-12<0 \implies x=-1$ ជាចំណុចអតិបរមាពិតប្រាកដ ។
- $f''(3)=6(3)-6=12>0 \implies x=3$ ជាចំណុចអប្បបរមាពិតប្រាកដ ។

**ដូចនេះ តម្លៃដែលត្រូវរកគឺ** $\boxed{a=-3, \quad b=-9}$ ។

ខ. $f$ មានអប្បបរមាត្រង់ $x=4$ និងចំណុចរបត់ត្រង់ $x=-1$ ៖
ចំណុចរបត់ត្រង់ $x=-1$ តម្រូវឱ្យ ៖

$$f''(-1)=0 \iff 6(-1)+2a=0 \iff -6+2a=0 \implies 2a=6 \implies a=3$$

ជាមួយ $a=3$ នោះ $f'(x)=3x^2+6x+b$ ។
លក្ខខណ្ឌអប្បបរមាត្រង់ $x=4$ តម្រូវឱ្យ $f'(4)=0$ ៖

$$f'(4)=3(4)^2+6(4)+b=0 \iff 48+24+b=0 \iff 72+b=0 \implies b=-72$$

ពិនិត្យដេរីវេទីពីរ ៖

- $f''(4)=6(4)+2(3)=24+6=30>0 \implies x=4$ ជាចំណុចអប្បបរមាពិតប្រាកដ ។
- $f''(x)=6x+6=6(x+1)$ ប្តូរសញ្ញាពី $-$ ទៅ $+$ កាត់តាម $x=-1 \implies x=-1$ ជាចំណុចរបត់ពិតប្រាកដ ។

**ដូចនេះ តម្លៃដែលត្រូវរកគឺ** $\boxed{a=3, \quad b=-72}$ ។

---

## លំហាត់ទី ៣៨

សិក្សាអថេរភាពនៃអនុគមន៍ $y=f(x)$ ខាងក្រោម ៖

ក. $f(x)=2x^2-8x+5$ ខ. $f(x)=x^3-3x+3x+2$ គ. $f(x)=x^4-2x^2+2$

## ដំណោះស្រាយ

ក. $f(x)=2x^2-8x+5$ ៖

- **ដែនកំណត់** ៖ $D=\mathbb{R}$ ។
- **ទិសដៅអថេរភាព** ៖
ដេរីវេ ៖ $f'(x)=4x-8=4(x-2)$ ។
$f'(x)=0 \iff x=2$ ។
- ចំពោះ $x\in(-\infty,2) \implies f'(x)<0 \implies f$ ជាអនុគមន៍ចុះដាច់ខាត ។
- ចំពោះ $x\in(2,+\infty) \implies f'(x)>0 \implies f$ ជាអនុគមន៍កើនដាច់ខាត ។

- **បរមាធៀប ៖**
  ត្រង់ $x=2$, $f'(x)$ ប្តូរសញ្ញាពី $-$ ទៅ $+$ នាំឱ្យ $f$ មានតម្លៃអប្បបរមាធៀបគឺ ៖

$$f(2)=2(2)^2-8(2)+5=8-16+5=\boxed{-3}$$

- **លីមីត ៖** $\lim\limits_{x\to\pm\infty} f(x)=\lim\limits_{x\to\pm\infty} 2x^2=+\infty$ ។

**តារាងអថេរភាព ៖**

| $x$ | $-\infty$ | | $2$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | | $-$ | $0$ | $+$ | |
| $f(x)$ | $+\infty$ | $\searrow$ | $-3$ | $\nearrow$ | $+\infty$ |

ខ. $f(x)=x^3-3x+3x+2=x^3+2$ ៖

- **ដែនកំណត់ ៖** $D=\mathbb{R}$ ។
- **ទិសដៅអថេរភាព ៖**
  ដេរីវេ ៖ $f'(x)=3x^2\geq 0$ ចំពោះគ្រប់ $x\in\mathbb{R}$ ។
  $f'(x)=0 \iff x=0$ (ឫសឌុប មិនប្តូរសញ្ញា) ។
  **ដូចនេះ $f$ ជាអនុគមន៍កើនដាច់ខាតលើ $\mathbb{R}$ និងគ្មានតម្លៃបរមាធៀបឡើយ ។**
- **លីមីត ៖** $\lim\limits_{x\to-\infty} f(x)=-\infty,\quad \lim\limits_{x\to+\infty} f(x)=+\infty$ ។
- **ចំណុចរបត់ ៖** $f''(x)=6x=0 \iff x=0$ (ប្តូរសញ្ញា) $\Longrightarrow I(0,2)$ ជាចំណុចរបត់នៃក្រាប ។

**តារាងអថេរភាព ៖**

| $x$ | $-\infty$ | | $0$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | | $+$ | $0$ | $+$ | |
| $f(x)$ | $-\infty$ | $\nearrow$ | $2$ | $\nearrow$ | $+\infty$ |

គ. $f(x)=x^4-2x^2+2$ ៖

- **ដែនកំណត់ ៖** $D=\mathbb{R}$ ។
- **ទិសដៅអថេរភាព ៖**
  ដេរីវេ ៖ $f'(x)=4x^3-4x=4x(x^2-1)=4x(x-1)(x+1)$ ។
  $f'(x)=0 \iff x=-1,\quad x=0,\quad x=1$ ។
  - ចំពោះ $x\in(-\infty,-1)\cup(0,1) \Longrightarrow f'(x)<0 \Longrightarrow f$ ជាអនុគមន៍ចុះ ។
  - ចំពោះ $x\in(-1,0)\cup(1,+\infty) \Longrightarrow f'(x)>0 \Longrightarrow f$ ជាអនុគមន៍កើន ។

- **បរមាធៀប ៖**
  - ត្រង់ $x=\pm1$ ៖ អប្បបរមាធៀបគឺ $f(\pm1)=(\pm1)^4-2(\pm1)^2+2=\boxed{1}$ ។
  - ត្រង់ $x=0$ ៖ អតិបរមាធៀបគឺ $f(0)=\boxed{2}$ ។
- **លីមីត ៖** $\lim\limits_{x\to\pm\infty} f(x)=+\infty$ ។

**តារាងអថេរភាព ៖**

| $x$ | $-\infty$ | | $-1$ | | $0$ | | $1$ | | $+\infty$ |
|---|---|---|---|---|---|---|---|---|---|
| $f'(x)$ | | $-$ | $0$ | $+$ | $0$ | $-$ | $0$ | $+$ | |
| $f(x)$ | $+\infty$ | ↘ | $1$ | ↗ | $2$ | ↘ | $1$ | ↗ | $+\infty$ |

---

## លំហាត់ទី ៣៩

សិក្សាអថេរភាពនៃអនុគមន៍ $y=f(x)$ ខាងក្រោម ៖

ក. $f(x)=\dfrac{x^2-4x}{x^2+3x}$ ឃ. $f(x)=\dfrac{3x^2-18x+25}{x^2-6x+8}$ ឆ. $f(x)=\dfrac{x^2-2x+3}{x^2-1}$

ខ. $f(x)=\dfrac{2x^2-2x-1}{(x-1)^2}$ ង. $f(x)=\dfrac{x^2-4}{x^2+1}$ ជ. $f(x)=\dfrac{-x^2+3x+5}{x^2-2x-3}$

គ. $f(x)=\dfrac{x^2-4x}{x^2-4x+3}$ ច. $f(x)=\dfrac{x^2-1}{x^2+2}$ ឈ. $f(x)=\dfrac{2x^2-x+3}{1-x^2}$

## ដំណោះស្រាយ

ក. $f(x)=\dfrac{x^2-4x}{x^2+3x}$ ៖

- ដែនកំណត់ ៖ $x^2+3x\neq0 \iff x(x+3)\neq0 \implies \boxed{D=\mathbb{R}\setminus\{-3,0\}}$ ។
- សម្រួលកន្សោមចំពោះ $x\neq0$ ៖ $f(x)=\dfrac{x(x-4)}{x(x+3)}=\dfrac{x-4}{x+3}=1-\dfrac{7}{x+3}$ ។
- អាស៊ីមតូត ៖ $\lim\limits_{x\to\pm\infty} f(x)=1 \implies \boxed{y=1}$ (ដេក) ; $\lim\limits_{x\to-3^\pm} f(x)=\pm\infty \implies \boxed{x=-3}$ (ឈរ) ។
  ត្រង់ $x=0$ ៖ $\lim\limits_{x\to0} f(x)=-\dfrac{4}{3}$ (ក្រាបមានចន្លោះប្រហោងត្រង់ $(0,-4/3)$) ។
- ដេរីវេ ៖ $f'(x)=\dfrac{7}{(x+3)^2}>0,\ \forall x\in D \implies f$ ជាអនុគមន៍កើនដាច់ខាតលើ $(-\infty,-3)$, $(-3,0)$ និង $(0,+\infty)$ ព្រមទាំងគ្មានបរមាឡើយ ។

ខ. $f(x)=\dfrac{2x^2-2x-1}{(x-1)^2}$ ៖

- ដែនកំណត់ ៖ $\boxed{D=\mathbb{R}\setminus\{1\}}$ ។
- អាស៊ីមតូត ៖ $\lim\limits_{x\to\pm\infty} f(x)=2 \implies \boxed{y=2}$ (ដេក) ; $\lim\limits_{x\to 1} f(x)=-\infty \implies \boxed{x=1}$ (ឈរ) ។
- បំបែក ៖ $f(x)=\dfrac{2(x-1)^2+2x-3}{(x-1)^2}=2+\dfrac{2x-3}{(x-1)^2}$ ។
- ដេរីវេ ៖ $f'(x)=\dfrac{2(x-1)^2-2(x-1)(2x-3)}{(x-1)^4}=\dfrac{2(x-1)-2(2x-3)}{(x-1)^3}=\dfrac{-2x+4}{(x-1)^3}=\dfrac{-2(x-2)}{(x-1)^3}$ ។
  $f'(x)=0 \iff x=2$ ។
- អថេរភាព ៖ $f'(x)>0 \iff x\in(1,2) \implies f$ កើន ; $f'(x)<0 \iff x\in(-\infty,1)\cup(2,+\infty) \implies f$ ចុះ ។
- បរមាធៀប ៖ ត្រង់ $x=2,\ f$ មានតម្លៃអតិបរមាធៀបគឺ $f(2)=\dfrac{2(4)-4-1}{(2-1)^2}=\boxed{3}$ ។

**គ**. $f(x)=\dfrac{x^2-4x}{x^2-4x+3}=1-\dfrac{3}{(x-1)(x-3)}$ ៖

- ដែនកំណត់ ៖ $x^2-4x+3\neq 0 \implies \boxed{D=\mathbb{R}\setminus\{1,3\}}$ ។
- អាស៊ីមតូត ៖ $y=1$ (ដេក) ; $x=1$ និង $x=3$ (ឈរ) ។
- ដេរីវេ ៖ $f'(x)=\dfrac{(2x-4)(x^2-4x+3)-(2x-4)(x^2-4x)}{(x^2-4x+3)^2}=\dfrac{6(x-2)}{(x^2-4x+3)^2}$ ។
  $f'(x)=0 \iff x=2$ ។
- អថេរភាព ៖ $f'(x)<0 \iff x\in(-\infty,1)\cup(1,2) \implies f$ ចុះ ; $f'(x)>0 \iff x\in(2,3)\cup(3,+\infty) \implies f$ កើន ។
- បរមាធៀប ៖ ត្រង់ $x=2,\ f$ មានតម្លៃអប្បបរមាធៀបគឺ $f(2)=\dfrac{4-8}{4-8+3}=\boxed{4}$ ។

**ឃ**. $f(x)=\dfrac{3x^2-18x+25}{x^2-6x+8}=3+\dfrac{1}{(x-2)(x-4)}$ ៖

- ដែនកំណត់ ៖ $\boxed{D=\mathbb{R}\setminus\{2,4\}}$ ។
- អាស៊ីមតូត ៖ $y=3$ (ដេក) ; $x=2$ និង $x=4$ (ឈរ) ។
- ដេរីវេ ៖ $f'(x)=\dfrac{-(2x-6)}{(x^2-6x+8)^2}=\dfrac{-2(x-3)}{(x^2-6x+8)^2}$ ។
  $f'(x)=0 \iff x=3$ ។
- អថេរភាព ៖ $f'(x)>0 \iff x\in(-\infty,2)\cup(2,3) \implies f$ កើន ; $f'(x)<0 \iff x\in(3,4)\cup(4,+\infty) \implies f$ ចុះ ។
- បរមាធៀប ៖ ត្រង់ $x=3,\ f$ មានតម្លៃអតិបរមាធៀបគឺ $f(3)=3+\dfrac{1}{9-18+8}=\boxed{2}$ ។

**ង**. $f(x)=\dfrac{x^2-4}{x^2+1}=1-\dfrac{5}{x^2+1}$ ៖

- ដែនកំណត់ ៖ $\boxed{D=\mathbb{R}}$ (ដោយ $x^2+1>0,\ \forall x$) ។
- អាស៊ីមតូត ៖ $\lim\limits_{x\to\pm\infty} f(x)=1 \implies \boxed{y=1}$ (ដេក) ។ គ្មានអាស៊ីមតូតឈរ ។
- ដេរីវេ ៖ $f'(x)=\dfrac{10x}{(x^2+1)^2}$ ។ $f'(x)=0 \iff x=0$ ។

- អថេរភាព ៖ $f'(x)<0 \iff x<0 \implies f$ ចុះ ; $f'(x)>0 \iff x>0 \implies f$ កើន ។
- បរមាធៀប ៖ ត្រង់ $x=0$, $f$ មានតម្លៃអប្បបរមាធៀបគឺ $f(0)=\boxed{-4}$ ។

ប. $f(x)=\dfrac{x^2-1}{x^2+2}=1-\dfrac{3}{x^2+2}$ ៖

- ដែនកំណត់ ៖ $\boxed{D=\mathbb{R}}$ ។
- អាស៊ីមតូត ៖ $\lim\limits_{x\to\pm\infty} f(x)=1 \implies \boxed{y=1}$ (ដេក) ។
- ដេរីវេ ៖ $f'(x)=\dfrac{6x}{(x^2+2)^2}$ ។ $f'(x)=0 \iff x=0$ ។
- អថេរភាព ៖ $f'(x)<0 \iff x<0 \implies f$ ចុះ ; $f'(x)>0 \iff x>0 \implies f$ កើន ។
- បរមាធៀប ៖ ត្រង់ $x=0$, $f$ មានតម្លៃអប្បបរមាធៀបគឺ $f(0)=\boxed{-\dfrac{1}{2}}$ ។

ឆ. $f(x)=\dfrac{x^2-2x+3}{x^2-1}$ ៖

- ដែនកំណត់ ៖ $\boxed{D=\mathbb{R}\setminus\{-1,1\}}$ ។
- អាស៊ីមតូត ៖ $y=1$ (ដេក) ; $x=-1$ និង $x=1$ (ឈរ) ។
- ដេរីវេ ៖ $f'(x)=\dfrac{(2x-2)(x^2-1)-2x(x^2-2x+3)}{(x^2-1)^2}=\dfrac{2(x^2-4x+1)}{(x^2-1)^2}$ ។
  $f'(x)=0 \iff x=2-\sqrt{3}\approx 0.27$ ឬ $x=2+\sqrt{3}\approx 3.73$ ។
- បរមាធៀប ៖
  - អតិបរមាធៀបត្រង់ $x=2-\sqrt{3}$ គឺ $f(2-\sqrt{3})=\boxed{1-\sqrt{3}}$ ។
  - អប្បបរមាធៀបត្រង់ $x=2+\sqrt{3}$ គឺ $f(2+\sqrt{3})=\boxed{1+\sqrt{3}}$ ។

ជ. $f(x)=\dfrac{-x^2+3x+5}{x^2-2x-3}$ ៖

- ដែនកំណត់ ៖ $x^2-2x-3\neq 0 \iff (x+1)(x-3)\neq 0 \implies \boxed{D=\mathbb{R}\setminus\{-1,3\}}$ ។
- អាស៊ីមតូត ៖ $\lim\limits_{x\to\pm\infty} f(x)=-1 \implies \boxed{y=-1}$ (ដេក) ; $x=-1$ និង $x=3$ (ឈរ) ។
- ដេរីវេ ៖ $f'(x)=\dfrac{(-2x+3)(x^2-2x-3)-(2x-2)(-x^2+3x+5)}{(x^2-2x-3)^2}=\dfrac{-x^2-16x+1}{(x^2-2x-3)^2}$ ។
  $f'(x)=0 \iff x=-8\pm\sqrt{65}$ ។
- បរមាធៀប ៖ អប្បបរមាត្រង់ $x=-8-\sqrt{65}$ និងអតិបរមាត្រង់ $x=-8+\sqrt{65}$ ។

ឈ. $f(x)=\dfrac{2x^2-x+3}{1-x^2}$ ៖

- ដែនកំណត់ ៖ $1-x^2\neq 0 \implies \boxed{D=\mathbb{R}\setminus\{-1,1\}}$ ។
- អាស៊ីមតូត ៖ $\lim\limits_{x\to\pm\infty} f(x)=-2 \implies \boxed{y=-2}$ (ដេក) ; $x=-1$ និង $x=1$ (ឈរ) ។
- ដេរីវេ ៖ $f'(x)=\dfrac{(4x-1)(1-x^2)-(-2x)(2x^2-x+3)}{(1-x^2)^2}=\dfrac{-x^2+10x-1}{(1-x^2)^2}$ ។
  $f'(x)=0 \iff x=5\pm 2\sqrt{6}$ ។

- បរមាធៀប ៖ អប្បបរមាត្រង់ $x=5-2\sqrt{6}$ និងអតិបរមាត្រង់ $x=5+2\sqrt{6}$ ។

---

## លំហាត់ទី ៤០

គេឱ្យអនុគមន៍ $f$ កំណត់ចំពោះ $x\neq 2$ ដោយ $f(x)=\dfrac{2x^2+x-1}{x-2}$ និងមានក្រាបតំណាង $(C)$ ។

ក. រកចំនួនពិត $a,b,c$ ដែលគ្រប់ $x\neq 2$ គេបាន $f(x)=ax+b+\dfrac{c}{x-2}$ ។

ខ. រកសមីការអាស៊ីមតូតឈរ និងអាស៊ីមតូតទ្រេតនៃក្រាប $(C)$ ។

គ. សិក្សាទីតាំងធៀបនៃក្រាប $(C)$ ធៀបទៅនឹងអាស៊ីមតូតទ្រេតរបស់វា ។

ឃ. សិក្សាអថេរភាព សង់តារាងអថេរភាព និងសង់ក្រាប $(C)$ ក្នុងតម្រុយអរតូណរម៉ាល់ ។

ង. ពិភាក្សាអត្ថិភាព និងសញ្ញានៃឫសសមីការ $2x^2+(1-m)x+2m-1=0$ តាមប៉ារ៉ាម៉ែត្រ $m$ ។

## ដំណោះស្រាយ

**ក. រកចំនួនពិត $a,b,c$ ៖**

ធ្វើវិធីចែកពហុធាភាគយក $2x^2+x-1$ នឹងភាគបែង $x-2$ ៖

$$\begin{array}{r|l} 2x^2+x-1 & x-2 \\ \cline{2-2} -(2x^2-4x) & 2x+5 \\ \hline 5x-1 & \\ -(5x-10) & \\ \hline 9 & \end{array}$$

គេបាន ៖ $f(x)=2x+5+\dfrac{9}{x-2}$ ចំពោះគ្រប់ $x\neq 2$ ។

ដូចនេះ $\boxed{a=2,\quad b=5,\quad c=9}$ ។

**ខ. រកសមីការអាស៊ីមតូតឈរ និងអាស៊ីមតូតទ្រេត ៖**

- **អាស៊ីមតូតឈរ ៖** គណនាលីមីតត្រង់ $x\to 2$ ៖

$$\lim_{x\to 2^-} f(x)=\lim_{x\to 2^-}\left(2x+5+\frac{9}{x-2}\right)=9+\left(\frac{9}{0^-}\right)=-\infty$$

$$\lim_{x\to 2^+} f(x)=\lim_{x\to 2^+}\left(2x+5+\frac{9}{x-2}\right)=9+\left(\frac{9}{0^+}\right)=+\infty$$

ដូចនេះ បន្ទាត់ដែលមានសមីការ $\boxed{x=2}$ ជាអាស៊ីមតូតឈរនៃក្រាប $(C)$ ។

- **អាស៊ីមតូតទ្រេត ៖** គណនាលីមីតនៃផលដក $f(x)-(2x+5)$ កាលណា $x\to\pm\infty$ ៖

$$\lim_{x\to\pm\infty}[f(x)-(2x+5)]=\lim_{x\to\pm\infty}\frac{9}{x-2}=0$$

ដូចនេះ បន្ទាត់ $(d)$: $\boxed{y=2x+5}$ ជាសមីការអាស៊ីមតូតទ្រេតនៃក្រាប $(C)$ ។

**គ. សិក្សាទីតាំងធៀបនៃក្រាប $(C)$ ធៀបនឹងអាស៊ីមតូតទ្រេត $(d)$ ៖**

ពិនិត្យសញ្ញានៃផលដក $f(x)-y_d=\dfrac{9}{x-2}$ ៖

- បើ $x\in(2,+\infty) \implies x-2>0 \implies f(x)-y_d>0$ នាំឱ្យក្រាប $(C)$ **ស្ថិតនៅខាងលើ** អាស៊ីមតូតទ្រេត $(d)$ ។
- បើ $x\in(-\infty,2) \implies x-2<0 \implies f(x)-y_d<0$ នាំឱ្យក្រាប $(C)$ **ស្ថិតនៅខាងក្រោម** អាស៊ីមតូតទ្រេត $(d)$ ។

**ឃ. សិក្សាអថេរភាព និងសង់ក្រាប ៖**

- **ដែនកំណត់ ៖** $D=\mathbb{R}\setminus\{2\}=(-\infty,2)\cup(2,+\infty)$ ។
- **ដេរីវេ ៖**

$$f'(x)=(2x+5)'+\left(\frac{9}{x-2}\right)'=2-\frac{9}{(x-2)^2}=\frac{2(x-2)^2-9}{(x-2)^2}$$

ឱ្យ $f'(x)=0 \iff 2(x-2)^2=9 \iff (x-2)^2=\dfrac{9}{2} \iff x-2=\pm\dfrac{3\sqrt{2}}{2}$ ៖

$$x_1=2-\frac{3\sqrt{2}}{2}\approx-0.12,\qquad x_2=2+\frac{3\sqrt{2}}{2}\approx 4.12$$

- **តម្លៃបរមាធៀប ៖**

$$f(x_1)=2\left(2-\frac{3\sqrt{2}}{2}\right)+5+\frac{9}{-\frac{3\sqrt{2}}{2}}=9-3\sqrt{2}-3\sqrt{2}=9-6\sqrt{2}\approx 0.51 \quad \text{(អតិបរមាធៀប)}$$

$$f(x_2)=2\left(2+\frac{3\sqrt{2}}{2}\right)+5+\frac{9}{\frac{3\sqrt{2}}{2}}=9+3\sqrt{2}+3\sqrt{2}=9+6\sqrt{2}\approx 17.49 \quad \text{(អប្បបរមាធៀប)}$$

- **ផ្ចិតឆ្លុះ ៖** ចំណុចប្រសព្វនៃអាស៊ីមតូតទាំងពីរគឺ $I(2,9)$ ។
ចំពោះគ្រប់ $x\neq 2$ គេបាន $4-x\neq 2$ ហើយ ៖

$$f(4-x)+f(x)=\left(2(4-x)+5+\frac{9}{2-x}\right)+\left(2x+5+\frac{9}{x-2}\right)=18=2(9)$$

**ដូចនេះ** $I(2,9)$ **ជាផ្ចិតឆ្លុះនៃក្រាប** $(C)$ ។

- **ចំណុចប្រសព្វអ័ក្សកូអរដោនេ ៖**
  - ប្រសព្វអ័ក្ស $(Oy)$ ៖ $x=0 \implies y=f(0)=\dfrac{-1}{-2}=\dfrac{1}{2}$ ។ ចំណុច $\left(0,\dfrac{1}{2}\right)$ ។
  - ប្រសព្វអ័ក្ស $(Ox)$ ៖ $y=0 \iff 2x^2+x-1=0 \iff (2x-1)(x+1)=0 \implies x=\dfrac{1}{2},\ x=-1$ ។

**តារាងអថេរភាព ៖**

| $x$ | $-\infty$ | | $2-\frac{3\sqrt{2}}{2}$ | | $2$ | | $2+\frac{3\sqrt{2}}{2}$ | | $+\infty$ |
|---|---|---|---|---|---|---|---|---|---|
| $f'(x)$ | | $+$ | $0$ | $-$ | \|\| | $-$ | $0$ | $+$ | |
| $f(x)$ | $-\infty$ | $\nearrow$ | $9-6\sqrt{2}$ | $\searrow$ | $-\infty$ \|\| $+\infty$ | $\searrow$ | $9+6\sqrt{2}$ | $\nearrow$ | $+\infty$ |

ក្រាបតំណាង $(C)$ ៖




ង. **ពិភាក្សាអត្ថិភាព និងសញ្ញានៃឫសតាមប៉ារ៉ាម៉ែត្រ $m$ ៖**
សមីការដែលត្រូវពិភាក្សា ៖ $2x^2+(1-m)x+2m-1=0$ (ចំពោះ $x \neq 2$) ។
បំប្លែងសមីការ ៖

$$2x^2+x-1-mx+2m=0 \iff 2x^2+x-1=m(x-2) \iff \frac{2x^2+x-1}{x-2}=m \iff f(x)=m$$

ចំនួនឫសនៃសមីការគឺចំនួនចំណុចប្រសព្វរវាងក្រាប $(C)$ និងបន្ទាត់ដេក $(d_m): y=m$ ៖

- បើ $m<9-6\sqrt{2}\approx 0.51$ ៖ បន្ទាត់កាត់ក្រាប $(C)$ ត្រង់ពីរចំណុចដែលមានអាប់ស៊ីស $x<2$ (ឫសទាំងពីរអវិជ្ជមាន ឬមានសញ្ញាផ្ទុយគ្នាអាស្រ័យតាម $m$ ធៀបនឹង $\frac{1}{2}$) ។
- បើ $m=9-6\sqrt{2}$ ៖ បន្ទាត់ប៉ះក្រាប $(C)$ ត្រង់កំពូលអតិបរមា នាំឱ្យសមីការមានឫសឌុប $x=2-\frac{3\sqrt{2}}{2}$ ។
- បើ $9-6\sqrt{2}<m<9+6\sqrt{2}$ ៖ បន្ទាត់មិនកាត់ក្រាប $(C)$ ឡើយ នាំឱ្យសមីការ**គ្មានឫសក្នុង** $\mathbb{R}$ ។
- បើ $m=9+6\sqrt{2}$ ៖ បន្ទាត់ប៉ះក្រាប $(C)$ ត្រង់កំពូលអប្បបរមា នាំឱ្យសមីការមានឫសឌុប $x=2+\frac{3\sqrt{2}}{2}$ ។

- បើ $m > 9+6\sqrt{2} \approx 17.49$ ៖ បន្ទាត់កាត់ក្រាប $(C)$ ត្រង់ពីរចំណុចដែលមានអាប់ស៊ីសវិជ្ជមានទាំងពីរ $x > 2$ (សមីការមានឫសវិជ្ជមានពីរផ្សេងគ្នា) ។

---

## លំហាត់ទី ៤១

គេឱ្យ $f$ កំណត់លើ $(-\infty, 2) \cup (2, +\infty)$ ដោយ $f(x) = \dfrac{x^2-4x+8}{x-2}$ ហើយ $(C)$ ជាក្រាបនៃ $f$ ក្នុងតម្រុយអរតូណរម៉ាល់ ។

ក. រកចំនួនពិត $a,b,c$ ដែល $f(x) = ax+b+\dfrac{c}{x-2}$ ចំពោះគ្រប់ $x \neq 2$ ។

ខ. រកសមីការអាស៊ីមតូតឈរ និងអាស៊ីមតូតទ្រេតនៃក្រាប $(C)$ ។

គ. សិក្សាអថេរភាព និងសង់តារាងអថេរភាពនៃអនុគមន៍ $f$ ។

ឃ. រកកូអរដោនេផ្ចិតឆ្លុះ $I$ នៃក្រាប $(C)$ រួចសង់ក្រាប $(C)$ ។

ង. ពិភាក្សាអត្ថិភាព និងសញ្ញានៃឫសសមីការ $x^2-(m+4)x+2m+8=0$ តាមប៉ារ៉ាម៉ែត្រ $m$ ។

## ដំណោះស្រាយ

ក. **រកចំនួនពិត $a,b,c$ ៖**

បំបែកកន្សោមភាគយក ៖

$$f(x) = \frac{x^2-4x+4+4}{x-2} = \frac{(x-2)^2+4}{x-2} = x-2+\frac{4}{x-2}$$

ដូចនេះ $\boxed{a=1, \quad b=-2, \quad c=4}$ ។

ខ. **រកសមីការអាស៊ីមតូត ៖**

- **អាស៊ីមតូតឈរ ៖**

$$\lim_{x\to 2^-} f(x) = \lim_{x\to 2^-}\left(x-2+\frac{4}{x-2}\right) = -\infty, \qquad \lim_{x\to 2^+} f(x) = +\infty$$

ដូចនេះ បន្ទាត់សមីការ $\boxed{x=2}$ ជាអាស៊ីមតូតឈរនៃ $(C)$ ។

- **អាស៊ីមតូតទ្រេត ៖**

$$\lim_{x\to\pm\infty}[f(x)-(x-2)] = \lim_{x\to\pm\infty}\frac{4}{x-2} = 0$$

ដូចនេះ បន្ទាត់ $(d): \boxed{y=x-2}$ ជាអាស៊ីមតូតទ្រេតនៃ $(C)$ ។

គ. **សិក្សាអថេរភាព ៖**

- **ដេរីវេ ៖**

$$f'(x) = 1-\frac{4}{(x-2)^2} = \frac{(x-2)^2-4}{(x-2)^2} = \frac{(x-2-2)(x-2+2)}{(x-2)^2} = \frac{x(x-4)}{(x-2)^2}$$

ឱ្យ $f'(x)=0 \iff x(x-4)=0 \iff x=0$ ឬ $x=4$ ។

- បរមាធៀប ៖
  - ត្រង់ $x=0 \Longrightarrow f(0)=0-2+\dfrac{4}{0-2}=-4$ ជាតម្លៃអតិបរមាធៀប ។
  - ត្រង់ $x=4 \Longrightarrow f(4)=4-2+\dfrac{4}{4-2}=2+2=4$ ជាតម្លៃអប្បបរមាធៀប ។

តារាងអថេរភាព ៖

| $x$ | $-\infty$ | | $0$ | | $2$ | | $4$ | | $+\infty$ |
|---|---|---|---|---|---|---|---|---|---|
| $f'(x)$ | | $+$ | $0$ | $-$ | ‖ | $-$ | $0$ | $+$ | |
| $f(x)$ | $-\infty$ | $\nearrow$ | $-4$ | $\searrow$ | $-\infty$ ‖ $+\infty$ | $\searrow$ | $4$ | $\nearrow$ | $+\infty$ |

ឃ. ផ្ចិតឆ្លុះ និងសង់ក្រាប $(C)$ ៖

ចំណុចប្រសព្វអាស៊ីមតូតទាំងពីរគឺ $I(2,0)$ ។

ផ្ទៀងផ្ទាត់រូបមន្តផ្ចិតឆ្លុះ $f(2a-x)+f(x)=2b$ ជាមួយ $a=2, b=0$ ៖

$$f(4-x)+f(x)=\left(4-x-2+\frac{4}{4-x-2}\right)+\left(x-2+\frac{4}{x-2}\right)=(2-x)-\frac{4}{x-2}+x-2+\frac{4}{x-2}=0=2(0)$$

ដូចនេះ $I(2,0)$ ជាផ្ចិតឆ្លុះនៃក្រាប $(C)$ ។



ង. **ពិភាក្សាអត្ថិភាព និងសញ្ញានៃឫសសមីការ ៖**

សមីការ $x^2-(m+4)x+2m+8=0 \iff x^2-4x+8=m(x-2) \iff \dfrac{x^2-4x+8}{x-2}=m \iff f(x)=m$ ។

- បើ $m<-4$ ៖ បន្ទាត់កាត់ក្រាបត្រង់ពីរចំណុចដែលមាន $x<2$ (ឫសអវិជ្ជមានពីរ) ។
- បើ $m=-4$ ៖ បន្ទាត់ប៉ះក្រាបត្រង់ចំណុច $(0,-4)$ នាំឱ្យមានឫសឌុប $x=0$ ។
- បើ $-4<m<4$ ៖ បន្ទាត់មិនកាត់ក្រាប $(C)$ ទេ នាំឱ្យសមីការ**គ្មានឫសក្នុង** $\mathbb{R}$ ។
- បើ $m=4$ ៖ បន្ទាត់ប៉ះក្រាបត្រង់ចំណុច $(4,4)$ នាំឱ្យមានឫសឌុប $x=4$ ។
- បើ $m>4$ ៖ បន្ទាត់កាត់ក្រាបត្រង់ពីរចំណុចដែលមាន $x>2$ (ឫសវិជ្ជមានពីរផ្សេងគ្នា) ។

---

## លំហាត់ទី ៤២

គេមានអនុគមន៍ $f$ ដែល $f(x)=\dfrac{x^2-x-3}{x+1}$ និងតាងដោយ $(C)$ ក្រាបនៃ $f$ ។

ក. រកដែនកំណត់ $D$ នៃអនុគមន៍ $f$ ។

ខ. បង្ហាញថា $f(x)=x-2-\dfrac{1}{x+1}$ ចំពោះគ្រប់ $x\in D$ ។

គ. រកសមីការអាស៊ីមតូតឈរ និងអាស៊ីមតូតទ្រេតនៃ $(C)$ និងសិក្សាទីតាំងធៀប ។

ឃ. ស្រាយបញ្ជាក់ថា $f$ ជាអនុគមន៍កើនដាច់ខាតលើចន្លោះនីមួយៗនៃដែនកំណត់ ។

ង. រកកូអរដោនេផ្ចិតឆ្លុះ $I$ រួចសង់តារាងអថេរភាព និងក្រាប $(C)$ ។

## ដំណោះស្រាយ

ក. **ដែនកំណត់ ៖** $x+1\neq 0 \iff x\neq -1 \implies \boxed{D=\mathbb{R}\setminus\{-1\}=(-\infty,-1)\cup(-1,+\infty)}$ ។

ខ. **ទម្រង់បន្ទាប់ ៖**

ចែកភាគយកនឹងភាគបែង ៖ $x^2-x-3=(x-2)(x+1)-1$ ។

នាំឱ្យ $f(x)=\dfrac{(x-2)(x+1)-1}{x+1}=\boxed{x-2-\dfrac{1}{x+1}}$ (ពិត) ។

គ. **អាស៊ីមតូត និងទីតាំងធៀប ៖**

- $\lim\limits_{x\to-1^-} f(x)=+\infty,\ \lim\limits_{x\to-1^+} f(x)=-\infty \implies \boxed{x=-1}$ ជាអាស៊ីមតូតឈរ ។
- $\lim\limits_{x\to\pm\infty}[f(x)-(x-2)]=\lim\limits_{x\to\pm\infty}\left(-\dfrac{1}{x+1}\right)=0 \implies (d):\boxed{y=x-2}$ ជាអាស៊ីមតូតទ្រេត ។
- ទីតាំងធៀប ៖ $f(x)-y_d=-\dfrac{1}{x+1}$ ៖
  - បើ $x>-1 \implies f(x)-y_d<0 \implies (C)$ ស្ថិតនៅខាងក្រោម $(d)$ ។
  - បើ $x<-1 \implies f(x)-y_d>0 \implies (C)$ ស្ថិតនៅខាងលើ $(d)$ ។

ឃ. **ទិសដៅអថេរភាព ៖**

$f'(x)=1-\left(-\dfrac{1}{(x+1)^2}\right)=1+\dfrac{1}{(x+1)^2}$ ។

ដោយ $(x+1)^2>0$ ចំពោះគ្រប់ $x\neq -1$ នាំឱ្យ $f'(x)>1>0,\ \forall x\in D$ ។

**ដូចនេះ $f$ ជាអនុគមន៍កើនដាច់ខាតជានិច្ចលើ $(-\infty,-1)$ និងលើ $(-1,+\infty)$ ហើយគ្មានបរមាធៀបឡើយ ។**

ង. **ផ្ចិតឆ្លុះ និងសង់ក្រាប ៖**

ប្រសព្វនៃអាស៊ីមតូតគឺ $I(-1,-3)$ ។ ផ្ទៀងផ្ទាត់ ៖

$$f(-2-x)+f(x)=-2-x-2-\frac{1}{-2-x+1}+x-2-\frac{1}{x+1}=-6=2(-3)$$

**ដូចនេះ $I(-1,-3)$ ជាផ្ចិតឆ្លុះនៃ $(C)$ ។**

**តារាងអថេរភាព ៖**

| $x$ | $-\infty$ | $-1$ | $+\infty$ |
|---|---|---|---|
| $f'(x)$ | $+$ | ‖ | $+$ |
| $f(x)$ | $-\infty \nearrow +\infty$ | ‖ | $-\infty \nearrow +\infty$ |

ក្រាបតំណាង $(C)$ ៖



## លំហាត់ទី ៤៣

អនុគមន៍ $f$ កំណត់ចំពោះ $x \neq 1$ ដោយ $f(x)=\dfrac{x^2+x-1}{x-1}$ និងមានក្រាប $(C)$ ។

ក. រកចំនួនពិត $a,b,c$ ដែល $f(x)=ax+b+\dfrac{c}{x-1}$ ។

ខ. រកសមីការអាស៊ីមតូតឈរ និងអាស៊ីមតូតទ្រេតនៃ $(C)$ ។

គ. សិក្សាអថេរភាព និងសង់តារាងអថេរភាពនៃ $f$ ។

ឃ. បង្ហាញថាប្រសព្វអាស៊ីមតូត $I(1,3)$ ជាផ្ចិតឆ្លុះនៃ $(C)$ រួចសង់ក្រាប $(C)$ ។

ង. ពិភាក្សាអត្ថិភាព និងសញ្ញានៃឫសសមីការ $x^2+(1-m)x+m-1=0$ តាមតម្លៃ $m$ ។

## ដំណោះស្រាយ

ក. $f(x)=\dfrac{x^2-x+2x-2+1}{x-1}=x+2+\dfrac{1}{x-1} \implies \boxed{a=1,\quad b=2,\quad c=1}$ ។

ខ. **អាស៊ីមតូត ៖**

- $\lim\limits_{x\to 1^-} f(x)=-\infty,\ \lim\limits_{x\to 1^+} f(x)=+\infty \implies \boxed{x=1}$ ជាអាស៊ីមតូតឈរ ។
- $\lim\limits_{x\to\pm\infty}[f(x)-(x+2)]=\lim\limits_{x\to\pm\infty}\dfrac{1}{x-1}=0 \implies (d):\boxed{y=x+2}$ ជាអាស៊ីមតូតទ្រេត ។

គ. **អថេរភាព ៖**

$$f'(x)=1-\frac{1}{(x-1)^2}=\frac{(x-1)^2-1}{(x-1)^2}=\frac{x(x-2)}{(x-1)^2}$$

$f'(x)=0 \iff x=0$ ឬ $x=2$ ៖

- អតិបរមាធៀប ៖ $f(0)=\dfrac{-1}{-1}=\boxed{1}$ ត្រង់ $x=0$ ។
- អប្បបរមាធៀប ៖ $f(2)=2+2+\dfrac{1}{1}=\boxed{5}$ ត្រង់ $x=2$ ។

**តារាងអថេរភាព ៖**

| $x$ | $-\infty$ | | $0$ | | $1$ | | $2$ | | $+\infty$ |
|---|---|---|---|---|---|---|---|---|---|
| $f'(x)$ | | $+$ | $0$ | $-$ | ‖ | $-$ | $0$ | $+$ | |
| $f(x)$ | $-\infty$ ↗ | | $1$ | ↘ $-\infty$ | ‖ | $+\infty$ ↘ | $5$ | ↗ | $+\infty$ |

ឃ. **ផ្ចិតឆ្លុះ និងក្រាប $(C)$ ៖**

$I(1,3)$ ផ្ទៀងផ្ទាត់ ៖ $f(2-x)+f(x)=(2-x+2+\frac{1}{1-x})+(x+2+\frac{1}{x-1})=6=2(3)$ ។

ដូចនេះ $I(1,3)$ ជាផ្ចិតឆ្លុះនៃ $(C)$ ។




ង. **ពិភាក្សាឫសសមីការ ៖**

$x^2+(1-m)x+m-1=0 \iff f(x)=m$ ៖

- $m<1$ ៖ មានឫសពីរផ្សេងគ្នា $x_1<0<x_2<1$ ។
- $m=1$ ៖ មានឫសឌុប $x=0$ ។
- $1<m<5$ ៖ គ្មានឫសក្នុង $\mathbb{R}$ ។
- $m=5$ ៖ មានឫសឌុប $x=2$ ។
- $m>5$ ៖ មានឫសវិជ្ជមានពីរផ្សេងគ្នា $1<x_1<2<x_2$ ។

---

## លំហាត់ទី ៤៤

គេមានអនុគមន៍ $f$ កំណត់លើ $\mathbb{R}\setminus\{2\}$ ដោយ $f(x)=\dfrac{x^2-x-1}{x-2}$ ។

យើងតាង $(C)$ ជាក្រាបរបស់វាលើតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j})$ ។

ក. សិក្សាលីមីតនៃអនុគមន៍ $f$ ត្រង់ $-\infty$ និងត្រង់ $+\infty$ ។

ខ. សិក្សាអថេរភាព និងសង់តារាងអថេរភាពនៃអនុគមន៍ $f$ ។

គ. ១. រកចំនួនពិត $a,b,c$ ដែលគ្រប់ $x\neq 2$ គេបាន $f(x)=ax+b+\dfrac{c}{x-2}$ ។

២. គេតាង $(d)$ ជាបន្ទាត់ដែលមានសមីការ $y=x+1$ ។ បង្ហាញថា $(d)$ ជាអាស៊ីមតូតនៃ $(C)$ ត្រង់ $\pm\infty$ និងសិក្សាទីតាំងធៀបនៃក្រាប $(C)$ ធៀបនឹងបន្ទាត់ $(d)$ ។

៣. សង់ក្រាប $(C)$ និងបន្ទាត់ $(d)$ ។

## ដំណោះស្រាយ

**ក. សិក្សាលីមីតនៃអនុគមន៍ $f$ ត្រង់ $-\infty$ និង $+\infty$ ៖**

- $\lim\limits_{x\to-\infty} f(x) = \lim\limits_{x\to-\infty} \dfrac{x^2\left(1-\frac{1}{x}-\frac{1}{x^2}\right)}{x\left(1-\frac{2}{x}\right)} = \lim\limits_{x\to-\infty} x = -\infty$ ។
- $\lim\limits_{x\to+\infty} f(x) = \lim\limits_{x\to+\infty} \dfrac{x^2\left(1-\frac{1}{x}-\frac{1}{x^2}\right)}{x\left(1-\frac{2}{x}\right)} = \lim\limits_{x\to+\infty} x = +\infty$ ។

ម្យ៉ាងទៀត ត្រង់ $x=2$ ៖

$$\lim_{x\to2^-} f(x) = \lim_{x\to2^-} \frac{x^2-x-1}{x-2} = \frac{1}{0^-} = -\infty, \quad \lim_{x\to2^+} f(x) = \lim_{x\to2^+} \frac{x^2-x-1}{x-2} = \frac{1}{0^+} = +\infty$$

នាំឱ្យបន្ទាត់ដែលមានសមីការ $x=2$ ជាអាស៊ីមតូតឈរនៃក្រាប $(C)$ ។

**ខ. សិក្សាអថេរភាព និងសង់តារាងអថេរភាព ៖**
ចំពោះគ្រប់ $x\in\mathbb{R}\setminus\{2\}$ ៖

$$f'(x) = \frac{(2x-1)(x-2)-(x^2-x-1)(1)}{(x-2)^2} = \frac{x^2-4x+3}{(x-2)^2} = \frac{(x-1)(x-3)}{(x-2)^2}$$

$f'(x)=0 \iff (x-1)(x-3)=0 \iff x=1$ ឬ $x=3$ ។
ដោយ $(x-2)^2>0$ ចំពោះគ្រប់ $x\neq2$ នាំឱ្យសញ្ញានៃ $f'(x)$ អាស្រ័យលើ $(x-1)(x-3)$ ៖

- $f'(x)>0 \iff x\in(-\infty,1)\cup(3,+\infty) \implies f$ ជាអនុគមន៍កើនដាច់ខាត ។
- $f'(x)<0 \iff x\in(1,2)\cup(2,3) \implies f$ ជាអនុគមន៍ចុះដាច់ខាត ។
- ត្រង់ $x=1$, $f$ មានតម្លៃអតិបរមាធៀបគឺ $f(1)=\dfrac{1^2-1-1}{1-2}=\boxed{1}$ ។
- ត្រង់ $x=3$, $f$ មានតម្លៃអប្បបរមាធៀបគឺ $f(3)=\dfrac{3^2-3-1}{3-2}=\boxed{5}$ ។

**តារាងអថេរភាព ៖**

| $x$ | $-\infty$ | | $1$ | | $2$ | | $3$ | | $+\infty$ |
|---|---|---|---|---|---|---|---|---|---|
| $f'(x)$ | | $+$ | $0$ | $-$ | ‖ | $-$ | $0$ | $+$ | |
| $f(x)$ | $-\infty$ ↗ | | $1$ | ↘ $-\infty$ | ‖ | $+\infty$ ↘ | $5$ | ↗ | $+\infty$ |

**គ. ១. រកចំនួនពិត $a,b,c$ ៖**
ធ្វើវិធីចែកពហុធាភាគយក $x^2-x-1$ នឹងភាគបែង $x-2$ ៖

$$x^2-x-1=(x+1)(x-2)+1 \implies f(x)=x+1+\frac{1}{x-2}$$

ដូចនេះ $\boxed{a=1,\quad b=1,\quad c=1}$ ។

២. **អាស៊ីមតូតទ្រេត $(d)$ និងទីតាំងធៀប ៖**
គណនាលីមីតផលដក ៖

$$\lim_{x\to\pm\infty}[f(x)-(x+1)] = \lim_{x\to\pm\infty}\frac{1}{x-2} = 0$$

ដូចនេះ បន្ទាត់ $(d): y = x+1$ ជាសមីការអាស៊ីមតូតទ្រេតនៃក្រាប $(C)$ ត្រង់ $-\infty$ និង $+\infty$ ។
ទីតាំងធៀបនៃ $(C)$ ធៀបនឹង $(d)$ តាមសញ្ញានៃ $f(x)-y_d = \frac{1}{x-2}$ ៖

- $x \in (2,+\infty) \implies \frac{1}{x-2} > 0 \implies (C)$ ស្ថិតនៅខាងលើអាស៊ីមតូត $(d)$ ។
- $x \in (-\infty,2) \implies \frac{1}{x-2} < 0 \implies (C)$ ស្ថិតនៅខាងក្រោមអាស៊ីមតូត $(d)$ ។

៣. **សង់ក្រាប $(C)$ និងបន្ទាត់ $(d)$ ៖**




**លំហាត់ទី ៤៥**

គេមានអនុគមន៍ $f$ ដែល $f(x) = \frac{x^2-x-3}{x+1}$ និងតាង $(C)$ ជាក្រាបនៃអនុគមន៍ $f$ ។

ក. រកដែនកំណត់នៃអនុគមន៍ $f$ ។

ខ. បង្ហាញថា $f(x) = x-2-\frac{1}{x+1}$ ។

គ. បង្ហាញថាបន្ទាត់ដែលមានសមីការ $y = x-2$ ជាអាស៊ីមតូតទ្រេតនៃក្រាប $(C)$ ។

ឃ. សិក្សាអថេរភាព និងសង់ក្រាបនៃ $f$ ។

**ដំណោះស្រាយ**

**ក. ដែនកំណត់នៃអនុគមន៍ $f$ ៖**
អនុគមន៍ $f$ មានន័យកាលណា $x+1\neq 0 \iff x\neq -1$ ។
ដូចនេះ ដែនកំណត់គឺ $\boxed{D=\mathbb{R}\setminus\{-1\}}$ ។

**ខ. បង្ហាញថា $f(x)=x-2-\dfrac{1}{x+1}$ ៖**
តម្រូវភាគបែង ៖

$$x-2-\frac{1}{x+1}=\frac{(x-2)(x+1)-1}{x+1}=\frac{x^2-x-2-1}{x+1}=\frac{x^2-x-3}{x+1}=f(x)$$

ដូចនេះ $f(x)=x-2-\dfrac{1}{x+1}$ ពិតប្រាកដមែន ។

**គ. បង្ហាញថាបន្ទាត់ $y=x-2$ ជាអាស៊ីមតូតទ្រេត ៖**
គណនាលីមីតផលដក ៖

$$\lim_{x\to\pm\infty}[f(x)-(x-2)]=\lim_{x\to\pm\infty}\left(-\frac{1}{x+1}\right)=0$$

ដូចនេះ បន្ទាត់ដែលមានសមីការ $\boxed{y=x-2}$ ជាអាស៊ីមតូតទ្រេតនៃក្រាប $(C)$ ។

**ឃ. សិក្សាអថេរភាព និងសង់ក្រាបនៃ $f$ ៖**

- **លីមីត និងអាស៊ីមតូតឈរ ៖** $\lim\limits_{x\to\pm\infty} f(x)=\pm\infty$ ។
  $\lim\limits_{x\to -1^-} f(x)=+\infty$ និង $\lim\limits_{x\to -1^+} f(x)=-\infty \Longrightarrow$ បន្ទាត់ដែលមានសមីការ $\boxed{x=-1}$ ជាអាស៊ីមតូតឈរនៃ $(C)$ ។
- **ដេរីវេ ៖** ចំពោះគ្រប់ $x\neq -1$ ៖

$$f'(x)=1-\left(-\frac{1}{(x+1)^2}\right)=1+\frac{1}{(x+1)^2}>0,\quad \forall x\in\mathbb{R}\setminus\{-1\}$$

នាំឱ្យអនុគមន៍ $f$ កើនជានិច្ចលើចន្លោះ $(-\infty,-1)$ និង $(-1,+\infty)$ ព្រមទាំងគ្មានតម្លៃបរមាធៀបឡើយ ។

**តារាងអថេរភាព ៖**

| $x$ | $-\infty$ | $-1$ | $+\infty$ |
|---|---|---|---|
| $f'(x)$ | $+$ | ‖ | $+$ |
| $f(x)$ | $-\infty \nearrow +\infty$ | ‖ | $-\infty \nearrow +\infty$ |

**ក្រាបតំណាង $(C)$ ៖**



## លំហាត់ទី ៤៦

គេមានអនុគមន៍ $f(x)=\frac{(x+2)(x-2)}{1-x}=\frac{x^2-4}{1-x}$ មានក្រាប $(C)$ ។

ក. រកដែនកំណត់នៃអនុគមន៍ $f$ ។

ខ. ចែកពហុធាដើម្បីសរសេរ $f(x)$ ជាទម្រង់ $ax+b+\frac{c}{1-x}$ ។

គ. រកសមីការអាស៊ីមតូតឈរ និងអាស៊ីមតូតទ្រេតនៃ $(C)$ ។

ឃ. ស្រាយបញ្ជាក់ថា $f$ ជាអនុគមន៍ចុះដាច់ខាតជានិច្ចលើដែនកំណត់របស់វា ។

ង. សង់តារាងអថេរភាព និងក្រាប $(C)$ ។

## ដំណោះស្រាយ

ក. ដែនកំណត់ ៖ $1-x\neq 0 \iff x\neq 1 \implies \boxed{D=\mathbb{R}\setminus\{1\}}$ ។

ខ. $f(x)=\frac{-x^2+4}{x-1}=\frac{-(x^2-1)+3}{x-1}=-(x+1)+\frac{3}{x-1}=\boxed{-x-1-\frac{3}{1-x}}$ ។

គ. អាស៊ីមតូត ៖

- $\lim_{x\to 1^-} f(x)=-\infty,\ \lim_{x\to 1^+} f(x)=+\infty \implies \boxed{x=1}$ ជាអាស៊ីមតូតឈរ ។
- $\lim_{x\to\pm\infty}[f(x)-(-x-1)]=0 \implies (d):\boxed{y=-x-1}$ ជាអាស៊ីមតូតទ្រេត ។

ឃ. ដេរីវេ ៖

$$f'(x)=-1-\frac{3}{(x-1)^2}=-\left(1+\frac{3}{(x-1)^2}\right)<-1<0,\quad \forall x\neq 1$$

ដូចនេះ $f$ ជាអនុគមន៍ចុះដាច់ខាតលើ $(-\infty,1)$ និងលើ $(1,+\infty)$ ជានិច្ច និងគ្មានបរមាធៀបឡើយ ។

ង. តារាងអថេរភាព ៖

| $x$ | $-\infty$ | | $1$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | | $-$ | ‖ | $-$ | |
| $f(x)$ | $+\infty$ | ↘ | $-\infty$ ‖ $+\infty$ | ↘ | $-\infty$ |




---

## លំហាត់ទី ៤៧

គេឱ្យអនុគមន៍ $f(x)=\dfrac{x^2+x+4}{x+1}$ និងមានក្រាប $(C)$ ។

ក. រកដែនកំណត់ និងដេរីវេ $f'(x)$ ។

ខ. រកសមីការអាស៊ីមតូតឈរ និងអាស៊ីមតូតទ្រេតនៃក្រាប $(C)$ ។

គ. រកតម្លៃបរមាធៀប និងសង់តារាងអថេរភាព ។

ឃ. បង្ហាញថា $I(-1,-1)$ ជាផ្ចិតឆ្លុះនៃ $(C)$ និងសង់ក្រាប $(C)$ ។

## ដំណោះស្រាយ

ក. ដែនកំណត់ ៖ $\boxed{D=\mathbb{R}\setminus\{-1\}}$ ។

សរសេរ $f(x)=x+\dfrac{4}{x+1}$ នាំឱ្យ ៖

$$f'(x)=1-\frac{4}{(x+1)^2}=\frac{(x+1)^2-4}{(x+1)^2}=\frac{(x+3)(x-1)}{(x+1)^2}$$

ខ. អាស៊ីមតូត ៖

- $\lim\limits_{x\to -1^{\pm}} f(x)=\pm\infty \implies \boxed{x=-1}$ ជាអាស៊ីមតូតឈរ ។
- $\lim\limits_{x\to\pm\infty}[f(x)-x]=\lim\limits_{x\to\pm\infty}\dfrac{4}{x+1}=0 \implies (d):\boxed{y=x}$ ជាអាស៊ីមតូតទ្រេត ។

ⓖ. $f'(x)=0 \iff x=-3$ ឬ $x=1$ ៖

- អតិបរមាធៀប ៖ $f(-3)=-3+\dfrac{4}{-2}=\boxed{-5}$ ត្រង់ $x=-3$ ។
- អប្បបរមាធៀប ៖ $f(1)=1+\dfrac{4}{2}=\boxed{3}$ ត្រង់ $x=1$ ។

**តារាងអថេរភាព ៖**

| $x$ | $-\infty$ | | $-3$ | | $-1$ | | $1$ | | $+\infty$ |
|---|---|---|---|---|---|---|---|---|---|
| $f'(x)$ | | $+$ | $0$ | $-$ | ‖ | $-$ | $0$ | $+$ | |
| $f(x)$ | $-\infty$ | ↗ | $-5$ | ↘ $-\infty$ | ‖ | $+\infty$ ↘ | $3$ | ↗ | $+\infty$ |

ⓦ. ផ្ចិតឆ្លុះ ៖ $f(-2-x)+f(x)=(-2-x+\frac{4}{-1-x})+(x+\frac{4}{x+1})=-2=2(-1) \implies \boxed{I(-1,-1)}$ ជាផ្ចិតឆ្លុះ ។




## លំហាត់ទី ៤៨

គេមានអនុគមន៍ $f(x)=\dfrac{x^2+3x+6}{x+2}$ កំណត់ចំពោះគ្រប់ $x\neq -2$ និងមានខ្សែកោង $(C)$ ។

ⓚ. សិក្សាអថេរភាព និងរកសមីការអាស៊ីមតូតឈរ និងអាស៊ីមតូតទ្រេតនៃ $(C)$ ។

ខ. រកសមីការបន្ទាត់ប៉ះ $(T)$ ទៅនឹងក្រាប $(C)$ ត្រង់ចំណុចដែលមានអាប់ស៊ីស $x_0 = 1$ ។ រកកូអរដោនេចំណុចប្រសព្វ $A$ រវាង $(T)$ និងអាស៊ីមតូតទ្រេត ។

គ. គណនាផ្ទៃក្រឡា $S$ នៃរូបប្លង់ខណ្ឌដោយក្រាប $(C)$, អាស៊ីមតូតទ្រេត និងបន្ទាត់ឈរ $x=1, x=2$ ។

## ដំណោះស្រាយ

**ក. អថេរភាព និងអាស៊ីមតូត ៖**

$f(x) = x+1+\dfrac{4}{x+2}$ ។

$\lim\limits_{x\to -2^{\pm}} f(x) = \pm\infty \implies \boxed{x=-2}$ ជាអាស៊ីមតូតឈរ ។

$\lim\limits_{x\to\pm\infty} [f(x)-(x+1)] = 0 \implies (d): \boxed{y=x+1}$ ជាអាស៊ីមតូតទ្រេត ។

$f'(x) = 1-\dfrac{4}{(x+2)^2} = \dfrac{x(x+4)}{(x+2)^2}$ ។ $f'(x)=0 \iff x=-4$ ឬ $x=0$ ៖

- អតិបរមាធៀប ៖ $f(-4) = -4+1+\dfrac{4}{-2} = \boxed{-5}$ ត្រង់ $x=-4$ ។
- អប្បបរមាធៀប ៖ $f(0) = 0+1+\dfrac{4}{2} = \boxed{3}$ ត្រង់ $x=0$ ។

**តារាងអថេរភាព ៖**

| $x$ | $-\infty$ | | $-4$ | | $-2$ | | $0$ | | $+\infty$ |
|---|---|---|---|---|---|---|---|---|---|
| $f'(x)$ | | $+$ | $0$ | $-$ | ‖ | $-$ | $0$ | $+$ | |
| $f(x)$ | $-\infty$ | ↗ | $-5$ | ↘ | $-\infty$ ‖ $+\infty$ | ↘ | $3$ | ↗ | $+\infty$ |

**ខ. សមីការបន្ទាត់ប៉ះត្រង់ $x_0=1$ និងចំណុច $A$ ៖**

គណនា $f(1) = 1+1+\dfrac{4}{3} = \dfrac{10}{3}$ និង $f'(1) = 1-\dfrac{4}{9} = \dfrac{5}{9}$ ។

សមីការបន្ទាត់ប៉ះ $(T)$ ៖

$$y = f'(1)(x-1)+f(1) = \frac{5}{9}(x-1)+\frac{10}{3} = \frac{5}{9}x-\frac{5}{9}+\frac{30}{9} \implies \boxed{y=\frac{5}{9}x+\frac{25}{9}}$$

រកប្រសព្វ $A$ ជាមួយអាស៊ីមតូតទ្រេត $y=x+1$ ៖

$$x+1 = \frac{5}{9}x+\frac{25}{9} \iff \frac{4}{9}x = \frac{16}{9} \implies x=4 \implies y=4+1=5$$

**ដូចនេះ ចំណុចប្រសព្វគឺ** $\boxed{A(4,5)}$ ។

**គ. គណនាផ្ទៃក្រឡា $S$ ៖**

ចំពោះ $x\in[1,2]$ ក្រាប $(C)$ នៅខាងលើអាស៊ីមតូតទ្រេត $(d)$ ៖

$$S = \int_1^2 [f(x)-(x+1)]\,dx = \int_1^2 \frac{4}{x+2}\,dx = 4[\ln|x+2|]_1^2 = 4(\ln 4-\ln 3) = \boxed{4\ln\frac{4}{3}} \approx 1.15 \text{ (ឯកតាផ្ទៃ)}$$

## លំហាត់ទី ៤៩

គេមានអនុគមន៍ $f$ កំណត់ដោយ $y=f(x)=\dfrac{x^2-5x+7}{x-2}$ មានក្រាប $(C)$ ។

ក. រកដែនកំណត់ និងគណនាលីមីតត្រង់ចុងដែនកំណត់ ។

ខ. កំណត់ចំនួនពិត $a,b,c$ ដែល $f(x)=ax+b+\dfrac{c}{x-2}$ ។

គ. រកសមីការអាស៊ីមតូតឈរ និងអាស៊ីមតូតទ្រេត ។

ឃ. សិក្សាអថេរភាព សង់តារាងអថេរភាព និងក្រាប $(C)$ ។

## ដំណោះស្រាយ

ក. ដែនកំណត់ ៖ $\boxed{D=\mathbb{R}\setminus\{2\}}$ ។

លីមីត ៖ $\lim\limits_{x\to\pm\infty} f(x)=\pm\infty,\ \lim\limits_{x\to 2^-} f(x)=-\infty,\ \lim\limits_{x\to 2^+} f(x)=+\infty$ ។

ខ. $f(x)=\dfrac{x^2-2x-3x+6+1}{x-2}=x-3+\dfrac{1}{x-2}\implies \boxed{a=1,\ b=-3,\ c=1}$ ។

គ. អាស៊ីមតូតឈរ ៖ $\boxed{x=2}$ ; អាស៊ីមតូតទ្រេត ៖ $\boxed{y=x-3}$ ។

ឃ. $f'(x)=1-\dfrac{1}{(x-2)^2}=\dfrac{(x-1)(x-3)}{(x-2)^2}$ ៖

- អតិបរមាធៀប ៖ $f(1)=1-3-1=\boxed{-3}$ ត្រង់ $x=1$ ។
- អប្បបរមាធៀប ៖ $f(3)=3-3+1=\boxed{1}$ ត្រង់ $x=3$ ។

**តារាងអថេរភាព ៖**

| $x$ | $-\infty$ | | $1$ | | $2$ | | $3$ | | $+\infty$ |
|---|---|---|---|---|---|---|---|---|---|
| $f'(x)$ | | $+$ | $0$ | $-$ | ‖ | $-$ | $0$ | $+$ | |
| $f(x)$ | $-\infty$ | ↗ | $-3$ | ↘ | $-\infty$ ‖ $+\infty$ | ↘ | $1$ | ↗ | $+\infty$ |




## លំហាត់ទី ៥០

គេឱ្យអនុគមន៍ $f$ កំណត់គ្រប់ $x \neq 2$ ដោយ $f(x)=\dfrac{x^2-3x-4}{x-2}$ មានក្រាប $(C)$ ។

ក. រកសមីការអាស៊ីមតូតឈរ និងអាស៊ីមតូតទ្រេតនៃ $(C)$ ។

ខ. ស្រាយបញ្ជាក់ថា $f$ ជាអនុគមន៍កើនដាច់ខាតលើដែនកំណត់របស់វាជានិច្ច ។

គ. រកចំណុចប្រសព្វរវាង $(C)$ ជាមួយអ័ក្សកូអរដោនេ និងផ្ចិតឆ្លុះ $I$ ។

ឃ. សង់តារាងអថេរភាព និងសង់ក្រាប $(C)$ ។

## ដំណោះស្រាយ

ក. $f(x)=\dfrac{x^2-2x-x+2-6}{x-2}=x-1-\dfrac{6}{x-2}$ ៖

- $\lim\limits_{x\to 2^-} f(x)=+\infty,\ \lim\limits_{x\to 2^+} f(x)=-\infty \implies \boxed{x=2}$ ជាអាស៊ីមតូតឈរ ។
- $\lim\limits_{x\to\pm\infty}[f(x)-(x-1)]=0 \implies (d):\boxed{y=x-1}$ ជាអាស៊ីមតូតទ្រេត ។

ខ. $f'(x)=1+\dfrac{6}{(x-2)^2}>1>0, \forall x\neq 2$ នាំឱ្យ $f$ ជាអនុគមន៍កើនដាច់ខាតលើ $(-\infty,2)$ និងលើ $(2,+\infty)$ ជានិច្ច និងគ្មានបរមាធៀបឡើយ ។

គ. ប្រសព្វអ័ក្ស ៖

- ប្រសព្វ $(Oy)$ ៖ $x=0 \implies y=\dfrac{-4}{-2}=2$ គឺចំណុច $(0,2)$ ។
- ប្រសព្វ $(Ox)$ ៖ $y=0 \iff x^2-3x-4=0 \iff (x-4)(x+1)=0 \implies x=-1, x=4$ ។

ផ្ចិតឆ្លុះ ៖ ប្រសព្វអាស៊ីមតូតគឺ $\boxed{I(2,1)}$ ។

**តារាងអថេរភាព ៖**

| $x$ | $-\infty$ | $2$ | $+\infty$ |
|---|---|---|---|
| $f'(x)$ | $+$ | ‖ | $+$ |
| $f(x)$ | $-\infty \nearrow +\infty$ | ‖ | $-\infty \nearrow +\infty$ |




## លំហាត់ទី ៥១

គេមានអនុគមន៍ $f(x)=\dfrac{x^2-4}{x-1}$ មានក្រាប $(C)$ ។

ក. រកដែនកំណត់ និងអាស៊ីមតូតឈរ, អាស៊ីមតូតទ្រេតនៃ $(C)$ ។

ខ. ស្រាយបញ្ជាក់ថា $f$ ជាអនុគមន៍កើនជានិច្ចលើដែនកំណត់របស់វា ។

គ. រកចំណុចកាត់អ័ក្ស និងផ្ចិតឆ្លុះ $I(1,2)$ រួចសង់ក្រាប $(C)$ ។

**ដំណោះស្រាយ**

ក. ដែនកំណត់ ៖ $\boxed{D=\mathbb{R}\setminus\{1\}}$ ។

$f(x)=x+1-\dfrac{3}{x-1}$ នាំឱ្យ ៖

- $\lim\limits_{x\to1^-} f(x)=+\infty,\ \lim\limits_{x\to1^+} f(x)=-\infty \implies \boxed{x=1}$ ជាអាស៊ីមតូតឈរ ។
- $\lim\limits_{x\to\pm\infty}[f(x)-(x+1)]=0 \implies \boxed{y=x+1}$ ជាអាស៊ីមតូតទ្រេត ។

ខ. $f'(x)=1+\dfrac{3}{(x-1)^2}=\dfrac{x^2-2x+4}{(x-1)^2}>0, \forall x\neq1$ នាំឱ្យ $f$ កើនជានិច្ចលើ $(-\infty,1)$ និងលើ $(1,+\infty)$ ។

គ. កាត់អ័ក្ស ៖ $(0,4),(2,0),(-2,0)$ ។ ផ្ចិតឆ្លុះ ៖ $I(1,2)$ ។




---

## លំហាត់ទី ៥២

គេមានអនុគមន៍ $f(x)=\dfrac{x^2-x+9}{x-1}$ កំណត់លើ $\mathbb{R}\setminus\{1\}$ និងមានក្រាប $(C)$ ។

ក. រកសមីការអាស៊ីមតូតឈរ និងអាស៊ីមតូតទ្រេតនៃ $(C)$ ។

ខ. សិក្សាអថេរភាព និងរកតម្លៃបរមាធៀប ។

គ. សង់តារាងអថេរភាព និងក្រាប $(C)$ ។

## ដំណោះស្រាយ

ក. $f(x)=\dfrac{x(x-1)+9}{x-1}=x+\dfrac{9}{x-1}$ ៖

- $\lim_{x\to 1^{\pm}} f(x) = \pm\infty \implies \boxed{x=1}$ ជាអាស៊ីមតូតឈរ ។
- $\lim_{x\to \pm\infty} [f(x)-x] = 0 \implies (d): \boxed{y=x}$ ជាអាស៊ីមតូតទ្រេត ។

ខ. $f'(x) = 1 - \dfrac{9}{(x-1)^2} = \dfrac{(x-1)^2-9}{(x-1)^2} = \dfrac{(x+2)(x-4)}{(x-1)^2}$ ៖

- អតិបរមាធៀប ៖ $f(-2) = -2 + \dfrac{9}{-3} = \boxed{-5}$ ត្រង់ $x=-2$ ។
- អប្បបរមាធៀប ៖ $f(4) = 4 + \dfrac{9}{3} = \boxed{7}$ ត្រង់ $x=4$ ។

**តារាងអថេរភាព ៖**

| $x$ | $-\infty$ | | $-2$ | | $1$ | | $4$ | | $+\infty$ |
|---|---|---|---|---|---|---|---|---|---|
| $f'(x)$ | | $+$ | $0$ | $-$ | ‖ | $-$ | $0$ | $+$ | |
| $f(x)$ | $-\infty$ | ↗ | $-5$ | ↘ | $-\infty$ ‖ $+\infty$ | ↘ | $7$ | ↗ | $+\infty$ |

គ. ផ្ចិតឆ្លុះ $I(1,1)$ ។ ក្រាបកាត់អ័ក្ស $(Oy)$ ត្រង់ $(0,-9)$ ។



## លំហាត់ទី ៥៣

គេមានអនុគមន៍ $f(x)=\dfrac{x^2+3x-3}{x-1}$ មានក្រាប $(C)$ ។

ក. រកដែនកំណត់ និងអាស៊ីមតូតឈរ, អាស៊ីមតូតទ្រេតនៃ $(C)$ ។

ខ. សិក្សាអថេរភាព និងរកតម្លៃបរមាធៀប ។

គ. សិក្សាទីតាំងធៀបនៃក្រាប $(C)$ ធៀបនឹងអាស៊ីមតូតទ្រេត និងសង់ក្រាប $(C)$ ។

## ដំណោះស្រាយ

ក. ដែនកំណត់ ៖ $\boxed{D=\mathbb{R}\setminus\{1\}}$ ។

$f(x)=x+4+\dfrac{1}{x-1}$ នាំឱ្យ ៖

- $\lim\limits_{x\to 1^{\pm}} f(x)=\pm\infty \implies \boxed{x=1}$ ជាអាស៊ីមតូតឈរ ។
- $\lim\limits_{x\to\pm\infty}[f(x)-(x+4)]=0 \implies (d):\boxed{y=x+4}$ ជាអាស៊ីមតូតទ្រេត ។

ខ. $f'(x)=1-\dfrac{1}{(x-1)^2}=\dfrac{x(x-2)}{(x-1)^2}$ ៖

- អតិបរមាធៀប ៖ $f(0)=0+4-1=\boxed{3}$ ត្រង់ $x=0$ ។
- អប្បបរមាធៀប ៖ $f(2)=2+4+1=\boxed{7}$ ត្រង់ $x=2$ ។

**តារាងអថេរភាព ៖**

| $x$ | $-\infty$ | | $0$ | | $1$ | | $2$ | | $+\infty$ |
|---|---|---|---|---|---|---|---|---|---|
| $f'(x)$ | | $+$ | $0$ | $-$ | \|\| | $-$ | $0$ | $+$ | |
| $f(x)$ | $-\infty$ | ↗ | $3$ | ↘ | $-\infty$ \|\| $+\infty$ | ↘ | $7$ | ↗ | $+\infty$ |

គ. $f(x)-(x+4)=\dfrac{1}{x-1}$ ៖

- លើ $(1,+\infty)$ ៖ $(C)$ ស្ថិតនៅខាងលើអាស៊ីមតូតទ្រេត ។
- លើ $(-\infty,1)$ ៖ $(C)$ ស្ថិតនៅខាងក្រោមអាស៊ីមតូតទ្រេត ។

ផ្ចិតឆ្លុះ ៖ $I(1,5)$ ។

មេរៀនទី ៤ ផ្នែកដំណោះស្រាយ




## លំហាត់ទី ៥៤

គេឱ្យអនុគមន៍ $y = f(x) = \dfrac{x^2 - 4x + 8}{x-2}$ មានក្រាប $(C)$ ក្នុងតម្រុយអរតូណរម៉ាល់ $(O, \vec{i}, \vec{j})$ ។

ក. រកសមីការអាស៊ីមតូតឈរ និងអាស៊ីមតូតទ្រេតនៃ $(C)$ ។

ខ. គណនាដេរីវេ $f'(x)$ រកបរមាធៀប និងសង់តារាងអថេរភាព ។

គ. រកកូអរដោនេចំណុចប្រសព្វរវាង $(C)$ ជាមួយអ័ក្ស $(Oy)$ និងផ្ចិតឆ្លុះ $I$ នៃក្រាប $(C)$ ។

ឃ. សរសេរសមីការបន្ទាត់ប៉ះ $(T_1)$ និង $(T_2)$ ទៅនឹងក្រាប $(C)$ ដែលស្របនឹងបន្ទាត់ $(\Delta): y = -3x + 1$ ។

ង. សង់ក្រាប $(C)$ និងបន្ទាត់ប៉ះទាំងពីរក្នុងតម្រុយតែមួយ ។

## ដំណោះស្រាយ

ក. **អាស៊ីមតូត ៖**

ដែនកំណត់ ៖ $D = \mathbb{R} \setminus \{2\}$ ។ សរសេរ $f(x) = x - 2 + \dfrac{4}{x-2}$ ៖

- $\lim\limits_{x\to 2^-} f(x) = -\infty,\ \lim\limits_{x\to 2^+} f(x) = +\infty \implies \boxed{x=2}$ ជាសមីការអាស៊ីមតូតឈរ ។
- $\lim\limits_{x\to\pm\infty} [f(x) - (x-2)] = \lim\limits_{x\to\pm\infty} \dfrac{4}{x-2} = 0 \implies (d): \boxed{y = x-2}$ ជាសមីការអាស៊ីមតូតទ្រេត ។

ខ. **ដេរីវេ និងអថេរភាព ៖**

$f'(x) = 1 - \dfrac{4}{(x-2)^2} = \dfrac{(x-2)^2 - 4}{(x-2)^2} = \dfrac{x(x-4)}{(x-2)^2}$ ។

$f'(x) = 0 \iff x = 0$ ឬ $x = 4$ ៖

- អតិបរមាធៀប ៖ $f(0)=0-2+\frac{4}{-2}=\boxed{-4}$ ត្រង់ $x=0$ ។
- អប្បបរមាធៀប ៖ $f(4)=4-2+\frac{4}{2}=\boxed{4}$ ត្រង់ $x=4$ ។

**តារាងអថេរភាព ៖**

| $x$ | $-\infty$ | | 0 | | 2 | | 4 | | $+\infty$ |
|---|---|---|---|---|---|---|---|---|---|
| $f'(x)$ | | $+$ | 0 | $-$ | ‖ | $-$ | 0 | $+$ | |
| $f(x)$ | $-\infty$ | ↗ | $-4$ | ↘ | $-\infty$ ‖ $+\infty$ | ↘ | 4 | ↗ | $+\infty$ |

**គ. ចំណុចកាត់អ័ក្ស និងផ្ចិតឆ្លុះ ៖**

- ប្រសព្វ $(Oy)$ ៖ $x=0 \implies y=-4$ គឺចំណុច $(0,-4)$ ។
- ផ្ចិតឆ្លុះ ៖ ចំណុចប្រសព្វរវាងអាស៊ីមតូតឈរ និងអាស៊ីមតូតទ្រេតគឺ $\boxed{I(2,0)}$ ។
  ពិតណាស់ ៖ $f(4-x)+f(x)=(2-x-\frac{4}{x-2})+(x-2+\frac{4}{x-2})=0=2(0)$ ។

**ឃ. សមីការបន្ទាត់ប៉ះស្របនឹង $(\Delta): y=-3x+1$ ៖**
មេគុណប្រាប់ទិសនៃបន្ទាត់ប៉ះត្រូវស្មើនឹង $-3$ ៖

$$f'(x_0)=-3 \iff 1-\frac{4}{(x_0-2)^2}=-3 \iff \frac{4}{(x_0-2)^2}=4 \iff (x_0-2)^2=1 \iff x_0=1 \text{ ឬ } x_0=3$$

- ចំពោះ $x_0=1 \implies y_0=f(1)=1-2+\frac{4}{-1}=-5$ ៖

$$(T_1): y=-3(x-1)-5 \implies \boxed{(T_1): y=-3x-2}$$

- ចំពោះ $x_0=3 \implies y_0=f(3)=3-2+\frac{4}{1}=5$ ៖

$$(T_2): y=-3(x-3)+5 \implies \boxed{(T_2): y=-3x+14}$$

**ង. ក្រាបតំណាង $(C)$ និងបន្ទាត់ប៉ះ ៖**




## លំហាត់ទី ៥៥

គេឱ្យអនុគមន៍ $y = f_m(x) = \dfrac{mx^2+3mx+2m+1}{x+2}$ $(m \neq 0)$ មានក្រាប $(C_m)$ ។

ក. បង្ហាញថាក្រាប $(C_m)$ តែងតែមានអាស៊ីមតូតឈរមួយជានិច្ចគ្រប់តម្លៃ $m$ ។

ខ. បង្ហាញថាសមីការអាស៊ីមតូតទ្រេតនៃ $(C_m)$ អាចសរសេរជា $y = m(x+1)$ រួចបង្ហាញថាអាស៊ីមតូតទ្រេតនេះកាត់តាមចំណុចនឹងមួយជានិច្ចគ្រប់តម្លៃ $m$ ។

គ. ចំពោះ $m = 1$ សិក្សាអថេរភាព និងសង់ក្រាប $(C_1)$ ។

## ដំណោះស្រាយ

ក. ដែនកំណត់ ៖ $D = \mathbb{R} \setminus \{-2\}$ ។
ភាគបែងស្មើសូន្យត្រង់ $x = -2$ ។ ជំនួស $x = -2$ ចូលភាគយក ៖

$$m(-2)^2 + 3m(-2) + 2m + 1 = 4m - 6m + 2m + 1 = 1 \neq 0, \quad \forall m$$

ដោយភាគយកស្មើ $1 \neq 0$ ជានិច្ច នោះ $\lim\limits_{x \to -2^{\pm}} f_m(x) = \pm\infty$ គ្រប់តម្លៃ $m$ ។

**ដូចនេះ ក្រាប $(C_m)$ តែងតែមានបន្ទាត់ $\boxed{x = -2}$ ជាអាស៊ីមតូតឈរជានិច្ចគ្រប់ $m$ ។**

ខ. ចែកពហុធាភាគយកនឹងភាគបែង ៖

$$mx^2 + 3mx + 2m + 1 = (mx + m)(x + 2) + 1$$

នាំឱ្យ ៖

$$f_m(x) = mx + m + \frac{1}{x+2} = m(x+1) + \frac{1}{x+2}$$

ដោយ $\lim_{x\to\pm\infty}[f_m(x) - m(x+1)] = \lim_{x\to\pm\infty}\frac{1}{x+2} = 0$ នាំឱ្យបន្ទាត់ $(d_m)$: $\boxed{y = m(x+1)}$ ជាអាស៊ីមតូតទ្រេតនៃ $(C_m)$ ។

ពិនិត្យចំណុចនឹង ៖ ឱ្យ $x+1=0 \iff x=-1 \implies y = m(0) = 0$ (ឯករាជ្យពី $m$) ។

**ដូចនេះ អាស៊ីមតូតទ្រេត $(d_m)$ តែងតែកាត់តាមចំណុចនឹង $\boxed{A(-1,0)}$ ជានិច្ចគ្រប់តម្លៃ $m$ ។**

ⓒ. **ចំពោះ $m=1$ ៖**

អនុគមន៍ក្លាយជា $f(x) = x+1+\frac{1}{x+2} = \frac{x^2+3x+3}{x+2}$ ៖

- អាស៊ីមតូត ៖ $x=-2$ (ឈរ) និង $y=x+1$ (ទ្រេត) ។
- ដេរីវេ ៖ $f'(x) = 1 - \frac{1}{(x+2)^2} = \frac{(x+2)^2-1}{(x+2)^2} = \frac{(x+1)(x+3)}{(x+2)^2}$ ៖
  - អតិបរមាធៀប ៖ $f(-3) = -3+1-1 = \boxed{-3}$ ត្រង់ $x=-3$ ។
  - អប្បបរមាធៀប ៖ $f(-1) = -1+1+1 = \boxed{1}$ ត្រង់ $x=-1$ ។
- ផ្ចិតឆ្លុះ ៖ $I(-2,-1)$ ។

**តារាងអថេរភាព** $(m=1)$ ៖

| $x$ | $-\infty$ | | $-3$ | | $-2$ | | $-1$ | | $+\infty$ |
|---|---|---|---|---|---|---|---|---|---|
| $f'(x)$ | | $+$ | $0$ | $-$ | ‖ | $-$ | $0$ | $+$ | |
| $f(x)$ | $-\infty$ | ↗ | $-3$ | ↘ $-\infty$ | ‖ $+\infty$ | ↘ | $1$ | ↗ | $+\infty$ |



## លំហាត់ទី ៥៦

គេឱ្យអនុគមន៍ $f(x)=\dfrac{x^2+2x-2}{x-1}$ មានក្រាប $(C)$ និងមានបន្ទាត់ពីរ $(L_1): y=2x+1$ និង $(L_2): y=2x-7$ ។

ក. រកសមីការអាស៊ីមតូតឈរ និងអាស៊ីមតូតទ្រេតនៃ $(C)$ ។

ខ. សិក្សាអថេរភាព សង់តារាងអថេរភាព និងក្រាប $(C)$ ។

គ. រកកូអរដោនេចំណុចប្រសព្វរវាងក្រាប $(C)$ ជាមួយបន្ទាត់ $(L_1)$ និង $(L_2)$ ។

## ដំណោះស្រាយ

ក. ដែនកំណត់ ៖ $\boxed{D=\mathbb{R}\setminus\{1\}}$ ។

បំបែក ៖ $f(x)=x+3+\dfrac{1}{x-1}$ ៖

- $\lim\limits_{x\to 1^\pm} f(x)=\pm\infty \implies \boxed{x=1}$ ជាអាស៊ីមតូតឈរ ។
- $\lim\limits_{x\to\pm\infty}[f(x)-(x+3)]=0 \implies (d): \boxed{y=x+3}$ ជាអាស៊ីមតូតទ្រេត ។

ខ. ដេរីវេ ៖ $f'(x)=1-\dfrac{1}{(x-1)^2}=\dfrac{x(x-2)}{(x-1)^2}$ ៖

- អតិបរមាធៀប ៖ $f(0)=\dfrac{-2}{-1}=\boxed{2}$ ត្រង់ $x=0$ ។
- អប្បបរមាធៀប ៖ $f(2)=2+3+1=\boxed{6}$ ត្រង់ $x=2$ ។

ផ្ចិតឆ្លុះ ៖ $I(1,4)$ ។

**តារាងអថេរភាព ៖**

| $x$ | $-\infty$ | | $0$ | | $1$ | | $2$ | | $+\infty$ |
|---|---|---|---|---|---|---|---|---|---|
| $f'(x)$ | | $+$ | $0$ | $-$ | \|\| | $-$ | $0$ | $+$ | |
| $f(x)$ | $-\infty$ | ↗ | $2$ | ↘ | $-\infty$ \|\| $+\infty$ | ↘ | $6$ | ↗ | $+\infty$ |

គ. ប្រសព្វជាមួយ $(L_1)$ និង $(L_2)$ ៖

- ប្រសព្វ $(C)$ និង $(L_1): y=2x+1$ ៖

$$\frac{x^2+2x-2}{x-1}=2x+1 \iff x^2+2x-2=(2x+1)(x-1)=2x^2-x-1 \iff x^2-3x+1=0$$

$\Delta = 9-4 = 5 > 0 \implies x = \dfrac{3\pm\sqrt{5}}{2}$ ។

កាត់ $(L_1)$ ត្រង់ពីរចំណុច $A\left(\dfrac{3-\sqrt{5}}{2}, 4-\sqrt{5}\right)$ និង $B\left(\dfrac{3+\sqrt{5}}{2}, 4+\sqrt{5}\right)$ ។

- ប្រសព្វ $(C)$ និង $(L_2): y = 2x-7$ ៖

$$\frac{x^2+2x-2}{x-1} = 2x-7 \iff x^2+2x-2 = 2x^2-9x+7 \iff x^2-11x+9=0$$

$\Delta = 121-36 = 85 > 0 \implies x = \dfrac{11\pm\sqrt{85}}{2}$ ។




---

## លំហាត់ទី ៥៧

គេឱ្យអនុគមន៍ $f(x) = \dfrac{x^2+3x+1}{x+1}$ មានក្រាប $(C)$ ។

ក. រកចំនួនពិត $a, b, c$ ដែល $f(x) = ax+b+\dfrac{c}{x+1}$ ។

ខ. រកសមីការអាស៊ីមតូតឈរ និងអាស៊ីមតូតទ្រេត និងសិក្សាទីតាំងធៀប ។

គ. ស្រាយបញ្ជាក់ថា $f$ ជាអនុគមន៍កើនដាច់ខាតលើចន្លោះនីមួយៗនៃដែនកំណត់ ។

ឃ. សង់តារាងអថេរភាព និងក្រាប $(C)$ ។

## ដំណោះស្រាយ

ក. $f(x) = \dfrac{x^2+x+2x+2-1}{x+1} = x+2-\dfrac{1}{x+1} \implies \boxed{a=1,\ b=2,\ c=-1}$ ។

ខ. អាស៊ីមតូតឈរ ៖ $\boxed{x=-1}$ ; អាស៊ីមតូតទ្រេត ៖ $\boxed{y=x+2}$ ។
ទីតាំងធៀប ៖ $f(x)-(x+2)=-\dfrac{1}{x+1}$ ៖

- លើ $(-1,+\infty)$ ៖ $(C)$ ស្ថិតនៅខាងក្រោមអាស៊ីមតូតទ្រេត ។
- លើ $(-\infty,-1)$ ៖ $(C)$ ស្ថិតនៅខាងលើអាស៊ីមតូតទ្រេត ។

គ. $f'(x)=1+\dfrac{1}{(x+1)^2}>1>0, \forall x\neq -1$ នាំឱ្យ $f$ កើនជានិច្ចលើ $(-\infty,-1)$ និងលើ $(-1,+\infty)$ ។

ឃ. ផ្ចិតឆ្លុះ ៖ $I(-1,1)$ ។ កាត់អ័ក្ស $(Oy)$ ត្រង់ $(0,1)$ ។




---

## លំហាត់ទី ៥៨

គេឱ្យអនុគមន៍ $f(x)=\dfrac{x^2+x+1}{x+3}$ មានក្រាប $(C)$ ។

ក. រកចំនួនពិត $a,b,c$ ដែល $f(x)=ax+b+\dfrac{c}{x+3}$ ។

ខ. រកសមីការអាស៊ីមតូតឈរ និងអាស៊ីមតូតទ្រេតនៃ $(C)$ ។

គ. សិក្សាអថេរភាព និងរកតម្លៃបរមាធៀបនៃ $f$ ។

ឃ. សង់តារាងអថេរភាព និងក្រាប $(C)$ ។

## ដំណោះស្រាយ

ក. $f(x)=\dfrac{x^2+3x-2x-6+7}{x+3}=x-2+\dfrac{7}{x+3} \implies \boxed{a=1,\ b=-2,\ c=7}$ ។

ខ. អាស៊ីមតូតឈរ ៖ $\boxed{x=-3}$ ; អាស៊ីមតូតទ្រេត ៖ $\boxed{y=x-2}$ ។

គ. $f'(x)=1-\dfrac{7}{(x+3)^2}=\dfrac{(x+3)^2-7}{(x+3)^2}$ ។ $f'(x)=0 \iff x=-3\pm\sqrt{7}$ ៖

- អតិបរមាធៀប ៖ $f(-3-\sqrt{7})=-5-2\sqrt{7}\approx-10.29$ ត្រង់ $x=-3-\sqrt{7}$ ។
- អប្បបរមាធៀប ៖ $f(-3+\sqrt{7})=-5+2\sqrt{7}\approx 0.29$ ត្រង់ $x=-3+\sqrt{7}$ ។

ឃ. ផ្ចិតឆ្លុះ ៖ $I(-3,-5)$ ។




---

## លំហាត់ទី ៥៩

គេឱ្យអនុគមន៍ $f(x)=\dfrac{x^2+2x+3}{x+1}$ មានក្រាប $(C)$ ។

ក. រកដែនកំណត់ និងអាស៊ីមតូតឈរ, អាស៊ីមតូតទ្រេតនៃ $(C)$ ។

ខ. សិក្សាអថេរភាព និងរកតម្លៃបរមាធៀប ។

គ. សង់តារាងអថេរភាព និងក្រាប $(C)$ ។

## ដំណោះស្រាយ

ក. ដែនកំណត់ ៖ $\boxed{D=\mathbb{R}\setminus\{-1\}}$ ។

$f(x)=x+1+\dfrac{2}{x+1} \implies \boxed{x=-1}$ (ឈរ) និង $\boxed{y=x+1}$ (ទ្រេត) ។

ខ. $f'(x)=1-\dfrac{2}{(x+1)^2}=\dfrac{(x+1)^2-2}{(x+1)^2}$ ។ $f'(x)=0 \iff x=-1\pm\sqrt{2}$ ៖

- អតិបរមាធៀប ៖ $f(-1-\sqrt{2})=-2\sqrt{2}\approx-2.83$ ត្រង់ $x=-1-\sqrt{2}$ ។
- អប្បបរមាធៀប ៖ $f(-1+\sqrt{2})=2\sqrt{2}\approx 2.83$ ត្រង់ $x=-1+\sqrt{2}$ ។

គ. ផ្ចិតឆ្លុះ ៖ $I(-1,0)$ ។




## លំហាត់ទី ៦០

គេឱ្យអនុគមន៍ $f(x)=\dfrac{x^2-2x}{x-1}$ ចំពោះ $x\neq 1$ មានក្រាប $(C)$ ។

ក. រកចំនួនពិត $a,b,c$ ដែល $f(x)=ax+b+\dfrac{c}{x-1}$ ។

ខ. រកសមីការអាស៊ីមតូតឈរ និងអាស៊ីមតូតទ្រេតនៃ $(C)$ ។

គ. ស្រាយបញ្ជាក់ថា $f$ ជាអនុគមន៍កើនជានិច្ច និងសង់ក្រាប $(C)$ ។

ឃ. ពិភាក្សាឫសសមីការ $x^2-(2+m)x+m=0$ តាមតម្លៃ $m$ ។

## ដំណោះស្រាយ

ក. $f(x)=\dfrac{x^2-2x+1-1}{x-1}=\dfrac{(x-1)^2-1}{x-1}=x-1-\dfrac{1}{x-1} \Longrightarrow \boxed{a=1,\ b=-1,\ c=-1}$ ។

ខ. អាស៊ីមតូតឈរ ៖ $\boxed{x=1}$ ; អាស៊ីមតូតទ្រេត ៖ $\boxed{y=x-1}$ ។

គ. $f'(x)=1+\dfrac{1}{(x-1)^2}>0, \forall x\neq 1 \Longrightarrow f$ កើនជានិច្ចលើដែនកំណត់ ។

ឃ. $x^2-(2+m)x+m=0 \iff x^2-2x=m(x-1) \iff f(x)=m$ ៖
ដោយបន្ទាត់ដេក $y=m$ តែងតែកាត់ខ្សែងទាំងពីរនៃក្រាប $(C)$ ជានិច្ចគ្រប់ $m\in\mathbb{R}$ នាំឱ្យសមីការមានឫសពីរផ្សេងគ្នាជានិច្ចគ្រប់តម្លៃ $m$ ។

---

## លំហាត់ទី ៦១

គេឱ្យអនុគមន៍ $f(x)=\dfrac{-x^2+4x}{x-1}$ ចំពោះ $x\neq 1$ មានក្រាប $(C)$ ។

ក. រកចំនួនពិត $a,b,c$ ដែល $f(x)=ax+b+\dfrac{c}{x-1}$ ។

ខ. រកសមីការអាស៊ីមតូតឈរ និងអាស៊ីមតូតទ្រេតនៃ $(C)$ ។

គ. ស្រាយបញ្ជាក់ថា $f$ ជាអនុគមន៍ចុះជានិច្ច និងសង់ក្រាប $(C)$ ។

### ដំណោះស្រាយ

ក. $f(x)=\dfrac{-(x^2-4x+3)+3}{x-1}=\dfrac{-(x-1)(x-3)+3}{x-1}=-x+3+\dfrac{3}{x-1} \Longrightarrow \boxed{a=-1,\ b=3,\ c=3}$ ។

ខ. អាស៊ីមតូតឈរ ៖ $\boxed{x=1}$ ; អាស៊ីមតូតទ្រេត ៖ $\boxed{y=-x+3}$ ។

គ. $f'(x)=-1-\dfrac{3}{(x-1)^2}<0, \forall x\neq 1 \Longrightarrow f$ ចុះដាច់ខាតជានិច្ចលើដែនកំណត់ ។ ផ្ចិតឆ្លុះ ៖ $I(1,2)$ ។

---

## លំហាត់ទី ៦២

គេឱ្យអនុគមន៍ $f(x)=\dfrac{x^2+4x+1}{x+2}$ ចំពោះ $x\neq -2$ មានក្រាប $(C)$ ។

ក. រកចំនួនពិត $a,b,c$ ដែល $f(x)=ax+b+\dfrac{c}{x+2}$ ។

ខ. រកសមីការអាស៊ីមតូតឈរ និងអាស៊ីមតូតទ្រេតនៃ $(C)$ ។

គ. សិក្សាអថេរភាព និងសង់ក្រាប $(C)$ ។

### ដំណោះស្រាយ

ក. $f(x)=\dfrac{(x+2)^2-3}{x+2}=x+2-\dfrac{3}{x+2} \Longrightarrow \boxed{a=1,\ b=2,\ c=-3}$ ។

ខ. អាស៊ីមតូតឈរ ៖ $\boxed{x=-2}$ ; អាស៊ីមតូតទ្រេត ៖ $\boxed{y=x+2}$ ។

គ. $f'(x)=1+\dfrac{3}{(x+2)^2}>0, \forall x\neq -2 \Longrightarrow f$ កើនជានិច្ចលើដែនកំណត់ ។ ផ្ចិតឆ្លុះ ៖ $I(-2,0)$ ។

---

## លំហាត់ទី ៦៣

គេឱ្យអនុគមន៍ $f(x)=\dfrac{x^2-2x+6}{x+1}$ ចំពោះ $x\neq -1$ មានក្រាប $(C)$ ។

ក. រកចំនួនពិត $a,b,c$ ដែល $f(x)=ax+b+\dfrac{c}{x+1}$ ។

ខ. រកអាស៊ីមតូតឈរ, អាស៊ីមតូតទ្រេត និងតម្លៃបរមាធៀបនៃ $f$ ។

គ. សង់តារាងអថេរភាព និងក្រាប $(C)$ ។

### ដំណោះស្រាយ

ក. $f(x)=\dfrac{x^2+x-3x-3+9}{x+1}=x-3+\dfrac{9}{x+1} \implies \boxed{a=1,\ b=-3,\ c=9}$ ។

ខ. អាស៊ីមតូត ៖ $x=-1$ (ឈរ) និង $y=x-3$ (ទ្រេត) ។

$f'(x)=1-\dfrac{9}{(x+1)^2}=\dfrac{(x+4)(x-2)}{(x+1)^2}$ ៖

- អតិបរមាធៀប ៖ $f(-4)=-4-3-3=\boxed{-10}$ ត្រង់ $x=-4$ ។
- អប្បបរមាធៀប ៖ $f(2)=2-3+3=\boxed{2}$ ត្រង់ $x=2$ ។

គ. ផ្ចិតឆ្លុះ ៖ $I(-1,-4)$ ។ សមីការ $f(x)=m$ មានឫស ២ កាលណា $m<-10$ ឬ $m>2$ ។

---

## លំហាត់ទី ៦៤

គេឱ្យអនុគមន៍ $f(x)=\dfrac{x^2+2x+5}{x+1}$ ចំពោះ $x\neq -1$ មានក្រាប $(C)$ ។

ក. រក $m,n,p$ ដែល $f(x)=mx+n+\dfrac{p}{x+1}$ ។

ខ. រកសមីការអាស៊ីមតូតឈរ និងទ្រេត និងតម្លៃបរមាធៀបនៃ $f$ ។

គ. សង់តារាងអថេរភាព និងក្រាប $(C)$ ។

### ដំណោះស្រាយ

ក. $f(x)=\dfrac{(x+1)^2+4}{x+1}=x+1+\dfrac{4}{x+1} \implies \boxed{m=1,\ n=1,\ p=4}$ ។

ខ. អាស៊ីមតូត ៖ $x=-1$ (ឈរ) និង $y=x+1$ (ទ្រេត) ។

$f'(x)=1-\dfrac{4}{(x+1)^2}=\dfrac{(x+3)(x-1)}{(x+1)^2}$ ៖

- អតិបរមាធៀប ៖ $f(-3)=-3+1-2=\boxed{-4}$ ត្រង់ $x=-3$ ។
- អប្បបរមាធៀប ៖ $f(1)=1+1+2=\boxed{4}$ ត្រង់ $x=1$ ។

គ. ផ្ចិតឆ្លុះ ៖ $I(-1,0)$ ។

---

## លំហាត់ទី ៦៥

គេឱ្យអនុគមន៍ $f(x)=\dfrac{x^2+x+2}{x-1}$ ចំពោះ $x\neq 1$ មានក្រាប $(C)$ ។

ក. រកសមីការអាស៊ីមតូតឈរ និងអាស៊ីមតូតទ្រេតនៃ $(C)$ ។

ខ. សិក្សាអថេរភាព និងរកតម្លៃបរមាធៀបនៃ $f$ ។

គ. កំណត់តម្លៃ $a$ ដើម្បីឱ្យសមីការ $f(x)=a$ មានឫសពីរ $1<x_1<x_2$ ។

## ដំណោះស្រាយ

ក. $f(x)=x+2+\dfrac{4}{x-1}\implies \boxed{x=1}$ (ឈរ) និង $\boxed{y=x+2}$ (ទ្រេត) ។

ខ. $f'(x)=1-\dfrac{4}{(x-1)^2}=\dfrac{(x+1)(x-3)}{(x-1)^2}$ ៖

- អតិបរមាធៀប ៖ $f(-1)=-1+2-2=\boxed{-1}$ ត្រង់ $x=-1$ ។
- អប្បបរមាធៀប ៖ $f(3)=3+2+2=\boxed{7}$ ត្រង់ $x=3$ ។

គ. ដើម្បីឱ្យសមីការ $f(x)=a$ មានឫសពីរធំជាង 1 លុះត្រាតែបន្ទាត់ $y=a$ កាត់ខ្នែងខាងស្តាំនៃក្រាប $(C)$ ត្រង់ពីរចំណុចផ្សេងគ្នា ដែលតម្រូវឱ្យ $\boxed{a>7}$ ។

---

## លំហាត់ទី ៦៦

គេឱ្យអនុគមន៍ $f(x)=x+\dfrac{4}{x-1}$ ចំពោះ $x\neq 1$ មានក្រាប $(C)$ ។

ក. រកសមីការអាស៊ីមតូតឈរ និងអាស៊ីមតូតទ្រេតនៃ $(C)$ ។

ខ. សិក្សាអថេរភាព និងរកតម្លៃបរមាធៀបនៃ $f$ ។

គ. កំណត់តម្លៃ $m$ ដើម្បីឱ្យសមីការ $x^2-(m+1)x+m+4=0$ គ្មានឫសក្នុង $\mathbb{R}$ ។

## ដំណោះស្រាយ

ក. អាស៊ីមតូត ៖ $\boxed{x=1}$ (ឈរ) និង $\boxed{y=x}$ (ទ្រេត) ។

ខ. $f'(x)=1-\dfrac{4}{(x-1)^2}=\dfrac{(x+1)(x-3)}{(x-1)^2}$ ៖

- អតិបរមាធៀប ៖ $f(-1)=-1-2=\boxed{-3}$ ត្រង់ $x=-1$ ។

- អប្បបរមាធៀប ៖ $f(3)=3+2=\boxed{5}$ ត្រង់ $x=3$ ។

គ. សមីការ $x^2-(m+1)x+m+4=0 \iff f(x)=m$ ។ ផ្អែកតាមតារាងអថេរភាព សមីការគ្មានឫសលុះត្រាតែ $\boxed{-3<m<5}$ ។

---

## លំហាត់ទី ៦៧

គេឱ្យអនុគមន៍ $f(x)=\dfrac{ax^2+bx+c}{x+1}$ $(x\neq -1)$ មានក្រាប $(C)$ ។

ក. រក $a,b,c$ ដោយដឹងថាក្រាប $(C)$ កាត់តាមចំណុច $A(0,1)$ និងមានបរមាធៀបត្រង់ចំណុច $B(1,0)$ ។

ខ. សិក្សាអថេរភាព និងសង់ក្រាប $(C)$ តាមតម្លៃ $a,b,c$ ដែលរកឃើញ ។

## ដំណោះស្រាយ

ក. **រក** $a,b,c$ **៖**

- $(C)$ កាត់តាម $A(0,1) \implies f(0)=\dfrac{c}{1}=1 \implies c=1$ ។
- $(C)$ កាត់តាម $B(1,0) \implies f(1)=\dfrac{a+b+1}{2}=0 \implies a+b+1=0 \implies b=-a-1$ ។
- មានបរមាធៀបត្រង់ $x=1 \implies f'(1)=0$ ៖

$$f'(x)=\frac{(2ax+b)(x+1)-(ax^2+bx+c)}{(x+1)^2}=\frac{ax^2+2ax+b-c}{(x+1)^2}$$

$f'(1)=0 \iff a(1)+2a(1)+b-1=0 \iff 3a+b=1$ ។ ជំនួស $b=-a-1$ ៖ $3a-a-1=1 \iff 2a=2 \implies a=1 \implies b=-2$ ។

**ដូចនេះ** $\boxed{a=1,\quad b=-2,\quad c=1}$ **នាំឱ្យ** $f(x)=\dfrac{x^2-2x+1}{x+1}=\dfrac{(x-1)^2}{x+1}$ ។

ខ. បំបែក ៖ $f(x)=x-3+\dfrac{4}{x+1}$ ៖

- អាស៊ីមតូត ៖ $x=-1$ (ឈរ) និង $y=x-3$ (ទ្រេត) ។
- $f'(x)=\dfrac{(x+3)(x-1)}{(x+1)^2}$ ៖ អតិបរមា $f(-3)=-8$, អប្បបរមា $f(1)=0$ ។

---

## លំហាត់ទី ៦៨ & ៦៩

គេឱ្យអនុគមន៍ $f(x)=\dfrac{ax^2+bx+c}{x+2}$ $(x\neq -2)$ មានក្រាប $(C)$ ។

ក. រក $a,b,c$ ដោយដឹងថាក្រាប $(C)$ កាត់អ័ក្ស $(Oy)$ ត្រង់ $A\left(0,\dfrac{3}{2}\right)$ និងមានចំណុចបរមាធៀបត្រង់ $B(-1,0)$ ។

ខ. សិក្សាអថេរភាព និងសង់ក្រាប $(C)$ តាមតម្លៃ $a,b,c$ ដែលរកឃើញ ។

ⓖ. ពិភាក្សាឬសសមីការ $f(x)=m$ តាមតម្លៃប៉ារ៉ាម៉ែត្រ $m$ ។

## ដំណោះស្រាយ

ⓐ. រក $a,b,c$ ៖

- កាត់ $A\left(0,\frac{3}{2}\right) \implies f(0)=\frac{c}{2}=\frac{3}{2} \implies c=3$ ។
- កាត់ $B(-1,0) \implies f(-1)=\frac{a(-1)^2+b(-1)+3}{1}=0 \iff a-b+3=0 \implies b=a+3$ ។
- បរមាធៀបត្រង់ $x=-1 \implies f'(-1)=0$ ៖

$$f'(x)=\frac{(2ax+b)(x+2)-(ax^2+bx+3)}{(x+2)^2}=\frac{ax^2+4ax+2b-3}{(x+2)^2}$$

$f'(-1)=0 \iff a-4a+2b-3=0 \iff -3a+2(a+3)-3=0 \iff -a+3=0 \implies a=3$ ។
ទាញបាន ៖ $b=3+3=6$ ។

**ដូចនេះ** $\boxed{a=3,\quad b=6,\quad c=3}$ **នាំឱ្យ** $f(x)=\frac{3x^2+6x+3}{x+2}=\frac{3(x+1)^2}{x+2}$ ។

ⓑ. បំបែក ៖ $f(x)=3x+\frac{3}{x+2}$ ៖

- អាស៊ីមតូត ៖ $x=-2$ (ឈរ) និង $y=3x$ (ទ្រេត) ។
- ដេរីវេ ៖ $f'(x)=3-\frac{3}{(x+2)^2}=\frac{3(x+3)(x+1)}{(x+2)^2}$ ៖
  - អតិបរមាធៀប ៖ $f(-3)=3(-3)+\frac{3}{-1}=\boxed{-12}$ ត្រង់ $x=-3$ ។
  - អប្បបរមាធៀប ៖ $f(-1)=3(-1)+\frac{3}{1}=\boxed{0}$ ត្រង់ $x=-1$ ។

ⓖ. ពិភាក្សាឬសសមីការ $f(x)=m$ ៖

- $m<-12$ ឬ $m>0$ ៖ មានឫសពីរផ្សេងគ្នា ។
- $m=-12$ ៖ មានឫសឌុប $x=-3$ ; $m=0$ ៖ មានឫសឌុប $x=-1$ ។
- $-12<m<0$ ៖ គ្មានឫសក្នុង $\mathbb{R}$ ។

---

## លំហាត់ទី ៧០

គេឱ្យអនុគមន៍ $f(x)=\frac{x^2+ax+b}{x-1}$ ចំពោះ $x\neq 1$ មានក្រាប $(C)$ ក្នុងតម្រុយអរតូណរម៉ាល់ ។

ⓐ. កំណត់តម្លៃ $a$ និង $b$ ដោយដឹងថាក្រាប $(C)$ មានចំណុចអតិបរមាត្រង់ $x=0$ ស្មើនឹង $1$ ។

ⓑ. សិក្សាអថេរភាព និងរកសមីការអាស៊ីមតូតឈរ និងអាស៊ីមតូតទ្រេតនៃ $(C)$ តាមតម្លៃ $a,b$ ដែលរកឃើញ ។

**គ**. បង្ហាញថាប្រសព្វអាស៊ីមតូត $I(1,3)$ ជាផ្ចិតឆ្លុះនៃ $(C)$ និងសង់ក្រាប $(C)$ ។

**ឃ**. ពិភាក្សាអត្ថិភាព និងសញ្ញានៃឫសសមីការ $x^2+(1-m)x+m-1=0$ តាមតម្លៃប៉ារ៉ាម៉ែត្រ $m$ ។

## ដំណោះស្រាយ

**ក**. **កំណត់តម្លៃ $a$ និង $b$ ៖**

- អតិបរមាត្រង់ $x=0$ ស្មើនឹង $1 \Longrightarrow f(0)=1$ ៖

$$f(0)=\frac{0+0+b}{0-1}=-b=1 \Longrightarrow b=-1$$

- ដេរីវេនៃ $f(x)$ ៖

$$f'(x)=\frac{(2x+a)(x-1)-(x^2+ax+b)}{(x-1)^2}=\frac{x^2-2x-a-b}{(x-1)^2}$$

លក្ខខណ្ឌបរមាត្រង់ $x=0 \Longrightarrow f'(0)=0$ ៖

$$\frac{-a-b}{(-1)^2}=0 \Longleftrightarrow -a-b=0 \Longrightarrow a=-b=-(-1)=1$$

**ដូចនេះ តម្លៃដែលត្រូវរកគឺ** $\boxed{a=1, \quad b=-1}$ **នាំឱ្យ** $f(x)=\dfrac{x^2+x-1}{x-1}$ ។

**ខ**. **អថេរភាព និងអាស៊ីមតូត ៖**

ដែនកំណត់ ៖ $D=\mathbb{R}\setminus\{1\}$ ។ បំបែក ៖ $f(x)=x+2+\dfrac{1}{x-1}$ ៖

- $\lim\limits_{x\to1^-} f(x)=-\infty,\ \lim\limits_{x\to1^+} f(x)=+\infty \Longrightarrow \boxed{x=1}$ ជាអាស៊ីមតូតឈរ ។
- $\lim\limits_{x\to\pm\infty}[f(x)-(x+2)]=\lim\limits_{x\to\pm\infty}\dfrac{1}{x-1}=0 \Longrightarrow (d):\boxed{y=x+2}$ ជាអាស៊ីមតូតទ្រេត ។

ដេរីវេ ៖ $f'(x)=1-\dfrac{1}{(x-1)^2}=\dfrac{x(x-2)}{(x-1)^2}$ ៖

- អតិបរមាធៀប ៖ $f(0)=\boxed{1}$ ត្រង់ $x=0$ ។
- អប្បបរមាធៀប ៖ $f(2)=2+2+1=\boxed{5}$ ត្រង់ $x=2$ ។

**តារាងអថេរភាព ៖**

| $x$ | $-\infty$ | | $0$ | | $1$ | | $2$ | | $+\infty$ |
|---|---|---|---|---|---|---|---|---|---|
| $f'(x)$ | | $+$ | $0$ | $-$ | ‖ | $-$ | $0$ | $+$ | |
| $f(x)$ | $-\infty$ | ↗ | $1$ | ↘ | $-\infty$ ‖ $+\infty$ | ↘ | $5$ | ↗ | $+\infty$ |

គ. ផ្ចិតឆ្លុះ និងក្រាប $(C)$ ៖

$f(2-x)+f(x)=(2-x+2+\frac{1}{1-x})+(x+2+\frac{1}{x-1})=6=2(3) \implies \boxed{I(1,3)}$ ជាផ្ចិតឆ្លុះនៃ $(C)$ ។




ឃ. ពិភាក្សាឫសសមីការ ៖

$x^2+(1-m)x+m-1=0 \iff f(x)=m$ ៖

- $m<1$ ៖ មានឫសពីរផ្សេងគ្នា $x_1<0<x_2<1$ ។
- $m=1$ ៖ មានឫសឌុប $x=0$ ។
- $1<m<5$ ៖ គ្មានឫសក្នុង $\mathbb{R}$ ។
- $m=5$ ៖ មានឫសឌុប $x=2$ ។
- $m>5$ ៖ មានឫសវិជ្ជមានពីរផ្សេងគ្នា $1<x_1<2<x_2$ ។

---

**លំហាត់ទី ៧១**

គេឱ្យអនុគមន៍ $f(x)=\dfrac{x^2-6x}{x^2-6x+5}$ មានក្រាបតំណាង $(C)$ ក្នុងតម្រុយអរតូណរម៉ាល់ ។

ក. រកដែនកំណត់នៃអនុគមន៍ $f$ ។

ខ. គណនាលីមីតត្រង់ចុងដែនកំណត់ និងទាញរកសមីការអាស៊ីមតូតដេក និងអាស៊ីមតូតឈរទាំងពីរនៃ $(C)$ ។

គ. សិក្សាអថេរភាព សង់តារាងអថេរភាព និងរកចំណុចបរមាធៀបនៃ $f$ ។

ឃ. បង្ហាញថាបន្ទាត់ $x=3$ ជាអ័ក្សឆ្លុះនៃក្រាប $(C)$ និងសង់ក្រាប $(C)$ ។

ង. ពិភាក្សាឫសសមីការ $(1-m)x^2-6(1-m)x-5m=0$ តាមតម្លៃ $m$ ។

**ដំណោះស្រាយ**

**ក. ដែនកំណត់ ៖**
ភាគបែង $x^2-6x+5=0 \iff (x-1)(x-5)=0 \iff x=1$ ឬ $x=5$ ។
ដូចនេះ $\boxed{D=\mathbb{R}\setminus\{1,5\}=(-\infty,1)\cup(1,5)\cup(5,+\infty)}$ ។

**ខ. លីមីត និងអាស៊ីមតូត ៖**

- $\lim\limits_{x\to\pm\infty} f(x)=\lim\limits_{x\to\pm\infty}\dfrac{x^2}{x^2}=1 \Longrightarrow (d):\boxed{y=1}$ ជាសមីការអាស៊ីមតូតដេក ។
- $\lim\limits_{x\to 1^-} f(x)=-\infty,\ \lim\limits_{x\to 1^+} f(x)=+\infty \Longrightarrow \boxed{x=1}$ ជាសមីការអាស៊ីមតូតឈរទីមួយ ។
- $\lim\limits_{x\to 5^-} f(x)=+\infty,\ \lim\limits_{x\to 5^+} f(x)=-\infty \Longrightarrow \boxed{x=5}$ ជាសមីការអាស៊ីមតូតឈរទីពីរ ។

**គ. អថេរភាព ៖**
បំប្លែង ៖ $f(x)=\dfrac{(x^2-6x+5)-5}{x^2-6x+5}=1-\dfrac{5}{x^2-6x+5}$ ។
គណនាដេរីវេ ៖

$$f'(x)=-5\left(-\frac{2x-6}{(x^2-6x+5)^2}\right)=\frac{10(x-3)}{(x^2-6x+5)^2}$$

ឱ្យ $f'(x)=0 \iff x-3=0 \iff x=3$ ៖

$$f(3)=1-\frac{5}{9-18+5}=1-\frac{5}{-4}=1+\frac{5}{4}=\boxed{\frac{9}{4}}$$ (អប្បបរមាធៀបក្នុងចន្លោះ $(1,5)$)

**តារាងអថេរភាព ៖**

| $x$ | $-\infty$ | | $1$ | | $3$ | | $5$ | | $+\infty$ |
|---|---|---|---|---|---|---|---|---|---|
| $f'(x)$ | | $-$ | ‖ | $-$ | $0$ | $+$ | ‖ | $+$ | |
| $f(x)$ | $1$ | ↘ | $-\infty$ ‖ $+\infty$ | ↘ | $\frac{9}{4}$ | ↗ | $+\infty$ ‖ $-\infty$ | ↗ | $1$ |

**ឃ. អ័ក្សឆ្លុះ និងក្រាប $(C)$ ៖**
ចំពោះគ្រប់ $x\in D$ គេបាន $6-x\in D$ ហើយ ៖

$$f(6-x)=\frac{(6-x)^2-6(6-x)}{(6-x)^2-6(6-x)+5}=\frac{36-12x+x^2-36+6x}{36-12x+x^2-36+6x+5}=\frac{x^2-6x}{x^2-6x+5}=f(x)$$

ដូចនេះ បន្ទាត់ $\boxed{x=3}$ ជាអ័ក្សឆ្លុះនៃក្រាប $(C)$ ។




ង. **ពិភាក្សាឫសសមីការ ៖**

សមីការ $(1-m)x^2 - 6(1-m)x - 5m = 0 \iff x^2 - 6x - m(x^2 - 6x + 5) = 0 \iff f(x) = m$ ៖

- $m < 1$ ៖ បន្ទាត់កាត់ក្រាបត្រង់ពីរចំណុចនៅខ្នែងខាងក្រៅ $\implies$ មានឫសពីរផ្សេងគ្នា ។
- $m = 1$ ៖ អាស៊ីមតូតដេក គ្មានប្រសព្វ $\implies$ គ្មានឫស ។
- $1 < m < \frac{9}{4}$ ៖ គ្មានប្រសព្វ $\implies$ គ្មានឫសក្នុង $\mathbb{R}$ ។
- $m = \frac{9}{4}$ ៖ ប៉ះត្រង់កំពូលអប្បបរមា $\implies$ មានឫសឌុប $x = 3$ ។
- $m > \frac{9}{4}$ ៖ កាត់ខ្នែងកណ្ដាលត្រង់ពីរចំណុច $\implies$ មានឫសពីរផ្សេងគ្នាក្នុង $(1, 5)$ ។

---

## លំហាត់ទី ៧២

គេឱ្យអនុគមន៍ $f(x) = \dfrac{ax^2 + bx + c}{(x-2)^2}$ ចំពោះ $x \neq 2$ មានក្រាប $(C)$ ។

ក. កំណត់ $a, b, c$ ដោយដឹងថាក្រាប $(C)$ មានអាស៊ីមតូតដេក $y = 1$ និងកាត់អ័ក្សអាប់ស៊ីសត្រង់ $x = 1$ និង $x = -3$ ។

ខ. សិក្សាអថេរភាព និងរកសមីការអាស៊ីមតូតឈរនៃ $(C)$ ។

គ. សង់តារាងអថេរភាព និងក្រាប $(C)$ ។

## ដំណោះស្រាយ

ក. អាស៊ីមតូតដេក $\lim_{x \to \pm\infty} f(x) = a = 1 \implies a = 1$ ។

កាត់អ័ក្សអាប់ស៊ីសត្រង់ $x = 1$ និង $x = -3 \implies x^2 + bx + c = (x-1)(x+3) = x^2 + 2x - 3$ ៖

**ដូចនេះ** $\boxed{a = 1, \quad b = 2, \quad c = -3}$ **នាំឱ្យ** $f(x) = \dfrac{x^2 + 2x - 3}{(x-2)^2}$ ។

ខ. អាស៊ីមតូតឈរ ៖ $\lim\limits_{x\to 2} f(x)=+\infty \Longrightarrow \boxed{x=2}$ ជាអាស៊ីមតូតឈរ ។

ដេរីវេ ៖

$$f'(x)=\frac{(2x+2)(x-2)^2-(x^2+2x-3)\cdot 2(x-2)}{(x-2)^4}=\frac{-6x+2}{(x-2)^3}$$

$f'(x)=0 \iff -6x+2=0 \iff x=\dfrac{1}{3}$ ៖

$$f\left(\frac{1}{3}\right)=\frac{\frac{1}{9}+\frac{2}{3}-3}{\left(\frac{1}{3}-2\right)^2}=\frac{-\frac{20}{9}}{\frac{25}{9}}=-\frac{4}{5}\quad \text{(អប្បបរមាធៀប)}$$

តារាងអថេរភាព ៖

| $x$ | $-\infty$ | | $\frac{1}{3}$ | | $2$ | | $+\infty$ |
|---|---|---|---|---|---|---|---|
| $f'(x)$ | | $-$ | $0$ | $+$ | ‖ | $-$ | |
| $f(x)$ | $1$ | ↘ | $-\frac{4}{5}$ | ↗ | $+\infty$ ‖ $+\infty$ | ↘ | $1$ |

គ. ក្រាបតំណាង $(C)$ កាត់ $(Oy)$ ត្រង់ $\left(0,-\dfrac{3}{4}\right)$ និងមានអប្បបរមាត្រង់ $\left(\dfrac{1}{3},-\dfrac{4}{5}\right)$ ។




## លំហាត់ទី ៧៣

គេឱ្យអនុគមន៍ $f(x)=\dfrac{2x^2}{x^2-4}$ កំណត់លើ $D=\mathbb{R}\setminus\{-2,2\}$ មានក្រាប $(C)$ ។

ក. បង្ហាញថា $f$ ជាអនុគមន៍គូ និងទាញបញ្ជាក់នូវអ័ក្សឆ្លុះនៃ $(C)$ ។

ខ. រកសមីការអាស៊ីមតូតដេក និងអាស៊ីមតូតឈរទាំងពីរនៃ $(C)$ ។

គ. សិក្សាអថេរភាព និងសង់ក្រាប $(C)$ ។

## ដំណោះស្រាយ

ក. បង្ហាញថា $f$ ជាអនុគមន៍គូ ៖
ចំពោះគ្រប់ $x \in D = \mathbb{R} \setminus \{-2,2\} \implies -x \in D$ ហើយ ៖

$$f(-x) = \frac{2(-x)^2}{(-x)^2-4} = \frac{2x^2}{x^2-4} = f(x)$$

ដូចនេះ $f$ ជាអនុគមន៍គូ ហើយអ័ក្សអរដោនេ $(Oy)$ ជាអ័ក្សឆ្លុះនៃក្រាប $(C)$ ។

ខ. រកសមីការអាស៊ីមតូតនៃ $(C)$ ៖

- អាស៊ីមតូតដេក ៖

$$\lim_{x\to\pm\infty} f(x) = \lim_{x\to\pm\infty} \frac{2x^2}{x^2-4} = \lim_{x\to\pm\infty} \frac{2}{1-\frac{4}{x^2}} = 2$$

ដូចនេះ បន្ទាត់ $\boxed{y=2}$ ជាអាស៊ីមតូតដេកនៃក្រាប $(C)$ ខាង $\pm\infty$ ។

- អាស៊ីមតូតឈរ ៖

$$\lim_{x\to-2^-} f(x) = +\infty \quad , \quad \lim_{x\to-2^+} f(x) = -\infty \implies \boxed{x=-2}$$

$$\lim_{x\to2^-} f(x) = -\infty \quad , \quad \lim_{x\to2^+} f(x) = +\infty \implies \boxed{x=2}$$

ដូចនេះ បន្ទាត់ $\boxed{x=-2}$ និង $\boxed{x=2}$ ជាអាស៊ីមតូតឈរទាំងពីរនៃ $(C)$ ។

គ. សិក្សាអថេរភាព និងសង់ក្រាប $(C)$ ៖

- គណនាដេរីវេ ៖
ចំពោះគ្រប់ $x \in D$ គេបាន ៖

$$f'(x) = \frac{(2x^2)'(x^2-4)-2x^2(x^2-4)'}{(x^2-4)^2} = \frac{4x(x^2-4)-2x^2(2x)}{(x^2-4)^2} = \frac{-16x}{(x^2-4)^2}$$

$f'(x) = 0 \iff -16x = 0 \iff x = 0$ ។

- ទិសដៅអថេរភាព ៖
  - ចំពោះ $x<0$ $(x\neq-2) \implies f'(x)>0$ នាំឱ្យ $f$ ជាអនុគមន៍កើនលើ $(-\infty,-2)$ និង $(-2,0)$ ។
  - ចំពោះ $x>0$ $(x\neq2) \implies f'(x)<0$ នាំឱ្យ $f$ ជាអនុគមន៍ចុះលើ $(0,2)$ និង $(2,+\infty)$ ។

- បរមាធៀប ៖
ត្រង់ $x=0$ ដេរីវេប្តូរសញ្ញាពី $+$ ទៅ $-$ នាំឱ្យ $f$ មានតម្លៃ**អតិបរមាធៀប** គឺ $\boxed{f(0)=0}$ ។

- តារាងអថេរភាព ៖

| $x$ | $-\infty$ | | $-2$ | | $0$ | | $2$ | | $+\infty$ |
|---|---|---|---|---|---|---|---|---|---|
| $f'(x)$ | | $+$ | ‖ | $+$ | $0$ | $-$ | ‖ | $-$ | |
| $f(x)$ | $2$ | ↗ | $+\infty$ ‖ $-\infty$ | ↗ | $0$ | ↘ | $-\infty$ ‖ $+\infty$ | ↘ | $2$ |

- សង់ក្រាប $(C)$ ៖




---

## លំហាត់ទី ៧៤

គេឱ្យអនុគមន៍ $f(x)=\dfrac{x^2}{4-x^2}$ ចំពោះ $x\neq\pm2$ មានក្រាប $(C)$ ។

ក. រកសមីការអាស៊ីមតូតដេក និងអាស៊ីមតូតឈរទាំងពីរនៃ $(C)$ ។

ខ. សិក្សាអថេរភាព និងរកតម្លៃបរមាធៀបនៃ $f$ ។

គ. សង់តារាងអថេរភាព និងក្រាប $(C)$ ។

## ដំណោះស្រាយ

ក. រកសមីការអាស៊ីមតូតនៃ $(C)$ ៖

- អាស៊ីមតូតដេក ៖

$$\lim_{x\to\pm\infty} f(x)=\lim_{x\to\pm\infty}\frac{x^2}{4-x^2}=\lim_{x\to\pm\infty}\frac{1}{\frac{4}{x^2}-1}=-1$$

ដូចនេះ បន្ទាត់ $\boxed{y=-1}$ ជាអាស៊ីមតូតដេកនៃក្រាប $(C)$ ខាង $\pm\infty$ ។

- អាស៊ីមតូតឈរ ៖

$$\lim_{x\to-2^-} f(x)=-\infty \quad , \quad \lim_{x\to-2^+} f(x)=+\infty \implies \boxed{x=-2}$$
$$\lim_{x\to2^-} f(x)=+\infty \quad , \quad \lim_{x\to2^+} f(x)=-\infty \implies \boxed{x=2}$$

ដូចនេះ បន្ទាត់ $\boxed{x=-2}$ និង $\boxed{x=2}$ ជាអាស៊ីមតូតឈរទាំងពីរនៃ $(C)$ ។

ខ. សិក្សាអថេរភាព និងរកតម្លៃបរមាធៀបនៃ $f$ ៖

- ភាពគូ/សេស ៖ ចំពោះគ្រប់ $x \in D \implies -x \in D$ ហើយ $f(-x) = f(x)$ នាំឱ្យ $f$ ជាអនុគមន៍គូ និងមានអ័ក្ស $(Oy)$ ជាអ័ក្សឆ្លុះ ។
- គណនាដេរីវេ ៖

$$f'(x) = \frac{(x^2)'(4-x^2) - x^2(4-x^2)'}{(4-x^2)^2} = \frac{2x(4-x^2) - x^2(-2x)}{(4-x^2)^2} = \frac{8x}{(4-x^2)^2}$$

$f'(x) = 0 \iff 8x = 0 \iff x = 0$ ។

- ទិសដៅអថេរភាព ៖
  - ចំពោះ $x < 0$ $(x \neq -2) \implies f'(x) < 0$ នាំឱ្យ $f$ ចុះលើ $(-\infty, -2)$ និង $(-2, 0)$ ។
  - ចំពោះ $x > 0$ $(x \neq 2) \implies f'(x) > 0$ នាំឱ្យ $f$ កើនលើ $(0, 2)$ និង $(2, +\infty)$ ។
- បរមាធៀប ៖ ត្រង់ $x = 0$ ដេរីវេប្តូរសញ្ញាពី $-$ ទៅ $+$ នាំឱ្យ $f$ មានតម្លៃ**អប្បបរមាធៀប** គឺ $\boxed{f(0) = 0}$ ។

## គ. សង់តារាងអថេរភាព និងក្រាប $(C)$ ៖

- **តារាងអថេរភាព ៖**

| $x$ | $-\infty$ | | $-2$ | | $0$ | | $2$ | | $+\infty$ |
|---|---|---|---|---|---|---|---|---|---|
| $f'(x)$ | | $-$ | ‖ | $-$ | $0$ | $+$ | ‖ | $+$ | |
| $f(x)$ | $-1$ | ↘ | $-\infty$ ‖ $+\infty$ | ↘ | $0$ | ↗ | $+\infty$ ‖ $-\infty$ | ↗ | $-1$ |

- **សង់ក្រាប $(C)$ ៖**



## លំហាត់ទី ៧៥

គេឱ្យអនុគមន៍ $f(x)=\dfrac{2x^2-9x+4}{x^2+x-12}=\dfrac{(2x-1)(x-4)}{(x+4)(x-3)}$ មានក្រាប $(C)$ ។

ក. រកដែនកំណត់នៃ $f$ និងសមីការអាស៊ីមតូតទាំងអស់នៃ $(C)$ ។

ខ. រកចំណុចកាត់អ័ក្សកូអរដោនេនៃក្រាប $(C)$ ។

គ. សិក្សាអថេរភាព និងសង់ក្រាប $(C)$ ។

## ដំណោះស្រាយ

### ក. រកដែនកំណត់ និងអាស៊ីមតូតនៃ $(C)$ ៖

- ដែនកំណត់ ៖ ភាគបែង $x^2+x-12=(x+4)(x-3)\neq 0 \iff x\neq -4$ និង $x\neq 3$ ។
  **ដូចនេះ** $\boxed{D=\mathbb{R}\setminus\{-4,3\}}$ ។
- អាស៊ីមតូតដេក ៖

$$\lim_{x\to\pm\infty} f(x)=\lim_{x\to\pm\infty}\frac{2x^2-9x+4}{x^2+x-12}=\lim_{x\to\pm\infty}\frac{2x^2}{x^2}=2$$

  **ដូចនេះ បន្ទាត់** $\boxed{y=2}$ **ជាអាស៊ីមតូតដេកនៃក្រាប** $(C)$ **ខាង** $\pm\infty$ ។
- អាស៊ីមតូតឈរ ៖

$$\lim_{x\to -4^-} f(x)=+\infty \quad , \quad \lim_{x\to -4^+} f(x)=-\infty \implies \boxed{x=-4}$$
$$\lim_{x\to 3^-} f(x)=+\infty \quad , \quad \lim_{x\to 3^+} f(x)=-\infty \implies \boxed{x=3}$$

  **ដូចនេះ បន្ទាត់** $\boxed{x=-4}$ **និង** $\boxed{x=3}$ **ជាអាស៊ីមតូតឈរទាំងពីរនៃ** $(C)$ ។

### ខ. រកចំណុចកាត់អ័ក្សកូអរដោនេ និងអាស៊ីមតូត ៖

- ប្រសព្វនឹងអ័ក្ស $(Oy)$ $(x=0)$ ៖ $y=f(0)=\dfrac{4}{-12}=-\dfrac{1}{3} \implies \left(0,-\dfrac{1}{3}\right)$ ។
- ប្រសព្វនឹងអ័ក្ស $(Ox)$ $(y=0)$ ៖ $(2x-1)(x-4)=0 \iff x=\dfrac{1}{2}$ ឬ $x=4$ ។
  ចំណុចប្រសព្វគឺ $\left(\dfrac{1}{2},0\right)$ និង $(4,0)$ ។
- ប្រសព្វនឹងអាស៊ីមតូតដេក $y=2$ ៖

$$\frac{2x^2-9x+4}{x^2+x-12}=2 \iff 2x^2-9x+4=2x^2+2x-24 \iff 11x=28 \iff x=\frac{28}{11}$$

  ចំណុចប្រសព្វគឺ $\left(\dfrac{28}{11},2\right)$ ។

### គ. សិក្សាអថេរភាព និងសង់ក្រាប $(C)$ ៖

- **គុណនាដេរីវេ ៖**
ចំពោះគ្រប់ $x \in D$ គេមាន ៖

$$f'(x) = \frac{(4x-9)(x^2+x-12)-(2x^2-9x+4)(2x+1)}{(x^2+x-12)^2}$$
$$= \frac{(4x^3-5x^2-57x+108)-(4x^3-16x^2-x+4)}{(x^2+x-12)^2}$$
$$= \frac{11x^2-56x+104}{(x^2+x-12)^2}$$

ពិនិត្យត្រីធាភាគយក $11x^2-56x+104$ មាន $\Delta' = (-28)^2 - 11(104) = 784 - 1144 = -360 < 0$ និង $a = 11 > 0$ ។
នាំឱ្យ $11x^2-56x+104 > 0, \forall x \in \mathbb{R}$ ។
**ដូចនេះ** $f'(x) > 0$ **ចំពោះគ្រប់** $x \in D$ **នាំឱ្យ** $f$ **ជាអនុគមន៍កើនដាច់ខាតលើចន្លោះនីមួយៗនៃដែនកំណត់ ហើយគ្មានបរមាធៀបឡើយ ។**

- **តារាងអថេរភាព ៖**

| $x$ | $-\infty$ | $-4$ | | $3$ | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | $+$ | ‖ | $+$ | ‖ | $+$ |
| $f(x)$ | $2 \nearrow +\infty$ | ‖ | $-\infty \nearrow +\infty$ | ‖ | $-\infty \nearrow 2$ |

- **សង់ក្រាប** $(C)$ **៖**




**លំហាត់ទី ៧៦ & ៨០**

គេឱ្យអនុគមន៍ $f(x) = \dfrac{3x^2-18x+25}{x^2-6x+8}$ មានក្រាប $(C)$ ។

ក. បង្ហាញថា $f(x)=3+\dfrac{1}{(x-2)(x-4)}$ រួចទាញរកអាស៊ីមតូតទាំងអស់នៃ $(C)$ ។

ខ. សិក្សាអថេរភាព និងរកតម្លៃបរមាធៀបនៃ $f$ ។

គ. បង្ហាញថាបន្ទាត់ $x=3$ ជាអ័ក្សឆ្លុះនៃ $(C)$ និងសង់ក្រាប $(C)$ ។

## ដំណោះស្រាយ

**ក. បង្ហាញទម្រង់ $f(x)$ និងទាញរកអាស៊ីមតូត ៖**

- ដោយ $x^2-6x+8=(x-2)(x-4) \implies D=\mathbb{R}\setminus\{2,4\}$ ។
  គេមាន ៖

$$f(x)=\frac{3(x^2-6x+8)+1}{x^2-6x+8}=3+\frac{1}{x^2-6x+8}=3+\frac{1}{(x-2)(x-4)} \quad \text{(ពិត)}$$

- អាស៊ីមតូតដេក ៖

$$\lim_{x\to\pm\infty} f(x)=\lim_{x\to\pm\infty}\left[3+\frac{1}{(x-2)(x-4)}\right]=3+0=3$$

**ដូចនេះ បន្ទាត់ $\boxed{y=3}$ ជាអាស៊ីមតូតដេកនៃក្រាប $(C)$ ខាង $\pm\infty$ ។**

- អាស៊ីមតូតឈរ ៖

$$\lim_{x\to2^-} f(x)=+\infty \quad , \quad \lim_{x\to2^+} f(x)=-\infty \implies \boxed{x=2}$$
$$\lim_{x\to4^-} f(x)=-\infty \quad , \quad \lim_{x\to4^+} f(x)=+\infty \implies \boxed{x=4}$$

**ដូចនេះ បន្ទាត់ $\boxed{x=2}$ និង $\boxed{x=4}$ ជាអាស៊ីមតូតឈរទាំងពីរនៃ $(C)$ ។**

**ខ. សិក្សាអថេរភាព និងរកតម្លៃបរមាធៀបនៃ $f$ ៖**

- គណនាដេរីវេ ៖

$$f'(x)=\left[3+\frac{1}{x^2-6x+8}\right]'=-\frac{(x^2-6x+8)'}{(x^2-6x+8)^2}=\frac{-2(x-3)}{(x^2-6x+8)^2}$$

  $f'(x)=0 \iff -2(x-3)=0 \iff x=3$ ។
- ទិសដៅអថេរភាព ៖
  - ចំពោះ $x<3$ $(x\neq2)$ $\implies f'(x)>0$ នាំឱ្យ $f$ កើនលើ $(-\infty,2)$ និង $(2,3)$ ។
  - ចំពោះ $x>3$ $(x\neq4)$ $\implies f'(x)<0$ នាំឱ្យ $f$ ចុះលើ $(3,4)$ និង $(4,+\infty)$ ។
- បរមាធៀប ៖ ត្រង់ $x=3$ ដេរីវេប្តូរសញ្ញាពី $+$ ទៅ $-$ នាំឱ្យ $f$ មានតម្លៃ**អតិបរមាធៀប** គឺ ៖

$$f(3)=3+\frac{1}{(3-2)(3-4)}=3-1=\boxed{2}$$

- តារាងអថេរភាព ៖

| $x$ | $-\infty$ | | $2$ | | $3$ | | $4$ | | $+\infty$ |
|---|---|---|---|---|---|---|---|---|---|
| $f'(x)$ | | $+$ | ‖ | $+$ | $0$ | $-$ | ‖ | $-$ | |
| $f(x)$ | $3$ ↗ | $+\infty$ | ‖ | $-\infty$ ↗ | $2$ | ↘ $-\infty$ | ‖ | $+\infty$ ↘ | $3$ |

**គ**. បង្ហាញថា $x=3$ ជាអ័ក្សឆ្លុះ និងសង់ក្រាប $(C)$ ៖

- ចំពោះគ្រប់ $h$ ដែល $3+h\in D \iff 3-h\in D$ គេមាន ៖

$$f(3+h)=3+\frac{1}{(3+h-2)(3+h-4)}=3+\frac{1}{(1+h)(-1+h)}=3+\frac{1}{h^2-1}$$
$$f(3-h)=3+\frac{1}{(3-h-2)(3-h-4)}=3+\frac{1}{(1-h)(-1-h)}=3+\frac{1}{h^2-1}$$

ដោយ $f(3+h)=f(3-h)$ ដូចនេះ បន្ទាត់ $\boxed{x=3}$ ជាអ័ក្សឆ្លុះនៃក្រាប $(C)$ ។

- សង់ក្រាប $(C)$ ៖




## លំហាត់ទី ៧៧

គេឱ្យអនុគមន៍ $f(x)=\dfrac{x^2+2x}{x^2+4}$ មានក្រាប $(C)$ ។

**ក**. រកដែនកំណត់នៃ $f$ និងសមីការអាស៊ីមតូតនៃ $(C)$ ។

**ខ**. គណនាដេរីវេ $f'(x)$ និងរកតម្លៃបរមាធៀបនៃ $f$ ។

**គ**. សង់តារាងអថេរភាព និងក្រាប $(C)$ ។

## ដំណោះស្រាយ

ក. រកដែនកំណត់ និងសមីការអាស៊ីមតូត ៖

- ដោយភាគបែង $x^2+4>0, \forall x \in \mathbb{R} \Longrightarrow \boxed{D=\mathbb{R}}$ ។
  ក្រាប $(C)$ គ្មានអាស៊ីមតូតឈរឡើយ ។
- អាស៊ីមតូតដេក ៖

$$\lim_{x\to\pm\infty} f(x) = \lim_{x\to\pm\infty} \frac{x^2+2x}{x^2+4} = \lim_{x\to\pm\infty} \frac{1+\frac{2}{x}}{1+\frac{4}{x^2}} = 1$$

ដូចនេះ បន្ទាត់ $\boxed{y=1}$ ជាអាស៊ីមតូតដេកនៃក្រាប $(C)$ ខាង $\pm\infty$ ។

ខ. គណនាដេរីវេ $f'(x)$ និងរកតម្លៃបរមាធៀប ៖

- គណនាដេរីវេ ៖

$$\begin{aligned} f'(x) &= \frac{(2x+2)(x^2+4)-(x^2+2x)(2x)}{(x^2+4)^2} \\ &= \frac{(2x^3+2x^2+8x+8)-(2x^3+4x^2)}{(x^2+4)^2} \\ &= \frac{-2x^2+8x+8}{(x^2+4)^2} = \frac{-2(x^2-4x-4)}{(x^2+4)^2} \end{aligned}$$

- រកឫសនៃ $f'(x)=0 \Longleftrightarrow x^2-4x-4=0$ ៖
  មាន $\Delta' = (-2)^2-(1)(-4) = 4+4 = 8 = (2\sqrt{2})^2 > 0$ ៖

$$x_1 = 2-2\sqrt{2} \approx -0.83 \quad , \quad x_2 = 2+2\sqrt{2} \approx 4.83$$

- តម្លៃបរមាធៀប ៖
  – ត្រង់ $x_1 = 2-2\sqrt{2}$ ដេរីវេប្តូរសញ្ញាពី $-$ ទៅ $+$ នាំឱ្យ $f$ មានតម្លៃអប្បបរមាធៀប គឺ ៖

$$f\left(2-2\sqrt{2}\right) = \boxed{\frac{1-\sqrt{2}}{2}} \approx -0.21$$

  – ត្រង់ $x_2 = 2+2\sqrt{2}$ ដេរីវេប្តូរសញ្ញាពី $+$ ទៅ $-$ នាំឱ្យ $f$ មានតម្លៃអតិបរមាធៀប គឺ ៖

$$f\left(2+2\sqrt{2}\right) = \boxed{\frac{1+\sqrt{2}}{2}} \approx 1.21$$

គ. សង់តារាងអថេរភាព និងក្រាប $(C)$ ៖

- តារាងអថេរភាព ៖

| $x$ | $-\infty$ | | $2-2\sqrt{2}$ | | $2+2\sqrt{2}$ | | $+\infty$ |
|---|---|---|---|---|---|---|---|
| $f'(x)$ | | $-$ | $0$ | $+$ | $0$ | $-$ | |
| $f(x)$ | $1$ | $\searrow$ | $\frac{1-\sqrt{2}}{2}$ | $\nearrow$ | $\frac{1+\sqrt{2}}{2}$ | $\searrow$ | $1$ |

- ចំណុចប្រសព្វសំខាន់ៗ ៖
  - កាត់ $(Ox)$ ៖ $x^2+2x=0 \Longrightarrow O(0,0)$ និង $(-2,0)$ ។
  - កាត់អាស៊ីមតូតដេក $y=1$ ៖ $x^2+2x=x^2+4 \Longleftrightarrow 2x=4 \Longleftrightarrow x=2 \Longrightarrow (2,1)$ ។
- សង់ក្រាប $(C)$ ៖




---

## លំហាត់ទី ៧៨ & ៨២

គេឱ្យអនុគមន៍ $f(x)=\dfrac{x^2-1}{(x+2)^2}$ កំណត់លើ $\mathbb{R}\setminus\{-2\}$ មានក្រាប $(C)$ ។

ក. រកសមីការអាស៊ីមតូតដេក និងអាស៊ីមតូតឈរនៃ $(C)$ ។

ខ. សិក្សាអថេរភាព និងរកតម្លៃបរមាធៀបនៃ $f$ ។

គ. សង់តារាងអថេរភាព និងក្រាប $(C)$ ។

## ដំណោះស្រាយ

ក. **រកសមីការអាស៊ីមតូតនៃ $(C)$ ៖**

- អាស៊ីមតូតដេក ៖

$$\lim_{x\to\pm\infty} f(x)=\lim_{x\to\pm\infty}\frac{x^2-1}{x^2+4x+4}=\lim_{x\to\pm\infty}\frac{1-\frac{1}{x^2}}{1+\frac{4}{x}+\frac{4}{x^2}}=1$$

**ដូចនេះ បន្ទាត់ $\boxed{y=1}$ ជាអាស៊ីមតូតដេកនៃក្រាប $(C)$ ខាង $\pm\infty$ ។**

- អាស៊ីមតូតឈរ ៖

ដោយ $\lim_{x\to-2}(x^2-1)=3>0$ និង $(x+2)^2>0, \forall x\neq -2$ នោះ ៖

$$\lim_{x\to-2^-} f(x)=+\infty \quad , \quad \lim_{x\to-2^+} f(x)=+\infty$$

**ដូចនេះ បន្ទាត់ $\boxed{x=-2}$ ជាអាស៊ីមតូតឈរនៃក្រាប $(C)$ ។**

ខ. **សិក្សាអថេរភាព និងរកតម្លៃបរមាធៀបនៃ $f$ ៖**

- គណនាដេរីវេ ៖

$$f'(x)=\frac{2x(x+2)^2-(x^2-1)\cdot 2(x+2)}{(x+2)^4}=\frac{2x(x+2)-2(x^2-1)}{(x+2)^3}$$
$$=\frac{2x^2+4x-2x^2+2}{(x+2)^3}=\frac{4x+2}{(x+2)^3}=\frac{2(2x+1)}{(x+2)^3}$$

$f'(x)=0 \iff 2(2x+1)=0 \iff x=-\frac{1}{2}$ ។

- ទិសដៅអថេរភាព ៖
សញ្ញានៃ $f'(x)$ អាស្រ័យលើផលគុណ $(2x+1)(x+2)$ ៖
  - ចំពោះ $x\in(-\infty,-2)$ ៖ $2x+1<0$ និង $x+2<0 \implies f'(x)>0$ (អនុគមន៍កើន) ។
  - ចំពោះ $x\in\left(-2,-\frac{1}{2}\right)$ ៖ $2x+1<0$ និង $x+2>0 \implies f'(x)<0$ (អនុគមន៍ចុះ) ។
  - ចំពោះ $x\in\left(-\frac{1}{2},+\infty\right)$ ៖ $2x+1>0$ និង $x+2>0 \implies f'(x)>0$ (អនុគមន៍កើន) ។
- បរមាធៀប ៖ ត្រង់ $x=-\frac{1}{2}$ ដេរីវេប្តូរសញ្ញាពី $-$ ទៅ $+$ នាំឱ្យ $f$ មានតម្លៃ**អប្បបរមាធៀប** គឺ ៖

$$f\left(-\frac{1}{2}\right)=\frac{\left(-\frac{1}{2}\right)^2-1}{\left(-\frac{1}{2}+2\right)^2}=\frac{\frac{1}{4}-1}{\left(\frac{3}{2}\right)^2}=\frac{-\frac{3}{4}}{\frac{9}{4}}=\boxed{-\frac{1}{3}}$$

គ. សង់តារាងអថេរភាព និងក្រាប $(C)$ ៖

- តារាងអថេរភាព ៖

| $x$ | $-\infty$ | | $-2$ | | $-\frac{1}{2}$ | | $+\infty$ |
|---|---|---|---|---|---|---|---|
| $f'(x)$ | | $+$ | ‖ | $-$ | $0$ | $+$ | |
| $f(x)$ | $1$ | ↗ | $+\infty$ ‖ $+\infty$ | ↘ | $-\frac{1}{3}$ | ↗ | $1$ |

- ចំណុចកាត់អ័ក្សកូអរដោនេ ៖
  - កាត់ $(Oy)$ ៖ $x=0 \implies y=-\frac{1}{4} \implies \left(0,-\frac{1}{4}\right)$ ។
  - កាត់ $(Ox)$ ៖ $x^2-1=0 \implies (-1,0)$ និង $(1,0)$ ។
  - កាត់ $y=1$ ៖ $x^2-1=x^2+4x+4 \iff 4x=-5 \iff x=-\frac{5}{4} \implies \left(-\frac{5}{4},1\right)$ ។
- សង់ក្រាប $(C)$ ៖




---

## លំហាត់ទី ៧៩

គេឱ្យអនុគមន៍ $f(x)=\dfrac{-x^2-2x+3}{x^2+3x+2}=\dfrac{-(x+3)(x-1)}{(x+1)(x+2)}$ មានក្រាប $(C)$ ។

ក. រកដែនកំណត់ និងអាស៊ីមតូតទាំងអស់នៃ $(C)$ ។

ខ. សិក្សាអថេរភាព និងសង់ក្រាប $(C)$ ។

## ដំណោះស្រាយ

ក. រកដែនកំណត់ និងអាស៊ីមតូតនៃ $(C)$ ៖

- ដែនកំណត់ ៖ ភាគបែង $x^2+3x+2=(x+1)(x+2)\neq 0 \iff x\neq -2$ និង $x\neq -1$ ។
  ដូចនេះ $\boxed{D=\mathbb{R}\setminus\{-2,-1\}}$ ។
- អាស៊ីមតូតដេក ៖

$$\lim_{x\to\pm\infty} f(x)=\lim_{x\to\pm\infty}\frac{-x^2-2x+3}{x^2+3x+2}=\lim_{x\to\pm\infty}\frac{-x^2}{x^2}=-1$$

  ដូចនេះ បន្ទាត់ $\boxed{y=-1}$ ជាអាស៊ីមតូតដេកនៃក្រាប $(C)$ ខាង $\pm\infty$ ។
- អាស៊ីមតូតឈរ ៖

$$\lim_{x\to-2^-} f(x)=+\infty \quad , \quad \lim_{x\to-2^+} f(x)=-\infty \implies \boxed{x=-2}$$

$$\lim_{x\to-1^-} f(x)=-\infty \quad , \quad \lim_{x\to-1^+} f(x)=+\infty \implies \boxed{x=-1}$$

  ដូចនេះ បន្ទាត់ $\boxed{x=-2}$ និង $\boxed{x=-1}$ ជាអាស៊ីមតូតឈរទាំងពីរនៃ $(C)$ ។

ខ. សិក្សាអថេរភាព និងសង់ក្រាប $(C)$ ៖

- គណនាដេរីវេ ៖
  ចំពោះគ្រប់ $x\in D$ គេមាន ៖

$$f'(x)=\frac{(-2x-2)(x^2+3x+2)-(-x^2-2x+3)(2x+3)}{(x^2+3x+2)^2}$$

$$= \frac{(-2x^3-8x^2-10x-4)-(-2x^3-7x^2+9)}{(x^2+3x+2)^2}$$

$$= \frac{-x^2-10x-13}{(x^2+3x+2)^2} = \frac{-(x^2+10x+13)}{(x^2+3x+2)^2}$$

- **រកឫស និងបរមាធៀប ៖**
  $f'(x)=0 \iff x^2+10x+13=0$ មាន $\Delta'=5^2-13=12=(2\sqrt{3})^2>0$ ៖

  $$x_1=-5-2\sqrt{3}\approx -8.46 \quad , \quad x_2=-5+2\sqrt{3}\approx -1.54$$

  – ត្រង់ $x_1=-5-2\sqrt{3}$ ដេរីវេប្តូរសញ្ញាពី $-$ ទៅ $+$ នាំឱ្យ $f$ មានតម្លៃអប្បបរមាធៀប គឺ ៖

  $$f(x_1)=\boxed{-8+4\sqrt{3}}\approx -1.07$$

  – ត្រង់ $x_2=-5+2\sqrt{3}$ ដេរីវេប្តូរសញ្ញាពី $+$ ទៅ $-$ នាំឱ្យ $f$ មានតម្លៃអតិបរមាធៀប គឺ ៖

  $$f(x_2)=\boxed{-8-4\sqrt{3}}\approx -14.93$$

- **តារាងអថេរភាព ៖**

| $x$ | $-\infty$ | $-5-2\sqrt{3}$ | | $-2$ | | $-5+2\sqrt{3}$ | | $-1$ | | $+\infty$ |
|---|---|---|---|---|---|---|---|---|---|---|
| $f'(x)$ | $-$ | $0$ | $+$ | ‖ | $+$ | $0$ | $-$ | ‖ | $-$ | |
| $f(x)$ | $-1 \searrow$ | $-8+4\sqrt{3}$ | $\nearrow +\infty$ | ‖ | $-\infty \nearrow$ | $-8-4\sqrt{3}$ | $\searrow -\infty$ | ‖ | $+\infty \searrow$ | $-1$ |

- **ចំណុចប្រសព្វសំខាន់ៗ ៖**

  – កាត់ $(Oy)$ ៖ $x=0 \implies y=\frac{3}{2}=1.5 \implies (0,1.5)$ ។

  – កាត់ $(Ox)$ ៖ $y=0 \iff -(x+3)(x-1)=0 \implies (-3,0)$ និង $(1,0)$ ។

  – កាត់អាស៊ីមតូតដេក $y=-1$ ៖ $\frac{-x^2-2x+3}{x^2+3x+2}=-1 \iff x+5=0 \iff x=-5 \implies (-5,-1)$ ។

- **សង់ក្រាប $(C)$ ៖**



## លំហាត់ទី ៨១

គេឱ្យអនុគមន៍ $f(x)=\dfrac{3x^2-12x+10}{x^2-4x+3}=3+\dfrac{1}{(x-1)(x-3)}$ មានក្រាប $(C)$ ។

ក. រកដែនកំណត់ និងអាស៊ីមតូតទាំងអស់នៃ $(C)$ ។

ខ. រកតម្លៃបរមាធៀប និងអ័ក្សឆ្លុះនៃ $(C)$ ។

គ. សង់តារាងអថេរភាព និងក្រាប $(C)$ ។

## ដំណោះស្រាយ

### ក. រកដែនកំណត់ និងអាស៊ីមតូតនៃ $(C)$ ៖

- ដែនកំណត់ ៖ ភាគបែង $x^2-4x+3=(x-1)(x-3)\neq 0 \iff x\neq 1$ និង $x\neq 3$ ។
  **ដូចនេះ** $\boxed{D=\mathbb{R}\setminus\{1,3\}}$ ។
- អាស៊ីមតូតដេក ៖

$$\lim_{x\to\pm\infty} f(x)=\lim_{x\to\pm\infty}\left[3+\frac{1}{(x-1)(x-3)}\right]=3$$

**ដូចនេះ បន្ទាត់** $\boxed{y=3}$ **ជាអាស៊ីមតូតដេកនៃក្រាប** $(C)$ **ខាង** $\pm\infty$ ។

- អាស៊ីមតូតឈរ ៖

$$\lim_{x\to 1^-} f(x)=+\infty \quad , \quad \lim_{x\to 1^+} f(x)=-\infty \implies \boxed{x=1}$$
$$\lim_{x\to 3^-} f(x)=-\infty \quad , \quad \lim_{x\to 3^+} f(x)=+\infty \implies \boxed{x=3}$$

**ដូចនេះ បន្ទាត់** $\boxed{x=1}$ **និង** $\boxed{x=3}$ **ជាអាស៊ីមតូតឈរទាំងពីរនៃ** $(C)$ ។

### ខ. រកតម្លៃបរមាធៀប និងអ័ក្សឆ្លុះនៃ $(C)$ ៖

- គណនាដេរីវេ ៖

$$f'(x)=\left[3+\frac{1}{x^2-4x+3}\right]'=-\frac{(x^2-4x+3)'}{(x^2-4x+3)^2}=\frac{-(2x-4)}{(x^2-4x+3)^2}=\frac{-2(x-2)}{(x^2-4x+3)^2}$$

$f'(x)=0 \iff -2(x-2)=0 \iff x=2$ ។

- ទិសដៅអថេរភាព ៖
  - ចំពោះ $x<2$ $(x\neq 1)$ $\implies f'(x)>0$ នាំឱ្យ $f$ កើនលើ $(-\infty,1)$ និង $(1,2)$ ។
  - ចំពោះ $x>2$ $(x\neq 3)$ $\implies f'(x)<0$ នាំឱ្យ $f$ ចុះលើ $(2,3)$ និង $(3,+\infty)$ ។
- បរមាធៀប ៖ ត្រង់ $x=2$ ដេរីវេប្តូរសញ្ញាពី $+$ ទៅ $-$ នាំឱ្យ $f$ មានតម្លៃ**អតិបរមាធៀប** គឺ ៖

$$f(2)=3+\frac{1}{(2-1)(2-3)}=3-1=\boxed{2}$$

- អ័ក្សឆ្លុះ ៖ ចំពោះគ្រប់ $h$ ដែល $2+h \in D \iff 2-h \in D$ គេមាន ៖

$$f(2+h) = 3 + \frac{1}{(1+h)(-1+h)} = 3 + \frac{1}{h^2-1} = f(2-h)$$

ដូចនេះ បន្ទាត់ $\boxed{x=2}$ ជាអ័ក្សឆ្លុះនៃក្រាប $(C)$ ។

**គ.** សង់តារាងអថេរភាព និងក្រាប $(C)$ ៖

- តារាងអថេរភាព ៖

| $x$ | $-\infty$ | | $1$ | | $2$ | | $3$ | | $+\infty$ |
|---|---|---|---|---|---|---|---|---|---|
| $f'(x)$ | | $+$ | ‖ | $+$ | $0$ | $-$ | ‖ | $-$ | |
| $f(x)$ | $3$ | $\nearrow$ | $+\infty$ ‖ $-\infty$ | $\nearrow$ | $2$ | $\searrow$ | $-\infty$ ‖ $+\infty$ | $\searrow$ | $3$ |

- ចំណុចប្រសព្វសំខាន់ៗ ៖
  - កាត់ $(Oy)$ ៖ $x=0 \implies y = \dfrac{10}{3} \approx 3.33 \implies \left(0, \dfrac{10}{3}\right)$ ។
  - កាត់ $(Ox)$ ៖ $3x^2 - 12x + 10 = 0 \implies x = \dfrac{6 \pm \sqrt{6}}{3}$ ។
- សង់ក្រាប $(C)$ ៖




---

## លំហាត់ទី ៨៣

គេឱ្យអនុគមន៍ $f(x) = \dfrac{3x^2-6x}{x^2+x-2} = \dfrac{3x(x-2)}{(x-1)(x+2)}$ មានក្រាប $(C)$ ។

**ក.** រកដែនកំណត់ និងអាស៊ីមតូតទាំងអស់នៃ $(C)$ ។

ខ. សិក្សាអថេរភាព និងសង់ក្រាប $(C)$ ។

## ដំណោះស្រាយ

ក. ដែនកំណត់ និងអាស៊ីមតូតនៃក្រាប $(C)$ ៖

- ដែនកំណត់ ៖
  អនុគមន៍មានន័យកាលណាភាគបែងខុសពីសូន្យ ៖

$$x^2+x-2\neq 0 \iff (x-1)(x+2)\neq 0 \iff x\neq 1 \text{ និង } x\neq -2$$

ដូចនេះ $\boxed{D=\mathbb{R}\setminus\{-2,1\}=(-\infty,-2)\cup(-2,1)\cup(1,+\infty)}$ ។

- អាស៊ីមតូតដេក ៖
  គណនាលីមីតត្រង់អនន្ត ៖

$$\lim_{x\to\pm\infty} f(x)=\lim_{x\to\pm\infty}\frac{3x^2-6x}{x^2+x-2}=\lim_{x\to\pm\infty}\frac{3x^2}{x^2}=3$$

ដូចនេះ បន្ទាត់ $\boxed{y=3}$ ជាអាស៊ីមតូតដេកនៃក្រាប $(C)$ កាលណា $x\to\pm\infty$ ។

- អាស៊ីមតូតឈរ ៖
  - ត្រង់ $x\to -2$ ៖ ភាគយក $3(-2)^2-6(-2)=24\neq 0$

$$\lim_{x\to -2^-} f(x)=\lim_{x\to -2^-}\frac{3x(x-2)}{(x-1)(x+2)}=\frac{24}{(-3)(0^-)}=+\infty$$

$$\lim_{x\to -2^+} f(x)=\lim_{x\to -2^+}\frac{3x(x-2)}{(x-1)(x+2)}=\frac{24}{(-3)(0^+)}=-\infty$$

ដូចនេះ បន្ទាត់ $\boxed{x=-2}$ ជាអាស៊ីមតូតឈរនៃក្រាប $(C)$ ។

  - ត្រង់ $x\to 1$ ៖ ភាគយក $3(1)^2-6(1)=-3\neq 0$

$$\lim_{x\to 1^-} f(x)=\lim_{x\to 1^-}\frac{3x(x-2)}{(x-1)(x+2)}=\frac{-3}{(0^-)(3)}=+\infty$$

$$\lim_{x\to 1^+} f(x)=\lim_{x\to 1^+}\frac{3x(x-2)}{(x-1)(x+2)}=\frac{-3}{(0^+)(3)}=-\infty$$

ដូចនេះ បន្ទាត់ $\boxed{x=1}$ ជាអាស៊ីមតូតឈរនៃក្រាប $(C)$ ។

ខ. សិក្សាអថេរភាព និងសង់ក្រាប $(C)$ ៖

- គណនាដេរីវេ $f'(x)$ ៖
  ចំពោះគ្រប់ $x\in D$ គេមាន ៖

$$f'(x)=\frac{(3x^2-6x)'(x^2+x-2)-(3x^2-6x)(x^2+x-2)'}{(x^2+x-2)^2}$$
$$=\frac{(6x-6)(x^2+x-2)-(3x^2-6x)(2x+1)}{(x^2+x-2)^2}$$

$$= \frac{(6x^3-18x+12)-(6x^3-9x^2-6x)}{(x^2+x-2)^2}$$

$$= \frac{9x^2-12x+12}{(x^2+x-2)^2} = \frac{3(3x^2-4x+4)}{(x^2+x-2)^2}$$

ពិនិត្យត្រីធាភាគយក $3x^2-4x+4$ ៖
មាន $\Delta' = (-2)^2-3(4) = 4-12 = -8 < 0$ និងមេគុណ $a = 3 > 0$ ។
នាំឱ្យ $3x^2-4x+4 > 0, \forall x \in \mathbb{R}$ ។
ម្យ៉ាងទៀត ភាគបែង $(x^2+x-2)^2 > 0$ ចំពោះគ្រប់ $x \in D$ ។
**ដូចនេះ** $f'(x) > 0$ **ចំពោះគ្រប់** $x \in D$ ។

- **ទិសដៅអថេរភាព ៖**
  ដោយ $f'(x) > 0, \forall x \in D$ នាំឱ្យអនុគមន៍ $f$ ជាអនុគមន៍កើនដាច់ខាតលើចន្លោះនីមួយៗនៃដែនកំណត់គឺ $(-\infty,-2)$, $(-2,1)$ និង $(1,+\infty)$ ។
  អនុគមន៍គ្មានតម្លៃបរមាធៀបឡើយ ។
- **តារាងអថេរភាព ៖**

| $x$ | $-\infty$    $-2$ | $-2$    $1$ | $1$    $+\infty$ |
|---|---|---|---|
| $f'(x)$ | $+$ | $+$ | $+$ |
| $f(x)$ | $3 \nearrow +\infty$ | $-\infty \nearrow +\infty$ | $-\infty \nearrow 3$ |

- **ចំណុចប្រសព្វ និងធាតុសំខាន់ៗនៃក្រាប** $(C)$ ៖
  - ប្រសព្វនឹងអ័ក្ស $(Ox)$ ៖ $y = 0 \iff 3x(x-2) = 0 \iff x = 0$ ឬ $x = 2 \implies O(0,0)$ និង $A(2,0)$ ។
  - ប្រសព្វនឹងអ័ក្ស $(Oy)$ ៖ $x = 0 \implies y = 0 \implies O(0,0)$ ។
  - ប្រសព្វនឹងអាស៊ីមតូតដេក $y = 3$ ៖

$$f(x) = 3 \iff \frac{3x^2-6x}{x^2+x-2} = 3 \iff 3x^2-6x = 3(x^2+x-2) \iff -6x = 3x-6 \iff x = \frac{2}{3}$$

  ដូចនេះ ក្រាប $(C)$ កាត់អាស៊ីមតូតដេកត្រង់ចំណុច $B\left(\frac{2}{3},3\right)$ ។
  - តម្លៃពិសេសមួយចំនួន ៖
    $x=-3 \implies f(-3) = \frac{45}{4} = 11.25$ ; $\quad x=-4 \implies f(-4) = 7.2$ ;
    $x=-1 \implies f(-1) = -\frac{9}{2} = -4.5$ ; $\quad x=3 \implies f(3) = 0.9$ ; $\quad x=4 \implies f(4) = \frac{4}{3} \approx 1.33$ ។
- **សង់ក្រាប** $(C)$ ៖




## លំហាត់ទី ៨៤

គេឱ្យអនុគមន៍ $f(x)=\dfrac{x^2}{x^2+x-2}=\dfrac{x^2}{(x-1)(x+2)}$ មានក្រាប $(C)$ ។

ក. រកដែនកំណត់ និងសមីការអាស៊ីមតូតទាំងអស់នៃ $(C)$ ។

ខ. គណនាដេរីវេ $f'(x)$ រកបរមាធៀប និងសង់តារាងអថេរភាព ។

គ. សង់ក្រាប $(C)$ ក្នុងតម្រុយអរតូណរម៉ាល់ ។

## ដំណោះស្រាយ

ក. ដែនកំណត់ ៖ $\boxed{D=\mathbb{R}\setminus\{-2,1\}}$ ។

អាស៊ីមតូតដេក ៖ $\lim_{x\to\pm\infty} f(x)=1 \implies \boxed{y=1}$ ។

អាស៊ីមតូតឈរ ៖ $\boxed{x=-2}$ និង $\boxed{x=1}$ ។

ខ. ដេរីវេ ៖

$$f'(x)=\frac{2x(x^2+x-2)-x^2(2x+1)}{(x^2+x-2)^2}=\frac{x^2-4x}{(x^2+x-2)^2}=\frac{x(x-4)}{(x^2+x-2)^2}$$

$f'(x)=0 \iff x=0$ ឬ $x=4$ ៖

- អតិបរមាធៀប ៖ $f(0)=\boxed{0}$ ត្រង់ $x=0$ ។
- អប្បបរមាធៀប ៖ $f(4)=\dfrac{16}{16+4-2}=\dfrac{16}{18}=\boxed{\dfrac{8}{9}}$ ត្រង់ $x=4$ ។

តារាងអថេរភាព ៖

| $x$ | $-\infty$ | $-2$ | $0$ | $1$ | $4$ | $+\infty$ |
|---|---|---|---|---|---|---|
| $f'(x)$ | $+$ | ‖ $+$ | $0$ | $-$ ‖ $-$ | $0$ | $+$ |
| $f(x)$ | $1 \nearrow +\infty$ | ‖ $-\infty \nearrow$ | $0$ | $\searrow -\infty$ ‖ $+\infty \searrow$ | $\frac{8}{9}$ | $\nearrow 1$ |

គ. ក្រាបតំណាង $(C)$ ៖



# ដំណោះស្រាយ មេរៀនទី ២ ៖ អនុគមន៍អិចស្ប៉ូណង់ស្យែល

## ក. ចម្លើយសំណួរពហុជ្រើសរើស (MCQ)

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 |
| ក | ខ | ក | ក | ក | ក | ក | ក | ក | ក |
| 11 | 12 | 13 | 14 | 15 | 16 | 17 | 18 | 19 | 20 |
| ក | ក | ក | ក | ក | ក | ក | ក | ក | ក |
| 21 | 22 | 23 | 24 | 25 | 26 | 27 | 28 | 29 | 30 |
| ក | ក | ក | ក | ក | ក | ក | ក | ក | ក |
| 31 | 32 | 33 | 34 | 35 | 36 | 37 | 38 | 39 | 40 |
| ក | ក | ក | ក | ក | ក | ក | ក | ក | ក |
| 41 | 42 | 43 | 44 | 45 | 46 | 47 | 48 | 49 | 50 |
| ក | ក | ក | ក | ក | ក | ក | ក | ក | ក |
| 51 | 52 | 53 | 54 | 55 | 56 | 57 | 58 | 59 | 60 |
| ក | ក | ក | ក | ក | ក | ក | ក | ក | ក |
| 61 | 62 | 63 | 64 | 65 | 66 | 67 | 68 | 69 | 70 |
| ក | ក | ក | ក | ក | ក | ក | ក | ក | ក |
| 71 | 72 | 73 | 74 | 75 | 76 | 77 | 78 | 79 | 80 |
| ក | ក | ក | ក | ក | ក | ក | ក | ក | ក |
| 81 | 82 | 83 | 84 | 85 | 86 | 87 | 88 | 89 | 90 |
| ក | ក | ក | ក | ក | ក | ក | ក | ក | ក |
| 91 | 92 | 93 | 94 | 95 | 96 | 97 | 98 | 99 | 100 |
| ក | ក | ក | ក | ក | ក | ក | ក | ក | ក |

មេរៀនទី ៤ ផ្នែកដំណោះស្រាយ

# ខ. ដំណោះស្រាយលម្អិតនៃលំហាត់អនុវត្តន៍

## លំហាត់ទី ១

គេឱ្យអនុគមន៍ $f$ កំណត់លើ $\mathbb{R}$ ដោយ $f(x)=e^x-x-1$ និងមានក្រាប $(C)$ ក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j})$ ។

ក. គណនា $\lim\limits_{x\to+\infty} f(x)$ និង $\lim\limits_{x\to-\infty} f(x)$ ។

ខ. គណនា $f'(x)$ រួចសិក្សាសញ្ញារបស់វា ទាញថា $f$ មានអប្បបរមាធៀបមួយ រួចគណនាតម្លៃបរមាធៀបនោះ។ ចូរគូសតារាងអថេរភាពនៃ $f$ ។

គ. បង្ហាញថា បន្ទាត់ $d: y=-x-1$ ជាអាស៊ីមតូតទ្រេតនៃខ្សែកោង $(C)$ កាលណា $x\to-\infty$ ។

ឃ. កំណត់កូអរដោនេនៃចំណុច $P$ នៃ $(C)$ ដែលបន្ទាត់ប៉ះនឹង $(C)$ ត្រង់ចំណុចនេះស្របទៅនឹងបន្ទាត់ $y=x$ ។

ង. សង់ $(C)$ និងបន្ទាត់ $d$ និងបន្ទាត់ប៉ះត្រង់ $P$ ។ (យក $\ln 2\approx 0.7$)

## ដំណោះស្រាយ

**ក. គណនាលីមីត $\lim\limits_{x\to+\infty} f(x)$ និង $\lim\limits_{x\to-\infty} f(x)$ ៖**

- កាលណា $x\to+\infty$ ៖ $\lim\limits_{x\to+\infty} f(x)=\lim\limits_{x\to+\infty} x\left(\frac{e^x}{x}-1-\frac{1}{x}\right)=+\infty$ ព្រោះ $\lim\limits_{x\to+\infty}\frac{e^x}{x}=+\infty$ និង $\lim\limits_{x\to+\infty}\frac{1}{x}=0$ ។
- កាលណា $x\to-\infty$ ៖ $\lim\limits_{x\to-\infty} f(x)=\lim\limits_{x\to-\infty}(e^x-x-1)=0-(-\infty)-1=+\infty$ ព្រោះ $\lim\limits_{x\to-\infty} e^x=0$ ។

**ខ. គណនា $f'(x)$ សិក្សាសញ្ញា និងគូសតារាងអថេរភាព ៖**

- ដេរីវេ ៖ ចំពោះគ្រប់ $x\in\mathbb{R}$ គេបាន $f'(x)=(e^x-x-1)'=e^x-1$ ។
- សញ្ញា $f'(x)$ ៖ $f'(x)=0 \iff e^x-1=0 \iff x=0$ ។ - បើ $x<0 \implies f'(x)<0$ ($f$ ចុះដាច់ខាតលើ $(-\infty,0)$) ។
 - បើ $x>0 \implies f'(x)>0$ ($f$ កើនដាច់ខាតលើ $(0,+\infty)$) ។
- បរមាធៀប ៖ $f'(x)$ ប្តូរសញ្ញាពី $(-)$ ទៅ $(+)$ ត្រង់ $x=0$ នាំឱ្យ $f$ មានអប្បបរមាធៀបគឺ $f(0)=e^0-0-1=0$ ។
- តារាងអថេរភាពនៃ $f$ ៖

| $x$ | $-\infty$ | | $0$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | | $-$ | $0$ | $+$ | |
| $f(x)$ | $+\infty$ | $\searrow$ | $0$ | $\nearrow$ | $+\infty$ |

**គ. បង្ហាញថាបន្ទាត់ $d: y=-x-1$ ជាអាស៊ីមតូតទ្រេតខាង $-\infty$ ៖**

- ពិនិត្យផលដក ៖ $f(x)-(-x-1)=(e^x-x-1)+x+1=e^x$ ។

- លីមីត ៖ $\lim_{x\to-\infty}[f(x)-(-x-1)] = \lim_{x\to-\infty} e^x = 0$ ។
  ដូចនេះ បន្ទាត់ $d: y=-x-1$ ជាអាស៊ីមតូតទ្រេតនៃក្រាប $(C)$ ខាង $-\infty$ ។
- ទីតាំងធៀប ៖ ដោយ $e^x > 0, \forall x \implies f(x) - y_d > 0$ នោះក្រាប $(C)$ នៅលើបន្ទាត់ $d$ ជានិច្ច ។

ឃ. កំណត់កូអរដោនេនៃចំណុច $P$ ដែលបន្ទាត់ប៉ះស្របនឹងបន្ទាត់ $y=x$ ៖

- បន្ទាត់ $y=x$ មានមេគុណប្រាប់ទិស $m=1$ ។
- បន្ទាត់ប៉ះស្របនឹង $y=x \iff f'(x_P)=1 \iff e^{x_P}-1=1 \iff e^{x_P}=2 \iff x_P=\ln 2\approx 0.7$ ។
- អរដោនេ ៖ $y_P = f(\ln 2) = e^{\ln 2} - \ln 2 - 1 = 2 - \ln 2 - 1 = 1 - \ln 2 \approx 0.3$ ។
  ដូចនេះ ចំណុច $P$ មានកូអរដោនេ $P(\ln 2, 1-\ln 2) \approx P(0.7, 0.3)$ ។
- សមីការបន្ទាត់ប៉ះ $(T_P)$ ៖ $y = 1\cdot(x-\ln 2) + 1 - \ln 2 = x + 1 - 2\ln 2 \approx x - 0.386$ ។

ង. សង់ក្រាប $(C)$ អាស៊ីមតូត $d$ និងបន្ទាត់ប៉ះ $T_P$ ក្នុងតម្រុយរួមគ្នា ៖




តារាងសង្ខេបធាតុសំខាន់ៗនៃក្រាប $(C)$ ៖

| ធាតុសំខាន់ៗ | សមីការ / កូអរដោនេពិត | តម្លៃប្រហែល |
|---|---|---|
| ដែនកំណត់ | $D=\mathbb{R}$ | $(-\infty,+\infty)$ |
| អាស៊ីមតូតទ្រេតខាង $-\infty$ | $d: y=-x-1$ | $y=-x-1$ |
| ចំណុចអប្បបរមាធៀប | $O(0,0)$ | $(0,0)$ |
| ចំណុចប៉ះ $P$ | $P(\ln 2, 1-\ln 2)$ | $(0.693, 0.307)$ |
| បន្ទាត់ប៉ះត្រង់ $P$ | $y=x+1-2\ln 2$ | $y\approx x-0.386$ |

## លំហាត់ទី ២

គេឱ្យអនុគមន៍ $f$ កំណត់លើ $\mathbb{R}$ ដោយ $f(x)=x-1+\frac{2}{e^x}$ និងមានក្រាប $(C)$ ក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j})$ ។

ក. កំណត់លីមីតនៃ $f(x)$ កាលណា $x\to+\infty$ ។ បង្ហាញថា បន្ទាត់ $d:y=x-1$ ជាអាស៊ីមតូតទ្រេតនៃ $(C)$ ។

ខ. បង្ហាញថា $f(x)=\frac{xe^x-e^x+2}{e^x}$ រួចទាញរកលីមីតនៃ $f(x)$ កាលណា $x\to-\infty$ ។

គ. គណនា $f'(x)$ រួចសិក្សាសញ្ញារបស់វា។ សង់តារាងអថេរភាពនៃ $f$ ។

ឃ. សរសេរសមីការបន្ទាត់ប៉ះ $T$ ទៅនឹង $(C)$ ត្រង់ចំណុចដែលមានអាប់ស៊ីស $0$ ។

ង. តាមក្រាហ្វិក កំណត់ចំនួនឫសនៃសមីការ $f(x)=2$ រួចអមឫសទាំងនោះដោយចំនួនគត់ពីរតគ្នា។

## ដំណោះស្រាយ

### ក. លីមីតត្រង់ $+\infty$ និងអាស៊ីមតូតទ្រេត $d$ ៖

- $\lim\limits_{x\to+\infty} f(x)=\lim\limits_{x\to+\infty}\left(x-1+\frac{2}{e^x}\right)=+\infty$ ព្រោះ $\lim\limits_{x\to+\infty}(x-1)=+\infty$ និង $\lim\limits_{x\to+\infty}\frac{2}{e^x}=0$ ។
- $\lim\limits_{x\to+\infty}[f(x)-(x-1)]=\lim\limits_{x\to+\infty}\frac{2}{e^x}=0 \implies d:y=x-1$ ជាអាស៊ីមតូតទ្រេតខាង $+\infty$ ។
- ទីតាំងធៀប ៖ $f(x)-(x-1)=\frac{2}{e^x}>0,\forall x \implies$ ក្រាប $(C)$ នៅលើបន្ទាត់ $d$ ជានិច្ច ។

### ខ. ទម្រង់ប្រភាគនៃ $f(x)$ និងលីមីតត្រង់ $-\infty$ ៖

- $f(x)=x-1+\frac{2}{e^x}=\frac{(x-1)e^x+2}{e^x}=\frac{xe^x-e^x+2}{e^x}$ (ពិត) ។
- គណនាលីមីត ៖ $\lim\limits_{x\to-\infty}(xe^x-e^x+2)=0-0+2=2$ និង $\lim\limits_{x\to-\infty}e^x=0^+$ ។

  ដូចនេះ $\lim\limits_{x\to-\infty} f(x)=\frac{2}{0^+}=+\infty$ ។

### គ. គណនា $f'(x)$ សិក្សាសញ្ញា និងសង់តារាងអថេរភាព ៖

- ដេរីវេ ៖ $f'(x)=1-2e^{-x}=\frac{e^x-2}{e^x}$ ។
- សញ្ញា ៖ $f'(x)=0 \iff e^x-2=0 \iff x=\ln 2\approx 0.693$ ។ - បើ $x<\ln 2 \implies f'(x)<0$ ($f$ ចុះ); បើ $x>\ln 2 \implies f'(x)>0$ ($f$ កើន) ។
- អប្បបរមាធៀប ៖ $f(\ln 2)=\ln 2-1+\frac{2}{2}=\ln 2\approx 0.693$ ។
- តារាងអថេរភាព ៖

| $x$ | $-\infty$ | | $\ln 2$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | | $-$ | $0$ | $+$ | |
| $f(x)$ | $+\infty$ | ↘ | $\ln 2$ | ↗ | $+\infty$ |

### ឃ. សមីការបន្ទាត់ប៉ះ $T$ ត្រង់ $x_0=0$ ៖ $f(0)=1,\ f'(0)=1-2=-1 \implies (T):y=-1(x-0)+1 \iff y=-x+1$ ។

ង. **កំណត់ចំនួនឫសនៃ $f(x)=2$ និងអមដោយចំនួនគត់ពីរតគ្នា ៖** ដោយ $\min f=\ln 2\approx 0.693<2$ ហើយ $f\to+\infty$ សងខាង នោះបន្ទាត់ $y=2$ កាត់ក្រាប $(C)$ ត្រង់ពីរចំណុចផ្សេងគ្នា $x_1<\ln 2<x_2$ (សមីការមានឫសពីរផ្សេងគ្នា) ៖ - $f(-1)=2e-2\approx 3.44>2$ និង $f(0)=1<2 \implies -1<x_1<0$ ។

- $f(2)=1+\frac{2}{e^2}\approx 1.27<2$ និង $f(3)=2+\frac{2}{e^3}\approx 2.10>2 \implies 2<x_2<3$ ។

ច. សង់ក្រាប $(C)$ អាស៊ីមតូត $d$ និងបន្ទាត់ប៉ះ $T$ ៖




តារាងសង្ខេបជាតុសំខាន់ៗនៃក្រាប $(C)$ ៖

| ជាតុសំខាន់ៗ | សមីការ / កូអរដោនេពិត | តម្លៃប្រហែល |
|---|---|---|
| អាស៊ីមតូតទ្រេតខាង $+\infty$ | $d: y = x - 1$ | $y = x - 1$ |
| ចំណុចអប្បបរមាធៀប | $M(\ln 2, \ln 2)$ | $(0.693, 0.693)$ |
| ប្រសព្វអ័ក្ស $(Oy)$ | $(0,1)$ | $(0,1)$ |
| បន្ទាត់ប៉ះត្រង់ $x = 0$ | $(T): y = -x + 1$ | $y = -x + 1$ |
| ឫសទីមួយនៃ $f(x) = 2$ | $x_1 \in (-1, 0)$ | $x_1 \approx -0.584$ |
| ឫសទីពីរនៃ $f(x) = 2$ | $x_2 \in (2, 3)$ | $x_2 \approx 2.843$ |

## លំហាត់ទី ៣

គេឱ្យអនុគមន៍ $f$ កំណត់លើ $\mathbb{R}\setminus\{0\}$ ដោយ $f(x)=\frac{e^x}{x}$ និងមានក្រាប $(C)$ ក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j})$ ។

ក. គណនាលីមីត $\lim\limits_{x\to+\infty} f(x)$, $\lim\limits_{x\to-\infty} f(x)$ និង $\lim\limits_{x\to 0} f(x)$ ។ ទាញរកអាស៊ីមតូតនៃក្រាប $(C)$ ។

ខ. គណនា និងសិក្សាសញ្ញាដេរីវេ $f'(x)$ ។ បង្ហាញថាអនុគមន៍ $f$ មានអប្បបរមាមួយ។ គណនាតម្លៃអប្បបរមានេះ ហើយសង់តារាងអថេរភាពនៃ $f$ ។

គ. បង្ហាញថា បន្ទាត់ប៉ះនឹងក្រាប $(C)$ ត្រង់អាប់ស៊ីស $x_0=1$ ជាបន្ទាត់ស្របនឹងអ័ក្សអាប់ស៊ីស។

ឃ. សង់ក្រាប $(C)$ ។ ប្រើក្រាប $(C)$ ចូរកំណត់តម្លៃ $m$ ដើម្បីឱ្យសមីការ $e^x-mx=0$ មានឫស។

## ដំណោះស្រាយ

ក. **គណនាលីមីត និងទាញរកអាស៊ីមតូតនៃក្រាប $(C)$ ៖**

- $\lim\limits_{x\to+\infty}\frac{e^x}{x}=+\infty$ (រូបមន្តគ្រឹះ) ។
- $\lim\limits_{x\to-\infty}\frac{e^x}{x}=\frac{0}{-\infty}=0 \implies y=0$ (អ័ក្ស $Ox$) ជា**អាស៊ីមតូតដេកខាង** $-\infty$ ។
- $\lim\limits_{x\to 0^+}\frac{e^x}{x}=\frac{1}{0^+}=+\infty$ និង $\lim\limits_{x\to 0^-}\frac{e^x}{x}=\frac{1}{0^-}=-\infty \implies x=0$ (អ័ក្ស $Oy$) ជា**អាស៊ីមតូតឈរ** ។

ខ. **គណនា $f'(x)$ សិក្សាសញ្ញា អប្បបរមា និងតារាងអថេរភាព ៖**

- $f'(x)=\frac{(e^x)'x-e^x(x)'}{x^2}=\frac{(x-1)e^x}{x^2}$ ។
- ដោយ $e^x>0$ និង $x^2>0$ ចំពោះគ្រប់ $x\neq 0$ នោះសញ្ញានៃ $f'(x)$ គឺតាម $(x-1)$ ៖
$f'(x)=0 \iff x=1$ ។ $f'(x)<0$ លើ $(-\infty,0)\cup(0,1)$ ($f$ ចុះ) និង $f'(x)>0$ លើ $(1,+\infty)$ ($f$ កើន) ។
- អប្បបរមាធៀបត្រង់ $x=1$ គឺ $f(1)=\frac{e^1}{1}=e\approx 2.718$ ។
- តារាងអថេរភាពនៃ $f$ ៖

| $x$ | $-\infty$ | | $0$ | | $1$ | | $+\infty$ |
|---|---|---|---|---|---|---|---|
| $f'(x)$ | | $-$ | ‖ | $-$ | $0$ | $+$ | |
| $f(x)$ | $0$ ↘ | $-\infty$ | ‖ | $+\infty$ ↘ | $e$ | ↗ | $+\infty$ |

គ. **បន្ទាត់ប៉ះត្រង់ $x_0=1$ ស្របនឹងអ័ក្សអាប់ស៊ីស ៖** $f'(1)=0 \implies (T): y=f'(1)(x-1)+f(1)=e$ (ជាបន្ទាត់ដេកស្របនឹងអ័ក្ស $Ox$) ។

ឃ. **ពិភាក្សាឫសនៃសមីការ $e^x-mx=0$ ៖** ចំពោះ $x\neq 0$ សមីការសមមូលនឹង $\frac{e^x}{x}=m \iff f(x)=m$ ។ តាមក្រាប និងតារាងអថេរភាព ៖ - បើ $m<0$ ៖ បន្ទាត់ $y=m$ កាត់ $(C)$ ខ្នែង $x<0$ ត្រង់មួយចំណុច $\implies$ មានឫសអវិជ្ជមានមួយ ។
- បើ $0\le m<e$ ៖ បន្ទាត់ $y=m$ មិនកាត់ $(C)$ ឡើយ $\implies$ គ្មានឫស ។
- បើ $m=e$ ៖ បន្ទាត់ $y=e$ ប៉ះ $(C)$ ត្រង់ $(1,e)$ $\implies$ មានឫសឌុប $x=1$ ។
- បើ $m>e$ ៖ បន្ទាត់ $y=m$ កាត់ $(C)$ ខ្នែង $x>0$ ត្រង់ពីរចំណុច $\implies$ មានឫសវិជ្ជមានពីរ ។

**សន្និដ្ឋាន ៖** សមីការមានឫសលុះត្រាតែ $m<0$ ឬ $m\ge e$ ។

ង. សង់ក្រាប $(C)$ អាស៊ីមតូត និងបន្ទាត់ប៉ះ ៖




តារាងសង្ខេបធាតុសំខាន់ៗនៃក្រាប $(C)$ ៖

| ធាតុសំខាន់ៗ | សមីការ / កូអរដោនេពិត | តម្លៃប្រហែល |
|---|---|---|
| ដែនកំណត់ | $D = \mathbb{R} \setminus \{0\}$ | $(-\infty, 0) \cup (0, +\infty)$ |
| អាស៊ីមតូតឈរ | $x = 0$ (អ័ក្ស $Oy$) | $x = 0$ |
| អាស៊ីមតូតដេកខាង $-\infty$ | $y = 0$ (អ័ក្ស $Ox$) | $y = 0$ |
| ចំណុចអប្បបរមាធៀប | $M(1, e)$ | $(1, 2.718)$ |
| បន្ទាត់ប៉ះត្រង់ $x = 1$ | $y = e$ (ស្របនឹងអ័ក្ស $Ox$) | $y \approx 2.718$ |
| លក្ខខណ្ឌ $e^x - mx = 0$ មានឫស | $m < 0$ ឬ $m \geq e$ | $m \in (-\infty, 0) \cup [2.718, +\infty)$ |

## លំហាត់ទី ៤

អនុគមន៍ $f$ កំណត់លើ $\mathbb{R}$ ដោយ $f(x)=(2x+1)e^{-2x}$ ហើយមានក្រាប $(C)$ ក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j})$ ។

ក. គណនាលីមីតកាលណា $x$ ខិតជិត $-\infty$ និង $+\infty$ រួចទាញសមីការអាស៊ីមតូតដេកនៃ $(C)$ ។

ខ. គណនាដេរីវេ $f'(x)$ និងសិក្សាសញ្ញា រួចគូសតារាងអថេរភាព។

គ. រកចំណុចប្រសព្វ $A$ រវាងក្រាប $(C)$ និងអ័ក្ស $x'Ox$ ។ សិក្សាសញ្ញានៃ $f$ ។

ឃ. សរសេរសមីការបន្ទាត់ប៉ះ $T$ ទៅនឹងក្រាប $(C)$ ត្រង់ចំណុច $A$ ។ សង់ក្រាប $(C)$ បន្ទាត់អាស៊ីមតូត និងបន្ទាត់ប៉ះ $T$ ក្នុងតម្រុយតែមួយ។

ង. ដោយប្រើក្រាប $(C)$ ចូរកំណត់តម្លៃ $m$ ដើម្បីឱ្យសមីការ $(2x+1)e^{-2x}=m$ មានឫសពីរផ្សេងគ្នា។

## ដំណោះស្រាយ

**ក. គណនាលីមីត និងទាញរកអាស៊ីមតូតដេក ៖**

- $\lim\limits_{x\to+\infty}(2x+1)e^{-2x}=\lim\limits_{x\to+\infty}\left(\frac{2x}{e^{2x}}+\frac{1}{e^{2x}}\right)=0 \implies y=0$ (អ័ក្ស $Ox$) ជា**អាស៊ីមតូតដេក**ខាង $+\infty$ ។
- $\lim\limits_{x\to-\infty}(2x+1)e^{-2x}=(-\infty)(+\infty)=-\infty$ ។

**ខ. គណនា $f'(x)$ សិក្សាសញ្ញា និងគូសតារាងអថេរភាព ៖**

- $f'(x)=2e^{-2x}+(2x+1)(-2e^{-2x})=-4xe^{-2x}$ ។
- ដោយ $e^{-2x}>0,\forall x$ នោះសញ្ញា $f'(x)$ គឺតាម $-4x$ ៖ $f'(x)=0 \iff x=0$ ។
  បើ $x<0 \implies f'(x)>0$ ($f$ កើន); បើ $x>0 \implies f'(x)<0$ ($f$ ចុះ) ។
- អតិបរមាធៀបត្រង់ $x=0$ គឺ $f(0)=(2(0)+1)e^{0}=1$ ។
- តារាងអថេរភាពនៃ $f$ ៖

| $x$ | $-\infty$ | | $0$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | | $+$ | $0$ | $-$ | |
| $f(x)$ | $-\infty$ | $\nearrow$ | $1$ | $\searrow$ | $0$ |

**គ. រកចំណុចប្រសព្វ $A$ និងសិក្សាសញ្ញានៃ $f(x)$ ៖** $f(x)=0 \iff 2x+1=0 \iff x=-\frac{1}{2} \implies A\left(-\frac{1}{2},0\right)$ ។
សញ្ញានៃ $f(x)$ គឺតាម $(2x+1)$ ៖ $f(x)<0$ លើ $\left(-\infty,-\frac{1}{2}\right)$, $f\left(-\frac{1}{2}\right)=0$, $f(x)>0$ លើ $\left(-\frac{1}{2},+\infty\right)$ ។

**ឃ. សមីការបន្ទាត់ប៉ះ $T$ ត្រង់ $A$ ៖** $f'\left(-\frac{1}{2}\right)=2e\approx 5.44 \implies (T): y=2e\left(x+\frac{1}{2}\right)=2ex+e\approx 5.437x+2.718$ ។

**ង. កំណត់ $m$ ដើម្បីឱ្យ $(2x+1)e^{-2x}=m$ មានឫសពីរផ្សេងគ្នា ៖** សមីការសមមូលនឹង $f(x)=m$ ។ តាមតារាងអថេរភាព $f$ កើនពី $-\infty$ ទៅ $1$ ហើយចុះទៅជិត $0$ ខាងស្តាំ។ ដូចនេះ បន្ទាត់ $y=m$ កាត់ $(C)$ ត្រង់ពីរចំណុចផ្សេងគ្នា លុះត្រាតែ $0<m<1$ ។

ច. សង់ក្រាប $(C)$ អាស៊ីមតូត និងបន្ទាត់ប៉ះ $T$ ៖




តារាងសង្ខេបធាតុសំខាន់ៗនៃក្រាប $(C)$ ៖

| ធាតុសំខាន់ៗ | សមីការ / កូអរដោនេពិត | តម្លៃប្រហែល |
|---|---|---|
| អាស៊ីមតូតដេកខាង $+\infty$ | $y=0$ (អ័ក្ស $Ox$) | $y=0$ |
| ចំណុចអតិបរមាធៀប | $M(0,1)$ | $(0,1)$ |
| ក | ក | ក | ក | ក | ក | ក | ក | ក | ក |
| 81 | 82 | 83 | 84 | 85 | 86 | 87 | 88 | 89 | 90 |
| ក | ក | ក | ក | ក | ក | ក | ក | ក | ក |
| 91 | 92 | 93 | 94 | 95 | 96 | 97 | 98 | 99 | 100 |
| ក | ក | ក | ក | ក | ក | ក | ក | ក | ក |

## ខ. ដំណោះស្រាយលម្អិតនៃលំហាត់អនុវត្តន៍

### លំហាត់ទី ១

គណនាតម្លៃនៃកន្សោមខាងក្រោម ៖

ក. $A = e^{\ln 7}$  ខ. $B = \ln(e^{x-2})$  គ. $C = \ln(e^{7x})$

### ដំណោះស្រាយ

ក. $A = e^{\ln 7}$ ៖
តាមរូបមន្តគ្រឹះនៃអនុគមន៍អិចស្ប៉ូណង់ស្យែល និងលោការីតនេពែរ $e^{\ln u} = u$ (ចំពោះ $u > 0$) ៖

$$A = e^{\ln 7} = \mathbf{7} \implies \boxed{A = 7}$$

ខ. $B = \ln(e^{x-2})$ ៖
តាមរូបមន្ត $\ln(e^u) = u$ (ចំពោះគ្រប់ $u \in \mathbb{R}$) ៖

$$B = \ln(e^{x-2}) = \mathbf{x-2} \implies \boxed{B = x-2}$$

គ. $C = \ln(e^{7x})$ ៖
អនុវត្តរូបមន្ត $\ln(e^u) = u$ ដោយ $u = 7x$ ៖

$$C = \ln(e^{7x}) = \mathbf{7x} \implies \boxed{C = 7x}$$

---

### លំហាត់ទី ២

សង់ក្រាបនៃអនុគមន៍ ៖

ក. $y = 3 - \ln x$

ខ. $y = \ln(x-3)$

គ. $y = \ln(2 + e^x)$

### ដំណោះស្រាយ

ក. $y = 3 - \ln x$ ៖

**១. ដែនកំណត់ ៖** $D = (0, +\infty)$ ។

**២. លីមីត និងអាស៊ីមតូត ៖**

- $\lim_{x \to 0^+} (3 - \ln x) = 3 - (-\infty) = +\infty \implies \boxed{x = 0}$ (អ័ក្ស $Oy$) ជាអាស៊ីមតូតឈរ។
- $\lim_{x \to +\infty} (3 - \ln x) = -\infty$ ។

៣. ដេរីវេ ៖ $y' = -\frac{1}{x} < 0, \forall x > 0 \implies$ អនុគមន៍ចុះដាច់ខាតលើ $(0, +\infty)$។

៤. ចំណុចប្រសព្វ ៖

- ប្រសព្វអ័ក្ស $(Ox)$ ៖ $3 - \ln x = 0 \iff \ln x = 3 \iff x = e^3 \approx 20.09$ ។
- ចំណុចងាយ ៖ បើ $x = 1 \implies y = 3$ ; បើ $x = e \approx 2.72 \implies y = 2$ ។




ខ. $y = \ln(x-3)$ ៖

១. ដែនកំណត់ ៖ $x - 3 > 0 \iff \boxed{D = (3, +\infty)}$ ។

២. លីមីត និងអាស៊ីមតូត ៖

- $\lim_{x \to 3^+} \ln(x-3) = -\infty \implies \boxed{x = 3}$ ជាអាស៊ីមតូតឈរ។
- $\lim_{x \to +\infty} \ln(x-3) = +\infty$ ។

៣. ដេរីវេ ៖ $y' = \frac{1}{x-3} > 0, \forall x > 3 \implies$ អនុគមន៍កើនដាច់ខាតលើ $(3, +\infty)$។

៤. ចំណុចប្រសព្វ ៖ $y = 0 \iff x - 3 = 1 \iff x = 4$ ។ ក្រាបកាត់អ័ក្ស $(Ox)$ ត្រង់ $(4, 0)$។




គ. $y = \ln(2 + e^x)$ ៖

១. ដែនកំណត់ ៖ ដោយ $e^x > 0, \forall x \in \mathbb{R} \implies 2 + e^x > 2 > 0 \implies \boxed{D = \mathbb{R}}$ ។

២. លីមីត និងអាស៊ីមតូត ៖

- $\lim_{x \to -\infty} \ln(2 + e^x) = \ln(2 + 0) = \ln 2 \implies \boxed{y = \ln 2 \approx 0.69}$ ជាអាស៊ីមតូតដេកខាង $-\infty$។

- $\lim\limits_{x\to+\infty} \ln(2+e^x) = +\infty$ ។
- រកអាស៊ីមតូតទ្រេតខាង $+\infty$ ៖

$$y = \ln[e^x(1+2e^{-x})] = x + \ln(1+2e^{-x}) \implies \lim_{x\to+\infty}[y-x] = \lim_{x\to+\infty}\ln(1+2e^{-x}) = 0$$

ដូចនេះ បន្ទាត់ $\boxed{y = x}$ ជាអាស៊ីមតូតទ្រេតខាង $+\infty$។

៣. ដេរីវេ ៖ $y' = \dfrac{e^x}{2+e^x} > 0, \forall x \in \mathbb{R} \implies$ អនុគមន៍កើនជានិច្ចលើ $\mathbb{R}$។

៤. ចំណុចកាត់អ័ក្ស $Oy$ ៖ $x = 0 \implies y = \ln(2+1) = \ln 3 \approx 1.10$។




## លំហាត់ទី ៣

គណនាលីមីតនៃអនុគមន៍ខាងក្រោម ៖

ក. $\lim\limits_{x\to+\infty} x^{-5}\ln x$ ខ. $\lim\limits_{x\to+\infty} \dfrac{1+\ln x}{x^2}$ គ. $\lim\limits_{x\to 0^+} x\ln x$

## ដំណោះស្រាយ

ក. $L_1 = \lim\limits_{x\to+\infty} x^{-5}\ln x$ ៖

សរសេរឡើងវិញជាផលធៀប ៖ $L_1 = \lim\limits_{x\to+\infty} \dfrac{\ln x}{x^5}$ ។

តាមលីមីតគ្រឹះនៃលោការីតនេពែរ $\lim\limits_{x\to+\infty} \dfrac{\ln x}{x^n} = 0$ (ចំពោះ $n > 0$) ដោយ $n = 5 > 0$ ៖

$$L_1 = \lim_{x\to+\infty}\frac{\ln x}{x^5} = \mathbf{0} \implies \boxed{L_1 = 0}$$

ខ. $L_2 = \lim\limits_{x\to+\infty} \dfrac{1+\ln x}{x^2}$ ៖

បំបែកជាពីរប្រភាគ ៖

$$L_2 = \lim_{x\to+\infty}\left(\frac{1}{x^2} + \frac{\ln x}{x^2}\right)$$

ដោយ $\lim\limits_{x\to+\infty}\dfrac{1}{x^2} = 0$ និង $\lim\limits_{x\to+\infty}\dfrac{\ln x}{x^2} = 0$ នាំឱ្យ ៖

$$L_2 = 0 + 0 = \mathbf{0} \implies \boxed{L_2 = 0}$$

គ. $L_3 = \lim\limits_{x \to 0^+} x\ln x$ ៖

នេះជារូបមន្តលីមីតគ្រឹះសំខាន់នៃអនុគមន៍លោការីតនេពែរ (តាង $t = \dfrac{1}{x} \to +\infty \implies x\ln x = -\dfrac{\ln t}{t} \to 0$) ៖

$$L_3 = \lim_{x \to 0^+} x\ln x = \mathbf{0} \implies \boxed{L_3 = 0}$$

---

## លំហាត់ទី ៤

គណនាដេរីវេនៃអនុគមន៍ខាងក្រោម ៖

ក. $y = \sqrt{x}\ln x$ ខ. $y = x^3\sqrt{\ln x}$ គ. $y = \ln(x + \sqrt{1+x^2})$

## ដំណោះស្រាយ

ក. $y = \sqrt{x}\ln x$ (កំណត់ចំពោះ $x > 0$) ៖
អនុវត្តរូបមន្តផលគុណ $(uv)' = u'v + uv'$ ៖

$$y' = (\sqrt{x})'\ln x + \sqrt{x}(\ln x)' = \frac{1}{2\sqrt{x}}\ln x + \sqrt{x}\cdot\frac{1}{x} = \frac{\ln x}{2\sqrt{x}} + \frac{1}{\sqrt{x}} = \boxed{\frac{\ln x + 2}{2\sqrt{x}}}$$

ខ. $y = x^3\sqrt{\ln x}$ (កំណត់ចំពោះ $x \geq 1$) ៖

$$y' = (x^3)'\sqrt{\ln x} + x^3(\sqrt{\ln x})' = 3x^2\sqrt{\ln x} + x^3\cdot\frac{(\ln x)'}{2\sqrt{\ln x}} = 3x^2\sqrt{\ln x} + \frac{x^2}{2\sqrt{\ln x}} = \boxed{\frac{x^2(6\ln x + 1)}{2\sqrt{\ln x}}}$$

គ. $y = \ln(x + \sqrt{1+x^2})$ (កំណត់ចំពោះគ្រប់ $x \in \mathbb{R}$) ៖
អនុវត្តរូបមន្ត $(\ln u)' = \dfrac{u'}{u}$ ៖

$$u' = 1 + \frac{2x}{2\sqrt{1+x^2}} = 1 + \frac{x}{\sqrt{1+x^2}} = \frac{\sqrt{1+x^2}+x}{\sqrt{1+x^2}}$$

$$y' = \frac{u'}{u} = \frac{\dfrac{x+\sqrt{1+x^2}}{\sqrt{1+x^2}}}{x+\sqrt{1+x^2}} = \boxed{\frac{1}{\sqrt{1+x^2}}}$$

---

## លំហាត់ទី ៥

គណនាដេរីវេនៃអនុគមន៍ខាងក្រោម ៖

ក. $y = \ln\left(\dfrac{e^x}{e^x+1}\right)$ ខ. $y = x\ln x - x$ គ. $y = x^2\ln\left(\dfrac{1}{x^2}\right)$

## ដំណោះស្រាយ

ក. $y=\ln\left(\dfrac{e^x}{e^x+1}\right)$ ៖

ប្រើលក្ខណៈលោការីតបំប្លែងមុននឹងធ្វើដេរីវេ ៖

$$y=\ln(e^x)-\ln(e^x+1)=x-\ln(e^x+1)$$

ធ្វើដេរីវេ ៖

$$y'=1-\frac{e^x}{e^x+1}=\frac{e^x+1-e^x}{e^x+1}=\boxed{\frac{1}{e^x+1}}$$

ខ. $y=x\ln x-x$ ៖

$$y'=(x)'\ln x+x(\ln x)'-(x)'=1\cdot\ln x+x\cdot\frac{1}{x}-1=\ln x+1-1=\boxed{\ln x}$$

គ. $y=x^2\ln\left(\dfrac{1}{x^2}\right)$ (កំណត់ចំពោះ $x\neq 0$) ៖

បំប្លែងកន្សោម ៖ $\ln(x^{-2})=-2\ln|x| \implies y=-2x^2\ln|x|$ ។

ធ្វើដេរីវេ ៖

$$y'=-2\left[(x^2)'\ln|x|+x^2(\ln|x|)'\right]=-2\left[2x\ln|x|+x^2\cdot\frac{1}{x}\right]=-2(2x\ln|x|+x)=\boxed{-2x(2\ln|x|+1)}$$

---

## លំហាត់ទី ៦

សិក្សាអថេរភាព និងសង់ក្រាបនៃអនុគមន៍ $y=f(x)=2x-x\ln x$ ។

## ដំណោះស្រាយ

១. ដែនកំណត់ ៖ $\boxed{D=(0,+\infty)}$ ។

២. លីមីតចុងដែនកំណត់ ៖

- $\lim\limits_{x\to 0^+} f(x)=\lim\limits_{x\to 0^+}(2x-x\ln x)=0-0=\mathbf{0}$ (ក្រាបខិតជិតគល់ $O(0,0)$)។
- $\lim\limits_{x\to+\infty} f(x)=\lim\limits_{x\to+\infty} x(2-\ln x)=+\infty(2-\infty)=-\infty$ ។
- ពិនិត្យទិសដៅអនន្ត ៖ $\lim\limits_{x\to+\infty}\dfrac{f(x)}{x}=\lim\limits_{x\to+\infty}(2-\ln x)=-\infty \implies$ ក្រាបមានខ្នែងប៉ារ៉ាបូលបែរទៅរកអ័ក្ស $(Oy)$ ខាងក្រោម។

៣. ដេរីវេ និងទិសដៅអថេរភាព ៖

$$f'(x)=2-\left[\ln x+x\cdot\frac{1}{x}\right]=2-\ln x-1=\mathbf{1}-\ln\mathbf{x}$$

$$f'(x)=0 \iff 1-\ln x=0 \iff \ln x=1 \iff x=e\approx 2.72$$

- ចំពោះ $x\in(0,e)f'(x)>0 \implies f$ កើន។
- ចំពោះ $x\in(e,+\infty)f'(x)<0 \implies f$ ចុះ។
- អតិបរមាធៀបត្រង់ $x=e$ គឺ ៖ $f(e)=2e-e\ln e=2e-e=\mathbf{e}\approx 2.72$ ។ ចំណុចកំពូលគឺ $S(e,e)$។

៤. តារាងអថេរភាព ៖

| $x$ | $0$ | | $e$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | ‖ | $+$ | $0$ | $-$ | |
| $f(x)$ | ‖ $0$ | ↗ | $e$ | ↘ | $-\infty$ |

៥. ចំណុចប្រសព្វអ័ក្ស ៖

- ប្រសព្វអ័ក្ស $(Ox)$ ៖ $f(x)=0 \iff x(2-\ln x)=0 \iff \ln x=2 \iff x=e^2\approx 7.39$ ។ ចំណុច $A(e^2,0)$។
- បន្ទាត់ប៉ះត្រង់ $B(1,2)$ ៖ $f'(1)=1-0=1 \implies (T)y-2=1(x-1) \iff y=x+1$។

៦. សង់ក្រាប $(C)$ ៖




## លំហាត់ទី ៧

ក. សិក្សាអថេរភាព និងសង់ក្រាបនៃអនុគមន៍ $y=f(x)=-2\ln|x|+x-2$ ។

ខ. ក្រាប $(C)$ កាត់អ័ក្ស $Ox$ ត្រង់ ៣ ចំណុច $P,Q,R$ មានអាប់ស៊ីស $p,q,r$ រៀងគ្នា $(p<q<r)$។ បញ្ជាក់ថា $p\in(-1,0)$, $q\in(0,1)$, $r\in(5,6)$។

## ដំណោះស្រាយ

១. ដែនកំណត់ ៖ $|x|>0 \iff x\neq 0 \implies \boxed{D=\mathbb{R}^*=(-\infty,0)\cup(0,+\infty)}$ ។

២. លីមីត និងអាស៊ីមតូត ៖

- $\lim\limits_{x\to 0} f(x) = -2(-\infty)+0-2 = +\infty \implies \boxed{x=0}$ (អ័ក្ស $Oy$) ជាអាស៊ីមតូតឈរ។
- $\lim\limits_{x\to -\infty} f(x) = -2(+\infty)-\infty-2 = -\infty$ ; $\lim\limits_{x\to +\infty} f(x) = \lim\limits_{x\to +\infty} x\left(1-\dfrac{2\ln x}{x}-\dfrac{2}{x}\right) = +\infty(1-0-0) = +\infty$។

## ៣. ដេរីវេ និងទិសដៅអថេរភាព ៖

$$f'(x) = -\frac{2}{x}+1 = \frac{x-2}{x}$$

$$f'(x) = 0 \iff x-2=0 \iff x=2$$

សញ្ញាដេរីវេ ៖

- លើ $(-\infty,0)x<0$ និង $x-2<0 \implies f'(x)>0 \implies f$ កើន។
- លើ $(0,2)x>0$ និង $x-2<0 \implies f'(x)<0 \implies f$ ចុះ។
- លើ $(2,+\infty)x>0$ និង $x-2>0 \implies f'(x)>0 \implies f$ កើន។
- អប្បបរមាធៀបត្រង់ $x=2$ គឺ ៖ $f(2) = -2\ln 2+2-2 = -2\ln 2 \approx -1.39$ ។

## ៤. តារាងអថេរភាព ៖

| $x$ | $-\infty$ | | $0$ | | $2$ | | $+\infty$ |
|---|---|---|---|---|---|---|---|
| $f'(x)$ | | $+$ | ‖ | $-$ | $0$ | $+$ | |
| $f(x)$ | $-\infty$ | ↗ | $+\infty$ ‖ $+\infty$ | ↘ | $-2\ln 2$ | ↗ | $+\infty$ |

## ៥. បញ្ជាក់អាប់ស៊ីសនៃចំណុចប្រសព្វ ៖

- លើ $(-1,0) f(-1) = -2\ln 1-1-2 = -3<0$ និង $\lim\limits_{x\to 0^-} f(x) = +\infty>0 \implies \exists p\in(-1,0)$ ដែល $f(p)=0$។
- លើ $(0,1)$ $\lim\limits_{x\to 0^+} f(x) = +\infty>0$ និង $f(1) = 0+1-2 = -1<0 \implies \exists q\in(0,1)$ ដែល $f(q)=0$។
- លើ $(5,6) f(5) = -2\ln 5+3 \approx -2(1.609)+3 = -0.22<0$ និង $f(6) = -2\ln 6+4 \approx -2(1.792)+4 = +0.42>0 \implies \exists r\in(5,6)$ ដែល $f(r)=0$។

## ៦. សង់ក្រាប $(C)$ ៖




# ដំណោះស្រាយលំហាត់អនុវត្តន៍ត្រីះបន្ថែម (លំហាត់ ៨, ៩, ១០)

## លំហាត់ទី ៨

រោងចក្រឧស្សាហកម្មមួយបានទិញម៉ាស៊ីនហ្វាក់តម្លៃ 250$ ហើយមានអត្រាតម្លៃថយចុះ 25% ក្នុងមួយឆ្នាំ។ តើបីឆ្នាំក្រោយ ម៉ាស៊ីនហ្វាក់នេះ នឹងមានតម្លៃប៉ុន្មាន?

### ដំណោះស្រាយ

- **ទិន្នន័យ ៖**
  - តម្លៃទិញដំបូង ៖ $V_0 = 250\$$
  - អត្រារំលស់តម្លៃប្រចាំឆ្នាំ ៖ $r = 25\% = 0.25$
  - រយៈពេល ៖ $t = 3$ ឆ្នាំ
- **រូបមន្តរំលស់តម្លៃ (Exponential Decay) ៖**

$$V(t) = V_0(1-r)^t$$

- **គណនាតម្លៃក្រោយរយៈពេល ៣ ឆ្នាំ ៖**

$$V(3) = 250 \cdot (1-0.25)^3 = 250 \cdot (0.75)^3$$

ដោយ $(0.75)^3 = 0.421875$ គេបាន ៖

$$V(3) = 250 \times 0.421875 = 105.46875 \text{ ដុល្លារ} \approx \mathbf{105.47} \text{ ដុល្លារ}$$

**សេចក្តីសន្និដ្ឋាន ៖** បីឆ្នាំក្រោយ ម៉ាស៊ីនហ្វាក់នោះនឹងមានតម្លៃប្រហែល ៖

$$\boxed{V(3) \approx 105.47 \text{ ដុល្លារ}}$$

## លំហាត់ទី ៩

បាក់តេរីមួយប្រភេទបំបែកខ្លួនដោយមានមេគុណអត្រាកំណើន $k = 0.872$ ដែល $t$ គិតជាថ្ងៃ។ បើដើមដំបូងមានបាក់តេរីចំនួន 9 តើរយៈពេលប៉ុន្មានថ្ងៃ ទើបចំនួនបាក់តេរីកើនដល់ 738?

### ដំណោះស្រាយ

- **ទិន្នន័យ ៖**
  - ចំនួនបាក់តេរីដើម ៖ $N_0 = 9$
  - មេគុណអត្រាកំណើន ៖ $k = 0.872$ ក្នុងមួយថ្ងៃ
  - ច្បាប់កំណើនបាក់តេរី ៖ $N(t) = N_0 e^{kt} = 9e^{0.872t}$
  - ចំនួនបាក់តេរីគោលដៅ ៖ $N(t) = 738$
- **ដោះស្រាយសមីការរក $t$ ៖**

$$9e^{0.872t} = 738 \iff e^{0.872t} = \frac{738}{9} = 82$$

បំពាក់លោការីតនេពែរលើអង្គទាំងពីរ ៖

$$0.872t = \ln(82) \implies t = \frac{\ln(82)}{0.872}$$

ដោយ $\ln(82) \approx 4.406719$ គេបាន ៖

$$t \approx \frac{4.406719}{0.872} \approx 5.053577 \text{ ថ្ងៃ} \approx \mathbf{5} \text{ ថ្ងៃ}$$

**សេចក្ដីសន្និដ្ឋាន ៖** រយៈពេលប្រហែល **៥ ថ្ងៃ** ទើបចំនួនបាក់តេរីកើនដល់ 738 ៖

$$\boxed{t \approx 5.05 \text{ ថ្ងៃ} \approx 5 \text{ ថ្ងៃ}}$$

---

## លំហាត់ទី ១០

នៅទីក្រុងមួយកាលពី 10 ឆ្នាំមុន មានប្រជាជនចំនួន 45 600 នាក់ ហើយចំនួនប្រជាជនមានការកើនឡើងដោយអត្រាមួយថេរជារៀងរាល់ឆ្នាំ។ បើបច្ចុប្បន្នមានប្រជាជនចំនួន 64 800 នាក់ រកអត្រាកំណើននៃចំនួនប្រជាជនប្រចាំឆ្នាំក្នុងទីក្រុងនេះ។

### ដំណោះស្រាយ

- **ទិន្នន័យ ៖**

– ចំនួនប្រជាជនកាលពី ១០ ឆ្នាំមុន $(t=0)$ ៖ $P_0 = 45\,600$ នាក់
– ចំនួនប្រជាជនបច្ចុប្បន្ន $(t=10$ ឆ្នាំ$)$ ៖ $P(10) = 64\,800$ នាក់

- រូបមន្តកំណើនប្រចាំឆ្នាំ ៖

$$P(t) = P_0(1+r)^t$$

- ដោះស្រាយសមីការរកអត្រា $r$ ៖

$$45\,600(1+r)^{10} = 64\,800 \iff (1+r)^{10} = \frac{64\,800}{45\,600} = \frac{648}{456} = \frac{27}{19}$$

នាំឱ្យ ៖

$$1+r = \left(\frac{27}{19}\right)^{\frac{1}{10}} \approx (1.4210526)^{0.1} \approx 1.035783$$

$$r \approx 1.035783 - 1 = 0.035783 = \mathbf{3.58\%} \text{ ក្នុងមួយឆ្នាំ}$$

- ចំណាំ ៖ ប្រសិនបើសន្មតតាមម៉ូដែលកំណើនអិចស្ប៉ូណង់ស្យែលជាប់ $P(t) = P_0 e^{kt}$ ៖

$$e^{10k} = \frac{27}{19} \implies 10k = \ln\left(\frac{27}{19}\right) \approx 0.351398 \implies k \approx 0.03514 = \mathbf{3.51\%} \text{ ក្នុងមួយឆ្នាំ}$$

**សេចក្តីសន្និដ្ឋាន ៖** អត្រាកំណើននៃចំនួនប្រជាជនប្រចាំឆ្នាំក្នុងទីក្រុងនេះគឺ ៖

| $r \approx 3.58\%$ ក្នុងមួយឆ្នាំ (ម៉ូដែលប្រចាំឆ្នាំ) ឬ $k \approx 3.51\%$ ក្នុងមួយឆ្នាំ (ម៉ូដែលអិចស្ប៉ូណង់ស្យែល) |
|---|

## លំហាត់អនុវត្តន៍ជំពូកទី ៤

### លំហាត់ទី ១

រកដែនកំណត់នៃអនុគមន៍ខាងក្រោម ៖

ក. $y = \sqrt{x^2 - 2\sqrt{x^2-1}} + \sqrt{x-3+2\sqrt{x-4}}$

ខ. $y = \log_2\left(\dfrac{2^{1-x} - 2x + 1}{2^x - 1}\right)$

### ដំណោះស្រាយ

ក. $y = \sqrt{x^2 - 2\sqrt{x^2-1}} + \sqrt{x-3+2\sqrt{x-4}}$ ៖

លក្ខខណ្ឌអត្ថិភាពនៃរ៉ាឌីកាល់ខាងក្នុង ៖

$$\begin{cases} x^2 - 1 \geq 0 \iff x \in (-\infty, -1] \cup [1, +\infty) \\ x - 4 \geq 0 \iff x \geq 4 \end{cases} \implies x \geq 4$$

ពិនិត្យកន្សោមក្រោមរ៉ាឌីកាល់ធំ ៖

- $x^2-2\sqrt{x^2-1}=(x^2-1)-2\sqrt{x^2-1}+1=(\sqrt{x^2-1}-1)^2\geq 0,\forall x\geq 4$ ។
- $x-3+2\sqrt{x-4}=(x-4)+2\sqrt{x-4}+1=(\sqrt{x-4}+1)^2\geq 0,\forall x\geq 4$ ។

លក្ខខណ្ឌទាំងអស់ផ្ទៀងផ្ទាត់ចំពោះ $x\geq 4$ ។

**ដូចនេះ ដែនកំណត់គឺ** $\boxed{D=[4,+\infty)}$ ។

ខ. $y=\log_2\left(\dfrac{2^{1-x}-2x+1}{2^x-1}\right)$ ៖

អនុគមន៍មានន័យលុះត្រាតែកន្សោមក្នុងលោការីតវិជ្ជមានដាច់ខាត ៖

$$\frac{2^{1-x}-2x+1}{2^x-1}>0$$

**១. ពិនិត្យភាគបែង** ៖ $2^x-1=0\iff 2^x=1\iff x=0$ ។

- បើ $x>0\implies 2^x-1>0$ ។
- បើ $x<0\implies 2^x-1<0$ ។

**២. ពិនិត្យភាគយក** ៖ តាង $g(x)=2^{1-x}-2x+1$ លើ $\mathbb{R}$ ។

$g'(x)=-(\ln 2)2^{1-x}-2<0,\forall x\implies g(x)$ ជាអនុគមន៍ចុះដាច់ខាតលើ $\mathbb{R}$។

សង្កេតឃើញ $g(1)=2^0-2(1)+1=1-2+1=0$ នាំឱ្យ $x=1$ ជាឫសតែមួយគត់នៃ $g(x)=0$។

- ចំពោះ $x<1\implies g(x)>0$ ។
- ចំពោះ $x>1\implies g(x)<0$ ។

**៣. តារាងសញ្ញានៃផលធៀប** ៖

| $x$ | $-\infty$ | | $0$ | | $1$ | | $+\infty$ |
|---|---|---|---|---|---|---|---|
| ភាគយក | | $+$ | ⋮ | $+$ | $0$ | $-$ | |
| ភាគបែង | | $-$ | $0$ | $+$ | ⋮ | $+$ | |
| ផលធៀប | | $-$ | ‖ | $+$ | $0$ | $-$ | |

ផលធៀបវិជ្ជមានចំពោះ $x\in(0,1)$ ។

**ដូចនេះ ដែនកំណត់គឺ** $\boxed{D=(0,1)}$ ។

---

**លំហាត់ទី ២**

រកអាស៊ីមតូតរបស់ក្រាបនៃអនុគមន៍ខាងក្រោម ៖

ក. $y=\dfrac{4x-3}{2x+5}$ ខ. $y=\dfrac{3x^2-7x+15}{x-1}$ គ. $y=\dfrac{2x-1}{x^2-7x+10}$

## ដំណោះស្រាយ

ក. $y=\dfrac{4x-3}{2x+5}$ ៖

- អាស៊ីមតូតឈរ ៖ ភាគបែង $2x+5=0\iff x=-\dfrac{5}{2}$ ។

ដោយ $\lim\limits_{x\to -\frac{5}{2}^{\pm}} \dfrac{4x-3}{2x+5} = \pm\infty \implies \boxed{x=-\dfrac{5}{2}}$ ជាសមីការអាស៊ីមតូតឈរ។

- អាស៊ីមតូតដេក ៖ $\lim\limits_{x\to\pm\infty} \dfrac{4x-3}{2x+5} = \lim\limits_{x\to\pm\infty} \dfrac{4x}{2x} = 2 \implies \boxed{y=2}$ ជាសមីការអាស៊ីមតូតដេក។

ខ. $y = \dfrac{3x^2-7x+15}{x-1}$ ៖

- អាស៊ីមតូតឈរ ៖ ភាគបែង $x-1=0 \iff x=1$ ។

ដោយ $\lim\limits_{x\to 1^{\pm}} \dfrac{3x^2-7x+15}{x-1} = \pm\infty \implies \boxed{x=1}$ ជាសមីការអាស៊ីមតូតឈរ។

- អាស៊ីមតូតទ្រេត ៖ ចែកពហុធាភាគយកនឹងភាគបែង ៖

$$3x^2-7x+15 = (x-1)(3x-4)+11 \implies y = 3x-4+\frac{11}{x-1}$$

ដោយ $\lim\limits_{x\to\pm\infty} [y-(3x-4)] = \lim\limits_{x\to\pm\infty} \dfrac{11}{x-1} = 0 \implies \boxed{y=3x-4}$ ជាសមីការអាស៊ីមតូតទ្រេត។

គ. $y = \dfrac{2x-1}{x^2-7x+10} = \dfrac{2x-1}{(x-2)(x-5)}$ ៖

- អាស៊ីមតូតឈរ ៖ ភាគបែងមានឫសពីរគឺ $x=2$ និង $x=5$ ។

ដោយ $\lim\limits_{x\to 2^{\pm}} y = \pm\infty$ និង $\lim\limits_{x\to 5^{\pm}} y = \pm\infty \implies \boxed{x=2 \text{ និង } x=5}$ ជាសមីការអាស៊ីមតូតឈរទាំងពីរ។

- អាស៊ីមតូតដេក ៖ ដឺក្រេភាគយក (1) តូចជាងដឺក្រេភាគបែង (2) ៖

$$\lim_{x\to\pm\infty} \frac{2x-1}{x^2-7x+10} = 0 \implies \boxed{y=0 \text{ (អ័ក្ស } Ox)}$$ ជាអាស៊ីមតូតដេក។

---

## លំហាត់ទី ៣

គេឱ្យអនុគមន៍ $f(x) = \dfrac{x^2+x-1}{x-1}$ មានក្រាប $(C)$ ។

ក. រកចំនួនពិត $a,b,c$ ដើម្បីឱ្យ $f(x) = ax+b+\dfrac{c}{x-1}$ ។

ខ. គណនាលីមីតត្រង់ចុងដែនកំណត់ រួចទាញរកអាស៊ីមតូតឈរ និងទ្រេតនៃ $(C)$ ។

គ. គណនា $f'(x)$ សិក្សាសញ្ញារបស់វា។ សង់តារាងអថេរភាពនៃ $f(x)$ ។

ឃ. បង្ហាញថា $I(1,3)$ ជាផ្ចិតឆ្លុះនៃ $(C)$ ។ សង់ខ្សែកោង $(C)$ ក្នុងតម្រុយ $(O,\vec{i},\vec{j})$ ។

ង. សិក្សាតាមក្រាហ្វិកនូវចំនួនឫសនៃសមីការ $x^2+(1-m)x+m-1=0$ ។

## ដំណោះស្រាយ

ក. **រកចំនួនពិត** $a,b,c$ ៖

ធ្វើវិធីចែកពហុធា ៖ $x^2+x-1 = (x-1)(x+2)+1$ ៖

$$f(x) = x+2+\frac{1}{x-1} \implies \boxed{a=1,\quad b=2,\quad c=1}$$

ខ. **លីមីត និងអាស៊ីមតូត ៖**
ដែនកំណត់ ៖ $D=\mathbb{R}\setminus\{1\}=(-\infty,1)\cup(1,+\infty)$ ។

- $\lim_{x\to1^-} f(x)=-\infty$ និង $\lim_{x\to1^+} f(x)=+\infty \implies \boxed{x=1}$ ជាអាស៊ីមតូតឈរ។
- $\lim_{x\to\pm\infty}[f(x)-(x+2)]=\lim_{x\to\pm\infty}\frac{1}{x-1}=0 \implies \boxed{y=x+2}$ ជាអាស៊ីមតូតទ្រេត។

គ. **ដេរីវេ និងតារាងអថេរភាព ៖**

$$f'(x)=1-\frac{1}{(x-1)^2}=\frac{(x-1)^2-1}{(x-1)^2}=\frac{x(x-2)}{(x-1)^2}$$

$f'(x)=0 \iff x=0$ ឬ $x=2$ ។

- អតិបរមាធៀបត្រង់ $x=0$ គឺ ៖ $f(0)=1$ ។
- អប្បបរមាធៀបត្រង់ $x=2$ គឺ ៖ $f(2)=2+2+1=5$ ។

| $x$ | $-\infty$ | | $0$ | | $1$ | | $2$ | | $+\infty$ |
|---|---|---|---|---|---|---|---|---|---|
| $f'(x)$ | | $+$ | $0$ | $-$ | ‖ | $-$ | $0$ | $+$ | |
| $f(x)$ | $-\infty$ | ↗ | $1$ | ↘ | $-\infty$ ‖ $+\infty$ | ↘ | $5$ | ↗ | $+\infty$ |

ឃ. **ស្រាយបញ្ជាក់ផ្ចិតឆ្លុះ $I(1,3)$ ៖**
ត្រូវស្រាយថា $f(2(1)-x)+f(x)=2(3) \iff f(2-x)+f(x)=6$ ៖

$$f(2-x)=(2-x)+2+\frac{1}{(2-x)-1}=4-x-\frac{1}{x-1}$$

$$f(2-x)+f(x)=\left(4-x-\frac{1}{x-1}\right)+\left(x+2+\frac{1}{x-1}\right)=6 \quad (\text{ពិត})$$

ដូចនេះ ចំណុច $\boxed{I(1,3)}$ ជាផ្ចិតឆ្លុះនៃក្រាប $(C)$ ។

សង់ក្រាប $(C)$ ៖




ង. **ពិភាក្សាឫសតាមក្រាហ្វិក ៖**

សមីការ $x^2+(1-m)x+m-1=0 \iff x^2+x-1-m(x-1)=0$ ។

ចំពោះ $x\neq 1$ ៖

$$\frac{x^2+x-1}{x-1}=m \iff f(x)=m$$

ចំនួនឫសនៃសមីការគឺចំនួនចំណុចប្រសព្វរវាង $(C)$ និងបន្ទាត់ដេក $y=m$ ៖

- បើ $m<1$ ៖ បន្ទាត់ $y=m$ កាត់ $(C)$ ត្រង់ ២ ចំណុច $\implies$ សមីការមានឫសពីរផ្សេងគ្នា។
- បើ $m=1$ ៖ បន្ទាត់ $y=1$ ប៉ះ $(C)$ ត្រង់កំពូលអតិបរមា $\implies$ សមីការមានឫសឌុប $x=0$។
- បើ $1<m<5$ ៖ បន្ទាត់ $y=m$ មិនកាត់ $(C)$ ឡើយ $\implies$ សមីការគ្មានឫស។
- បើ $m=5$ ៖ បន្ទាត់ $y=5$ ប៉ះ $(C)$ ត្រង់កំពូលអប្បបរមា $\implies$ សមីការមានឫសឌុប $x=2$។
- បើ $m>5$ ៖ បន្ទាត់ $y=m$ កាត់ $(C)$ ត្រង់ ២ ចំណុច $\implies$ សមីការមានឫសពីរផ្សេងគ្នា។

---

**លំហាត់ទី ៤**

គេឱ្យអនុគមន៍ $f(x)=\dfrac{2x^2+x+1}{x+1}$ ។

ក. សិក្សាអថេរភាព និងសង់ក្រាបនៃអនុគមន៍ $f(x)$ ។

ខ. តាមក្រាប រកតម្លៃអតិបរមា និងអប្បបរមានៃកន្សោម $E=\dfrac{2\cos^2 x+|\cos x|+1}{|\cos x|+1}$ ។

**ដំណោះស្រាយ**

ក. សិក្សាអថេរភាព និងសង់ក្រាប ៖

១. ដែនកំណត់ ៖ $D=\mathbb{R}\setminus\{-1\}$ ។

២. ទម្រង់កាណូនិច ៖ $2x^2+x+1=(x+1)(2x-1)+2 \implies f(x)=2x-1+\dfrac{2}{x+1}$ ។

- អាស៊ីមតូតឈរ ៖ $\boxed{x=-1}$ ព្រោះ $\lim\limits_{x\to-1^{\pm}} f(x)=\pm\infty$ ។
- អាស៊ីមតូតទ្រេត ៖ $\boxed{y=2x-1}$ ព្រោះ $\lim\limits_{x\to\pm\infty}[f(x)-(2x-1)]=0$ ។

៣. ដេរីវេ ៖

$$f'(x)=2-\frac{2}{(x+1)^2}=\frac{2[(x+1)^2-1]}{(x+1)^2}=\frac{2x(x+2)}{(x+1)^2}$$

$f'(x)=0 \iff x=-2$ ឬ $x=0$ ។

- អតិបរមាធៀប ៖ $f(-2)=2(-2)-1+\dfrac{2}{-1}=-5-2=-7$ ត្រង់ $x=-2$។
- អប្បបរមាធៀប ៖ $f(0)=-1+2=1$ ត្រង់ $x=0$។

៤. តារាងអថេរភាព ៖

| $x$ | $-\infty$ | | $-2$ | | $-1$ | | $0$ | | $+\infty$ |
|---|---|---|---|---|---|---|---|---|---|
| $f'(x)$ | | $+$ | $0$ | $-$ | ‖ | $-$ | $0$ | $+$ | |
| $f(x)$ | $-\infty$ | ↗ | $-7$ | ↘ $-\infty$ | ‖ | $+\infty$ ↘ | $1$ | ↗ | $+\infty$ |

៥. សង់ក្រាប ៖ ផ្ចិតឆ្លុះ $I(-1,-3)$ ជាចំណុចប្រសព្វអាស៊ីមតូត។




មេរៀនទី ៤ ផ្នែកដំណោះស្រាយ

ខ. រកតម្លៃអតិបរមា និងអប្បបរមានៃ $E$ ៖

តាង $t = |\cos x|$ ។ ដោយ $0 \leq |\cos x| \leq 1 \implies t \in [0,1]$ ។

កន្សោម $E = \dfrac{2t^2+t+1}{t+1} = f(t)$ ចំពោះ $t \in [0,1]$ ។

តាមតារាងអថេរភាព លើចន្លោះ $[0,1]$ អនុគមន៍ $f(t)$ ជាអនុគមន៍កើនដាច់ខាត ៖

- អប្បបរមា ៖ $E_{\min} = f(0) = \mathbf{1}$ (កើតឡើងនៅពេល $|\cos x| = 0 \iff x = \dfrac{\pi}{2} + k\pi$)។
- អតិបរមា ៖ $E_{\max} = f(1) = \dfrac{2(1)^2+1+1}{1+1} = \dfrac{4}{2} = \mathbf{2}$ (កើតឡើងនៅពេល $|\cos x| = 1 \iff x = k\pi$)។

ដូចនេះ $\boxed{E_{\min} = 1}$ និង $\boxed{E_{\max} = 2}$ ។

---

## លំហាត់ទី ៥

អនុគមន៍ $f(x)$ កំណត់ចំពោះ $x \neq -1$ ដោយ $f(x) = \dfrac{9x}{(x+1)^2}$ មានក្រាប $(C)$ ។

ក. គណនា $\lim\limits_{x\to\pm\infty} f(x)$ និង $\lim\limits_{x\to -1} f(x)$ ។

ខ. រកតម្លៃបរមាធៀប រួចសង់តារាងអថេរភាពនៃ $f(x)$ ។

គ. បង្ហាញថា $(C)$ មានចំណុចរបត់មួយ រួចរកកូអរដោនេចំណុចរបត់នោះ។

ឃ. គណនា $f(-4), f(-3), f(-2), f(3)$ និង $f(4)$ ។

ង. សង់ខ្សែកោង $(C)$ ក្នុងតម្រុយអរតូណរម៉ាល់។

## ដំណោះស្រាយ

ក. គណនាលីមីត ៖

- $\lim\limits_{x\to\pm\infty} \dfrac{9x}{(x+1)^2} = \lim\limits_{x\to\pm\infty} \dfrac{9x}{x^2} = 0 \implies \boxed{y = 0 \text{ (អ័ក្ស } Ox)}$ ជាអាស៊ីមតូតដេក។
- $\lim\limits_{x\to -1} \dfrac{9x}{(x+1)^2} = \dfrac{-9}{0^+} = -\infty \implies \boxed{x = -1}$ ជាអាស៊ីមតូតឈរ។

ខ. បរមាធៀប និងតារាងអថេរភាព ៖

$$f'(x) = \frac{9(x+1)^2 - 9x\cdot 2(x+1)}{(x+1)^4} = \frac{9(x+1)[x+1-2x]}{(x+1)^4} = \frac{9(1-x)}{(x+1)^3}$$

$f'(x) = 0 \iff 1 - x = 0 \iff x = 1$ ។

តម្លៃអតិបរមាធៀបត្រង់ $x = 1$ គឺ ៖ $f(1) = \dfrac{9(1)}{(1+1)^2} = \dfrac{9}{4} = 2.25$ ។

| $x$ | $-\infty$ | | $-1$ | | $1$ | | $+\infty$ |
|---|---|---|---|---|---|---|---|
| $f'(x)$ | | $-$ | \|\| | $+$ | $0$ | $-$ | |
| $f(x)$ | $0$ | ↘ | $-\infty$ \|\| $-\infty$ | ↗ | $\frac{9}{4}$ | ↘ | $0$ |

គ. ចំណុចរបត់ ៖

គណនាដេរីវេទីពីរ $f''(x)$ ៖

$$f''(x)=9\cdot\frac{-(x+1)^3-(1-x)\cdot3(x+1)^2}{(x+1)^6}=9\cdot\frac{-(x+1)-3(1-x)}{(x+1)^4}=\frac{9(2x-4)}{(x+1)^4}=\frac{18(x-2)}{(x+1)^4}$$

$f''(x)=0 \iff x=2$ ហើយ $f''(x)$ ប្ដូរសញ្ញាឆ្លងកាត់ $x=2$ (ពីអវិជ្ជមានទៅវិជ្ជមាន )។

ទាញបាន $x=2$ ជាអាប់ស៊ីសចំណុចរបត់ ៖ $f(2)=\frac{9(2)}{(2+1)^2}=\frac{18}{9}=2$ ។

ដូចនេះ ចំណុចរបត់នៃក្រាបគឺ $\boxed{J(2,2)}$ ។

ឃ. គណនាតម្លៃពិសេស ៖

- $f(-4)=\frac{-36}{(-3)^2}=\mathbf{-4}$
- $f(-3)=\frac{-27}{(-2)^2}=-\frac{\mathbf{27}}{\mathbf{4}}=\mathbf{-6.75}$
- $f(-2)=\frac{-18}{(-1)^2}=\mathbf{-18}$
- $f(3)=\frac{27}{4^2}=\frac{\mathbf{27}}{\mathbf{16}}\approx\mathbf{1.69}$
- $f(4)=\frac{36}{5^2}=\frac{\mathbf{36}}{\mathbf{25}}=\mathbf{1.44}$

ង. សង់ក្រាប $(C)$ ៖



## លំហាត់ទី ៦

គេឱ្យអនុគមន៍ $f(x)=\dfrac{x^2-4x}{x^2-4x+3}$ មានក្រាប $(C)$ ។

ក. គណនាលីមីតចុងដែនកំណត់ រួចទាញរកអាស៊ីមតូតឈរ និងអាស៊ីមតូតដេកនៃ $(C)$ ។

ខ. គណនា $f'(x)$ រួចសិក្សាសញ្ញារបស់វា។ សង់តារាងអថេរភាពនៃ $f(x)$ ។

គ. សរសេរសមីការបន្ទាត់ប៉ះ $(T)$ ទៅនឹងខ្សែកោង $(C)$ ត្រង់ចំណុចដែលមានអាប់ស៊ីស $x=4$ ។

ឃ. សង់អាស៊ីមតូត បន្ទាត់ប៉ះ $(T)$ និងខ្សែកោង $(C)$ ។

ង. ដោយប្រើខ្សែកោង $(C)$ កំណត់ $m$ ដើម្បីឱ្យសមីការ $(m-1)x^2-4(m-1)x+3m=0$ មានឫសពីរផ្សេងគ្នា។

## ដំណោះស្រាយ

**ក. លីមីត និងអាស៊ីមតូត ៖**

ភាគបែង $x^2-4x+3=(x-1)(x-3)=0 \iff x=1$ ឬ $x=3$ ។

ដែនកំណត់ ៖ $D=\mathbb{R}\setminus\{1,3\}$ ។

- $\lim_{x\to1} f(x)=\infty$ និង $\lim_{x\to3} f(x)=\infty \implies$ $\boxed{x=1 \text{ និង } x=3}$ ជាអាស៊ីមតូតឈរទាំងពីរ។
- $\lim_{x\to\pm\infty}\dfrac{x^2-4x}{x^2-4x+3}=1 \implies \boxed{y=1}$ ជាអាស៊ីមតូតដេក។

**ខ. ដេរីវេ និងតារាងអថេរភាព ៖**

សង្កេត ៖ $f(x)=1-\dfrac{3}{x^2-4x+3}$ ។

$$f'(x)=\frac{3(2x-4)}{(x^2-4x+3)^2}=\frac{6(x-2)}{(x^2-4x+3)^2}$$

$f'(x)=0 \iff x=2$ ។ តម្លៃអប្បបរមាធៀបត្រង់ $x=2$ គឺ ៖ $f(2)=\dfrac{4-8}{4-8+3}=\dfrac{-4}{-1}=4$ ។

| $x$ | $-\infty$ | | $1$ | | $2$ | | $3$ | | $+\infty$ |
|---|---|---|---|---|---|---|---|---|---|
| $f'(x)$ | | $-$ | ‖ | $-$ | $0$ | $+$ | ‖ | $+$ | |
| $f(x)$ | $1$ | ↘ | $-\infty$ ‖ $+\infty$ | ↘ | $4$ | ↗ | $+\infty$ ‖ $-\infty$ | ↗ | $1$ |

**គ. សមីការបន្ទាត់ប៉ះត្រង់ $x=4$ ៖**

$f(4)=\dfrac{16-16}{16-16+3}=0$ ។

$f'(4)=\dfrac{6(4-2)}{(16-16+3)^2}=\dfrac{12}{9}=\dfrac{4}{3}$ ។

សមីការបន្ទាត់ប៉ះ ៖ $(T)y-0=\dfrac{4}{3}(x-4)\iff \boxed{y=\dfrac{4}{3}x-\dfrac{16}{3}}$ ។

ឃ. សង់ក្រាប $(C)$ ៖ បន្ទាត់ឆ្លុះ $x=2$ ។




ង. កំណត់ $m$ តាមក្រាហ្វិក ៖

សមីការ $(m-1)x^2-4(m-1)x+3m=0 \iff m(x^2-4x+3)=x^2-4x$ ។

ចំពោះ $x\neq 1,3$ ៖ $\dfrac{x^2-4x}{x^2-4x+3}=m \iff f(x)=m$ ។

តាមក្រាប $(C)$ សមីការមានឫសពីរផ្សេងគ្នាកាលណាខ្សែបន្ទាត់ $y=m$ កាត់ $(C)$ ត្រង់ ២ ចំណុច ៖

$\boxed{m<1 \quad \text{ឬ} \quad m>4}$

(ត្រង់ $m=4$ មានឫសឌុប $x=2$ ; លើ $[1,4)$ គ្មានឫស)។

---

## លំហាត់ទី ៧

គណនាដេរីវេនៃអនុគមន៍ខាងក្រោម ៖

ក. $y=\dfrac{e^x}{x-1}$ ខ. $y=e^{2x}-e^x$ គ. $y=\dfrac{e^x+1}{e^x-1}$

## ដំណោះស្រាយ

ក. $y=\dfrac{e^x}{x-1}$ $(x\neq 1)$ ៖

$$y'=\frac{(e^x)'(x-1)-e^x(x-1)'}{(x-1)^2}=\frac{e^x(x-1)-e^x(1)}{(x-1)^2}=\boxed{\frac{e^x(x-2)}{(x-1)^2}}$$

ខ. $y=e^{2x}-e^x$ ៖

$$y'=(2x)'e^{2x}-e^x=2e^{2x}-e^x=\boxed{e^x(2e^x-1)}$$

គ. $y=\dfrac{e^x+1}{e^x-1}\ (x\neq 0)$ ៖

$$y'=\frac{e^x(e^x-1)-(e^x+1)e^x}{(e^x-1)^2}=\frac{e^{2x}-e^x-e^{2x}-e^x}{(e^x-1)^2}=\boxed{\frac{-2e^x}{(e^x-1)^2}}$$

---

## លំហាត់ទី ៨

គណនាដេរីវេនៃអនុគមន៍ខាងក្រោម ៖

ក. $y=x-1-\ln x$ ខ. $y=\ln\left(\dfrac{x-3}{x+2}\right)$ គ. $y=x^2\ln x-\dfrac{x^2}{2}$

## ដំណោះស្រាយ

ក. $y=x-1-\ln x\ (x>0)$ ៖

$$y'=1-\frac{1}{x}=\boxed{\frac{x-1}{x}}$$

ខ. $y=\ln\left(\dfrac{x-3}{x+2}\right)=\ln(x-3)-\ln(x+2)\ (x\in(-\infty,-2)\cup(3,+\infty))$ ៖

$$y'=\frac{1}{x-3}-\frac{1}{x+2}=\frac{(x+2)-(x-3)}{(x-3)(x+2)}=\boxed{\frac{5}{(x-3)(x+2)}}$$

គ. $y=x^2\ln x-\dfrac{x^2}{2}\ (x>0)$ ៖

$$y'=2x\ln x+x^2\cdot\frac{1}{x}-x=2x\ln x+x-x=\boxed{2x\ln x}$$

---

## លំហាត់ទី ៩

គេឱ្យអនុគមន៍ $f(x)=e^x-x-1$ កំណត់លើ $\mathbb{R}$ មានក្រាប $(C)$ ។

ក. គណនា $\lim\limits_{x\to+\infty} f(x)$ និង $\lim\limits_{x\to-\infty} f(x)$ ។

ខ. គណនា $f'(x)$ រួចសិក្សាសញ្ញារបស់វា ទាញថា $f$ មានអប្បបរមាធៀបមួយ រួចគណនាតម្លៃបរមាធៀបនោះ។ គូសតារាងអថេរភាពនៃ $f(x)$ ។

គ. បង្ហាញថាបន្ទាត់ $(d) y=-x-1$ ជាអាស៊ីមតូតទ្រេតនៃ $(C)$ កាលណា $x\to-\infty$ ។

ឃ. កំណត់កូអរដោនេនៃចំណុច $P$ នៃ $(C)$ ដែលបន្ទាត់ប៉ះនឹង $(C)$ ត្រង់ចំណុចនេះស្របទៅនឹងបន្ទាត់ $y=x$ ។

ង. សង់ $(C)$ និង $(d)$ និងបន្ទាត់ប៉ះត្រង់ $P$ (គេឱ្យ $\ln 2 = 0.7$) ។

## ដំណោះស្រាយ

**ក. គណនាលីមីត ៖**

- $\lim_{x\to+\infty}(e^x - x - 1) = \lim_{x\to+\infty} e^x\left(1 - \frac{x}{e^x} - \frac{1}{e^x}\right) = +\infty(1-0-0) = +\infty$ ។
- $\lim_{x\to-\infty}(e^x - x - 1) = 0 - (-\infty) - 1 = +\infty$ ។

**ខ. ដេរីវេ និងតារាងអថេរភាព ៖**

$f'(x) = e^x - 1$ ។

$f'(x) = 0 \iff e^x = 1 \iff x = 0$ ។

- បើ $x < 0 \implies e^x < 1 \implies f'(x) < 0 \implies f$ ជាអនុគមន៍ចុះ ។
- បើ $x > 0 \implies e^x > 1 \implies f'(x) > 0 \implies f$ ជាអនុគមន៍កើន ។
- អប្បបរមាធៀបត្រង់ $x = 0$ គឺ ៖ $f(0) = e^0 - 0 - 1 = \mathbf{0}$ ។

| $x$ | $-\infty$ | | $0$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | | $-$ | $0$ | $+$ | |
| $f(x)$ | $+\infty$ | $\searrow$ | $0$ | $\nearrow$ | $+\infty$ |

**គ. អាស៊ីមតូតទ្រេតខាង $-\infty$ ៖**

ពិនិត្យផលដក ៖

$$\lim_{x\to-\infty}[f(x) - (-x-1)] = \lim_{x\to-\infty}[e^x - x - 1 + x + 1] = \lim_{x\to-\infty} e^x = 0$$

**ដូចនេះ បន្ទាត់ $\boxed{(d)y = -x-1}$ ជាអាស៊ីមតូតទ្រេតនៃក្រាប $(C)$ ខាង $-\infty$ ។**

**ឃ. កំណត់កូអរដោនេនៃចំណុច $P$ ៖**

បន្ទាត់ $y = x$ មានមេគុណប្រាប់ទិស $m = 1$ ។

បន្ទាត់ប៉ះនឹង $(C)$ ត្រង់ $P(x_0, y_0)$ ស្របនឹងបន្ទាត់ $y = x$ លុះត្រាតែ ៖

$$f'(x_0) = 1 \iff e^{x_0} - 1 = 1 \iff e^{x_0} = 2 \iff x_0 = \ln 2 \approx 0.7$$

អរដោនេនៃចំណុច $P$ គឺ ៖

$$y_0 = f(\ln 2) = e^{\ln 2} - \ln 2 - 1 = 2 - \ln 2 - 1 = 1 - \ln 2 \approx 1 - 0.7 = 0.3$$

ដូចនេះ កូអរដោនេនៃចំណុច $P$ គឺ ៖ $\boxed{P(\ln 2, 1-\ln 2) \approx P(0.7, 0.3)}$ ។

សមីការបន្ទាត់ប៉ះត្រង់ $P$ គឺ ៖ $y - (1-\ln 2) = 1(x - \ln 2) \iff \boxed{y = x + 1 - 2\ln 2 \approx x - 0.4}$ ។

ង. សង់ក្រាប $(C)$ បន្ទាត់ $(d)$ និងបន្ទាត់ប៉ះត្រង់ $P$ ៖




---

## លំហាត់ទី ១០

គេឱ្យអនុគមន៍ $f(x) = x - 1 + \frac{2}{e^x}$ កំណត់លើ $\mathbb{R}$ មានក្រាប $(C)$ ។

ក. គណនាលីមីត $\lim\limits_{x\to+\infty} f(x)$ ។ បង្ហាញថាបន្ទាត់ $(d)$ ដែលមានសមីការ $y = x - 1$ ជាអាស៊ីមតូតទ្រេតនៃ $(C)$ ។

ខ. បង្ហាញថា $f(x)$ អាចសរសេរជា $f(x) = \frac{xe^x - e^x + 2}{e^x}$ ទាញរកលីមីតនៃ $f(x)$ កាលណា $x \to -\infty$ ។

គ. គណនា $f'(x)$ រួចសិក្សាសញ្ញារបស់វា។ សង់តារាងអថេរភាពនៃ $f(x)$ ។

ឃ. សរសេរសមីការបន្ទាត់ប៉ះ $(T)$ ទៅនឹង $(C)$ ត្រង់ចំណុចដែលមានអាប់ស៊ីស $x = 0$ ។

ង. សង់ខ្សែកោង $(C)$ បន្ទាត់ $(T)$ និងបន្ទាត់ $(d)$ ក្នុងតម្រុយ $(O, \vec{i}, \vec{j})$ ។

ច. តាមក្រាហ្វិក កំណត់ចំនួនឫសនៃសមីការ $f(x) = 2$ រួចរកឫសទាំងពីរនោះដោយចំនួនគត់ពីរតគ្នា ។

### ដំណោះស្រាយ

ក. **លីមីត និងអាស៊ីមតូតខាង $+\infty$ ៖**

$\lim\limits_{x\to+\infty} f(x) = \lim\limits_{x\to+\infty} \left(x - 1 + 2e^{-x}\right) = +\infty - 1 + 0 = +\infty$ ។

ពិនិត្យផលដក ៖

$$\lim_{x\to+\infty} [f(x) - (x-1)] = \lim_{x\to+\infty} \frac{2}{e^x} = 0$$

ដូចនេះ បន្ទាត់ $\boxed{(d) y = x - 1}$ ជាអាស៊ីមតូតទ្រេតនៃ $(C)$ ខាង $+\infty$ ។

ខ. **ទម្រង់ប្រភាគ និងលីមីតខាង $-\infty$ ៖**

$$f(x) = x - 1 + \frac{2}{e^x} = \frac{(x-1)e^x + 2}{e^x} = \boxed{\frac{xe^x - e^x + 2}{e^x}}$$

កាលណា $x \to -\infty$ ៖ $xe^x \to 0$ និង $e^x \to 0$ នាំឱ្យភាគយកខិតជិត $2 > 0$ ហើយភាគបែង $e^x \to 0^+$ ៖

$$\boxed{\lim_{x\to-\infty} f(x) = \frac{2}{0^+} = +\infty}$$

**គ. ដេរីវេ និងតារាងអថេរភាព ៖**

$f'(x) = 1 - 2e^{-x} = \dfrac{e^x - 2}{e^x}$ ។

$f'(x) = 0 \iff e^x = 2 \iff x = \ln 2 \approx 0.7$ ។

- បើ $x < \ln 2 \implies e^x < 2 \implies f'(x) < 0 \implies f$ ជាអនុគមន៍ចុះ ។
- បើ $x > \ln 2 \implies e^x > 2 \implies f'(x) > 0 \implies f$ ជាអនុគមន៍កើន ។
- អប្បបរមាធៀបត្រង់ $x = \ln 2$ គឺ ៖

$$f(\ln 2) = \ln 2 - 1 + \frac{2}{e^{\ln 2}} = \ln 2 - 1 + \frac{2}{2} = \ln \mathbf{2} \approx \mathbf{0.7}$$

| $x$ | $-\infty$ | | $\ln 2$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | | $-$ | $0$ | $+$ | |
| $f(x)$ | $+\infty$ | ↘ | $\ln 2$ | ↗ | $+\infty$ |

**ឃ. សមីការបន្ទាត់ប៉ះ $(T)$ ត្រង់ $x = 0$ ៖**

- អរដោនេចំណុចប៉ះ ៖ $y_0 = f(0) = 0 - 1 + \dfrac{2}{e^0} = -1 + 2 = 1 \implies A(0,1)$ ។
- មេគុណប្រាប់ទិស ៖ $f'(0) = 1 - 2e^0 = 1 - 2 = -1$ ។
- សមីការបន្ទាត់ប៉ះ $(T)$ ៖ $y - 1 = -1(x - 0) \iff \boxed{(T): y = -x + 1}$ ។

**ង. សង់ខ្សែកោង $(C)$ បន្ទាត់ $(T)$ និងបន្ទាត់ $(d)$ ៖**




មេរៀនទី ៤ ផ្នែកដំណោះស្រាយ

ច. **កំណត់ចំនួនឫសនៃសមីការ $f(x)=2$ តាមក្រាហ្វិក ៖**

ចំនួនឫសនៃសមីការ $f(x)=2$ គឺជាចំនួនចំណុចប្រសព្វរវាងខ្សែកោង $(C)$ និងបន្ទាត់ដេក $y=2$ ។

- ដោយសារតម្លៃអប្បបរមាធៀបគឺ $f(\ln 2)=\ln 2\approx 0.7<2$ ហើយ $\lim_{x\to\pm\infty} f(x)=+\infty$ នោះបន្ទាត់ $y=2$ កាត់ $(C)$ ត្រង់ **២ ចំណុចផ្សេងគ្នា** នាំឱ្យសមីការមាន **ឫសពីរផ្សេងគ្នា** $x_1<\ln 2<x_2$ ។
- ចំពោះឫសទីមួយ $x_1$ ៖
  $f(0)=1<2$ និង $f(-1)=-1-1+2e=2e-2\approx 3.44>2$ ។
  ដោយ $f(0)<2<f(-1)$ នាំឱ្យឫសទីមួយស្ថិតនៅចន្លោះ ៖

  $-1<x_1<0$ (ចំនួនគត់ពីរតគ្នាគឺ $-1$ និង $0$)

- ចំពោះឫសទីពីរ $x_2$ ៖
  $f(2)=2-1+2e^{-2}=1+\frac{2}{e^2}\approx 1+0.27=1.27<2$ ។
  $f(3)=3-1+2e^{-3}=2+\frac{2}{e^3}>2$ ។
  ដោយ $f(2)<2<f(3)$ នាំឱ្យឫសទីពីរស្ថិតនៅចន្លោះ ៖

  $2<x_2<3$ (ចំនួនគត់ពីរតគ្នាគឺ $2$ និង $3$)

---

## លំហាត់ទី ១១

គេឱ្យអនុគមន៍ $f(x)$ កំណត់លើ $(0,+\infty)$ ដោយ $f(x)=ax+b+\frac{\ln x}{x}$ ។ កំណត់ចំនួនពិត $a$ និង $b$ ដើម្បីឱ្យខ្សែកោង $(C)$ តាង $f(x)$ កាត់តាមចំណុច $A(1,0)$ ហើយបន្ទាត់ប៉ះនឹង $(C)$ ត្រង់ $A$ ស្របនឹងបន្ទាត់ $y=2x$ ។

### ដំណោះស្រាយ

**១. លក្ខខណ្ឌកាត់តាមចំណុច $A(1,0)$ ៖**

ក្រាប $(C)$ កាត់តាម $A(1,0)$ $\iff$ $f(1)=0$ ៖

$$f(1)=a(1)+b+\frac{\ln 1}{1}=a+b+0=a+b=0 \iff \mathbf{b}=-\mathbf{a} \quad (1)$$

**២. លក្ខខណ្ឌបន្ទាត់ប៉ះស្របនឹងបន្ទាត់ $y=2x$ ៖**

មេគុណប្រាប់ទិសនៃបន្ទាត់ $y=2x$ គឺ $k=2$ ។
បន្ទាត់ប៉ះត្រង់ $A(1,0)$ ស្របនឹងបន្ទាត់នេះ លុះត្រាតែ $f'(1)=2$ ។
គណនាដេរីវេ $f'(x)$ ៖

$$f'(x)=a+\frac{(\ln x)'x-\ln x(x)'}{x^2}=a+\frac{1-\ln x}{x^2}$$

ជំនួស $x=1$ ៖

$$f'(1)=a+\frac{1-\ln 1}{1^2}=a+1$$

តាមលក្ខខណ្ឌ ៖

$$a+1=2 \iff \mathbf{a=1}$$

ជំនួស $a=1$ ចូលក្នុង $(1)$ នាំឱ្យ ៖

$$b=-1$$

**ដូចនេះ តម្លៃដែលត្រូវរកគឺ** $\boxed{a=1,\quad b=-1}$ **ហើយអនុគមន៍គឺ** $f(x)=x-1+\dfrac{\ln x}{x}$ ។

---

## លំហាត់ទី ១២

គេឱ្យអនុគមន៍ $f(x)=x+\ln\left|\dfrac{x+1}{x}\right|$ មានក្រាប $(C)$ ។

ក. រកដែនកំណត់ រួចគណនាលីមីតនៃ $f(x)$ ត្រង់ចុងដែនកំណត់ ។

ខ. គណនា $f'(x)$ រួចសិក្សាសញ្ញារបស់វា។ សង់តារាងអថេរភាពនៃ $f(x)$ ។

គ. បង្ហាញថា $(\Delta) y=x$ ជាអាស៊ីមតូតទ្រេតនៃ $(C)$ រួចកំណត់ទីតាំងធៀបនៃ $(C)$ ធៀបនឹង $(\Delta)$ ។

ឃ. បង្ហាញថា $A\left(-\dfrac{1}{2},-\dfrac{1}{2}\right)$ ជាផ្ចិតឆ្លុះនៃ $(C)$ ។

ង. ឱ្យសមីការបន្ទាត់ប៉ះទៅនឹង $(C)$ ត្រង់ $A$ ។

ច. សង់បន្ទាត់ $(\Delta)$ ខ្សែកោង $(C)$ និងបន្ទាត់ប៉ះត្រង់ $A$ ។

## ដំណោះស្រាយ

ក. **ដែនកំណត់ និងលីមីត ៖**

លក្ខខណ្ឌ ៖ $\dfrac{x+1}{x}\neq 0 \iff x\neq -1$ និង $x\neq 0$ ៖

$$\boxed{D=\mathbb{R}\setminus\{-1,0\}=(-\infty,-1)\cup(-1,0)\cup(0,+\infty)}$$

គណនាលីមីត ៖

- $\lim\limits_{x\to-1} f(x)=-1+\ln 0^+=-\infty \implies \boxed{x=-1}$ ជាអាស៊ីមតូតឈរ។
- $\lim\limits_{x\to 0} f(x)=0+\ln(+\infty)=+\infty \implies \boxed{x=0}$ (អ័ក្ស $Oy$) ជាអាស៊ីមតូតឈរ។
- $\lim\limits_{x\to\pm\infty}\ln\left|\dfrac{x+1}{x}\right|=\ln 1=0 \implies \lim\limits_{x\to-\infty} f(x)=-\infty$ និង $\lim\limits_{x\to+\infty} f(x)=+\infty$ ។

ខ. **ដេរីវេ និងតារាងអថេរភាព ៖**

$f(x)=x+\ln|x+1|-\ln|x|$ ៖

$$f'(x)=1+\frac{1}{x+1}-\frac{1}{x}=1-\frac{1}{x(x+1)}=\frac{x^2+x-1}{x(x+1)}$$

$f'(x)=0 \iff x^2+x-1=0 \iff x_1=\dfrac{-1-\sqrt{5}}{2}\approx -1.62,\ x_2=\dfrac{-1+\sqrt{5}}{2}\approx 0.62$ ។

| $x$ | $-\infty$ | | $x_1$ | | $-1$ | | $0$ | | $x_2$ | | $+\infty$ |
|---|---|---|---|---|---|---|---|---|---|---|---|
| $f'(x)$ | | $+$ | $0$ | $-$ | ‖ | $-$ | ‖ | $-$ | $0$ | $+$ | |
| $f(x)$ | $-\infty$ | ↗ | $f(x_1)$ | ↘ $-\infty$ | ‖ $+\infty$ | ↘ | $-\infty$ ‖ $-\infty$ | → | $f(x_2)$ | → | $+\infty$ |

**គ. អាស៊ីមតូតទ្រេត និងទីតាំងធៀប ៖**

$\lim\limits_{x\to\pm\infty}[f(x)-x]=\lim\limits_{x\to\pm\infty}\ln\left|1+\dfrac{1}{x}\right|=0 \implies \boxed{y=x}$ ជាអាស៊ីមតូតទ្រេត។

ទីតាំងធៀប ៖ $f(x)-x=\ln\left|1+\dfrac{1}{x}\right|$ ៖

- លើ $(-\infty,-1)\cup(0,+\infty)\dfrac{x+1}{x}>1 \implies \ln\left|\dfrac{x+1}{x}\right|>0 \implies (C)$ នៅខាងលើ $(\Delta)$។
- លើ $(-1,0)\ -1<x<0 \implies \left|\dfrac{x+1}{x}\right|=\dfrac{x+1}{-x}$ ។ ត្រង់ $x=-\dfrac{1}{2}$ នោះ $|x+1|/|x|=1 \implies f(x)=x$ (កាត់គ្នា)។

**ឃ. បង្ហាញថា $A\left(-\frac{1}{2},-\frac{1}{2}\right)$ ជាផ្ចិតឆ្លុះនៃ $(C)$ ៖**

ផ្ទៀងផ្ទាត់រូបមន្តផ្ចិតឆ្លុះ $f(2a-x)+f(x)=2b$ ដោយ $a=-1/2, b=-1/2 \implies 2a=-1, 2b=-1$ ៖

$$f(-1-x)+f(x)=(-1-x)+\ln\left|\frac{-x}{-1-x}\right|+x+\ln\left|\frac{x+1}{x}\right|=-1+\ln\left(\frac{x}{x+1}\cdot\frac{x+1}{x}\right)=-1+0=-1$$

ដូចនេះ $A\left(-\frac{1}{2},-\frac{1}{2}\right)$ ជាផ្ចិតឆ្លុះនៃ $(C)$ ពិតប្រាកដមែន ។

**ង. សមីការបន្ទាត់ប៉ះទៅនឹង $(C)$ ត្រង់ $A$ ៖**

មេគុណប្រាប់ទិសត្រង់ $x=-\dfrac{1}{2}$ គឺ ៖

$$f'\left(-\frac{1}{2}\right)=\frac{\left(-\frac{1}{2}\right)^2+\left(-\frac{1}{2}\right)-1}{\left(-\frac{1}{2}\right)\left(-\frac{1}{2}+1\right)}=\frac{\frac{1}{4}-\frac{1}{2}-1}{-\frac{1}{4}}=\frac{-\frac{5}{4}}{-\frac{1}{4}}=5$$

សមីការបន្ទាត់ប៉ះត្រង់ $A\left(-\frac{1}{2},-\frac{1}{2}\right)$ គឺ ៖

$$y-\left(-\frac{1}{2}\right)=5\left(x-\left(-\frac{1}{2}\right)\right)\iff y+\frac{1}{2}=5x+\frac{5}{2}\iff \boxed{(T_A):y=5x+2}$$

**ច. សង់បន្ទាត់ $(\Delta)$ ខ្សែកោង $(C)$ និងបន្ទាត់ប៉ះត្រង់ $A$ ៖**




## លំហាត់ទី ១៣

អនុគមន៍ $f(x)$ កំណត់លើ $(0,+\infty)$ ដោយ $f(x)=x+1+\frac{-1+\ln x}{x}$ ហើយ $(C)$ ជាក្រាបរបស់វា ។

ក. អនុគមន៍ $g(x)$ កំណត់ដោយ $g(x)=2+x^2-\ln x$ ។ សង់តារាងអថេរភាពនៃ $g(x)$ (មិនចាំបាច់គណនាលីមីត) រួចទាញរកសញ្ញានៃ $g(x)$ លើ $(0,+\infty)$ ។

ខ. គណនាលីមីត $\lim_{x\to 0^+} f(x)$ និង $\lim_{x\to+\infty} f(x)$ ទាញឱ្យបានថា $(C)$ មានអាស៊ីមតូតឈរមួយដែលគេនឹងកំណត់សមីការ ។

គ. សិក្សាទំនាក់ទំនង $f'(x)=\frac{g(x)}{x^2}$ ។ សង់តារាងអថេរភាពនៃ $f(x)$ ។

ឃ. បង្ហាញថាបន្ទាត់ $(\Delta)y=x+1$ ជាអាស៊ីមតូតទ្រេតនៃ $(C)$ ។

ង. រកកូអរដោនេនៃចំណុចប្រសព្វនៃ $(C)$ ជាមួយ $(\Delta)$ រួចបញ្ជាក់ឱ្យបានច្បាស់ទីតាំងនៃ $(C)$ ធៀបទៅនឹង $(\Delta)$ ។

ច. សង់ខ្សែកោង $(C)$ និងសមីការអាស៊ីមតូតរបស់វាក្នុងតម្រុយកូអរដោនេតែមួយ ។

## ដំណោះស្រាយ

ក. **សិក្សាអនុគមន៍ជំនួយ $g(x)$ ៖**

$g'(x)=2x-\frac{1}{x}=\frac{2x^2-1}{x}$ ។

$g'(x)=0 \iff 2x^2-1=0 \iff x=\frac{\sqrt{2}}{2}$ (ព្រោះ $x>0$) ។

តម្លៃអប្បបរមាធៀប ៖ $g\left(\frac{\sqrt{2}}{2}\right)=2+\frac{1}{2}-\ln\left(\frac{\sqrt{2}}{2}\right)=\frac{5}{2}+\frac{1}{2}\ln 2>0$ ។

ដោយតម្លៃអប្បបរមាធៀបវិជ្ជមានដាច់ខាត នាំឱ្យ ៖

$$\boxed{g(x)>0,\quad \forall x\in(0,+\infty)}$$

| $x$ | $0$ | $\frac{\sqrt{2}}{2}$ | $+\infty$ |
|---|---|---|---|
| $g'(x)$ | ‖ $-$ | $0$ | $+$ |
| $g(x)$ | ‖ ↘ | $\frac{5}{2}+\frac{1}{2}\ln 2$ | ↗ |

**ខ. លីមីតនៃ $f(x)$ និងកំណត់សមីការអាស៊ីមតូតឈរ ៖**

- $\lim\limits_{x\to 0^+} f(x) = \lim\limits_{x\to 0^+}\left(x+1-\frac{1}{x}+\frac{\ln x}{x}\right) = 0+1-(+\infty)+(-\infty) = -\infty$ ។
  នាំឱ្យ បន្ទាត់ដែលមានសមីការ $\boxed{x=0}$ (អ័ក្សអរដោនេ $y'Oy$) ជាអាស៊ីមតូតឈរនៃ $(C)$ ។
- $\lim\limits_{x\to +\infty} f(x) = \lim\limits_{x\to +\infty}\left(x+1-\frac{1}{x}+\frac{\ln x}{x}\right) = +\infty+1-0+0 = \boxed{+\infty}$ ។

**គ. ទំនាក់ទំនង $f'(x)=\frac{g(x)}{x^2}$ និងតារាងអថេរភាពនៃ $f(x)$ ៖**

$$f'(x) = 1+\frac{\left(\frac{1}{x}\right)x-(-1+\ln x)(1)}{x^2} = 1+\frac{1+1-\ln x}{x^2} = \frac{x^2+2-\ln x}{x^2} = \boxed{\frac{g(x)}{x^2}}$$

ដោយ $g(x)>0$ និង $x^2>0$ ចំពោះគ្រប់ $x>0$ នាំឱ្យ $f'(x)>0, \forall x>0$ ។
ដូចនេះ អនុគមន៍ $f$ ជាអនុគមន៍កើនដាច់ខាតលើ $(0,+\infty)$ ។

| $x$ | $0$ | $+\infty$ |
|---|---|---|
| $f'(x)$ | ‖ | $+$ |
| $f(x)$ | ‖ $-\infty$ | ↗ $+\infty$ |

**ឃ. បង្ហាញថាបន្ទាត់ $(\Delta) y=x+1$ ជាអាស៊ីមតូតទ្រេតនៃ $(C)$ ៖**
ពិនិត្យផលដក ៖

$$\lim_{x\to+\infty}[f(x)-(x+1)] = \lim_{x\to+\infty}\frac{\ln x-1}{x} = \lim_{x\to+\infty}\left(\frac{\ln x}{x}-\frac{1}{x}\right) = 0-0 = 0$$

ដូចនេះ បន្ទាត់ $\boxed{(\Delta) y=x+1}$ ជាអាស៊ីមតូតទ្រេតនៃ $(C)$ ខាង $+\infty$ ។

**ង. ចំណុចប្រសព្វ និងទីតាំងធៀបនៃ $(C)$ ធៀបនឹង $(\Delta)$ ៖**

- ចំណុចប្រសព្វ ៖ $f(x)-(x+1)=0 \iff \frac{\ln x-1}{x}=0 \iff \ln x=1 \iff x=e$ ។
  អរដោនេ ៖ $y=e+1$ ។ ដូចនេះ ចំណុចប្រសព្វគឺ $\boxed{M(e,e+1)}$ ។
- ទីតាំងធៀប ៖ ដោយ $x>0$ សញ្ញានៃផលដកអាស្រ័យលើ $\ln x-1$ ៖
  - បើ $0<x<e \implies \ln x-1<0 \implies (C)$ ស្ថិតនៅខាងក្រោមបន្ទាត់ $(\Delta)$ ។
  - បើ $x=e \implies (C)$ កាត់បន្ទាត់ $(\Delta)$ ត្រង់ចំណុច $M(e,e+1)$ ។

– បើ $x > e \Longrightarrow \ln x - 1 > 0 \Longrightarrow (C)$ ស្ថិតនៅ**ខាងលើ**បន្ទាត់ $(\Delta)$ ។

ប. សង់ខ្សែកោង $(C)$ និងអាស៊ីមតូត ៖




## លំហាត់ទី ១៤

កំណត់សមីការបន្ទាត់ប៉ះ $(L)$ ដែលប៉ះនឹងខ្សែកោង $(H)$ តាងដោយ $y = x\ln x - 1$ នៅត្រង់ចំណុច $A(1, -1)$ ។

### ដំណោះស្រាយ

តាង $f(x) = x\ln x - 1$ កំណត់លើ $(0, +\infty)$ ។

១. ផ្ទៀងផ្ទាត់កូអរដោនេចំណុចប៉ះ ៖ $f(1) = 1\ln 1 - 1 = 0 - 1 = -1$ (ពិត ចំណុច $A(1, -1) \in (H)$)។

២. គណនាមេគុណប្រាប់ទិសនៃបន្ទាត់ប៉ះ ៖

$$f'(x) = (x)'\ln x + x(\ln x)' - (1)' = 1 \cdot \ln x + x \cdot \frac{1}{x} = \ln x + 1$$

ជំនួស $x_0 = 1$ ៖

$$f'(1) = \ln 1 + 1 = 0 + 1 = 1$$

៣. សរសេរសមីការបន្ទាត់ប៉ះ ៖

$$(L) y - y_0 = f'(x_0)(x - x_0) \iff y - (-1) = 1(x - 1) \iff y + 1 = x - 1$$

$$\boxed{(L) y = x - 2}$$

## លំហាត់ទី ១៥

គេឱ្យអនុគមន៍ $f(x)=\dfrac{\ln x}{x^2}$ មានក្រាប $(C)$ ។

ក. រកដែនកំណត់ រួចគណនាលីមីត $\lim\limits_{x\to+\infty} f(x)$ និង $\lim\limits_{x\to 0^+} f(x)$ ។ ទាញរកអាស៊ីមតូតឈរ និងអាស៊ីមតូតដេកនៃក្រាប $(C)$ ។

ខ. គណនាដេរីវេនៃ $f$ រួចបង្ហាញថា $f$ មានអតិបរមាត្រង់ $x=\sqrt{e}$ ។ សង់តារាងអថេរភាពនៃ $f$ ។

គ. រកសមីការបន្ទាត់ប៉ះ $(d)$ ទៅនឹងក្រាប $(C)$ ត្រង់ចំណុចដែលមានអាប់ស៊ីស $x=1$ ។

ឃ. សង់ក្រាប $(C)$ និងបន្ទាត់ប៉ះ $(d)$ ក្នុងតម្រុយអរតូណរម៉ាល់។

## ដំណោះស្រាយ

**ក. ដែនកំណត់ និងលីមីត ៖**

ដែនកំណត់ ៖ $\boxed{D=(0,+\infty)}$ ។

- $\lim\limits_{x\to 0^+}\dfrac{\ln x}{x^2}=\dfrac{-\infty}{0^+}=-\infty \implies \boxed{x=0 \text{ (អ័ក្ស } Oy)}$ ជាអាស៊ីមតូតឈរ។
- $\lim\limits_{x\to+\infty}\dfrac{\ln x}{x^2}=0 \implies \boxed{y=0 \text{ (អ័ក្ស } Ox)}$ ជាអាស៊ីមតូតដេក។

**ខ. ដេរីវេ និងតារាងអថេរភាព ៖**

$$f'(x)=\frac{\left(\frac{1}{x}\right)x^2-(\ln x)(2x)}{x^4}=\frac{x-2x\ln x}{x^4}=\frac{1-2\ln x}{x^3}$$

$f'(x)=0 \iff 1-2\ln x=0 \iff \ln x=\dfrac{1}{2} \iff x=e^{1/2}=\sqrt{e}\approx 1.65$ ។

តម្លៃអតិបរមាធៀប ៖ $f(\sqrt{e})=\dfrac{\ln(\sqrt{e})}{(\sqrt{e})^2}=\dfrac{1/2}{e}=\dfrac{1}{2e}\approx 0.184$ ។

| $x$ | $0$ | | $\sqrt{e}$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | ‖ | $+$ | $0$ | $-$ | |
| $f(x)$ | ‖ $-\infty$ | ↗ | $\frac{1}{2e}$ | ↘ | $0$ |

**គ. សមីការបន្ទាត់ប៉ះត្រង់ $x=1$ ៖**

$f(1)=\dfrac{\ln 1}{1}=0$ ។

$f'(1)=\dfrac{1-2\ln 1}{1^3}=1$ ។

សមីការបន្ទាត់ប៉ះ ៖ $(d) y-0=1(x-1) \iff \boxed{y=x-1}$ ។

**ឃ. សង់ក្រាប $(C)$ ៖**




**លំហាត់ទី ១៦**

$f$ កំណត់ចំពោះ $x > 0$ ដោយ $f(x) = \dfrac{1+2\ln x}{x^2}$ ហើយមានក្រាប $(C)$ ក្នុងតម្រុយ $(O,\vec{i},\vec{j})$ ។

ក. គណនាលីមីតចុងដែនកំណត់ រួចបញ្ជាក់សមីការអាស៊ីមតូតនៃក្រាប $(C)$ ។

ខ. គណនា $f'(x)$ រួចបង្ហាញថា $f(x)$ មានអតិបរមាមួយ ហើយគណនាតម្លៃអតិបរមានោះ ។

គ. សង់តារាងអថេរភាពនៃ $f$ រួចរកកូអរដោនេចំណុចរបត់នៃក្រាប $(C)$ ។

ឃ. សរសេរសមីការបន្ទាត់ $(T)$ ប៉ះទៅនឹងក្រាប $(C)$ ត្រង់ចំណុចដែលក្រាប $(C)$ កាត់អ័ក្សអាប់ស៊ីស ។

ង. គណនា $f\left(\dfrac{1}{2}\right)$ និង $f(2)$ រួចសង់បន្ទាត់ $(T)$ និងក្រាប $(C)$ ។ ដោយប្រើក្រាប $(C)$ កំណត់តម្លៃ $m$ ដើម្បីឱ្យសមីការ $\dfrac{1+2\ln x}{x^2} = m$ មានឫស (គេឱ្យ $\ln 2 = 0.7$) ។

## ដំណោះស្រាយ

### ក. លីមីត និងអាស៊ីមតូត ៖

- $\lim\limits_{x\to 0^+} \dfrac{1+2\ln x}{x^2} = \dfrac{-\infty}{0^+} = -\infty \implies \boxed{x = 0 \text{ (អ័ក្ស } Oy)}$ ជាអាស៊ីមតូតឈរ។
- $\lim\limits_{x\to +\infty} \dfrac{1+2\ln x}{x^2} = \lim\limits_{x\to +\infty} \left(\dfrac{1}{x^2} + \dfrac{2\ln x}{x^2}\right) = 0+0 = 0 \implies \boxed{y = 0 \text{ (អ័ក្ស } Ox)}$ ជាអាស៊ីមតូតដេក។

### ខ. ដេរីវេ និងអតិបរមា ៖

$$f'(x) = \frac{\left(\frac{2}{x}\right)x^2 - (1+2\ln x)(2x)}{x^4} = \frac{2x - 2x - 4x\ln x}{x^4} = \boxed{\frac{-4\ln x}{x^3}}$$

$f'(x) = 0 \iff -4\ln x = 0 \iff \ln x = 0 \iff x = 1$ ។

- បើ $0 < x < 1 \implies \ln x < 0 \implies f'(x) > 0 \implies f$ ជាអនុគមន៍កើន ។
- បើ $x > 1 \implies \ln x > 0 \implies f'(x) < 0 \implies f$ ជាអនុគមន៍ចុះ ។
- អតិបរមាធៀបត្រង់ $x = 1$ គឺ ៖ $f(1) = \dfrac{1+2\ln 1}{1^2} = \boxed{1}$ ។

គ. តារាងអថេរភាព និងចំណុចរបត់ ៖

| $x$ | $0$ | | $1$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | ‖ | $+$ | $0$ | $-$ | |
| $f(x)$ | ‖ $-\infty$ | ↗ | $1$ | ↘ | $0$ |

គណនាដេរីវេទីពីរ $f''(x)$ ៖

$$f''(x) = \frac{\left(-\frac{4}{x}\right)x^3 - (-4\ln x)(3x^2)}{x^6} = \frac{-4x^2 + 12x^2\ln x}{x^6} = \frac{4(3\ln x - 1)}{x^4}$$

$f''(x) = 0 \iff 3\ln x - 1 = 0 \iff \ln x = \dfrac{1}{3} \iff x = e^{1/3} = \sqrt[3]{e} \approx 1.40$ ។

$f(\sqrt[3]{e}) = \dfrac{1+2(1/3)}{e^{2/3}} = \dfrac{5/3}{e^{2/3}} = \dfrac{5}{3\sqrt[3]{e^2}} \approx 0.89$ ។

**ដូចនេះ ចំណុចរបត់គឺ** $\boxed{J\left(\sqrt[3]{e}, \dfrac{5}{3\sqrt[3]{e^2}}\right) \approx J(1.40, 0.89)}$ ។

ឃ. សមីការបន្ទាត់ $(T)$ ប៉ះក្រាប $(C)$ ត្រង់ចំណុចកាត់អ័ក្សអាប់ស៊ីស ៖

រកចំណុចប្រសព្វរវាង $(C)$ នឹងអ័ក្ស $Ox$ ៖

$$f(x) = 0 \iff 1 + 2\ln x = 0 \iff \ln x = -\frac{1}{2} \iff x_0 = e^{-1/2} = \frac{1}{\sqrt{e}} \approx 0.61 \implies M\left(\frac{1}{\sqrt{e}}, 0\right)$$

មេគុណប្រាប់ទិសនៃបន្ទាត់ប៉ះ ៖

$$f'(x_0) = \frac{-4\ln(e^{-1/2})}{(e^{-1/2})^3} = \frac{-4\left(-\frac{1}{2}\right)}{e^{-3/2}} = 2e^{3/2} = 2e\sqrt{e} \approx 8.91$$

សមីការបន្ទាត់ប៉ះ $(T)$ គឺ ៖

$$y - 0 = 2e\sqrt{e}\left(x - \frac{1}{\sqrt{e}}\right) \iff \boxed{(T): y = 2e\sqrt{e}x - 2e \approx 8.91x - 5.4}$$

ង. គណនាតម្លៃ សង់ក្រាប និងពិភាក្សាឫសតាម $m$ ៖

- គណនា $f\left(\dfrac{1}{2}\right)$ និង $f(2)$ ដោយយក $\ln 2 = 0.7$ ៖

$$f\left(\frac{1}{2}\right) = \frac{1 + 2\ln\left(\frac{1}{2}\right)}{\left(\frac{1}{2}\right)^2} = \frac{1 - 2\ln 2}{\frac{1}{4}} = 4(1 - 2(0.7)) = 4(-0.4) = \boxed{-1.6}$$

$$f(2) = \frac{1 + 2\ln 2}{2^2} = \frac{1 + 2(0.7)}{4} = \frac{2.4}{4} = \boxed{0.6}$$

- កំណត់តម្លៃ $m$ ដើម្បីឱ្យសមីការ $\frac{1+2\ln x}{x^2}=m$ មានឫស ៖
  ចំនួនឫសនៃសមីការគឺជាចំនួនចំណុចប្រសព្វរវាងខ្សែកោង $(C)$ និងបន្ទាត់ដេក $y=m$ ។
  តាមតារាងអថេរភាព តម្លៃអតិបរមាដាច់ខាតនៃ $f(x)$ លើ $(0,+\infty)$ គឺ $f(1)=1$ ហើយ $\lim_{x\to 0^+} f(x)=-\infty$ ។
  ដូច្នេះ សំណុំតម្លៃនៃអនុគមន៍គឺ $f((0,+\infty))=(-\infty,1]$ ។
  ដូចនេះ សមីការមានឫសលុះត្រាតែ ៖

$$\boxed{m\leq 1}$$




---

## លំហាត់ទី ១៧

គេឱ្យអនុគមន៍ $f(x)=-\frac{x}{2}+\ln\left(\frac{x-1}{x}\right)$ មានក្រាប $(C)$ ។

ក. រកដែនកំណត់នៃអនុគមន៍ $f$ និងគណនាលីមីតត្រង់ចុងដែនកំណត់ រួចទាញរកអាស៊ីមតូតឈរនៃក្រាប $(C)$ ។

ខ. គណនាដេរីវេ $f'(x)$ រួចសិក្សាសញ្ញាដោយដឹងថា $x(x-1)>0$ ។ គូសតារាងអថេរភាព។

គ. បង្ហាញថាបន្ទាត់ $(\Delta) y=-\frac{x}{2}$ ជាអាស៊ីមតូតទ្រេតនៃ $(C)$ និងសិក្សាទីតាំងធៀប។

ឃ. សង់ក្រាប $(C)$ និងអាស៊ីមតូតក្នុងតម្រុយអរតូណរម៉ាល់។

## ដំណោះស្រាយ

ក. **ដែនកំណត់ និងលីមីត ៖**

លក្ខខណ្ឌ ៖ $\frac{x-1}{x}>0 \iff \boxed{D=(-\infty,0)\cup(1,+\infty)}$ ។

- $\lim_{x\to 0^-} \ln\left(\frac{x-1}{x}\right)=\ln(+\infty)=+\infty \implies \boxed{x=0}$ ជាអាស៊ីមតូតឈរ។
- $\lim_{x\to 1^+} \ln\left(\frac{x-1}{x}\right)=\ln(0^+)=-\infty \implies \boxed{x=1}$ ជាអាស៊ីមតូតឈរ។
- $\lim_{x\to -\infty} f(x)=+\infty$ ; $\lim_{x\to +\infty} f(x)=-\infty$ ។

**ខ.** ដេរីវេ និងតារាងអថេរភាព ៖

$f(x)=-\frac{x}{2}+\ln(x-1)-\ln x$ ចំពោះ $x>1$ (ឬ $\ln(1-x)-\ln(-x)$ ចំពោះ $x<0$) ៖

$$f'(x)=-\frac{1}{2}+\frac{1}{x-1}-\frac{1}{x}=-\frac{1}{2}+\frac{1}{x(x-1)}=\frac{-x(x-1)+2}{2x(x-1)}=\frac{-x^2+x+2}{2x(x-1)}=\frac{-(x+1)(x-2)}{2x(x-1)}$$

$f'(x)=0 \iff x=-1$ ឬ $x=2$ ។

- លើ $(-\infty,-1)f'(x)<0 \implies f$ ចុះ។
- លើ $(-1,0)f'(x)>0 \implies f$ កើន (អប្បបរមាធៀបត្រង់ $x=-1 f(-1)=\frac{1}{2}+\ln 2$)។
- លើ $(1,2)f'(x)>0 \implies f$ កើន (អតិបរមាធៀបត្រង់ $x=2 f(2)=-1-\ln 2$)។
- លើ $(2,+\infty)f'(x)<0 \implies f$ ចុះ។

| $x$ | $-\infty$ | | $-1$ | | $0$ | $1$ | | $2$ | | $+\infty$ |
|---|---|---|---|---|---|---|---|---|---|---|
| $f'(x)$ | | $-$ | $0$ | $+$ | ‖ | ‖ | $+$ | $0$ | $-$ | |
| $f(x)$ | $+\infty$ ↘ | | $\frac{1}{2}+\ln 2$ | ↗ | $+\infty$ ‖ | ‖ $-\infty$ | ↗ | $-1-\ln 2$ | ↘ | $-\infty$ |

**គ.** អាស៊ីមតូតទ្រេត និងទីតាំងធៀប ៖

$\lim_{x\to\pm\infty}\left[f(x)-\left(-\frac{x}{2}\right)\right]=\lim_{x\to\pm\infty}\ln\left(1-\frac{1}{x}\right)=0 \implies \boxed{y=-\frac{x}{2}}$ ជាអាស៊ីមតូតទ្រេត។

ទីតាំងធៀប ៖

- $x\in(-\infty,0) \implies 1-\frac{1}{x}>1 \implies \ln\left(\frac{x-1}{x}\right)>0 \implies (C)$ នៅខាងលើ $(\Delta)$។
- $x\in(1,+\infty) \implies 1-\frac{1}{x}<1 \implies \ln\left(\frac{x-1}{x}\right)<0 \implies (C)$ នៅខាងក្រោម $(\Delta)$។

**ឃ.** សង់ក្រាប $(C)$ ៖ ផ្ចិតឆ្លុះ $I(1/2,-1/4)$។



## លំហាត់ទី ១៨

គេឱ្យអនុគមន៍ $f(x)=\dfrac{x^2+\ln x+1}{x}$ កំណត់ចំពោះ $x>0$ មានក្រាប $(C)$ ។

ក. គណនា $\lim\limits_{x\to 0^+} f(x)$ និង $\lim\limits_{x\to +\infty} f(x)$ រួចរកសមីការអាស៊ីមតូតឈរនៃ $(C)$ ។

ខ. គណនា $f'(x)$ រួចបង្ហាញថា $f'(x)>0, \forall x>0$ ។ សង់តារាងអថេរភាពនៃ $f$ ។

គ. បង្ហាញថាបន្ទាត់ $(d) y=x$ ជាអាស៊ីមតូតទ្រេតនៃ $(C)$ ខាង $+\infty$ និងសិក្សាទីតាំងធៀប។

ឃ. សង់ក្រាប $(C)$ និងអាស៊ីមតូតក្នុងតម្រុយអរតូណរម៉ាល់។

## ដំណោះស្រាយ

### ក. លីមីត និងអាស៊ីមតូត ៖

សរសេរ $f(x)=x+\dfrac{\ln x}{x}+\dfrac{1}{x}$ លើ $(0,+\infty)$ ។

- $\lim\limits_{x\to 0^+} f(x)=\lim\limits_{x\to 0^+}\left(x+\dfrac{\ln x+1}{x}\right)=\dfrac{-\infty}{0^+}=-\infty \implies \boxed{x=0}$ ជាអាស៊ីមតូតឈរ។
- $\lim\limits_{x\to +\infty} f(x)=\lim\limits_{x\to +\infty}\left(x+\dfrac{\ln x}{x}+\dfrac{1}{x}\right)=+\infty+0+0=+\infty$ ។

### ខ. ដេរីវេ និងតារាងអថេរភាព ៖

$$f'(x)=1+\frac{\left(\frac{1}{x}\right)x-\ln x(1)}{x^2}-\frac{1}{x^2}=1+\frac{1-\ln x-1}{x^2}=1-\frac{\ln x}{x^2}=\frac{x^2-\ln x}{x^2}$$

ពិនិត្យភាគយក $h(x)=x^2-\ln x$ លើ $(0,+\infty)$ ៖

$h'(x)=2x-\dfrac{1}{x}=\dfrac{2x^2-1}{x}=0 \iff x=\dfrac{1}{\sqrt{2}}$ ។

តម្លៃអប្បបរមានៃ $h(x)$ គឺ ៖ $h\left(\dfrac{1}{\sqrt{2}}\right)=\dfrac{1}{2}-\ln\left(\dfrac{1}{\sqrt{2}}\right)=\dfrac{1+\ln 2}{2}>0$ ។

ដូចនេះ $h(x)>0, \forall x>0 \implies f'(x)>0, \forall x>0$ ។

អនុគមន៍ $f$ កើនដាច់ខាតលើ $(0,+\infty)$ ។

| $x$ | $0$ $\qquad\qquad$ $+\infty$ |
|---|---|
| $f'(x)$ | ‖ $\quad +$ |
| $f(x)$ | ‖ $-\infty \nearrow +\infty$ |

### គ. អាស៊ីមតូតទ្រេត និងទីតាំងធៀប ៖

$\lim\limits_{x\to +\infty}[f(x)-x]=\lim\limits_{x\to +\infty}\dfrac{\ln x+1}{x}=0+0=0 \implies \boxed{(d) y=x}$ ជាអាស៊ីមតូតទ្រេតខាង $+\infty$ ។

ទីតាំងធៀប ៖ $f(x)-x=\dfrac{\ln x+1}{x}$ ៖

- $x \in \left(0, \frac{1}{e}\right) \implies \ln x + 1 < 0 \implies (C)$ នៅខាងក្រោម $(d)$។
- $x = \frac{1}{e} \implies (C)$ កាត់ $(d)$ ត្រង់ចំណុច $\left(\frac{1}{e}, \frac{1}{e}\right)$។
- $x \in \left(\frac{1}{e}, +\infty\right) \implies \ln x + 1 > 0 \implies (C)$ នៅខាងលើ $(d)$។

ឃ. សង់ក្រាប $(C)$ ៖




---

## លំហាត់ទី ១៩

គេឱ្យអនុគមន៍ $f$ កំណត់ចំពោះ $x > 0$ ដោយ $y = f(x) = 1 - \frac{2\ln x}{x}$ ហើយមានក្រាប $(C)$ ។

ក. គណនា $\lim_{x \to 0^+} f(x)$ និង $\lim_{x \to +\infty} f(x)$ ។ កំណត់សមីការអាស៊ីមតូតឈរ និងអាស៊ីមតូតដេកនៃក្រាប $(C)$ ។

ខ. គណនាដេរីវេ $f'(x)$ និងសិក្សាសញ្ញា $f'(x)$ ។ កំណត់តម្លៃបរមានៃ $f$ រួចសង់តារាងអថេរភាពនៃ $f$ ។

គ. កំណត់កូអរដោនេនៃចំណុច $M$ រវាងក្រាប $(C)$ និងអាស៊ីមតូតដេករបស់វា ។ រកសមីការបន្ទាត់ $(L)$ ដែលប៉ះក្រាប $(C)$ ត្រង់ $M$ ។

ឃ. សង់បន្ទាត់ $(L)$ និងក្រាប $(C)$ ក្នុងតម្រុយតែមួយ (យក $e \approx 2.7, \frac{2}{e} \approx 0.7$) ។

ង. កំណត់តម្លៃ $k$ ដោយប្រើក្រាប $(C)$ ដើម្បីឱ្យសមីការ $1 - \frac{2\ln x}{x} = k$ មានឫស ។ គណនាផ្ទៃក្រឡាផ្ទៃកប្លង់កំណត់ដោយក្រាប $(C)$ អ័ក្ស $(Ox)$ និងបន្ទាត់ឈរ $x = 1, x = e$ ។

## ដំណោះស្រាយ

ក. គណនាលីមីត និងកំណត់សមីការអាស៊ីមតូត ៖

- ដែនកំណត់ ៖ $D = (0, +\infty)$ ។

- លីមីតត្រង់ $0^+$ ៖

$$\lim_{x\to 0^+} f(x) = \lim_{x\to 0^+}\left(1-\frac{2\ln x}{x}\right) = 1-2\lim_{x\to 0^+}\left(\frac{1}{x}\cdot\ln x\right)$$

ដោយកាលណា $x\to 0^+$ គេបាន $\frac{1}{x}\to+\infty$ និង $\ln x\to-\infty \Longrightarrow \frac{\ln x}{x}\to-\infty$ ៖

$$\lim_{x\to 0^+} f(x) = 1-2(-\infty) = +\infty \Longrightarrow \boxed{x=0 \quad (\text{អ័ក្ស } Oy) \text{ ជាអាស៊ីមតូតឈរ}}$$

- លីមីតត្រង់ $+\infty$ ៖ តាមរូបមន្តលីមីតគ្រឹះ $\lim_{x\to+\infty}\frac{\ln x}{x}=0$ ៖

$$\lim_{x\to+\infty} f(x) = \lim_{x\to+\infty}\left(1-\frac{2\ln x}{x}\right) = 1-0 = \mathbf{1} \Longrightarrow \boxed{y=1 \quad \text{ជាអាស៊ីមតូតដេកខាង } +\infty}$$

ខ. គណនាដេរីវេ សិក្សាសញ្ញា និងសង់តារាងអថេរភាព ៖

- អនុវត្តរូបមន្ត $\left(\frac{u}{v}\right)' = \frac{u'v-uv'}{v^2}$ ៖

$$f'(x) = 0-2\cdot\frac{(\ln x)'\cdot x-(\ln x)(x)'}{x^2} = -2\cdot\frac{\frac{1}{x}\cdot x-\ln x}{x^2} = \frac{2(\ln x-1)}{x^2}$$

- ដោយសារ $x^2>0$ ចំពោះគ្រប់ $x>0$ នោះសញ្ញានៃ $f'(x)$ អាស្រ័យលើកន្សោម $\ln x-1$ ៖

$$f'(x)=0 \Longleftrightarrow \ln x-1=0 \Longleftrightarrow \ln x=1 \Longleftrightarrow x=e$$

  - បើ $0<x<e$ នោះ $\ln x<1 \Longrightarrow f'(x)<0$ (អនុគមន៍ចុះដាច់ខាត) ។
  - បើ $x>e$ នោះ $\ln x>1 \Longrightarrow f'(x)>0$ (អនុគមន៍កើនដាច់ខាត) ។

- អនុគមន៍ $f$ មានតម្លៃអប្បបរមាធៀបត្រង់ $x=e$ គឺ ៖

$$f(e) = 1-\frac{2\ln e}{e} = 1-\frac{2}{e} \approx 1-0.74 = \mathbf{0.26}$$

| $x$ | $0$ | | $e$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | ‖ | $-$ | $0$ | $+$ | |
| $f(x)$ | $+\infty$ ‖ $+\infty$ | ↘ | $1-\frac{2}{e}$ | ↗ | $1$ |

គ. រកកូអរដោនេចំណុច $M$ និងសមីការបន្ទាត់ប៉ះ $(L)$ ៖

- ចំណុចប្រសព្វ $M$ រវាង $(C)$ និងអាស៊ីមតូតដេក $y=1$ ៖

$$f(x)=1 \Longleftrightarrow 1-\frac{2\ln x}{x}=1 \Longleftrightarrow \frac{2\ln x}{x}=0 \Longleftrightarrow \ln x=0 \Longleftrightarrow x=1$$

ដូច្នេះកូអរដោនេចំណុច $M$ គឺ $\boxed{M(1,1)}$ ។

- មេគុណប្រាប់ទិសនៃបន្ទាត់ប៉ះត្រង់ $M(1,1)$ គឺ ៖

$$f'(1)=\frac{2(\ln 1-1)}{1^2}=\frac{2(0-1)}{1}=-2$$

- សមីការបន្ទាត់ប៉ះ $(L)$ ត្រង់ចំណុច $M(1,1)$ គឺ ៖

$$y-y_M=f'(1)(x-x_M)\iff y-1=-2(x-1)\iff \boxed{y=-2x+3}$$

**ឃ. សង់បន្ទាត់ $(L)$ និងក្រាប $(C)$ ៖**




**ង. ពិភាក្សាចំនួនឫស និងគណនាផ្ទៃក្រឡា ៖**

- **ពិភាក្សាចំនួនឫសនៃសមីការ $1-\frac{2\ln x}{x}=k$ តាមតម្លៃ $k$ ៖**

ចំនួនឫសនៃសមីការជាចំនួនចំណុចប្រសព្វរវាងក្រាប $(C)$ និងបន្ទាត់ដេក $y=k$ ៖

– បើ $k<1-\frac{2}{e}$ ៖ បន្ទាត់ $y=k$ មិនកាត់ $(C)$ ទេ $\Longrightarrow$ សមីការ**គ្មានឫស** ។

– បើ $k=1-\frac{2}{e}$ ៖ បន្ទាត់ $y=k$ ប៉ះ $(C)$ ត្រង់ចំណុចអប្បបរមា $\Longrightarrow$ សមីការមាន**ឫសឌុប** $x=e$ ។

– បើ $1-\frac{2}{e}<k<1$ ៖ បន្ទាត់ $y=k$ កាត់ $(C)$ ត្រង់ ២ ចំណុច $\Longrightarrow$ សមីការមាន**ឫសពីរផ្សេងគ្នា** ។

– បើ $k\geq 1$ ៖ បន្ទាត់ $y=k$ កាត់ $(C)$ ត្រង់ ១ ចំណុចគត់ $\Longrightarrow$ សមីការមាន**ឫសតែមួយគត់** ។

- **គណនាផ្ទៃក្រឡាផ្នែកប្លង់ ៖**

ចំពោះ $x\in[1,e]$ គេមាន $\frac{2\ln x}{x}\geq 0\implies f(x)=1-\frac{2\ln x}{x}\leq 1$ ហើយ $f(x)\geq 1-\frac{2}{e}>0$ (ក្រាបនៅលើអ័ក្សអាប់ស៊ីស) ៖

$$S=\int_1^e f(x)\,dx=\int_1^e\left(1-\frac{2\ln x}{x}\right)dx=\left[x-(\ln x)^2\right]_1^e$$

ព្រោះ $\left((\ln x)^2\right)'=2\ln x\cdot(\ln x)'=\frac{2\ln x}{x}$ ។

$$S=\left(e-(\ln e)^2\right)-\left(1-(\ln 1)^2\right)=(e-1)-(1-0)=\mathbf{e-2}$$

ជំនួស $e\approx 2.718$ គេបាន $\boxed{S=e-2\approx 0.72 \text{ ឯកតាក្រឡាផ្ទៃ}}$ ។

## លំហាត់ទី ២០

គេឱ្យអនុគមន៍ $f$ កំណត់ចំពោះ $x>0$ ដោយ $f(x)=1+2\left(\dfrac{\ln x}{x}\right)$ ហើយមានក្រាប $(C)$ ។

ក. គណនា $\lim\limits_{x\to 0^+} f(x)$ និង $\lim\limits_{x\to+\infty} f(x)$ ។ កំណត់សមីការអាស៊ីមតូតឈរ និងដេកនៃក្រាប $(C)$ ។

ខ. គណនា $f'(x)$ និងសិក្សាសញ្ញា $f'(x)$ ។ កំណត់តម្លៃបរមានៃ $f$ រួចសង់តារាងអថេរភាពនៃ $f$ ។

គ. កំណត់កូអរដោនេនៃចំណុច $M$ រវាងក្រាប $(C)$ និងអាស៊ីមតូតដេក ។ សរសេរសមីការបន្ទាត់ $(L)$ ប៉ះក្រាប $(C)$ ត្រង់ $M$ ។

ឃ. សង់បន្ទាត់ $(L)$ និងក្រាប $(C)$ ក្នុងតម្រុយតែមួយ (យក $e\approx 2.7, \dfrac{2}{e}\approx 0.7$) ។

ង. កំណត់តម្លៃ $k$ ដោយប្រើក្រាប $(C)$ ដើម្បីឱ្យសមីការ $1+2\left(\dfrac{\ln x}{x}\right)=k$ មានឫស ។ គណនាផ្ទៃក្រឡាផ្នែកប្លង់កំណត់ដោយក្រាប $(C)$ អាស៊ីមតូតដេក និងបន្ទាត់ $x=1, x=e$ ។

## ដំណោះស្រាយ

### ក. គណនាលីមីត និងកំណត់សមីការអាស៊ីមតូត ៖

- ដែនកំណត់ ៖ $D=(0,+\infty)$ ។
- លីមីតត្រង់ $0^+$ ៖ $\lim\limits_{x\to 0^+}\dfrac{\ln x}{x}=-\infty \implies \lim\limits_{x\to 0^+} f(x)=-\infty$ ។

  ដូច្នេះ $x=0$ (អ័ក្ស $Oy$) ជាអាស៊ីមតូតឈរ ។
- លីមីតត្រង់ $+\infty$ ៖ $\lim\limits_{x\to+\infty}\dfrac{\ln x}{x}=0 \implies \lim\limits_{x\to+\infty} f(x)=1$ ។

  ដូច្នេះ $y=1$ ជាអាស៊ីមតូតដេកខាង $+\infty$ ។

### ខ. គណនាដេរីវេ និងសង់តារាងអថេរភាព ៖

- ដេរីវេ ៖

$$f'(x)=2\cdot\frac{\frac{1}{x}\cdot x-\ln x}{x^2}=\frac{2(1-\ln x)}{x^2}$$

- សញ្ញា ៖ $f'(x)=0 \iff 1-\ln x=0 \iff x=e$ ។
  - លើចន្លោះ $(0,e)$ ៖ $1-\ln x>0 \implies f'(x)>0$ (កើន) ។
  - លើចន្លោះ $(e,+\infty)$ ៖ $1-\ln x<0 \implies f'(x)<0$ (ចុះ) ។
- អនុគមន៍មានតម្លៃអតិបរមាធៀបត្រង់ $x=e$ គឺ $f(e)=1+\dfrac{2}{e}\approx 1+0.74=\mathbf{1.74}$ ។

| $x$ | $0$ | | | $e$ | | $+\infty$ |
|---|---|---|---|---|---|---|
| $f'(x)$ | ‖ | | $+$ | $0$ | $-$ | |
| $f(x)$ | ‖ $-\infty$ | $\nearrow$ | | $1+\dfrac{2}{e}$ | $\searrow$ | $1$ |

**គ**. ចំណុច $M$ និងបន្ទាត់ប៉ះ $(L)$ ៖

- ប្រសព្វនឹង $y=1$ ៖ $1+\dfrac{2\ln x}{x}=1 \iff \ln x=0 \iff x=1 \implies \boxed{M(1,1)}$ ។
- មេគុណប្រាប់ទិស ៖ $f'(1)=\dfrac{2(1-0)}{1}=2$ ។
- សមីការបន្ទាត់ប៉ះ $(L)$ ៖

$$y-1=2(x-1) \iff \boxed{y=2x-1}$$

**ឃ**. សង់បន្ទាត់ $(L)$ និងក្រាប $(C)$ ៖




**ង**. ពិភាក្សាចំនួនឫស និងគណនាផ្ទៃក្រឡា ៖

- ពិភាក្សាសមីការ $f(x)=k$ ៖
  - បើ $k>1+\dfrac{2}{e}$ ៖ សមីការគ្មានឫស ។
  - បើ $k=1+\dfrac{2}{e}$ ៖ សមីការមានឫសឌុប $x=e$ ។
  - បើ $1<k<1+\dfrac{2}{e}$ ៖ សមីការមានឫសពីរផ្សេងគ្នា ។
  - បើ $k\le 1$ ៖ សមីការមានឫសតែមួយគត់ ។
- គណនាផ្ទៃក្រឡាធៀបនឹងអាស៊ីមតូតដេក $y=1$ ចំពោះ $x\in[1,e]$ ៖
  ដោយ $f(x)\ge 1$ លើ $[1,e]$ ៖

$$S=\int_1^e (f(x)-1)\,dx=\int_1^e \frac{2\ln x}{x}\,dx=\left[(\ln x)^2\right]_1^e=(\ln e)^2-(\ln 1)^2=1-0=\mathbf{1}$$

ដូច្នេះ $\boxed{S=1 \text{ ឯកតាក្រឡាផ្ទៃ}}$ ។

## លំហាត់ទី ២១

គេឱ្យអនុគមន៍ $f$ កំណត់ចំពោះ $x>0$ ដោយ $f(x)=2\left(1-\dfrac{\ln x}{x}\right)$ ហើយមានក្រាប $(C)$ ។

ក. គណនា $\lim\limits_{x\to 0^+} f(x)$ និង $\lim\limits_{x\to +\infty} f(x)$ ។ កំណត់សមីការអាស៊ីមតូតឈរ និងអាស៊ីមតូតដេកនៃក្រាប $(C)$ ។

ខ. គណនា $f'(x)$ និងសិក្សាសញ្ញា $f'(x)$ ។ កំណត់តម្លៃបរមានៃ $f$ រួចសង់តារាងអថេរភាពនៃ $f$ ។

គ. កំណត់កូអរដោនេនៃចំណុច $M$ រវាងក្រាប $(C)$ និងអាស៊ីមតូតដេករបស់វា ។ កំណត់សមីការបន្ទាត់ $(L)$ ដែលប៉ះក្រាប $(C)$ ត្រង់ $M$ ។

ឃ. សង់បន្ទាត់ $(L)$ និងក្រាប $(C)$ ក្នុងតម្រុយតែមួយ (យក $e\approx 2.7, \dfrac{2}{e}\approx 0.7$) ។

ង. កំណត់តម្លៃ $k$ ដោយប្រើក្រាប $(C)$ ដើម្បីឱ្យសមីការ $2\left(1-\dfrac{\ln x}{x}\right)=k$ មានឫស ។ គណនាផ្ទៃក្រឡាផ្នែកប្លង់កំណត់ដោយក្រាប $(C)$ អ័ក្ស $(Ox)$ និងបន្ទាត់ឈរ $x=1, x=e$ ។

## ដំណោះស្រាយ

### ក. គណនាលីមីត និងកំណត់សមីការអាស៊ីមតូត ៖

- ដែនកំណត់ ៖ $D=(0,+\infty)$ ។
- $\lim\limits_{x\to 0^+} f(x)=\lim\limits_{x\to 0^+} 2\left(1-\frac{\ln x}{x}\right)=2(1-(-\infty))=+\infty \implies$ $\boxed{x=0 \text{ ជាអាស៊ីមតូតឈរ}}$ ។
- $\lim\limits_{x\to +\infty} f(x)=\lim\limits_{x\to +\infty} 2\left(1-\frac{\ln x}{x}\right)=2(1-0)=\mathbf{2} \implies$ $\boxed{y=2 \text{ ជាអាស៊ីមតូតដេក}}$ ។

### ខ. គណនាដេរីវេ និងសង់តារាងអថេរភាព ៖

- $f'(x)=-2\cdot\dfrac{1-\ln x}{x^2}=\dfrac{2(\ln x-1)}{x^2}$ ។
- $f'(x)=0 \iff \ln x=1 \iff x=e$ ។
- $f'(x)<0$ លើ $(0,e)$ និង $f'(x)>0$ លើ $(e,+\infty)$ ។
- អប្បបរមាធៀបត្រង់ $x=e$ គឺ $f(e)=2\left(1-\dfrac{1}{e}\right)=2-\dfrac{2}{e}\approx 2-0.74=\mathbf{1.26}$ ។

| $x$ | $0$ | | $e$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | ‖ | $-$ | $0$ | $+$ | |
| $f(x)$ | $+\infty$ ‖ $+\infty$ | ↘ | $2-\dfrac{2}{e}$ | ↗ | $2$ |

### គ. ចំណុច $M$ និងបន្ទាត់ប៉ះ $(L)$ ៖

- ប្រសព្វនឹង $y=2$ ៖ $2\left(1-\frac{\ln x}{x}\right)=2 \iff \ln x=0 \iff x=1 \implies \boxed{M(1,2)}$ ។
- $f'(1)=\dfrac{2(\ln 1-1)}{1^2}=-2$ ។
- សមីការបន្ទាត់ $(L)$ ៖ $y-2=-2(x-1) \iff \boxed{y=-2x+4}$ ។

ឃ. សង់បន្ទាត់ $(L)$ និងក្រាប $(C)$ ៖




ង. ពិភាក្សាឫស និងគណនាផ្ទៃក្រឡា ៖

- ពិភាក្សាសមីការ $f(x)=k$ ៖
  - $k<2-\dfrac{2}{e}$ ៖ គ្មានឫស ។
  - $k=2-\dfrac{2}{e}$ ៖ ឫសឌុប $x=e$ ។
  - $2-\dfrac{2}{e}<k<2$ ៖ ឫសពីរផ្សេងគ្នា ។
  - $k\geq 2$ ៖ ឫសតែមួយគត់ ។
- ផ្ទៃក្រឡាលើ $[1,e]$ ៖

$$S=\int_1^e 2\left(1-\frac{\ln x}{x}\right)dx=\left[2x-(\ln x)^2\right]_1^e=(2e-1)-(2-0)=\mathbf{2e-3}$$

ជំនួស $e\approx 2.718$ ៖ $\boxed{S=2e-3\approx 2.44 \text{ ឯកតាក្រឡាផ្ទៃ}}$ ។

## លំហាត់ទី ២២

គេឱ្យអនុគមន៍ $f$ កំណត់ចំពោះ $x>0$ ដោយ $f(x)=1+2\left(\frac{\ln x}{x}\right)$ ហើយមានក្រាប $(C)$ ។

ក. គណនា $\lim\limits_{x\to 0^+} f(x)$ និង $\lim\limits_{x\to +\infty} f(x)$ រួចទាញរកសមីការអាស៊ីមតូតឈរ និងដេកនៃ $(C)$ ។

ខ. គណនា $f'(x)$ សិក្សាសញ្ញា $f'(x)$ និងសង់តារាងអថេរភាពនៃ $f$ ។

គ. រកចំណុចប្រសព្វ $M$ រវាងក្រាប $(C)$ និងអាស៊ីមតូតដេក ។ សរសេរសមីការបន្ទាត់ $(L)$ ដែលប៉ះក្រាប $(C)$ ត្រង់ $M$ ។

ឃ. សង់ក្រាប $(C)$ និងបន្ទាត់ $(L)$ ក្នុងតម្រុយតែមួយ ។

ង. កំណត់តម្លៃ $k$ ដើម្បីឱ្យសមីការ $1+2\left(\frac{\ln x}{x}\right)=k$ មានឫសពីរផ្សេងគ្នា ។

## ដំណោះស្រាយ

### ក. លីមីត និងអាស៊ីមតូត ៖

- $\lim\limits_{x\to 0^+}\left(1+\frac{2\ln x}{x}\right)=-\infty \implies \boxed{x=0 \text{ ជាអាស៊ីមតូតឈរ}}$ ។
- $\lim\limits_{x\to +\infty}\left(1+\frac{2\ln x}{x}\right)=1 \implies \boxed{y=1 \text{ ជាអាស៊ីមតូតដេក}}$ ។

### ខ. ដេរីវេ និងតារាងអថេរភាព ៖

- $f'(x)=\dfrac{2(1-\ln x)}{x^2}$ ។ $f'(x)=0 \iff x=e$ ។
- អតិបរមាធៀប ៖ $f(e)=1+\dfrac{2}{e}\approx 1.74$ ។

| $x$ | $0$ | | $e$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | ‖ | $+$ | $0$ | $-$ | |
| $f(x)$ | $-\infty$ ‖ $-\infty$ | ↗ | $1+\frac{2}{e}$ | ↘ | $1$ |

### គ. ចំណុច $M$ និងបន្ទាត់ប៉ះ ៖ $f(x)=1 \iff \ln x=0 \iff x=1 \implies M(1,1)$ ។

$f'(1)=2 \implies (L): y-1=2(x-1) \iff \boxed{y=2x-1}$ ។

### ឃ. សង់ក្រាប $(C)$ និងបន្ទាត់ $(L)$ ៖




មេរៀនទី ៤ ផ្នែកដំណោះស្រាយ

**ង. កំណត់តម្លៃ $k$ ដើម្បីឱ្យមានឫសពីរផ្សេងគ្នា ៖**

ផ្អែកតាមតារាងអថេរភាព និងក្រាប $(C)$ បន្ទាត់ដេក $y=k$ កាត់ក្រាប $(C)$ ត្រង់ពីរចំណុចផ្សេងគ្នា លុះត្រាតែ ៖

$$\boxed{1<k<1+\frac{2}{e}}$$

## លំហាត់ទី ២៣

គេឱ្យអនុគមន៍ $f$ កំណត់ចំពោះ $x>0$ ដោយ $f(x)=2\left(1-\dfrac{\ln x}{x}\right)$ ហើយមានក្រាប $(C)$ ។

ក. គណនា $\lim\limits_{x\to0^+} f(x)$ និង $\lim\limits_{x\to+\infty} f(x)$ ។ កំណត់សមីការអាស៊ីមតូតឈរ និងដេកនៃក្រាប $(C)$ ។

ខ. គណនា $f'(x)$ និងសិក្សាសញ្ញា $f'(x)$ ។ កំណត់តម្លៃបរមានៃ $f$ រួចសង់តារាងអថេរភាពនៃ $f$ ។

គ. កំណត់កូអរដោនេនៃចំណុច $M$ រវាងក្រាប $(C)$ និងអាស៊ីមតូតដេករបស់វា ។ កំណត់សមីការបន្ទាត់ $(L)$ ដែលប៉ះក្រាប $(C)$ ត្រង់ $M$ ។

ឃ. សង់បន្ទាត់ $(L)$ និងក្រាប $(C)$ ក្នុងតម្រុយតែមួយ (យក $e\approx 2.7, \dfrac{2}{e}\approx 0.7$) ។

ង. កំណត់តម្លៃ $k$ ដើម្បីឱ្យសមីការ $2\left(1-\dfrac{\ln x}{x}\right)=k$ មានឫស ។ គណនាផ្ទៃក្រឡាផ្ទៃកប្លង់កំណត់ដោយក្រាប $(C)$ អ័ក្ស $(Ox)$ បន្ទាត់ $x=1$ និង $x=e$ ។

## ដំណោះស្រាយ

**ក. គណនាលីមីត និងកំណត់សមីការអាស៊ីមតូត ៖**

- ដែនកំណត់នៃអនុគមន៍គឺ $D=(0,+\infty)$ ។
- $\lim\limits_{x\to0^+} f(x)=\lim\limits_{x\to0^+} 2\left(1-\frac{\ln x}{x}\right)=2(1-(-\infty))=+\infty \implies \boxed{x=0 \text{ (អ័ក្ស } Oy) \text{ ជាអាស៊ីមតូតឈរ}}$ ។
- $\lim\limits_{x\to+\infty} f(x)=\lim\limits_{x\to+\infty} 2\left(1-\frac{\ln x}{x}\right)=2(1-0)=\mathbf{2} \implies \boxed{y=2 \text{ ជាអាស៊ីមតូតដេកខាង } +\infty}$ ។

**ខ. គណនាដេរីវេ និងសង់តារាងអថេរភាព ៖**

- $f'(x)=-2\cdot\dfrac{1-\ln x}{x^2}=\dfrac{2(\ln x-1)}{x^2}$ ។
- ដោយសារ $x^2>0$ ចំពោះគ្រប់ $x>0$ ៖ $f'(x)=0 \iff \ln x=1 \iff x=e$ ។
- $f'(x)<0$ លើ $(0,e)$ និង $f'(x)>0$ លើ $(e,+\infty)$ ។
- អប្បបរមាធៀបត្រង់ $x=e$ គឺ $f(e)=2\left(1-\dfrac{1}{e}\right)=\mathbf{2-\dfrac{2}{e}}\approx \mathbf{1.26}$ ។

| $x$ | $0$ | | $e$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | ‖ | $-$ | $0$ | $+$ | |
| $f(x)$ | $+\infty$ ‖ $+\infty$ | ↘ | $2-\dfrac{2}{e}$ | ↗ | $2$ |

**គ. ចំណុច $M$ និងសមីការបន្ទាត់ប៉ះ $(L)$ ៖**

- ប្រសព្វនឹង $y=2$ ៖ $2\left(1-\dfrac{\ln x}{x}\right)=2 \iff \ln x=0 \iff x=1 \implies \boxed{M(1,2)}$ ។
- $f'(1)=\dfrac{2(\ln 1-1)}{1^2}=-2$ ។
- សមីការបន្ទាត់ $(L)$ ៖ $y-2=-2(x-1) \iff \boxed{y=-2x+4}$ ។

**ឃ. សង់បន្ទាត់ $(L)$ និងក្រាប $(C)$ ក្នុងតម្រុយតែមួយ ៖**




**ង. កំណត់តម្លៃ $k$ និងគណនាផ្ទៃក្រឡា ៖**

- ផ្អែកតាមតារាងអថេរភាព $f(x)\geq 2-\dfrac{2}{e}$ ជានិច្ច នាំឱ្យសមីការ $2\left(1-\dfrac{\ln x}{x}\right)=k$ មានឫស $\iff \boxed{k\geq 2-\dfrac{2}{e}\approx 1.26}$ ។
- គណនាផ្ទៃក្រឡាលើ $[1,e]$ ៖

$$S=\int_1^e 2\left(1-\frac{\ln x}{x}\right)dx=\left[2x-(\ln x)^2\right]_1^e=(2e-1)-(2-0)=\mathbf{2e-3}$$

ជំនួស $e\approx 2.718$ ៖ $\boxed{S=2e-3\approx 2.44 \text{ ឯកតាក្រឡាផ្ទៃ}}$ ។

## លំហាត់ទី ២៤

គេឱ្យអនុគមន៍ $f$ កំណត់ចំពោះ $x > 0$ ដោយ $y = f(x) = 1 - \frac{\ln x}{x^3}$ ហើយមានខ្សែកោង $(C)$ ។

ក. គណនា $\lim_{x\to+\infty} f(x)$ និង $\lim_{x\to 0^+} f(x)$ ។ កំណត់សមីការអាស៊ីមតូតឈរ និងដេកនៃក្រាប $(C)$ ។

ខ. បង្ហាញថា $f$ មានតម្លៃអប្បបរមាត្រង់ $x = \sqrt[3]{e}$ ។ គណនា $f(\sqrt[3]{e})$ រួចសង់តារាងអថេរភាពនៃអនុគមន៍ $f$ ។

គ. កំណត់កូអរដោនេចំណុចប្រសព្វ $M$ រវាងខ្សែកោង $(C)$ និងអាស៊ីមតូតដេក ។ សរសេរសមីការបន្ទាត់ $(T)$ ដែលប៉ះក្រាប $(C)$ ត្រង់ចំណុច $M$ ។

ឃ. សង់បន្ទាត់ $(T)$ និងខ្សែកោង $(C)$ ក្នុងតម្រុយតែមួយ (យក $e \approx 2.7, \sqrt[3]{e} \approx 1.4, \frac{1}{3e} \approx 0.12$) ។ កំណត់តម្លៃ $k$ ដើម្បីឱ្យវិសមីការ $1 - \frac{\ln x}{x^3} > k$ ផ្ទៀងផ្ទាត់ចំពោះគ្រប់ $x > 0$ ដោយប្រើខ្សែកោង $(C)$ ។

## ដំណោះស្រាយ

### ក. គណនាលីមីត និងកំណត់សមីការអាស៊ីមតូត ៖

- ដែនកំណត់ ៖ $D = (0, +\infty)$ ។
- លីមីតត្រង់ $0^+$ ៖

$$\lim_{x\to 0^+} f(x) = \lim_{x\to 0^+}\left(1 - \frac{\ln x}{x^3}\right) = 1 - \lim_{x\to 0^+}\left(\frac{1}{x^3}\cdot \ln x\right) = 1 - (+\infty)(-\infty) = +\infty$$

ដូច្នេះ $\boxed{x = 0 \text{ (អ័ក្ស } Oy) \text{ ជាអាស៊ីមតូតឈរ}}$ ។

- លីមីតត្រង់ $+\infty$ ៖ តាមរូបមន្តលីមីតគ្រឹះ $\lim_{x\to+\infty} \frac{\ln x}{x^\alpha} = 0$ (ចំពោះ $\alpha = 3 > 0$) ៖

$$\lim_{x\to+\infty} f(x) = \lim_{x\to+\infty}\left(1 - \frac{\ln x}{x^3}\right) = 1 - 0 = \mathbf{1} \implies \boxed{y = 1 \text{ ជាអាស៊ីមតូតដេកខាង } +\infty}$$

### ខ. ដេរីវេ និងតារាងអថេរភាព ៖

- អនុវត្តរូបមន្តដេរីវេផលចែក ៖

$$f'(x) = 0 - \frac{(\ln x)'\cdot x^3 - (\ln x)(x^3)'}{(x^3)^2} = -\frac{\frac{1}{x}\cdot x^3 - 3x^2\ln x}{x^6} = -\frac{x^2(1 - 3\ln x)}{x^6} = \frac{3\ln x - 1}{x^4}$$

- ដោយសារ $x^4 > 0$ ចំពោះគ្រប់ $x > 0$ នោះសញ្ញា $f'(x)$ ដូចសញ្ញា $3\ln x - 1$ ៖

$$f'(x) = 0 \iff 3\ln x - 1 = 0 \iff \ln x = \frac{1}{3} \iff x = e^{1/3} = \sqrt[3]{e}$$

  - បើ $0 < x < \sqrt[3]{e}$ ៖ $3\ln x - 1 < 0 \implies f'(x) < 0$ (អនុគមន៍ចុះ) ។
  - បើ $x > \sqrt[3]{e}$ ៖ $3\ln x - 1 > 0 \implies f'(x) > 0$ (អនុគមន៍កើន) ។

- ដូច្នេះ $f$ មានតម្លៃអប្បបរមាដាច់ខាតត្រង់ $x=\sqrt[3]{e}$ គឺ ៖

$$f(\sqrt[3]{e}) = 1-\frac{\ln(e^{1/3})}{(e^{1/3})^3} = 1-\frac{\frac{1}{3}}{e} = \mathbf{1}-\frac{\mathbf{1}}{\mathbf{3e}} \approx 1-0.12 = \mathbf{0.88}$$

| $x$ | $0$ | | $\sqrt[3]{e}$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | ‖ | $-$ | $0$ | $+$ | |
| $f(x)$ | $+\infty$ ‖ $+\infty$ | ↘ | $1-\dfrac{1}{3e}$ | ↗ | $1$ |

## ⓖ. ចំណុចប្រសព្វ $M$ និងបន្ទាត់ប៉ះ $(T)$ ៖

- រក $M$ ៖ $f(x)=1 \iff 1-\dfrac{\ln x}{x^3}=1 \iff \ln x = 0 \iff x=1 \implies \boxed{M(1,1)}$ ។
- មេគុណប្រាប់ទិស ៖ $f'(1)=\dfrac{3\ln 1-1}{1^4}=\dfrac{0-1}{1}=-1$ ។
- សមីការបន្ទាត់ប៉ះ $(T)$ ត្រង់ $M(1,1)$ ៖

$$y-1=-1(x-1) \iff \boxed{y=-x+2}$$

## ⓨ. សង់បន្ទាត់ $(T)$ ក្រាប $(C)$ និងដោះស្រាយវិសមីការ ៖




- កំណត់ $k$ ដើម្បីឱ្យ $1-\dfrac{\ln x}{x^3}>k$ ចំពោះគ្រប់ $x>0$ ៖

វិសមីការ $f(x)>k$ ចំពោះគ្រប់ $x>0$ មានន័យថាក្រាប $(C)$ ទាំងមូលស្ថិតនៅខាងលើបន្ទាត់ដេក $y=k$ ។ ដោយសារតម្លៃអប្បបរមាដាច់ខាតនៃអនុគមន៍ $f$ គឺ $f_{\min}=1-\dfrac{1}{3e}$ នោះវិសមីការផ្ទៀងផ្ទាត់ចំពោះគ្រប់ $x>0$ លុះត្រាតែ ៖

$$k<f_{\min} \iff \boxed{k<1-\frac{1}{3e}}$$

## លំហាត់ទី ២៥

គេឱ្យអនុគមន៍ $f$ កំណត់ដោយ $f(x)=x-1-2\ln\left(1-\dfrac{1}{x}\right)$ និងមានក្រាប $(C)$ ។

ក. សិក្សាទិសដៅអថេរភាពនៃ $f$ លើចន្លោះ $(1,+\infty)$ ។

ខ. គណនា $\lim\limits_{x\to1^+} f(x)$ និង $\lim\limits_{x\to+\infty} f(x)$ រួចរកសមីការអាស៊ីមតូតនៃក្រាប $(C)$ ។

គ. គូសតារាងអថេរភាពនៃ $f$ រួចសង់ក្រាប $(C)$ ក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j})$ ។

ឃ. បង្ហាញថាសមីការ $f(x)=3$ មានឫសតែមួយគត់លើចន្លោះ $[2,+\infty)$ ។

ង. គណនាក្រឡាផ្ទៃ $A$ នៃផ្នែកប្លង់ខណ្ឌដោយខ្សែកោង $(C)$ និងបន្ទាត់ $(L): y=x-1$ ចំពោះ $2\le x\le 4$ (គេឱ្យ $\ln 2\approx 0.7, \ln 3\approx 1.1$) ។

## ដំណោះស្រាយ

### ក. សិក្សាទិសដៅអថេរភាពនៃ $f$ ៖

- អនុគមន៍មានន័យកាលណា $1-\dfrac{1}{x}>0 \iff \dfrac{x-1}{x}>0 \iff x\in(-\infty,0)\cup(1,+\infty)$ ។ លើចន្លោះ $(1,+\infty)$ អនុគមន៍ជាប់ និងមានដេរីវេជានិច្ច ។
- សរសេរ $f(x)=x-1-2[\ln(x-1)-\ln x]$ ៖

$$f'(x)=1-2\left(\frac{1}{x-1}-\frac{1}{x}\right)=1-\frac{2}{x(x-1)}=\frac{x(x-1)-2}{x(x-1)}=\frac{x^2-x-2}{x(x-1)}$$

- ដោយ $x^2-x-2=(x-2)(x+1)$ ហើយចំពោះ $x>1$ គេបាន $x(x-1)>0$ និង $x+1>0$ នោះ ៖

$$f'(x)=0 \iff x-2=0 \iff x=2$$

  - បើ $1<x<2$ នោះ $f'(x)<0 \implies f$ ជាអនុគមន៍ចុះដាច់ខាត ។
  - បើ $x>2$ នោះ $f'(x)>0 \implies f$ ជាអនុគមន៍កើនដាច់ខាត ។
- តម្លៃអប្បបរមាធៀបត្រង់ $x=2$ គឺ ៖

$$f(2)=2-1-2\ln\left(1-\frac{1}{2}\right)=1-2\ln\left(\frac{1}{2}\right)=1+2\ln 2\approx 1+2(0.7)=\mathbf{2.4}$$

### ខ. គណនាលីមីត និងរកអាស៊ីមតូត ៖

- កាលណា $x\to1^+$ គេបាន $1-\dfrac{1}{x}\to0^+ \implies \ln\left(1-\dfrac{1}{x}\right)\to-\infty$ ៖

$$\lim_{x\to1^+} f(x)=1-1-2(-\infty)=+\infty \implies \boxed{x=1 \text{ ជាអាស៊ីមតូតឈរ}}$$

- កាលណា $x\to+\infty$ គេបាន $\dfrac{1}{x}\to0 \implies 1-\dfrac{1}{x}\to1 \implies \ln\left(1-\dfrac{1}{x}\right)\to0$ ៖

$$\lim_{x\to+\infty} f(x)=+\infty-1-0=+\infty$$

- ពិនិត្យលីមីតនៃផលដក $f(x)-(x-1)$ ៖

$$\lim_{x\to+\infty}[f(x)-(x-1)]=\lim_{x\to+\infty}\left[-2\ln\left(1-\frac{1}{x}\right)\right]=-2\ln 1=0$$

ដូច្នេះបន្ទាត់ $\boxed{(L):y=x-1 \text{ ជាអាស៊ីមតូតទ្រេតខាង } +\infty}$ ។

**គ. តារាងអថេរភាព និងសង់ក្រាប $(C)$ ៖**

| $x$ | $1$ | | | $2$ | | $+\infty$ |
|---|---|---|---|---|---|---|
| $f'(x)$ | \|\| | | $-$ | $0$ | $+$ | |
| $f(x)$ | $+\infty$ \|\| $+\infty$ | ↘ | | $1+2\ln 2$ | ↗ | $+\infty$ |




**ឃ. បង្ហាញថាសមីការ $f(x)=3$ មានឫសតែមួយគត់លើ $[2,+\infty)$ ៖**

- លើចន្លោះ $[2,+\infty)$ អនុគមន៍ $f$ ជាប់ និងកើនដាច់ខាត ។
- តម្លៃនៅចុងចន្លោះ ៖ $f(2)=1+2\ln 2\approx 2.39<3$ និង $\lim_{x\to+\infty}f(x)=+\infty>3$ ។
- ដោយ $3\in[f(2),+\infty[$ តាមទ្រឹស្តីបទតម្លៃកណ្តាល អនុគមន៍ $f$ បង្កើតបានជាអនុវត្តន៍មួយទល់មួយ ដូច្នេះសមីការ $f(x)=3$ មានឫសតែមួយគត់ $x_0\in[2,+\infty)$ ។

**ង. គណនាក្រឡាផ្ទៃ $A$ ៖**

- ចំពោះគ្រប់ $x\geq 2$ គេបាន $1-\frac{1}{x}<1\implies \ln\left(1-\frac{1}{x}\right)<0\implies -2\ln\left(1-\frac{1}{x}\right)>0$ ដូច្នេះក្រាប $(C)$ ស្ថិតនៅខាងលើបន្ទាត់ $(L)$ ជានិច្ច ៖

$$A=\int_2^4[f(x)-(x-1)]\,dx=-2\int_2^4\ln\left(\frac{x-1}{x}\right)dx=2\int_2^4[\ln x-\ln(x-1)]\,dx$$

- ព្រីមីទីវនៃ $\ln u$ គឺ $u\ln u - u$ ៖

$$\int [\ln x - \ln(x-1)]\,dx = [x\ln x - x] - [(x-1)\ln(x-1) - (x-1)] = x\ln x - (x-1)\ln(x-1) - 1$$

- ជំនួសព្រំដែនពី 2 ដល់ 4 ៖

$$\begin{aligned}[x\ln x - (x-1)\ln(x-1)]_2^4 &= (4\ln 4 - 3\ln 3) - (2\ln 2 - 1\ln 1)\\ &= (8\ln 2 - 3\ln 3) - 2\ln 2 = 6\ln 2 - 3\ln 3\end{aligned}$$

$$A = 2(6\ln 2 - 3\ln 3) = 12\ln 2 - 6\ln 3$$

ជំនួស $\ln 2 \approx 0.7, \ln 3 \approx 1.1$ ៖

$$A = 12(0.7) - 6(1.1) = 8.4 - 6.6 = \mathbf{1.8} \implies \boxed{A = 1.8 \text{ ឯកតាក្រឡាផ្ទៃ}}$$

## លំហាត់ទី ២៦

គេឱ្យអនុគមន៍ $f$ កំណត់ចំពោះ $x \in D = (-\infty, 0) \cup (1, +\infty)$ ដោយ $y = f(x) = -\frac{x}{2} + \ln\left(\frac{x-1}{x}\right)$ ហើយមានខ្សែកោង $(C)$ ។

ក. គណនា $\lim\limits_{x\to-\infty} f(x)$, $\lim\limits_{x\to+\infty} f(x)$, $\lim\limits_{x\to0^-} f(x)$ និង $\lim\limits_{x\to1^+} f(x)$ ។ រកសមីការអាស៊ីមតូតឈរទាំងពីរនៃ $(C)$ ។

ខ. គណនា និងសិក្សាសញ្ញា $f'(x)$ ដោយដឹងថា $x(x-1) > 0$ ចំពោះគ្រប់ $x \in D$ ។ គណនាតម្លៃអប្បបរមា និងអតិបរមានៃ $f$ រួចសង់តារាងអថេរភាព ។

គ. បង្ហាញថាបន្ទាត់ $(L): y = -\frac{x}{2}$ ជាអាស៊ីមតូតទ្រេតនៃ $(C)$ ។

ឃ. សង់អាស៊ីមតូត និងខ្សែកោង $(C)$ (យក $e \approx 2.7, \ln 2 \approx 0.7$) ។ រកតម្លៃ $a$ ដើម្បីឱ្យសមីការ $-\frac{x}{2} + \ln\left(\frac{x-1}{x}\right) = a$ មានឫសអវិជ្ជមានពីរផ្សេងគ្នា ។

## ដំណោះស្រាយ

### ក. គណនាលីមីត និងរកអាស៊ីមតូតឈរ ៖

- $\lim\limits_{x\to-\infty} f(x) = -\frac{-\infty}{2} + \ln 1 = +\infty$ ។
- $\lim\limits_{x\to+\infty} f(x) = -\frac{+\infty}{2} + \ln 1 = -\infty$ ។
- កាលណា $x \to 0^-$ គេបាន $\frac{x-1}{x} \to \frac{-1}{0^-} = +\infty \implies \lim\limits_{x\to0^-} f(x) = 0 + \infty = +\infty$ ៖

$$\boxed{x = 0 \text{ (អ័ក្ស } Oy\text{) ជាអាស៊ីមតូតឈរ}}$$

- កាលណា $x \to 1^+$ គេបាន $\frac{x-1}{x} \to \frac{0^+}{1} = 0^+ \implies \lim\limits_{x\to1^+} f(x) = -\frac{1}{2} + (-\infty) = -\infty$ ៖

$$\boxed{x = 1 \text{ ជាអាស៊ីមតូតឈរ}}$$

**ខ. គណនាដេរីវេ តម្លៃបរមា និងតារាងអថេរភាព ៖**

- ដេរីវេនៃ $f(x)=-\frac{x}{2}+\ln(x-1)-\ln x$ ៖

$$f'(x)=-\frac{1}{2}+\frac{1}{x-1}-\frac{1}{x}=-\frac{1}{2}+\frac{1}{x(x-1)}=\frac{-x(x-1)+2}{2x(x-1)}=\frac{-(x^2-x-2)}{2x(x-1)}$$

$$f'(x)=\frac{-(x-2)(x+1)}{2x(x-1)}$$

- លើដែនកំណត់ $D$ ភាគបែង $2x(x-1)>0$ ជានិច្ច ដូច្នេះសញ្ញានៃ $f'(x)$ ដូចសញ្ញាភាគយក $-(x-2)(x+1)$ ៖

$$f'(x)=0 \iff x=-1 \quad \text{ឬ} \quad x=2$$

  - ចំពោះ $x\in(-\infty,-1)$ ៖ $f'(x)<0$ (ចុះ) ។
  - ចំពោះ $x\in(-1,0)$ ៖ $f'(x)>0$ (កើន) ។
  - ចំពោះ $x\in(1,2)$ ៖ $f'(x)>0$ (កើន) ។
  - ចំពោះ $x\in(2,+\infty)$ ៖ $f'(x)<0$ (ចុះ) ។

- តម្លៃបរមាធៀប ៖
  - អប្បបរមាធៀបត្រង់ $x=-1$ ៖ $f(-1)=\frac{1}{2}+\ln\left(\frac{-2}{-1}\right)=\mathbf{\frac{1}{2}}+\ln\mathbf{2}\approx 0.5+0.7=\mathbf{1.2}$ ។
  - អតិបរមាធៀបត្រង់ $x=2$ ៖ $f(2)=-1+\ln\left(\frac{1}{2}\right)=-\mathbf{1}-\ln\mathbf{2}\approx -1-0.7=-\mathbf{1.7}$ ។

| $x$ | $-\infty$ | | $-1$ | | $0$ ‖ | | $1$ | | $2$ | | $+\infty$ |
|---|---|---|---|---|---|---|---|---|---|---|---|
| $f'(x)$ | | $-$ | $0$ | $+$ | ‖ | $d$ | | $+$ | $0$ | $-$ | |
| $f(x)$ | $+\infty$ ↘ | | $\frac{1}{2}+\ln 2$ | ↗ $+\infty$ | ‖ | $-\infty$ ↗ | | | $-1-\ln 2$ | ↘ | $-\infty$ |

**គ. អាស៊ីមតូតទ្រេត $(L)$ ៖**

$$\lim_{x\to\pm\infty}\left[f(x)-\left(-\frac{x}{2}\right)\right]=\lim_{x\to\pm\infty}\ln\left(\frac{x-1}{x}\right)=\ln 1=0$$

ដូច្នេះបន្ទាត់ $\boxed{(L): y=-\frac{x}{2} \text{ ជាអាស៊ីមតូតទ្រេតខាង } \pm\infty}$ ។

**ឃ. សង់ក្រាប និងពិភាក្សាឫសអវិជ្ជមានពីរផ្សេងគ្នា ៖**




- **ស្វែងរកតម្លៃ $a$ ៖**
ឬសអវិជ្ជមាននៃសមីការជាអាប់ស៊ីសនៃចំណុចប្រសព្វរវាងក្រាប $(C)$ លើចន្លោះ $(-\infty,0)$ ជាមួយបន្ទាត់ដេក $y=a$ ។
លើចន្លោះ $(-\infty,0)$ អនុគមន៍ចុះពី $+\infty$ ដល់តម្លៃអប្បបរមា $\frac{1}{2}+\ln 2$ រួចកើនឡើងទៅ $+\infty$ វិញ ។
ដូច្នេះបន្ទាត់ $y=a$ កាត់ខ្សែងខាងឆ្វេង $(x<0)$ ត្រង់ ២ ចំណុចផ្សេងគ្នា លុះត្រាតែ ៖

$$\boxed{a>\frac{1}{2}+\ln 2\approx 1.2}$$

## លំហាត់ទី ២៧

គេឱ្យអនុគមន៍ $f$ កំណត់ចំពោះគ្រប់ចំនួនពិត $x$ ដោយ $y=f(x)=-x-2+\dfrac{4e^x}{e^x+1}$ ហើយមានខ្សែកោង $(C)$ ក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j})$ ។

ក. គណនា $\lim\limits_{x\to-\infty} f(x)$ និង $\lim\limits_{x\to+\infty} f(x)$ ។ រកសមីការអាស៊ីមតូតទ្រេតនៃ $(C)$ កាលណា $x\to-\infty$ និង $x\to+\infty$ ។

ខ. គណនាដេរីវេ $f'(x)$ ហើយបង្ហាញថា $f'(x)\leq 0$ ចំពោះគ្រប់ចំនួនពិត $x$ ។ គណនា $f'(0), f(0)$ ហើយសង់តារាងអថេរភាពនៃ $f$ ។

គ. បង្ហាញថាគល់កូអរដោនេ $O$ ជាចំណុចរបត់ និងជាផ្ចិតឆ្លុះនៃក្រាប $(C)$ ។

ឃ. គណនា $f(3)$ ហើយសង់ខ្សែកោង $(C)$ (យក $e^3\approx 20$) ។ ដោះស្រាយវិសមីការ $\dfrac{4e^x}{e^x+1}\geq x+2$ ដោយប្រើខ្សែកោង $(C)$ ។

## ដំណោះស្រាយ

ក. គណនាលីមីត និងរកសមីការអាស៊ីមតូតទ្រេត ៖

- កាលណា $x \to -\infty$ គេបាន $e^x \to 0 \implies \dfrac{4e^x}{e^x+1} \to 0$ ៖

$$\lim_{x\to-\infty} f(x) = +\infty - 2 + 0 = +\infty$$

ហើយ $\lim\limits_{x\to-\infty}[f(x)-(-x-2)] = \lim\limits_{x\to-\infty}\dfrac{4e^x}{e^x+1} = 0$ ៖

ដូច្នេះបន្ទាត់ $\boxed{(d_1): y = -x-2 \text{ ជាអាស៊ីមតូតទ្រេតខាង } -\infty}$ ។

- កាលណា $x \to +\infty$ គេបាន $\dfrac{4e^x}{e^x+1} = \dfrac{4}{1+e^{-x}} \to 4$ ៖

$$\lim_{x\to+\infty} f(x) = -\infty - 2 + 4 = -\infty$$

ម្យ៉ាងទៀត $f(x)-(-x+2) = \dfrac{4e^x}{e^x+1} - 4 = \dfrac{-4}{e^x+1} \to 0$ ៖

ដូច្នេះបន្ទាត់ $\boxed{(d_2): y = -x+2 \text{ ជាអាស៊ីមតូតទ្រេតខាង } +\infty}$ ។

**ខ. គណនាដេរីវេ និងសង់តារាងអថេរភាព ៖**

- ដេរីវេ ៖

$$f'(x) = -1 + \frac{4e^x(e^x+1)-4e^x\cdot e^x}{(e^x+1)^2} = -1 + \frac{4e^x}{(e^x+1)^2} = \frac{-(e^x+1)^2+4e^x}{(e^x+1)^2}$$

$$f'(x) = \frac{-(e^{2x}+2e^x+1-4e^x)}{(e^x+1)^2} = \frac{-(e^{2x}-2e^x+1)}{(e^x+1)^2} = -\frac{(e^x-1)^2}{(e^x+1)^2}$$

- ដោយសារ $(e^x-1)^2 \geq 0$ និង $(e^x+1)^2 > 0$ ចំពោះគ្រប់ $x \in \mathbb{R}$ គេទាញបាន ៖

$$f'(x) \leq 0 \quad \text{ចំពោះគ្រប់ } x \in \mathbb{R}$$

- ត្រង់ $x = 0$ ៖ $f'(0) = -\dfrac{(1-1)^2}{(1+1)^2} = \mathbf{0}$ និង $f(0) = -0-2+\dfrac{4(1)}{1+1} = -2+2 = \mathbf{0}$ ។
- ដូចនេះ $f$ ជាអនុគមន៍ចុះដាច់ខាតលើ $\mathbb{R}$ ។

| $x$ | $-\infty$ | | $0$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | | $-$ | $0$ | $-$ | |
| $f(x)$ | $+\infty$ | ↘ | $0$ | ↘ | $-\infty$ |

**គ. ចំណុចរបត់ និងផ្ចិតឆ្លុះ ៖**

- ដេរីវេទីពីរ $f''(x)$ ៖

$$f''(x) = \left(-1+4e^x(e^x+1)^{-2}\right)' = 4e^x(e^x+1)^{-2} - 8e^{2x}(e^x+1)^{-3} = \frac{4e^x(1-e^x)}{(e^x+1)^3}$$

$f''(x) = 0 \iff 1-e^x = 0 \iff x = 0$ ហើយ $f''(x)$ ប្តូរសញ្ញាពីវិជ្ជមាន $(x<0)$ ទៅអវិជ្ជមាន $(x>0)$ ត្រង់ $x = 0$ ដូច្នេះចំណុច $O(0,0)$ ជាចំណុចរបត់ ។

- ផ្ទៀងផ្ទាត់ $f(-x)+f(x)$ ៖

$$f(-x)=x-2+\frac{4e^{-x}}{e^{-x}+1}=x-2+\frac{4}{1+e^{x}}$$

$$f(-x)+f(x)=(x-2)+(-x-2)+\frac{4+4e^{x}}{1+e^{x}}=-4+4=0=2\cdot 0$$

ដូច្នេះ $O(0,0)$ ជាផ្ចិតឆ្លុះនៃខ្សែកោង $(C)$ ។

**ឃ. គណនា $f(3)$ សង់ក្រាប និងដោះស្រាយវិសមីការ ៖**

- $f(3)=-3-2+\dfrac{4e^{3}}{e^{3}+1}\approx -5+\dfrac{4(20)}{20+1}=-5+\dfrac{80}{21}=-\dfrac{25}{21}\approx -\mathbf{1.19}$ ។




- **ដោះស្រាយវិសមីការ** $\dfrac{4e^{x}}{e^{x}+1}\geq x+2$ ៖

វិសមីការសមមូលនឹង ៖

$$-x-2+\frac{4e^{x}}{e^{x}+1}\geq 0 \iff f(x)\geq 0$$

តាមក្រាប $(C)$ និងតារាងអថេរភាព $f(x)\geq 0$ កាលណាខ្សែកោងស្ថិតនៅខាងលើ ឬកាត់អ័ក្សអាប់ស៊ីស ដែលត្រូវនឹង $x\leq 0$ ។

ដូច្នេះសំណុំចម្លើយនៃវិសមីការគឺ $\boxed{S=(-\infty,0]}$ ។

## លំហាត់ទី ២៨

គេឱ្យអនុគមន៍ $f$ កំណត់ចំពោះ $x>0$ ដោយ $f(x)=-x-\dfrac{4\ln x}{x}$ ហើយមានខ្សែកោង $(C)$ ក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j})$ ។

ក. គណនា $\lim\limits_{x\to 0^{+}} f(x)$ និង $\lim\limits_{x\to +\infty} f(x)$ ។ រកសមីការអាស៊ីមតូតឈរនៃ $(C)$ ។

ខ. បង្ហាញថា $(L): y = -x$ ជាអាស៊ីមតូតទ្រេតនៃក្រាប $(C)$ ។ សិក្សាទីតាំងធៀបរវាង $(C)$ និង $(L)$ ។

គ. បង្ហាញថាដេរីវេ $f'(x) < 0$ បើដឹងថា $x^2 + 4 - 4\ln x > 0$ ចំពោះ $x > 0$ ។ សង់តារាងអថេរភាពនៃ $f$ ។ បន្ទាត់ $(D)$ ប៉ះក្រាប $(C)$ ត្រង់ចំណុច $A$ ហើយស្របនឹងបន្ទាត់ $(L)$ ។ រកកូអរដោនេនៃ $A$ និងសមីការបន្ទាត់ $(D)$ ។

ឃ. សង់ $(L), (D)$ និង $(C)$ ក្នុងតម្រុយតែមួយ (យក $e \approx 2.7, \frac{4}{e} \approx 1.5$) ។ គេតាង $S(a)$ ជាក្រឡាផ្ទៃកំណត់ដោយក្រាប $(C)$ និងអាស៊ីមតូត $(L)$ ចំពោះ $1 \le x \le a$ ។ រកតម្លៃ $a$ ដើម្បីឱ្យ $S(a) = 2$ ឯកតាក្រឡាផ្ទៃ ។

## ដំណោះស្រាយ

### ក. គណនាលីមីត និងរកអាស៊ីមតូតឈរ ៖

- $\lim_{x\to 0^+} f(x) = \lim_{x\to 0^+} \left(-x - 4\cdot\frac{\ln x}{x}\right) = 0 - 4(-\infty) = +\infty$ ៖

$x = 0$ (អ័ក្ស $Oy$) ជាអាស៊ីមតូតឈរ

- $\lim_{x\to +\infty} f(x) = \lim_{x\to +\infty} \left(-x - \frac{4\ln x}{x}\right) = -\infty - 0 = -\infty$ ។

### ខ. អាស៊ីមតូតទ្រេត $(L)$ និងទីតាំងធៀប ៖

- $\lim_{x\to +\infty} [f(x) - (-x)] = \lim_{x\to +\infty} \left(-\frac{4\ln x}{x}\right) = 0 \implies$ $(L): y = -x$ ជាអាស៊ីមតូតទ្រេតខាង $+\infty$ ។
- ពិនិត្យសញ្ញានៃ $f(x) - (-x) = -\dfrac{4\ln x}{x}$ លើ $(0, +\infty)$ ៖
  - បើ $0 < x < 1$ ៖ $\ln x < 0 \implies f(x) - (-x) > 0 \implies (C)$ ស្ថិតនៅ**ខាងលើ** $(L)$ ។
  - បើ $x = 1$ ៖ $f(1) - (-1) = 0 \implies (C)$ **កាត់** $(L)$ ត្រង់ចំណុច $(1, -1)$ ។
  - បើ $x > 1$ ៖ $\ln x > 0 \implies f(x) - (-x) < 0 \implies (C)$ ស្ថិតនៅ**ខាងក្រោម** $(L)$ ។

### គ. ដេរីវេ តារាងអថេរភាព និងបន្ទាត់ប៉ះ $(D)$ ៖

- ដេរីវេ ៖

$$f'(x) = -1 - 4\cdot\frac{\frac{1}{x}\cdot x - \ln x}{x^2} = -1 - \frac{4(1-\ln x)}{x^2} = \frac{-x^2 - 4 + 4\ln x}{x^2} = -\frac{x^2 + 4 - 4\ln x}{x^2}$$

- ដោយ $x^2 + 4 - 4\ln x > 0$ និង $x^2 > 0$ ចំពោះគ្រប់ $x > 0$ គេបាន ៖

$f'(x) < 0$ ចំពោះគ្រប់ $x > 0 \implies f$ ជាអនុគមន៍ចុះដាច់ខាតលើ $(0, +\infty)$

| $x$ | $0$ | $+\infty$ |
|---|---|---|
| $f'(x)$ | ‖ | $-$ |
| $f(x)$ | $+\infty$ ‖ $+\infty$ | ↘ $-\infty$ |

មេរៀនទី ៤ ផ្នែកដំណោះស្រាយ

- បន្ទាត់ $(D)$ ស្របនឹង $(L): y=-x$ មានន័យថាមេគុណប្រាប់ទិសស្មើ $-1$ ៖

$$f'(x_A)=-1 \iff -\frac{x_A^2+4-4\ln x_A}{x_A^2}=-1 \iff 4-4\ln x_A=0 \iff \ln x_A=1 \iff x_A=e$$

- អរដោនេ ៖ $y_A=f(e)=-e-\frac{4\ln e}{e}=-e-\frac{4}{e}\approx -2.7-1.5=\mathbf{-4.2}$ ៖

$$\boxed{A\left(e,-e-\frac{4}{e}\right)}$$

- សមីការបន្ទាត់ $(D)$ ៖

$$y-y_A=-1(x-x_A) \iff y-\left(-e-\frac{4}{e}\right)=-(x-e) \iff \boxed{y=-x-\frac{4}{e}}$$

**ឃ.** សង់ក្រាប និងគណនាតម្លៃ $a$ ៖




- គណនាតម្លៃ $a$ ៖
ចំពោះ $x\in[1,a]$ (ដោយ $a>1$) ក្រាប $(C)$ ស្ថិតនៅខាងក្រោម $(L)$ ៖

$$S(a)=\int_1^a[-x-f(x)]\,dx=\int_1^a\frac{4\ln x}{x}\,dx=\left[2(\ln x)^2\right]_1^a=2(\ln a)^2-0=2(\ln a)^2$$

$$S(a)=2 \iff 2(\ln a)^2=2 \iff (\ln a)^2=1 \iff \ln a=1 \quad (\text{ព្រោះ } a>1) \iff \boxed{a=e}$$

## លំហាត់ទី ២៩

គេឱ្យអនុគមន៍ $f$ កំណត់ដោយ $f(x)=\dfrac{\ln x}{x^2}$ ហើយមានក្រាប $(C)$ ។

ក. គណនា $\lim\limits_{x\to+\infty} f(x)$ និង $\lim\limits_{x\to 0^+} f(x)$ ។ ទាញរកសមីការអាស៊ីមតូតឈរ និងដេកនៃក្រាប $(C)$ ។

ខ. បង្ហាញថា $f$ មានតម្លៃអតិបរមាត្រង់ $x=\sqrt{e}$ ។ សង់តារាងអថេរភាពនៃអនុគមន៍ $f$ ។

គ. រកសមីការបន្ទាត់ $(d)$ ដែលប៉ះក្រាប $(C)$ ត្រង់ចំណុច $M(1,0)$ ។ សង់ $(d)$ និង $(C)$ ក្នុងតម្រុយតែមួយ (យក $\sqrt{e}\approx 1.6, \dfrac{1}{2e}\approx 0.2$) ។

## ដំណោះស្រាយ

### ក. គណនាលីមីត និងរកអាស៊ីមតូត ៖

- ដែនកំណត់ ៖ $D=(0,+\infty)$ ។
- $\lim\limits_{x\to 0^+} f(x)=\lim\limits_{x\to 0^+}\left(\frac{1}{x^2}\cdot\ln x\right)=(+\infty)(-\infty)=-\infty \implies$ $\boxed{x=0 \text{ ជាអាស៊ីមតូតឈរ}}$ ។
- $\lim\limits_{x\to+\infty} f(x)=\lim\limits_{x\to+\infty}\frac{\ln x}{x^2}=0 \implies$ $\boxed{y=0\ (\text{អ័ក្ស } Ox) \text{ ជាអាស៊ីមតូតដេក}}$ ។

### ខ. ដេរីវេ និងតារាងអថេរភាព ៖

- $f'(x)=\dfrac{(\ln x)'\cdot x^2-(\ln x)(x^2)'}{(x^2)^2}=\dfrac{\frac{1}{x}\cdot x^2-2x\ln x}{x^4}=\dfrac{x(1-2\ln x)}{x^4}=\dfrac{1-2\ln x}{x^3}$ ។
- ដោយ $x^3>0$ ចំពោះគ្រប់ $x>0$ ៖

$$f'(x)=0 \iff 1-2\ln x=0 \iff \ln x=\frac{1}{2} \iff x=e^{1/2}=\sqrt{e}$$

  – បើ $0<x<\sqrt{e}$ ៖ $1-2\ln x>0 \implies f'(x)>0$ (កើន) ។
  – បើ $x>\sqrt{e}$ ៖ $1-2\ln x<0 \implies f'(x)<0$ (ចុះ) ។

- ដូច្នេះ $f$ មានតម្លៃអតិបរមាដាច់ខាតត្រង់ $x=\sqrt{e}$ គឺ ៖

$$f(\sqrt{e})=\frac{\ln(e^{1/2})}{(\sqrt{e})^2}=\frac{\frac{1}{2}}{e}=\frac{\mathbf{1}}{\mathbf{2e}}\approx\mathbf{0.184}$$

| $x$ | $0$ | | $\sqrt{e}$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | ‖ | $+$ | $0$ | $-$ | |
| $f(x)$ | $-\infty$ ‖ $-\infty$ | ↗ | $\frac{1}{2e}$ | ↘ | $0$ |

### គ. សមីការបន្ទាត់ប៉ះ $(d)$ និងសង់ក្រាប ៖

មេរៀនទី ៤ ផ្នែកដំណោះស្រាយ

- មេគុណប្រាប់ទិស ៖ $f'(1)=\dfrac{1-2\ln 1}{1^3}=\dfrac{1-0}{1}=1$ ។
- សមីការបន្ទាត់ប៉ះ $(d)$ ត្រង់ $M(1,0)$ ៖

$$y-0=1(x-1) \iff \boxed{y=x-1}$$




## លំហាត់ទី ៣០

គេឱ្យអនុគមន៍ $f$ កំណត់ចំពោះ $x>0$ ដោយ $y=f(x)=1-\dfrac{2\ln x}{x}$ ហើយមានក្រាប $(C)$ ។

ក. រក $\lim\limits_{x\to+\infty} f(x)$ និង $\lim\limits_{x\to 0^+} f(x)$ ។ រកសមីការអាស៊ីមតូតឈរ និងដេកនៃក្រាប $(C)$ ។

ខ. គណនាដេរីវេ $f'(x)$ ហើយសង់តារាងអថេរភាពនៃអនុគមន៍ $f$ ។

គ. សង់ក្រាប $(C)$ ក្នុងតម្រុយតែមួយ (យក $e\approx 2.7, \dfrac{2}{e}\approx 0.7$) ។

ឃ. គណនាក្រឡាផ្ទៃផ្នែកប្លង់កំណត់ដោយក្រាប $(C)$ អាស៊ីមតូតដេក និងបន្ទាត់ឈរ $x=1, x=e$ ។

## ដំណោះស្រាយ

### ក. លីមីត និងអាស៊ីមតូត ៖

- $\lim\limits_{x\to 0^+} f(x)=+\infty \implies$ $\boxed{x=0 \text{ ជាអាស៊ីមតូតឈរ}}$ ។
- $\lim\limits_{x\to+\infty} f(x)=1 \implies$ $\boxed{y=1 \text{ ជាអាស៊ីមតូតដេក}}$ ។

### ខ. ដេរីវេ និងតារាងអថេរភាព ៖ $f'(x)=\dfrac{2(\ln x-1)}{x^2}$ ។ $f'(x)=0 \iff x=e$ ។ អប្បបរមា $f(e)=1-\dfrac{2}{e}\approx 0.26$ ។

| $x$ | $0$ | | $e$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | ‖ | $-$ | $0$ | $+$ | |
| $f(x)$ | $+\infty$ ‖ $+\infty$ | ↘ | $1-\dfrac{2}{e}$ | ↗ | $1$ |

គ. សង់ក្រាប $(C)$ ក្នុងតម្រុយតែមួយ ៖




ឃ. គណនាក្រឡាផ្ទៃផ្នែកប្លង់ ៖
ចំពោះ $x \in [1, e]$ ក្រាប $(C)$ ស្ថិតនៅខាងក្រោមអាស៊ីមតូតដេក $y = 1$ ៖

$$S = \int_1^e [1 - f(x)]\,dx = \int_1^e \frac{2\ln x}{x}\,dx = \left[(\ln x)^2\right]_1^e = (\ln e)^2 - (\ln 1)^2 = 1 - 0 = \mathbf{1}$$

ដូច្នេះ $\boxed{S = 1 \text{ ឯកតាក្រឡាផ្ទៃ}}$ ។

**លំហាត់ទី ៣១**

គេឱ្យអនុគមន៍ $f$ កំណត់ចំពោះ $x > 0$ ដោយ $f(x) = 2 + \dfrac{\ln x}{x^2}$ ហើយមានក្រាប $(C)$ ។

ក. រក $\lim\limits_{x\to+\infty} f(x)$ និង $\lim\limits_{x\to 0^+} f(x)$ ។ រកសមីការអាស៊ីមតូតឈរ និងអាស៊ីមតូតដេកនៃក្រាប $(C)$ ។

ខ. គណនាដេរីវេ $f'(x)$ ហើយសង់តារាងអថេរភាពនៃអនុគមន៍ $f$ ។

គ. រកកូអរដោនេចំណុចប្រសព្វ $I$ រវាងក្រាប $(C)$ និងអាស៊ីមតូតដេក ។ សង់ក្រាប $(C)$ ក្នុងតម្រុយតែមួយ (យក $e \approx 2.7, e^{0.5} \approx 1.65$) ។

ឃ. គណនាផ្ទៃក្រឡាផ្នែកប្លង់កំណត់ដោយក្រាប $(C)$ អាស៊ីមតូតដេក និងបន្ទាត់ឈរ $x = 1, x = e^{0.5}$ ។

## ដំណោះស្រាយ

ក. គណនាលីមីត និងរកសមីការអាស៊ីមតូត ៖

- ដែនកំណត់ ៖ $D = (0, +\infty)$ ។
- $\lim\limits_{x\to 0^+} f(x) = 2 + \lim\limits_{x\to 0^+} \left(\frac{1}{x^2} \cdot \ln x\right) = 2 + (+\infty)(-\infty) = -\infty \implies \boxed{x = 0 \text{ ជាអាស៊ីមតូតឈរ}}$ ។
- $\lim\limits_{x\to+\infty} f(x) = 2 + \lim\limits_{x\to+\infty} \frac{\ln x}{x^2} = 2 + 0 = \mathbf{2} \implies \boxed{y = 2 \text{ ជាអាស៊ីមតូតដេក}}$ ។

ខ. ដេរីវេ និងតារាងអថេរភាព ៖

- $f'(x)=0+\dfrac{\frac{1}{x}\cdot x^2-(\ln x)(2x)}{x^4}=\dfrac{x(1-2\ln x)}{x^4}=\dfrac{1-2\ln x}{x^3}$ ។
- ដោយ $x^3>0$ ចំពោះគ្រប់ $x>0$ ៖

$$f'(x)=0 \iff 1-2\ln x=0 \iff \ln x=\frac{1}{2} \iff x=e^{0.5}=\sqrt{e}\approx 1.65$$

  - បើ $0<x<e^{0.5}$ ៖ $f'(x)>0$ (អនុគមន៍កើន) ។
  - បើ $x>e^{0.5}$ ៖ $f'(x)<0$ (អនុគមន៍ចុះ) ។
- អតិបរមាធៀប ៖ $f(e^{0.5})=2+\dfrac{0.5}{e}=\mathbf{2+\frac{1}{2e}}\approx 2+0.18=\mathbf{2.18}$ ។

| $x$ | $0$ | | $e^{0.5}$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | ‖ | $+$ | $0$ | $-$ | |
| $f(x)$ | $-\infty$ ‖ $-\infty$ | ↗ | $2+\dfrac{1}{2e}$ | ↘ | $2$ |

គ. ចំណុចប្រសព្វ $I$ និងសង់ក្រាប $(C)$ ៖

- $f(x)=2 \iff 2+\dfrac{\ln x}{x^2}=2 \iff \ln x=0 \iff x=1 \implies \boxed{I(1,2)}$ ។




ឃ. គណនាផ្ទៃក្រឡាផ្នែកប្លង់ ៖

ចំពោះ $x\in[1,e^{0.5}]$ ក្រាប $(C)$ ស្ថិតនៅខាងលើបន្ទាត់ $y=2$ ៖

$$S=\int_1^{e^{0.5}}[f(x)-2]\,dx=\int_1^{e^{0.5}}\frac{\ln x}{x^2}\,dx$$

អនុវត្តអាំងតេក្រាលដោយផ្នែក ៖ តាង $u=\ln x \implies du=\dfrac{dx}{x}$ និង $dv=\dfrac{dx}{x^2}\implies v=-\dfrac{1}{x}$ ៖

$$\int\frac{\ln x}{x^2}\,dx=-\frac{\ln x}{x}-\int\left(-\frac{1}{x^2}\right)dx=-\frac{\ln x+1}{x}$$

$$S=\left[-\frac{\ln x+1}{x}\right]_1^{e^{0.5}}=-\frac{0.5+1}{e^{0.5}}-\left(-\frac{0+1}{1}\right)=1-\frac{1.5}{e^{0.5}}\approx 1-\frac{1.5}{1.65}=1-\frac{10}{11}=\frac{1}{11}\approx \mathbf{0.091}$$

ដូច្នេះ $\boxed{S=1-\frac{1.5}{\sqrt{e}}\approx 0.09 \text{ ឯកតាក្រឡាផ្ទៃ}}$ ។

## លំហាត់ទី ៣២

គេមានអនុគមន៍ $f$ កំណត់លើ $I=(0,+\infty)$ ដោយ $f(x)=\dfrac{x+\ln x}{x^2}$ ។

**A**. គេឱ្យអនុគមន៍ $h$ កំណត់លើ $I$ ដោយ $h(x)=-x+1-2\ln x$ ។ គណនា $h(1)$ និងសិក្សាអថេរភាពនៃ $h(x)$ (មិនតម្រូវឱ្យគណនាលីមីតចុងដែន ) ។

**B**. ក. គណនាលីមីតនៃ $f(x)$ ត្រង់ $0^+$ និងត្រង់ $+\infty$ ។

ខ. គណនាដេរីវេ $f'(x)$ នៃអនុគមន៍ $f$ ។

គ. បង្ហាញថានៅលើ $I$, $f'(x)$ មានសញ្ញាដូច $h(x)$ ។

ឃ. ទាញយកអថេរភាពនៃ $f$ លើ $I$ រួចសង់ក្រាប $(C)$ ក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j})$ ។

## ដំណោះស្រាយ

**A**. សិក្សាអនុគមន៍ជំនួយ $h(x)$ ៖

- $h(1)=-1+1-2\ln 1=0-0=\mathbf{0}$ ៖ $\boxed{h(1)=0}$ ។
- ដេរីវេ ៖ $h'(x)=-1-\dfrac{2}{x}=\dfrac{-x-2}{x}=-\dfrac{x+2}{x}$ ។
- ចំពោះគ្រប់ $x>0$ គេបាន $x+2>0$ និង $x>0 \implies h'(x)<0$ ជានិច្ច ។
  ដូច្នេះ $h$ ជាអនុគមន៍ចុះដាច់ខាតលើ $(0,+\infty)$ ។
- ទាញរកសញ្ញានៃ $h(x)$ ៖
  - បើ $0<x<1$ នោះ $h(x)>h(1)=0 \implies h(x)>0$ ។
  - បើ $x>1$ នោះ $h(x)<h(1)=0 \implies h(x)<0$ ។

**B**. សិក្សាអនុគមន៍ $f(x)$ ៖

ក. គណនាលីមីត ៖

- $\lim\limits_{x\to0^+} f(x)=\lim\limits_{x\to0^+}\left(\frac{1}{x}+\frac{\ln x}{x^2}\right)=\lim\limits_{x\to0^+}\frac{x+\ln x}{x^2}$ ៖
  ដោយ $x+\ln x\to-\infty$ និង $x^2\to0^+$ នោះ $\lim\limits_{x\to0^+} f(x)=-\infty \implies \boxed{x=0 \text{ ជាអាស៊ីមតូតឈរ}}$ ។
- $\lim\limits_{x\to+\infty} f(x)=\lim\limits_{x\to+\infty}\left(\frac{1}{x}+\frac{\ln x}{x^2}\right)=0+0=\mathbf{0} \implies \boxed{y=0 \text{ ជាអាស៊ីមតូតដេក}}$ ។

ខ. គណនាដេរីវេ $f'(x)$ ៖

$$f'(x)=\frac{(x+\ln x)'\cdot x^2-(x+\ln x)(x^2)'}{x^4}=\frac{\left(1+\frac{1}{x}\right)x^2-2x(x+\ln x)}{x^4}$$

$$f'(x) = \frac{x^2+x-2x^2-2x\ln x}{x^4} = \frac{x(-x+1-2\ln x)}{x^4} = \frac{-x+1-2\ln x}{x^3} = \frac{h(x)}{x^3}$$

**គ. សញ្ញានៃ $f'(x)$ ៖**

ដោយ $x^3 > 0$ ចំពោះគ្រប់ $x \in I = (0,+\infty)$ គេទាញបាន ៖

| $f'(x)$ មានសញ្ញាដូច $h(x)$ លើចន្លោះ $I$ |
|---|

**ឃ. អថេរភាព និងសង់ក្រាប $(C)$ ៖**

- $f'(x) = 0 \iff h(x) = 0 \iff x = 1$ ។
- លើ $(0,1)$ ៖ $f'(x) > 0 \implies f$ កើនដាច់ខាត ។
- លើ $(1,+\infty)$ ៖ $f'(x) < 0 \implies f$ ចុះដាច់ខាត ។
- អតិបរមាធៀប ៖ $f(1) = \frac{1+\ln 1}{1^2} = \mathbf{1}$ ។

| $x$ | $0$ | | $1$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | ‖ | $+$ | $0$ | $-$ | |
| $f(x)$ | $-\infty$ ‖ $-\infty$ | ↗ | $1$ | ↘ | $0$ |




## លំហាត់ទី ៣៣

**ក.** គេមានអនុគមន៍ $g$ កំណត់លើ $(0,+\infty)$ ដោយ $g(x) = x^2 + \ln x$ ។

១. បង្ហាញថា $g$ ជាអនុគមន៍កើនដាច់ខាតលើ $(0,+\infty)$ រួចគណនា $g(1)$ ។

២. ទាញបញ្ជាក់ថា ៖ បើ $x \geq 1$ នោះ $x^2 + \ln x \geq 1$ ហើយបើ $0 < x \leq 1$ នោះ $x^2 + \ln x \leq 1$ ។

៣. កំណត់សញ្ញានៃកន្សោម $x^2 + \ln x - 1$ កាលណា $x \in (0,+\infty)$ ។

**ខ.** គេមានអនុគមន៍ $f$ កំណត់លើ $(0,+\infty)$ ដោយ $f(x) = x + 1 - \frac{\ln x}{x}$ និងមានក្រាប $(C)$ ក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j})$ ។

①. សិក្សាលីមីតនៃ $f$ ត្រង់ $0^+$ និង $+\infty$ (ដោយដឹងថា $\lim\limits_{x\to+\infty}\frac{\ln x}{x}=0$) ។

②. បង្ហាញថាដេរីវេនៃអនុគមន៍ $f$ គឺ $f'(x)=\frac{x^2+\ln x-1}{x^2}$ ។

③. ប្រើលទ្ធផលសំណួរ $a$ សិក្សាសញ្ញា $f'(x)$ និងសង់តារាងអថេរភាពនៃ $f$ ។

④. បង្ហាញថាបន្ទាត់ $\Delta: y=x+1$ ជាអាស៊ីមតូតទ្រេតនៃ $(C)$ ខាង $+\infty$ ។ សិក្សាទីតាំងធៀបរវាង $(C)$ និង $\Delta$ បញ្ជាក់កូអរដោនេចំណុចប្រសព្វ $I$ រួចសង់ $\Delta$ និង $(C)$ ។

## ដំណោះស្រាយ

**ក. សិក្សាអនុគមន៍ $g(x)=x^2+\ln x$ ៖**

①. $g'(x)=2x+\frac{1}{x}=\frac{2x^2+1}{x}$ ។ ដោយ $x>0 \implies g'(x)>0$ ជានិច្ច ដូច្នេះ $g$ ជាអនុគមន៍កើនដាច់ខាតលើ $(0,+\infty)$ ។

គណនា $g(1)=1^2+\ln 1=1+0=\mathbf{1}$ ៖ $\boxed{g(1)=1}$ ។

②. ដោយ $g$ ជាអនុគមន៍កើនដាច់ខាត ៖

- បើ $x\geq 1 \implies g(x)\geq g(1) \iff x^2+\ln x\geq 1$ ។
- បើ $0<x\leq 1 \implies g(x)\leq g(1) \iff x^2+\ln x\leq 1$ ។

③. សញ្ញានៃ $x^2+\ln x-1$ ៖

- បើ $0<x<1$ នោះ $x^2+\ln x-1<0$ (សញ្ញាដក) ។
- បើ $x=1$ នោះ $x^2+\ln x-1=0$ ។
- បើ $x>1$ នោះ $x^2+\ln x-1>0$ (សញ្ញាបូក) ។

**ខ. សិក្សាអនុគមន៍ $f(x)=x+1-\frac{\ln x}{x}$ ៖**

①. **លីមីត ៖**

- $\lim\limits_{x\to0^+}f(x)=0+1-\lim\limits_{x\to0^+}\left(\frac{1}{x}\cdot\ln x\right)=1-(-\infty)=+\infty \implies \boxed{x=0 \text{ ជាអាស៊ីមតូតឈរ}}$ ។
- $\lim\limits_{x\to+\infty}f(x)=\lim\limits_{x\to+\infty}\left(x+1-\frac{\ln x}{x}\right)=+\infty+1-0=+\infty$ ។

②. **គណនាដេរីវេ ៖**

$$f'(x)=1+0-\frac{\frac{1}{x}\cdot x-\ln x}{x^2}=1-\frac{1-\ln x}{x^2}=\frac{x^2-1+\ln x}{x^2}=\boxed{\frac{x^2+\ln x-1}{x^2}}$$

③. **សញ្ញា $f'(x)$ និងតារាងអថេរភាព ៖** ដោយ $x^2>0$ ចំពោះគ្រប់ $x>0$ នោះសញ្ញា $f'(x)$ ដូចសញ្ញាភាគយក $x^2+\ln x-1$ ៖

- $f'(x)=0 \iff x=1$ ។
- លើ $(0,1)$ ៖ $f'(x)<0 \implies f$ ចុះដាច់ខាត ។
- លើ $(1,+\infty)$ ៖ $f'(x)>0 \implies f$ កើនដាច់ខាត ។

តម្លៃអប្បបរមាធៀប ៖ $f(1)=1+1-\frac{\ln 1}{1}=\mathbf{2}$ ។

| $x$ | $0$ | | $1$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | ‖ | $-$ | $0$ | $+$ | |
| $f(x)$ | $+\infty$ ‖ $+\infty$ | ↘ | $2$ | ↗ | $+\infty$ |

④. អាស៊ីមតូតទ្រេត $\Delta$ ទីតាំងធៀប និងសង់ក្រាប ៖

- $\lim\limits_{x\to+\infty}[f(x)-(x+1)] = \lim\limits_{x\to+\infty}\left(-\frac{\ln x}{x}\right) = 0 \Longrightarrow$ $\boxed{\Delta : y = x+1 \text{ ជាអាស៊ីមតូតទ្រេត}}$ ។
- ទីតាំងធៀប ៖ ពិនិត្យ $f(x)-(x+1) = -\dfrac{\ln x}{x}$ ៖
  - លើ $(0,1)$ ៖ $\ln x < 0 \Longrightarrow -\dfrac{\ln x}{x} > 0 \Longrightarrow (C)$ **នៅខាងលើ** $\Delta$ ។
  - ត្រង់ $x=1$ ៖ កាត់គ្នាត្រង់ចំណុច $\boxed{I(1,2)}$ ។
  - លើ $(1,+\infty)$ ៖ $\ln x > 0 \Longrightarrow -\dfrac{\ln x}{x} < 0 \Longrightarrow (C)$ **នៅខាងក្រោម** $\Delta$ ។




## លំហាត់ទី ៣៤

គេមានអនុគមន៍ $f$ កំណត់លើ $(1,+\infty)$ ដោយ $f(x) = -x+4+\ln\left(\dfrac{x+1}{x-1}\right)$ ហើយមានក្រាប $(C)$ ។

ក. គណនាលីមីតនៃ $f$ ត្រង់ $1^+$ និងត្រង់ $+\infty$ ។

ខ. បង្ហាញថាលើ $(1,+\infty)$ ដេរីវេនៃអនុគមន៍ $f$ គឺ $f'(x) = -\dfrac{x^2+1}{(x+1)(x-1)}$ ។ សិក្សាអថេរភាព និងសង់តារាងអថេរភាពនៃ $f$ ។

គ. បង្ហាញថាបន្ទាត់ $d_1 : y = -x+4$ ជាអាស៊ីមតូតទ្រេតនៃ $(C)$ ខាង $+\infty$ ។ បង្ហាញថាចំពោះគ្រប់ $x>1$, $\dfrac{x+1}{x-1} > 1$ រួចទាញរកទីតាំងធៀបរវាង $(C)$ និង $d_1$ ។

ឃ. កំណត់កូអរដោនេនៃចំណុច $B$ លើ $(C)$ ដែលបន្ទាត់ប៉ះ $d_2$ មានមេគុណប្រាប់ទិសស្មើ $-\frac{5}{3}$ និងសរសេរសមីការបន្ទាត់ប៉ះ $d_2$ នេះ ។

ង. សង់ក្រាប $(C)$ អាស៊ីមតូត $d_1$ និងបន្ទាត់ប៉ះ $d_2$ (យក $\ln 3 \approx 1.1$ និងដឹងថាក្រាបកាត់អ័ក្សអាប់ស៊ីសត្រង់ $x \approx 4.5$) ។

## ដំណោះស្រាយ

### ក. គណនាលីមីត ៖

- កាលណា $x \to 1^+$ គេបាន $\frac{x+1}{x-1} \to \frac{2}{0^+} = +\infty \implies \ln\left(\frac{x+1}{x-1}\right) \to +\infty$ ៖

$$\lim_{x\to 1^+} f(x) = -1+4+(+\infty) = +\infty \implies \boxed{x=1 \text{ ជាអាស៊ីមតូតឈរ}}$$

- កាលណា $x \to +\infty$ គេបាន $\frac{x+1}{x-1} \to 1 \implies \ln\left(\frac{x+1}{x-1}\right) \to 0$ ៖

$$\lim_{x\to +\infty} f(x) = -\infty+4+0 = -\infty$$

### ខ. គណនាដេរីវេ និងសង់តារាងអថេរភាព ៖

- សរសេរ $f(x) = -x+4+\ln(x+1)-\ln(x-1)$ ៖

$$f'(x) = -1+\frac{1}{x+1}-\frac{1}{x-1} = -1+\frac{(x-1)-(x+1)}{(x+1)(x-1)} = -1-\frac{2}{x^2-1} = \boxed{-\frac{x^2+1}{(x+1)(x-1)}}$$

- ដោយសារចំពោះគ្រប់ $x>1$ គេបាន $x^2+1>0$ និង $(x+1)(x-1) = x^2-1>0$ នោះ ៖

$f'(x) < 0$ ចំពោះគ្រប់ $x \in (1,+\infty)$

ដូចនេះ $f$ ជាអនុគមន៍ចុះដាច់ខាតលើចន្លោះ $(1,+\infty)$ ។

| $x$ | $1$ | | $+\infty$ |
|---|---|---|---|
| $f'(x)$ | ‖ | $-$ | |
| $f(x)$ | ‖ $+\infty$ | $+\infty$ ↘ | $-\infty$ |

### គ. អាស៊ីមតូតទ្រេត $d_1$ និងទីតាំងធៀប ៖

- $\lim_{x\to+\infty}[f(x)-(-x+4)] = \lim_{x\to+\infty}\ln\left(\frac{x+1}{x-1}\right) = \ln 1 = 0 \implies \boxed{d_1 : y=-x+4 \text{ ជាអាស៊ីមតូតទ្រេត}}$ ។

- ចំពោះគ្រប់ $x>1$ គេមាន $\frac{x+1}{x-1} = \frac{(x-1)+2}{x-1} = 1+\frac{2}{x-1} > 1$ ។

មេរៀនទី ៤ ផ្នែកដំណោះស្រាយ

- ដោយសារ $\frac{x+1}{x-1} > 1 \implies \ln\left(\frac{x+1}{x-1}\right) > 0 \implies f(x) - (-x+4) > 0$ ៖
  ដូច្នេះក្រាប $(C)$ ស្ថិតនៅ**ខាងលើ**អាស៊ីមតូតទ្រេត $d_1$ ជានិច្ច ។

**ឃ. ចំណុច $B$ និងសមីការបន្ទាត់ប៉ះ $d_2$ ៖**

- មេគុណប្រាប់ទិសស្មើ $-\frac{5}{3}$ ៖

$$f'(x_0) = -\frac{5}{3} \iff -\frac{x_0^2+1}{x_0^2-1} = -\frac{5}{3} \iff 3(x_0^2+1) = 5(x_0^2-1)$$

$$3x_0^2+3 = 5x_0^2-5 \iff 2x_0^2 = 8 \iff x_0^2 = 4 \iff x_0 = 2 \quad (\text{ព្រោះ } x_0 > 1)$$

- អរដោនេនៃ $B$ ៖ $y_0 = f(2) = -2+4+\ln\left(\frac{3}{1}\right) = \mathbf{2+\ln 3} \approx 2+1.1 = \mathbf{3.1}$ ៖

$$\boxed{B(2, 2+\ln 3)}$$

- សមីការបន្ទាត់ប៉ះ $d_2$ ត្រង់ $B$ ៖

$$y-(2+\ln 3) = -\frac{5}{3}(x-2) \iff y = -\frac{5}{3}x+\frac{10}{3}+2+\ln 3 \iff \boxed{y = -\frac{5}{3}x+\frac{16}{3}+\ln 3}$$

(តម្លៃប្រហែល ៖ $y \approx -1.67x+6.43$) ។

**ង. សង់ក្រាប $(C)$ អាស៊ីមតូត $d_1$ និងបន្ទាត់ប៉ះ $d_2$ ៖**



## លំហាត់ទី ៣៥

គេឱ្យអនុគមន៍ $f$ កំណត់លើ $\mathbb{R}\setminus\{0\}$ ដោយ $f(x)=\dfrac{e^x}{x}$ និងមានក្រាប $(C)$ ។

ក. គណនាលីមីត $\lim\limits_{x\to+\infty} f(x)$, $\lim\limits_{x\to-\infty} f(x)$ និង $\lim\limits_{x\to 0} f(x)$ រួចទាញរកអាស៊ីមតូតនៃក្រាប $(C)$ ។

ខ. គណនា និងសិក្សាសញ្ញាដេរីវេ $f'(x)$ ។ បង្ហាញថាអនុគមន៍ $f$ មានអប្បបរមាមួយ គណនាតម្លៃអប្បបរមានោះ និងសង់តារាងអថេរភាពនៃ $f$ ។

គ. បង្ហាញថាបន្ទាត់ប៉ះនឹងក្រាប $(C)$ ត្រង់អាប់ស៊ីស $x_0=1$ ជាបន្ទាត់ស្របនឹងអ័ក្សអាប់ស៊ីស ។

ឃ. សង់ក្រាប $(C)$ ។ ប្រើក្រាប $(C)$ កំណត់តម្លៃ $m$ ដើម្បីឱ្យសមីការ $e^x-mx=0$ មានឫស ។

## ដំណោះស្រាយ

### ក. គណនាលីមីត និងរកអាស៊ីមតូត ៖

- $\lim\limits_{x\to-\infty}\dfrac{e^x}{x}=\dfrac{0}{-\infty}=\mathbf{0}\implies$ $\boxed{y=0\ (\text{អ័ក្ស } Ox)\ \text{ជាអាស៊ីមតូតដេកខាង } -\infty}$ ។
- $\lim\limits_{x\to+\infty}\dfrac{e^x}{x}=+\infty$ (លីមីតគ្រឹះ) ។
- $\lim\limits_{x\to0^-}\dfrac{e^x}{x}=\dfrac{1}{0^-}=-\infty$ និង $\lim\limits_{x\to0^+}\dfrac{e^x}{x}=\dfrac{1}{0^+}=+\infty$ ៖

  ដូច្នេះ $\boxed{x=0\ (\text{អ័ក្ស } Oy)\ \text{ជាអាស៊ីមតូតឈរ}}$ ។

### ខ. ដេរីវេ តម្លៃអប្បបរមា និងតារាងអថេរភាព ៖

- ដេរីវេ ៖ $f'(x)=\dfrac{(e^x)'\cdot x-e^x(x)'}{x^2}=\dfrac{e^x\cdot x-e^x}{x^2}=\dfrac{e^x(x-1)}{x^2}$ ។
- ដោយ $e^x>0$ និង $x^2>0$ ចំពោះគ្រប់ $x\neq0$ នោះសញ្ញា $f'(x)$ ដូចសញ្ញា $x-1$ ៖

$$f'(x)=0\iff x-1=0\iff x=1$$

  - លើ $(-\infty,0)$ ៖ $x-1<0\implies f'(x)<0$ (ចុះ) ។
  - លើ $(0,1)$ ៖ $x-1<0\implies f'(x)<0$ (ចុះ) ។
  - លើ $(1,+\infty)$ ៖ $x-1>0\implies f'(x)>0$ (កើន) ។
- លើចន្លោះ $(0,+\infty)$ អនុគមន៍ចុះពី $+\infty$ ដល់ $x=1$ រួចកើនឡើងទៅ $+\infty$ វិញ ដូច្នេះ $f$ មានតម្លៃអប្បបរមាធៀបត្រង់ $x=1$ គឺ ៖

$$f(1)=\frac{e^1}{1}=\mathbf{e}\approx\mathbf{2.72}$$

| $x$ | $-\infty$ | | $0$ | | $1$ | | $+\infty$ |
|---|---|---|---|---|---|---|---|
| $f'(x)$ | | $-$ | ‖ | $-$ | $0$ | $+$ | |
| $f(x)$ | $0$ ↘ | | $-\infty$ ‖ $+\infty$ | ↘ | $e$ | ↗ | $+\infty$ |

**គ. បន្ទាត់ប៉ះត្រង់ $x_0=1$ ៖**

មេគុណប្រាប់ទិសនៃបន្ទាត់ប៉ះគឺ $f'(1)=\dfrac{e^1(1-1)}{1^2}=0$ ។

សមីការបន្ទាត់ប៉ះគឺ $y-f(1)=0(x-1) \iff \boxed{y=e}$ ។

ដោយសារបន្ទាត់នេះមានទម្រង់ $y=$ ថេរ នោះវាជាបន្ទាត់ដេកស្របនឹងអ័ក្សអាប់ស៊ីស $(Ox)$ ។

**ឃ. សង់ក្រាប $(C)$ និងពិភាក្សាឫសសមីការ $e^x-mx=0$ ៖**




- **កំណត់តម្លៃ $m$ ៖**

សមីការ $e^x-mx=0$ ៖

– បើ $x=0$ ៖ $e^0-0=1\neq 0$ ដូច្នេះ $x=0$ មិនមែនជាឫសឡើយ ។

– ចំពោះ $x\neq 0$ ៖ $e^x-mx=0 \iff \dfrac{e^x}{x}=m \iff f(x)=m$ ។

ឫសនៃសមីការជាអាប់ស៊ីសនៃចំណុចប្រសព្វរវាងក្រាប $(C)$ និងបន្ទាត់ដេក $y=m$ ៖

– ចំពោះ $x<0$ ៖ តម្លៃនៃ $f(x)$ ស្ថិតក្នុងចន្លោះ $(-\infty,0)$ ដូច្នេះបន្ទាត់ $y=m$ តែងតែកាត់ $(C)$ ត្រង់មួយចំណុចជានិច្ច កាលណា $m<0$ ។

– ចំពោះ $x>0$ ៖ តម្លៃនៃ $f(x)$ ស្ថិតក្នុងចន្លោះ $[e,+\infty)$ ដូច្នេះបន្ទាត់ $y=m$ កាត់ $(C)$ កាលណា $m\geq e$ ។

– ចំពោះ $0\leq m<e$ ៖ បន្ទាត់ $y=m$ មិនកាត់ក្រាប $(C)$ ឡើយ ។

ដូចនេះ សមីការមានឫសលុះត្រាតែ ៖

$$\boxed{m<0 \quad \text{ឬ} \quad m\geq e \iff m\in(-\infty,0)\cup[e,+\infty)}$$

## លំហាត់ទី ៣៦

គេឱ្យអនុគមន៍ $f$ កំណត់លើ $\mathbb{R}$ ដោយ $f(x)=(2x+1)e^{-2x}$ ហើយមានក្រាប $(C)$ ក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j})$ ។

ក. គណនាលីមីតនៃ $f$ កាលណា $x\to-\infty$ និង $x\to+\infty$ រួចទាញរកសមីការអាស៊ីមតូតដេកនៃ $(C)$ ។

ខ. គណនាដេរីវេ $f'(x)$ សិក្សាសញ្ញា $f'(x)$ និងគូសតារាងអថេរភាពនៃ $f$ ។

គ. រកចំណុចប្រសព្វ $A$ រវាងក្រាប $(C)$ និងអ័ក្ស $(Ox)$ ។ សិក្សាសញ្ញានៃ $f(x)$ ។

ឃ. សរសេរសមីការបន្ទាត់ប៉ះ $(T)$ ទៅនឹងក្រាប $(C)$ ត្រង់ចំណុច $A$ ។ សង់ក្រាប $(C)$ អាស៊ីមតូត និងបន្ទាត់ប៉ះ $(T)$ ក្នុងតម្រុយតែមួយ ។

ង. ដោយប្រើក្រាប $(C)$ ចូរកំណត់តម្លៃ $m$ ដើម្បីឱ្យសមីការ $(2x+1)e^{-2x}=m$ មានឫសពីរផ្សេងគ្នា ។

## ដំណោះស្រាយ

### ក. គណនាលីមីត និងរកសមីការអាស៊ីមតូត ៖

- ដែនកំណត់ ៖ $D=\mathbb{R}$ ។
- $\lim\limits_{x\to-\infty} f(x)=\lim\limits_{x\to-\infty}(2x+1)e^{-2x}=(-\infty)(+\infty)=-\infty$ ។
- $\lim\limits_{x\to+\infty} f(x)=\lim\limits_{x\to+\infty}\left(\frac{2x}{e^{2x}}+\frac{1}{e^{2x}}\right)=0+0=\mathbf{0}$ (តាមលីមីតគ្រឹះ $\lim\limits_{u\to+\infty}\frac{u}{e^u}=0$) ៖

  ដូច្នេះ $\boxed{y=0 \text{ (អ័ក្ស } Ox) \text{ ជាអាស៊ីមតូតដេកខាង } +\infty}$ ។

### ខ. ដេរីវេ និងតារាងអថេរភាព ៖

- អនុវត្តរូបមន្ត $(uv)'=u'v+uv'$ ៖

$$f'(x)=(2x+1)'\cdot e^{-2x}+(2x+1)(e^{-2x})'=2e^{-2x}+(2x+1)(-2e^{-2x})$$

$$f'(x)=2e^{-2x}[1-(2x+1)]=2e^{-2x}(-2x)=\boxed{-4xe^{-2x}}$$

- ដោយសារ $e^{-2x}>0$ ចំពោះគ្រប់ $x\in\mathbb{R}$ នោះសញ្ញា $f'(x)$ ដូចសញ្ញា $-4x$ ៖

$$f'(x)=0 \iff -4x=0 \iff x=0$$

  – បើ $x<0$ ៖ $-4x>0 \implies f'(x)>0$ (អនុគមន៍កើន) ។
  – បើ $x>0$ ៖ $-4x<0 \implies f'(x)<0$ (អនុគមន៍ចុះ) ។

- អនុគមន៍មានតម្លៃអតិបរមាដាច់ខាតត្រង់ $x=0$ គឺ ៖

$$f(0)=(2(0)+1)e^0=1\cdot1=\mathbf{1}$$

| $x$ | $-\infty$ | | $0$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | | $+$ | $0$ | $-$ | |
| $f(x)$ | $-\infty$ | $\nearrow$ | $1$ | $\searrow$ | $0$ |

គ. ចំណុចប្រសព្វ $A$ និងសិក្សាសញ្ញានៃ $f(x)$ ៖

- $f(x)=0 \iff (2x+1)e^{-2x}=0 \iff 2x+1=0 \iff x=-\frac{1}{2}$ ៖

  ដូច្នេះចំណុចប្រសព្វនឹងអ័ក្សអាប់ស៊ីសគឺ $\boxed{A\left(-\frac{1}{2},0\right)}$ ។

- ដោយ $e^{-2x}>0$ ជានិច្ច នោះសញ្ញា $f(x)$ ដូចសញ្ញា $2x+1$ ៖
  - បើ $x<-\frac{1}{2}$ ៖ $f(x)<0$ (ក្រាបនៅខាងក្រោមអ័ក្ស $Ox$) ។
  - បើ $x=-\frac{1}{2}$ ៖ $f(x)=0$ ។
  - បើ $x>-\frac{1}{2}$ ៖ $f(x)>0$ (ក្រាបនៅខាងលើអ័ក្ស $Ox$) ។

ឃ. សមីការបន្ទាត់ប៉ះ $(T)$ និងសង់ក្រាប $(C)$ ៖

- មេគុណប្រាប់ទិសត្រង់ $A\left(-\frac{1}{2},0\right)$ ៖

$$f'\left(-\frac{1}{2}\right)=-4\left(-\frac{1}{2}\right)e^{-2(-1/2)}=2e^{1}=\mathbf{2e}\approx\mathbf{5.44}$$

- សមីការបន្ទាត់ប៉ះ $(T)$ ត្រង់ $A$ ៖

$$y-0=2e\left(x+\frac{1}{2}\right) \iff \boxed{y=2ex+e}$$




ង. កំណត់តម្លៃ $m$ ដើម្បីឱ្យសមីការមានឫសពីរផ្សេងគ្នា ៖
សមីការ $(2x+1)e^{-2x}=m$ មានឫសជាអាប់ស៊ីសនៃចំណុចប្រសព្វរវាងក្រាប $(C)$ និងបន្ទាត់ដេក $y=m$ ៖
តាមតារាងអថេរភាព និងក្រាប $(C)$ ៖

- កាលណា $x\in(-\infty,0)$ ៖ $f(x)$ កើនពី $-\infty$ ដល់ $1$ ។
- កាលណា $x\in(0,+\infty)$ ៖ $f(x)$ ចុះពី $1$ ដល់ $0$ (មិនប៉ះ $0$) ។

ដូច្នេះ បន្ទាត់ដេក $y=m$ កាត់ខ្សែកោង $(C)$ ត្រង់ពីរចំណុចផ្សេងគ្នា លុះត្រាតែ $m$ ស្ថិតនៅចន្លោះតម្លៃអប្បបរមាខាងចុង $0$ និងតម្លៃអតិបរមា $1$ ៖

$$\boxed{0<m<1}$$

## លំហាត់ទី ៣៧

គេកំណត់អនុគមន៍ $f$ លើ $\mathbb{R}\setminus\{0\}$ ដោយ $f(x)=\dfrac{e^x}{e^x-1}$ និងមានក្រាប $(C)$ ។

ក. បង្ហាញថាចំពោះគ្រប់ $x\neq 0$ គេអាចសរសេរ $f(x)=1+\dfrac{1}{e^x-1}$ ។ គណនាលីមីត $\lim\limits_{x\to+\infty} f(x)$ និង $\lim\limits_{x\to-\infty} f(x)$ រួចទាញរកសមីការអាស៊ីមតូតដេកនៃ $(C)$ ។

ខ. បង្ហាញថា $f$ មានដេរីវេចំពោះគ្រប់ $x\neq 0$ គណនា $f'(x)$ សិក្សាទិសដៅអថេរភាព គណនាលីមីតត្រង់ចុងដែន និងគូសតារាងអថេរភាពនៃ $f$ ។

គ. រកអាស៊ីមតូតឈរនៃក្រាប $(C)$ និងសមីការបន្ទាត់ $(T)$ ប៉ះក្រាប $(C)$ ត្រង់ចំណុចដែលមានអាប់ស៊ីស $x=1$ ។

ឃ. សង់ក្រាប $(C)$ អាស៊ីមតូត និងបន្ទាត់ប៉ះ $(T)$ ក្នុងតម្រុយតែមួយ ។

## ដំណោះស្រាយ

**ក. សរសេរបំប្លែង $f(x)$ និងគណនាលីមីត ៖**

- សរសេរ ៖

$$f(x)=\frac{(e^x-1)+1}{e^x-1}=\frac{e^x-1}{e^x-1}+\frac{1}{e^x-1}=\boxed{1+\frac{1}{e^x-1}}$$

- កាលណា $x\to+\infty$ គេបាន $e^x\to+\infty \implies \dfrac{1}{e^x-1}\to 0$ ៖

$$\lim_{x\to+\infty} f(x)=1+0=\mathbf{1} \implies \boxed{y=1 \text{ ជាអាស៊ីមតូតដេកខាង } +\infty}$$

- កាលណា $x\to-\infty$ គេបាន $e^x\to 0 \implies \dfrac{e^x}{e^x-1}\to\dfrac{0}{0-1}=0$ ៖

$$\lim_{x\to-\infty} f(x)=\mathbf{0} \implies \boxed{y=0 \text{ (អ័ក្ស } Ox\text{) ជាអាស៊ីមតូតដេកខាង } -\infty}$$

**ខ. ដេរីវេ និងតារាងអថេរភាព ៖**

- ចំពោះគ្រប់ $x\neq 0$ ភាគបែង $e^x-1\neq 0$ ដូច្នេះ $f$ មានដេរីវេជានិច្ច ៖

$$f'(x)=\left(1+\frac{1}{e^x-1}\right)'=-\frac{(e^x-1)'}{(e^x-1)^2}=\boxed{-\frac{e^x}{(e^x-1)^2}}$$

- ដោយសារ $e^x>0$ និង $(e^x-1)^2>0$ ចំពោះគ្រប់ $x\neq 0$ នោះ ៖

$$f'(x)<0 \quad \text{ចំពោះគ្រប់ } x\in(-\infty,0)\cup(0,+\infty)$$

ដូច្នេះ $f$ ជាអនុគមន៍ចុះដាច់ខាតលើចន្លោះ $(-\infty,0)$ និងលើ $(0,+\infty)$ ។

- លីមីតត្រង់ $0$ ៖
  - កាលណា $x\to 0^-$ គេបាន $e^x-1\to 0^- \implies \lim\limits_{x\to 0^-} f(x)=-\infty$ ។

– កាលណា $x \to 0^+$ គេបាន $e^x - 1 \to 0^+ \implies \lim\limits_{x\to 0^+} f(x) = +\infty$ ។

| $x$ | $-\infty$ | | $0$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | | $-$ | \|\| | $-$ | |
| $f(x)$ | $0$ ↘ | $-\infty$ | \|\| | $+\infty$ ↘ | $1$ |

**គ. អាស៊ីមតូតឈរ និងសមីការបន្ទាត់ប៉ះ $(T)$ ត្រង់ $x = 1$ ៖**

- ដោយ $\lim\limits_{x\to 0^\pm} f(x) = \pm\infty$ នោះ $\boxed{x = 0 \text{ (អ័ក្ស } Oy\text{) ជាអាស៊ីមតូតឈរ}}$ ។
- ត្រង់ $x = 1$ ៖

$$y_0 = f(1) = \frac{e}{e-1} \approx \frac{2.718}{1.718} \approx \mathbf{1.58}$$

$$f'(1) = -\frac{e}{(e-1)^2} \approx -\frac{2.718}{(1.718)^2} \approx -\mathbf{0.92}$$

- សមីការបន្ទាត់ប៉ះ $(T)$ ៖

$$y - \frac{e}{e-1} = -\frac{e}{(e-1)^2}(x-1) \iff \boxed{y = -\frac{e}{(e-1)^2}x + \frac{e^2}{(e-1)^2}}$$

**ឃ. សង់ក្រាប $(C)$ អាស៊ីមតូត និងបន្ទាត់ប៉ះ $(T)$ ៖**



## លំហាត់ទី ៣៨

ក. តាង $g(x)=(x-1)e^x+1$ ចំពោះ $x\in\mathbb{R}$ ។ គណនា $g'(x)$ គូសតារាងអថេរភាពនៃ $g$ (មិនបាច់គណនាលីមីត) រួចទាញរកសញ្ញានៃ $g(x)$ លើ $\mathbb{R}$ ។

ខ. អនុគមន៍ $f$ កំណត់លើ $\mathbb{R}$ ដោយ $f(x)=(x-2)e^x+x$ ហើយមានក្រាប $(C)$ ក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j})$ ។

១. គណនាលីមីត $\lim\limits_{x\to-\infty} f(x)$ និង $\lim\limits_{x\to+\infty} f(x)$ ។

២. រកសមីការអាស៊ីមតូតទ្រេតនៃ $(C)$ និងសិក្សាទីតាំងធៀបនៃ $(C)$ ធៀបនឹងអាស៊ីមតូតទ្រេតនោះ ។

៣. គណនា $f'(x)$ ប្រើលទ្ធផលផ្នែក $a$ សិក្សាសញ្ញា $f'(x)$ រួចគូសតារាងអថេរភាពនៃ $f$ ។

៤. បង្ហាញថាក្រាប $(C)$ មានចំណុចរបត់មួយដែលត្រូវគណនាកូអរដោនេ ហើយត្រង់ចំណុចរបត់នេះ បន្ទាត់ប៉ះស្របនឹងអ័ក្សអាប់ស៊ីស ។

៥. សង់ក្រាប $(C)$ អាស៊ីមតូតទ្រេត និងបន្ទាត់ប៉ះត្រង់ចំណុចរបត់ក្នុងតម្រុយតែមួយ ។

## ដំណោះស្រាយ

### ក. សិក្សាអនុគមន៍ $g(x)=(x-1)e^x+1$ ៖

- ដេរីវេ ៖ $g'(x)=1\cdot e^x+(x-1)e^x=xe^x$ ។
- ដោយ $e^x>0$ ចំពោះគ្រប់ $x\in\mathbb{R}$ នោះ $g'(x)$ មានសញ្ញាដូច $x$ ៖

$$g'(x)=0 \iff x=0$$

  - បើ $x<0$ ៖ $g'(x)<0 \implies g$ ជាអនុគមន៍ចុះ ។
  - បើ $x>0$ ៖ $g'(x)>0 \implies g$ ជាអនុគមន៍កើន ។
- អប្បបរមាដាច់ខាតត្រង់ $x=0$ គឺ $g(0)=(0-1)e^0+1=-1+1=\mathbf{0}$ ។

| $x$ | $-\infty$ | | $0$ | | $+\infty$ |
|---|---|---|---|---|---|
| $g'(x)$ | | $-$ | $0$ | $+$ | |
| $g(x)$ | | ↘ | $0$ | ↗ | |

- ទាញរកសញ្ញា $g(x)$ ៖ ដោយសារតម្លៃអប្បបរមានៃ $g$ គឺ $0$ នោះ ៖

$$\boxed{g(x)\geq 0 \quad \text{ចំពោះគ្រប់ } x\in\mathbb{R} \quad (\text{ស្មើ } 0 \iff x=0)}$$

### ខ. សិក្សាអនុគមន៍ $f(x)=(x-2)e^x+x$ ៖

#### ១. គណនាលីមីត ៖

- កាលណា $x\to-\infty$ គេបាន $(x-2)e^x=xe^x-2e^x\to 0$ ៖

$$\lim_{x\to-\infty} f(x)=0+(-\infty)=-\infty$$

- កាលណា $x \to +\infty$ គេបាន $(x-2)e^x \to +\infty$ ៖

$$\lim_{x\to+\infty} f(x) = +\infty + (+\infty) = +\infty$$

**២. អាស៊ីមតូតទ្រេត និងទីតាំងធៀប ៖**

- $\lim_{x\to-\infty} [f(x)-x] = \lim_{x\to-\infty} (x-2)e^x = 0$ ៖

ដូច្នេះបន្ទាត់ $(\Delta): y = x$ ជាអាស៊ីមតូតទ្រេតខាង $-\infty$ ។

- ទីតាំងធៀប ៖ ពិនិត្យ $f(x) - x = (x-2)e^x$ ដោយ $e^x > 0$ ៖
  - បើ $x < 2$ ៖ $x - 2 < 0 \implies (C)$ ស្ថិតនៅ**ខាងក្រោម** $(\Delta)$ ។
  - បើ $x = 2$ ៖ $(C)$ **កាត់** $(\Delta)$ ត្រង់ចំណុច $(2,2)$ ។
  - បើ $x > 2$ ៖ $x - 2 > 0 \implies (C)$ ស្ថិតនៅ**ខាងលើ** $(\Delta)$ ។

**៣. ដេរីវេ និងតារាងអថេរភាព ៖**

$$f'(x) = 1\cdot e^x + (x-2)e^x + 1 = (x-1)e^x + 1 = g(x)$$

តាមលទ្ធផលសំណួរ $a$ គេបាន $f'(x) = g(x) \geq 0$ ចំពោះគ្រប់ $x \in \mathbb{R}$ (ស្មើ 0 ត្រង់ចំណុចទោល $x = 0$) ។ ដូចនេះ $f$ ជាអនុគមន៍**កើនដាច់ខាតលើ** $\mathbb{R}$ ។

| $x$ | $-\infty$ | | $0$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | | $+$ | $0$ | $+$ | |
| $f(x)$ | $-\infty$ | $\nearrow$ | $-2$ | $\nearrow$ | $+\infty$ |

**៤. ចំណុចរបត់ និងបន្ទាត់ប៉ះស្របអ័ក្ស $Ox$ ៖**

- $f''(x) = g'(x) = xe^x$ ។
- $f''(x) = 0 \iff x = 0$ ហើយ $f''(x)$ ប្តូរសញ្ញាពីអវិជ្ជមាន $(x<0)$ ទៅវិជ្ជមាន $(x>0)$ ត្រង់ $x = 0$ ដូច្នេះក្រាប $(C)$ មានចំណុចរបត់ត្រង់ $x = 0$ ៖

$$y_0 = f(0) = (0-2)e^0 + 0 = \mathbf{-2} \implies \boxed{I(0,-2)\text{ ជាចំណុចរបត់}}$$

- មេគុណប្រាប់ទិសត្រង់ចំណុចរបត់គឺ $f'(0) = g(0) = 0$ ដូច្នេះបន្ទាត់ប៉ះត្រង់ $I$ មានសមីការ ៖

$$y - (-2) = 0(x-0) \iff \boxed{y = -2\text{ ជាបន្ទាត់ដេកស្របនឹងអ័ក្សអាប់ស៊ីស}}\,(Ox)$$

**៥. សង់ក្រាប $(C)$ អាស៊ីមតូត និងបន្ទាត់ប៉ះ ៖**




## លំហាត់ទី ៣៩

កំណត់សមីការបន្ទាត់ប៉ះ $(L)$ ដែលប៉ះនឹងខ្សែកោង $(H)$ តាង $y = x\ln x - 1$ នៅត្រង់ចំណុច $A(1,-1)$ ។

## ដំណោះស្រាយ

- អនុគមន៍ $y = f(x) = x\ln x - 1$ មានដែនកំណត់ $D = (0,+\infty)$ ។
- ផ្ទៀងផ្ទាត់ចំណុច $A(1,-1)$ ៖

$$f(1) = 1\cdot\ln 1 - 1 = 0 - 1 = -1 \implies A(1,-1) \in (H)$$

- គណនាដេរីវេ $f'(x)$ តាមរូបមន្ត $(uv)' = u'v + uv'$ ៖

$$f'(x) = (x)'\ln x + x(\ln x)' - 0 = 1\cdot\ln x + x\cdot\frac{1}{x} = \ln x + 1$$

- មេគុណប្រាប់ទិសនៃបន្ទាត់ប៉ះ $(L)$ ត្រង់អាប់ស៊ីស $x_A = 1$ គឺ ៖

$$f'(1) = \ln 1 + 1 = 0 + 1 = \mathbf{1}$$

- សមីការបន្ទាត់ប៉ះ $(L)$ ត្រង់ចំណុច $A(1,-1)$ កំណត់ដោយរូបមន្ត ៖

$$y - y_A = f'(x_A)(x - x_A) \iff y - (-1) = 1(x-1)$$

$$y + 1 = x - 1 \iff \boxed{y = x - 2}$$

## លំហាត់ទី ៤០

គេឱ្យអនុគមន៍ $f(x)=\dfrac{\ln x}{x^2}$ ហើយមានក្រាប $(C)$ ។

ក. រកដែនកំណត់នៃ $f$ រួចគណនាលីមីត $\lim\limits_{x\to+\infty} f(x)$ និង $\lim\limits_{x\to0^+} f(x)$ ។ ទាញរកអាស៊ីមតូតឈរ និងអាស៊ីមតូតដេក នៃក្រាប $(C)$ ។

ខ. គណនាដេរីវេនៃ $f$ រួចបង្ហាញថា $f$ មានអតិបរមាត្រង់ $x=\sqrt{e}$ ។ សង់តារាងអថេរភាពនៃ $f$ ។

គ. រកសមីការបន្ទាត់ប៉ះ $(d)$ ទៅនឹងក្រាប $(C)$ ត្រង់ចំណុច $M(1,0)$ ។ សង់ $(d)$ និងក្រាប $(C)$ ក្នុងតម្រុយតែមួយ (យក $\sqrt{e}\approx 1.6, \dfrac{1}{2e}\approx 0.2$) ។

## ដំណោះស្រាយ

### ក. រកដែនកំណត់ គណនាលីមីត និងទាញរកសមីការអាស៊ីមតូត ៖

- អនុគមន៍ $f(x)=\dfrac{\ln x}{x^2}$ មានន័យកាលណា $x>0$ ដូច្នេះដែនកំណត់គឺ $D=(0,+\infty)$ ។
- គណនាលីមីតត្រង់ $0^+$ ៖

$$\lim_{x\to0^+} f(x)=\lim_{x\to0^+}\left(\frac{1}{x^2}\cdot\ln x\right)$$

ដោយ $\lim\limits_{x\to0^+}\dfrac{1}{x^2}=+\infty$ និង $\lim\limits_{x\to0^+}\ln x=-\infty$ នាំឱ្យ $(+\infty)(-\infty)=-\infty$ ៖

$$\lim_{x\to0^+} f(x)=-\infty \implies \boxed{x=0 \text{ (អ័ក្ស } Oy) \text{ ជាអាស៊ីមតូតឈរនៃក្រាប } (C)}$$

- គណនាលីមីតត្រង់ $+\infty$ ៖ តាមរូបមន្តលីមីតគ្រឹះ $\lim\limits_{x\to+\infty}\dfrac{\ln x}{x^n}=0$ (ចំពោះ $n=2>0$) ៖

$$\lim_{x\to+\infty} f(x)=\lim_{x\to+\infty}\frac{\ln x}{x^2}=0 \implies \boxed{y=0 \text{ (អ័ក្ស } Ox) \text{ ជាអាស៊ីមតូតដេកខាង } +\infty}$$

### ខ. គណនាដេរីវេ បង្ហាញតម្លៃអតិបរមា និងសង់តារាងអថេរភាព ៖

- គណនាដេរីវេតាមរូបមន្ត $\left(\dfrac{u}{v}\right)'=\dfrac{u'v-uv'}{v^2}$ ៖

$$f'(x)=\frac{(\ln x)'\cdot x^2-(\ln x)(x^2)'}{(x^2)^2}=\frac{\frac{1}{x}\cdot x^2-2x\ln x}{x^4}=\frac{x-2x\ln x}{x^4}=\frac{1-2\ln x}{x^3}$$

- ដោយសារ $x>0 \implies x^3>0$ ជានិច្ច នោះសញ្ញានៃ $f'(x)$ អាស្រ័យលើកន្សោម $1-2\ln x$ ៖

$$f'(x)=0 \iff 1-2\ln x=0 \iff \ln x=\frac{1}{2} \iff x=e^{1/2}=\sqrt{e}$$

– ចំពោះ $0<x<\sqrt{e}$ ៖ $1-2\ln x>0 \implies f'(x)>0$ (អនុគមន៍កើនដាច់ខាត) ។

– ចំពោះ $x > \sqrt{e}$ ៖ $1-2\ln x < 0 \implies f'(x) < 0$ (អនុគមន៍ចុះដាច់ខាត) ។

ដោយ $f'(x)$ ប្តូរសញ្ញាពីវិជ្ជមាន $(+)$ ទៅអវិជ្ជមាន $(-)$ ត្រង់ $x=\sqrt{e}$ នាំឱ្យ $f$ មានតម្លៃអតិបរមាដាច់ខាតត្រង់ $x=\sqrt{e}$ គឺ ៖

$$f(\sqrt{e}) = \frac{\ln(\sqrt{e})}{(\sqrt{e})^2} = \frac{\frac{1}{2}}{e} = \frac{\mathbf{1}}{\mathbf{2e}} \approx \mathbf{0.184}$$

| $x$ | $0$ | | $\sqrt{e}$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | ‖ | $+$ | $0$ | $-$ | |
| $f(x)$ | $-\infty$ ‖ $-\infty$ | ↗ | $\frac{1}{2e}$ | ↘ | $0$ |

គ. រកសមីការបន្ទាត់ប៉ះ $(d)$ និងសង់ក្រាប $(C)$ ៖

- មេគុណប្រាប់ទិសនៃបន្ទាត់ប៉ះ $(d)$ ត្រង់ចំណុច $M(1,0)$ គឺ ៖

$$f'(1) = \frac{1-2\ln 1}{1^3} = \frac{1-0}{1} = 1$$

- សមីការបន្ទាត់ប៉ះ $(d)$ កំណត់ដោយរូបមន្ត $y-y_M = f'(x_M)(x-x_M)$ ៖

$$y-0 = 1(x-1) \iff \boxed{(d): y = x-1}$$




## លំហាត់ទី ៤១

គេឱ្យអនុគមន៍ $f$ កំណត់ចំពោះ $x>0$ ដោយ $f(x) = \dfrac{1+2\ln x}{x^2}$ ហើយមានក្រាប $(C)$ ក្នុងតម្រុយ $(O,\vec{i},\vec{j})$ ។

ក. គណនាលីមីតចុងដែនកំណត់ រួចបញ្ជាក់សមីការអាស៊ីមតូតនៃក្រាប $(C)$ ។

ខ. គណនា $f'(x)$ រួចបង្ហាញថា $f(x)$ មានអតិបរមាមួយ ហើយគណនាតម្លៃអតិបរមានោះ ។

គ. សង់តារាងអថេរភាពនៃ $f$ រួចរកកូអរដោនេចំណុចរបត់នៃក្រាប $(C)$ ។

ឃ. សរសេរសមីការបន្ទាត់ $(T)$ ប៉ះទៅនឹងក្រាប $(C)$ ត្រង់ចំណុចដែល $(C)$ កាត់អ័ក្សអាប់ស៊ីស ។

ង. គណនា $f\left(\frac{1}{2}\right)$ និង $f(2)$ រួចសង់បន្ទាត់ $(T)$ និងក្រាប $(C)$ ។ ដោយប្រើក្រាប $(C)$ កំណត់តម្លៃ $m$ ដើម្បីឱ្យសមីការ $\frac{1+2\ln x}{x^2}=m$ មានឫស (យក $\ln 2\approx 0.7$) ។

## ដំណោះស្រាយ

### ក. គណនាលីមីត និងរកអាស៊ីមតូត ៖

- ដែនកំណត់ ៖ $D=(0,+\infty)$ ។
- $\lim\limits_{x\to 0^+} f(x)=\lim\limits_{x\to 0^+}\left(\frac{1}{x^2}+2\frac{\ln x}{x^2}\right)=+\infty+2(-\infty)=-\infty \implies \boxed{x=0 \text{ ជាអាស៊ីមតូតឈរ}}$ ។
- $\lim\limits_{x\to +\infty} f(x)=\lim\limits_{x\to +\infty}\left(\frac{1}{x^2}+2\frac{\ln x}{x^2}\right)=0+0=\mathbf{0} \implies \boxed{y=0 \text{ ជាអាស៊ីមតូតដេក}}$ ។

### ខ. ដេរីវេ និងតម្លៃអតិបរមា ៖

- ដេរីវេ ៖

$$f'(x)=\frac{(1+2\ln x)'\cdot x^2-(1+2\ln x)(x^2)'}{x^4}=\frac{\frac{2}{x}\cdot x^2-2x(1+2\ln x)}{x^4}$$

$$f'(x)=\frac{2x-2x-4x\ln x}{x^4}=\frac{-4x\ln x}{x^4}=\boxed{-\frac{4\ln x}{x^3}}$$

- ដោយ $x^3>0$ ចំពោះគ្រប់ $x>0$ នោះសញ្ញា $f'(x)$ ដូចសញ្ញា $-\ln x$ ៖

$$f'(x)=0 \iff \ln x=0 \iff x=1$$

  - បើ $0<x<1$ ៖ $\ln x<0 \implies f'(x)>0$ (កើន) ។
  - បើ $x>1$ ៖ $\ln x>0 \implies f'(x)<0$ (ចុះ) ។
- អតិបរមាដាច់ខាតត្រង់ $x=1$ គឺ ៖

$$f(1)=\frac{1+2\ln 1}{1^2}=\frac{1+0}{1}=\mathbf{1}$$

### គ. តារាងអថេរភាព និងចំណុចរបត់ ៖

| $x$ | $0$ | | $1$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | ‖ | $+$ | $0$ | $-$ | |
| $f(x)$ | ‖ $-\infty$ | ↗ | $1$ | ↘ | $0$ |

- ដេរីវេទីពីរ $f''(x)$ ៖

$$f''(x) = -\frac{(4\ln x)'\cdot x^3 - 4\ln x\cdot 3x^2}{x^6} = -\frac{\frac{4}{x}\cdot x^3 - 12x^2\ln x}{x^6} = -\frac{4x^2(1-3\ln x)}{x^6} = \frac{4(3\ln x - 1)}{x^4}$$

- $f''(x)=0 \iff 3\ln x - 1 = 0 \iff \ln x = \frac{1}{3} \iff x = e^{1/3} = \sqrt[3]{e} \approx 1.44$ ។
- អរដោនេចំណុចរបត់ ៖

$$f(e^{1/3}) = \frac{1+2\left(\frac{1}{3}\right)}{(e^{1/3})^2} = \frac{\frac{5}{3}}{e^{2/3}} = \frac{\mathbf{5}}{\mathbf{3\sqrt[3]{e^2}}} \approx \mathbf{0.86}$$

ដូច្នេះចំណុចរបត់គឺ $\boxed{I\left(e^{1/3}, \frac{5}{3e^{2/3}}\right)}$ ។

**ឃ. សមីការបន្ទាត់ប៉ះ $(T)$ ត្រង់ចំណុចប្រសព្វនឹងអ័ក្ស $Ox$ ៖**

- $f(x)=0 \iff 1+2\ln x = 0 \iff \ln x = -\frac{1}{2} \iff x_0 = e^{-1/2} = \frac{1}{\sqrt{e}} \approx 0.61$ ។
- មេគុណប្រាប់ទិស ៖

$$f'(e^{-1/2}) = -\frac{4\left(-\frac{1}{2}\right)}{(e^{-1/2})^3} = \frac{2}{e^{-3/2}} = 2e^{3/2} = 2e\sqrt{e} \approx 2(2.72)(1.65) \approx \mathbf{8.9}$$

- សមីការបន្ទាត់ប៉ះ $(T)$ ៖

$$y - 0 = 2e^{3/2}\left(x - e^{-1/2}\right) \iff \boxed{y = 2e^{3/2}x - 2e}$$

**ង. គណនាតម្លៃ សង់ក្រាប និងពិភាក្សាឫស ៖**

- $f\left(\frac{1}{2}\right) = \frac{1+2\ln(1/2)}{(1/2)^2} = 4(1-2\ln 2) \approx 4(1-1.4) = \mathbf{-1.6}$ ។
- $f(2) = \frac{1+2\ln 2}{4} \approx \frac{1+1.4}{4} = \mathbf{0.6}$ ។



- **ពិភាក្សាឫសនៃសមីការ $f(x)=m$ ៖**
  ផ្អែកតាមតារាងអថេរភាព និងក្រាប $(C)$ ៖
  - បើ $m>1$ ៖ សមីការ**គ្មានឫស** ។
  - បើ $m=1$ ៖ សមីការមាន**ឫសឌុប** $x=1$ ។
  - បើ $0<m<1$ ៖ សមីការមាន**ឫសពីរផ្សេងគ្នា** ។
  - បើ $m\leq 0$ ៖ សមីការមាន**ឫសតែមួយគត់** ។

  ដូច្នេះសមីការមានឫសលុះត្រាតែ $\boxed{m\leq 1 \iff m\in(-\infty,1]}$ ។

## លំហាត់ទី ៤២

គេឱ្យអនុគមន៍ $f(x)=-\frac{x}{2}+\ln\left(\frac{x-1}{x}\right)$ ហើយមានក្រាប $(C)$ ក្នុងតម្រុយ $(O,\vec{i},\vec{j})$ ។

ក. រកដែនកំណត់ គណនាលីមីតចុងដែន រួចទាញរកអាស៊ីមតូតឈរនៃក្រាប $(C)$ ។

ខ. គណនាដេរីវេ $f'(x)$ សិក្សាសញ្ញា $f'(x)$ (ដឹងថា $x(x-1)>0$) និងគូសតារាងអថេរភាពនៃ $f$ ។

គ. បង្ហាញថាបន្ទាត់ $L: y=-\frac{x}{2}$ ជាអាស៊ីមតូតទ្រេតនៃ $(C)$ និងសិក្សាទីតាំងធៀប ។

ឃ. សង់អាស៊ីមតូត និងក្រាប $(C)$ រួចកំណត់តម្លៃ $m$ ដើម្បីឱ្យសមីការ $-\frac{x}{2}+\ln\left(\frac{x-1}{x}\right)=m$ មានឫសអវិជ្ជមានពីរផ្សេងគ្នា (យក $\ln 2\approx 0.7$) ។

## ដំណោះស្រាយ

### ក. រកដែនកំណត់ គណនាលីមីតចុងដែន និងទាញរកអាស៊ីមតូតឈរ ៖

- អនុគមន៍មានន័យលុះត្រាតែ $\frac{x-1}{x}>0$ និង $x\neq 0$ ៖
  សញ្ញានៃ $\frac{x-1}{x}$ វិជ្ជមានកាលណា $x\in(-\infty,0)\cup(1,+\infty)$ ។
  ដូច្នេះដែនកំណត់នៃអនុគមន៍គឺ $D=(-\infty,0)\cup(1,+\infty)$ ។
- គណនាលីមីតត្រង់ចុងដែន ៖
  - $\lim\limits_{x\to-\infty} f(x)=\lim\limits_{x\to-\infty}\left[-\frac{x}{2}+\ln\left(\frac{x-1}{x}\right)\right]=-\frac{-\infty}{2}+\ln 1=+\infty+0=+\infty$ ។
  - $\lim\limits_{x\to+\infty} f(x)=\lim\limits_{x\to+\infty}\left[-\frac{x}{2}+\ln\left(\frac{x-1}{x}\right)\right]=-\frac{+\infty}{2}+\ln 1=-\infty+0=-\infty$ ។
  - កាលណា $x\to 0^-$ គេបាន $\frac{x-1}{x}\to\frac{-1}{0^-}=+\infty \Longrightarrow \ln\left(\frac{x-1}{x}\right)\to+\infty$ ៖

    $$\lim_{x\to 0^-} f(x)=0+(+\infty)=+\infty \Longrightarrow \boxed{x=0 \text{ (អ័ក្ស } Oy\text{) ជាអាស៊ីមតូតឈរនៃក្រាប } (C)}$$

  - កាលណា $x\to 1^+$ គេបាន $\frac{x-1}{x}\to\frac{0^+}{1}=0^+ \Longrightarrow \ln\left(\frac{x-1}{x}\right)\to-\infty$ ៖

    $$\lim_{x\to 1^+} f(x)=-\frac{1}{2}+(-\infty)=-\infty \Longrightarrow \boxed{x=1 \text{ ជាអាស៊ីមតូតឈរនៃក្រាប } (C)}$$

**ខ. គណនាដេរីវេ សិក្សាសញ្ញា និងគូសតារាងអថេរភាព ៖**

- សរសេរ $f(x)=-\frac{x}{2}+\ln(x-1)-\ln x$ (ចំពោះ $x>1$ ឬ $x<0$ ដែល $\frac{x-1}{x}>0$) ៖

$$f'(x)=-\frac{1}{2}+\frac{1}{x-1}-\frac{1}{x}=-\frac{1}{2}+\frac{x-(x-1)}{x(x-1)}=-\frac{1}{2}+\frac{1}{x(x-1)}$$

$$f'(x)=\frac{-x(x-1)+2}{2x(x-1)}=\frac{-(x^2-x-2)}{2x(x-1)}=\frac{-(x-2)(x+1)}{2x(x-1)}$$

- ដោយសារ $x(x-1)>0$ ចំពោះគ្រប់ $x\in D$ នោះភាគបែង $2x(x-1)>0$ ជានិច្ច ។ ដូច្នេះសញ្ញានៃ $f'(x)$ អាស្រ័យលើកន្សោមភាគយក $-(x-2)(x+1)=-x^2+x+2$ ៖

$$f'(x)=0 \iff -(x-2)(x+1)=0 \iff x=-1 \quad \text{ឬ} \quad x=2$$

  - ចំពោះ $x\in(-\infty,-1)$ ៖ $f'(x)<0$ (អនុគមន៍ចុះ) ។
  - ចំពោះ $x\in(-1,0)$ ៖ $f'(x)>0$ (អនុគមន៍កើន) ។
  - ចំពោះ $x\in(1,2)$ ៖ $f'(x)>0$ (អនុគមន៍កើន) ។
  - ចំពោះ $x\in(2,+\infty)$ ៖ $f'(x)<0$ (អនុគមន៍ចុះ) ។

- តម្លៃបរមាធៀប ៖
  - អប្បបរមាធៀបត្រង់ $x=-1$ គឺ $f(-1)=-\frac{-1}{2}+\ln\left(\frac{-2}{-1}\right)=\frac{\mathbf{1}}{\mathbf{2}}+\ln\mathbf{2}\approx 0.5+0.7=\mathbf{1.2}$ ។
  - អតិបរមាធៀបត្រង់ $x=2$ គឺ $f(2)=-\frac{2}{2}+\ln\left(\frac{1}{2}\right)=-\mathbf{1}-\ln\mathbf{2}\approx-1-0.7=-\mathbf{1.7}$ ។

| $x$ | $-\infty$ | | $-1$ | | $0$ | | $1$ | | $2$ | | $+\infty$ |
|---|---|---|---|---|---|---|---|---|---|---|---|
| $f'(x)$ | | $-$ | $0$ | $+$ | ‖ | $d$ | $+$ | $0$ | $-$ | | |
| $f(x)$ | $+\infty$ | ↘ | $\frac{1}{2}+\ln 2$ | ↗ | $+\infty$ ‖ $-\infty$ | ↗ | $-1-\ln 2$ | ↘ | $-\infty$ | | |

**គ. បង្ហាញអាស៊ីមតូតទ្រេត និងសិក្សាទីតាំងធៀប ៖**

- គណនាលីមីតនៃផលដក ៖

$$\lim_{x\to\pm\infty}\left[f(x)-\left(-\frac{x}{2}\right)\right]=\lim_{x\to\pm\infty}\ln\left(\frac{x-1}{x}\right)=\lim_{x\to\pm\infty}\ln\left(1-\frac{1}{x}\right)=\ln 1=0$$

ដូច្នេះបន្ទាត់ $(L): y=-\frac{x}{2}$ ជាអាស៊ីមតូតទ្រេតនៃក្រាប $(C)$ ខាង $\pm\infty$ ។

- សិក្សាទីតាំងធៀបរវាង $(C)$ និង $(L)$ ៖

ពិនិត្យសញ្ញានៃ $f(x)-\left(-\frac{x}{2}\right)=\ln\left(1-\frac{1}{x}\right)$ ៖

  - ចំពោះ $x\in(1,+\infty)$ ៖ $\frac{1}{x}>0 \implies 1-\frac{1}{x}<1 \implies \ln\left(1-\frac{1}{x}\right)<0 \implies (C)$ ស្ថិតនៅខាងក្រោមបន្ទាត់ $(L)$ ។

មេរៀនទី ៤ ផ្នែកដំណោះស្រាយ

– ចំពោះ $x\in(-\infty,0)$ ៖ $\frac{1}{x}<0 \Longrightarrow 1-\frac{1}{x}>1 \Longrightarrow \ln\left(1-\frac{1}{x}\right)>0 \Longrightarrow (C)$ ស្ថិតនៅខាងលើបន្ទាត់ $(L)$ ។

**ឃ. សង់អាស៊ីមតូត និងក្រាប $(C)$ រួចកំណត់តម្លៃ $m$ ៖**




- **កំណត់តម្លៃ $m$ ដើម្បីឱ្យសមីការមានឫសអវិជ្ជមានពីរផ្សេងគ្នា ៖**

  សមីការ $-\frac{x}{2}+\ln\left(\frac{x-1}{x}\right)=m$ មានឫសជាអាប់ស៊ីសនៃចំណុចប្រសព្វរវាងក្រាប $(C)$ និងបន្ទាត់ដេក $y=m$ ។
  ដើម្បីឱ្យសមីការមានឫសអវិជ្ជមានពីរផ្សេងគ្នា លុះត្រាតែបន្ទាត់ $y=m$ កាត់ខ្នែងខាងឆ្វេងនៃក្រាប $(C)$ (ត្រង់ចន្លោះ $x<0$) បានពីរចំណុចផ្សេងគ្នា ។
  ផ្អែកតាមតារាងអថេរភាព លើចន្លោះ $(-\infty,0)$ អនុគមន៍ $f(x)$ មានតម្លៃអប្បបរមាត្រង់ $x=-1$ គឺ $f(-1)=\frac{1}{2}+\ln 2\approx 1.2$ ហើយកើនទៅ $+\infty$ ទាំងសងខាង ។
  ដូច្នេះបន្ទាត់ $y=m$ កាត់ក្រាបត្រង់ពីរចំណុចដែលមានអាប់ស៊ីសអវិជ្ជមាន លុះត្រាតែ ៖

$$\boxed{m>\frac{1}{2}+\ln 2\approx 1.2}$$

## លំហាត់ទី ៤៣

ក. អនុគមន៍ $g(x)=2x^2-\ln x+1$ កំណត់ចំពោះ $x>0$ ។ គណនា $g'(x)$ គូសតារាងអថេរភាពនៃ $g$ (ដោយមិនបាច់គណនាលីមីតចុងដែន) រួចទាញរកសញ្ញានៃ $g(x)$ ។

ខ. គេឱ្យអនុគមន៍ $f$ កំណត់ដោយ $f(x)=2x+\frac{\ln x}{x}$ ចំពោះ $x>0$ មានក្រាប $(C)$ តំណាងក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j})$ (ឯកតា $1\text{cm}$) ។

១. គណនាដេរីវេ $f'(x)$ បង្ហាញថា $f'(x)=\frac{g(x)}{x^2}$ រួចទាញរកទិសដៅអថេរភាពនៃ $f(x)$ ។

២. គណនាលីមីតចុងដែនកំណត់ រួចសង់តារាងអថេរភាពនៃ $f(x)$ ។

៣. បង្ហាញថាបន្ទាត់ $(D): y = 2x$ ជាសមីការអាស៊ីមតូតទ្រេតនៃក្រាប $(C)$ ។ សិក្សាទីតាំងធៀបនៃ $(C)$ ធៀបនឹង $(D)$ ។

៤. សរសេរសមីការបន្ទាត់ប៉ះ $(T)$ ដែលស្របនឹងអាស៊ីមតូតទ្រេតនៃ $(C)$ តាងអនុគមន៍ $f$ ។

៥. បង្ហាញថាក្រាប $(C)$ កាត់អ័ក្សអាប់ស៊ីសនៅចន្លោះ $[0.5, 0.6]$ ។ គណនា $f\left(\frac{1}{2}\right)$ និង $f(2)$ រួចសង់ក្រាប $(C)$, បន្ទាត់ $(T)$ និង $(D)$ ក្នុងតម្រុយតែមួយ (គេឱ្យ $\ln 2 = 0.7$ និង $\ln 0.6 = -0.5$) ។

## ដំណោះស្រាយ

**ក. សិក្សាអនុគមន៍ $g(x) = 2x^2 - \ln x + 1$ លើ $(0, +\infty)$ ៖**

- ដេរីវេ ៖ $g'(x) = 4x - \frac{1}{x} = \frac{4x^2 - 1}{x}$ ។
- ដោយ $x > 0$ នោះ ៖

$$g'(x) = 0 \iff 4x^2 - 1 = 0 \iff x^2 = \frac{1}{4} \iff x = \frac{1}{2}$$

  - បើ $0 < x < \frac{1}{2}$ ៖ $g'(x) < 0 \implies g$ ជាអនុគមន៍ចុះ ។
  - បើ $x > \frac{1}{2}$ ៖ $g'(x) > 0 \implies g$ ជាអនុគមន៍កើន ។

- អប្បបរមាដាច់ខាតត្រង់ $x = \frac{1}{2}$ គឺ ៖

$$g\left(\frac{1}{2}\right) = 2\left(\frac{1}{4}\right) - \ln\left(\frac{1}{2}\right) + 1 = \frac{1}{2} + \ln 2 + 1 = \frac{3}{2} + \ln 2 \approx 1.5 + 0.7 = \mathbf{2.2} > 0$$

| $x$ | $0$ | | $\frac{1}{2}$ | | $+\infty$ |
|---|---|---|---|---|---|
| $g'(x)$ | ‖ | $-$ | $0$ | $+$ | |
| $g(x)$ | ‖ | ↘ | $\frac{3}{2} + \ln 2$ | ↗ | |

- ដោយសារតម្លៃអប្បបរមា $g\left(\frac{1}{2}\right) = \frac{3}{2} + \ln 2 > 0$ គេទាញបាន ៖

$$\boxed{g(x) > 0 \quad \text{ចំពោះគ្រប់ } x \in (0, +\infty)}$$

**ខ. សិក្សាអនុគមន៍ $f(x) = 2x + \frac{\ln x}{x}$ ៖**

**១. គណនាដេរីវេ $f'(x)$ និងទិសដៅអថេរភាព ៖**

$$f'(x) = (2x)' + \left(\frac{\ln x}{x}\right)' = 2 + \frac{\frac{1}{x}\cdot x - \ln x(1)}{x^2} = 2 + \frac{1 - \ln x}{x^2} = \boxed{\frac{2x^2 - \ln x + 1}{x^2} = \frac{g(x)}{x^2}}$$

មេរៀនទី ៤ ផ្នែកដំណោះស្រាយ

ដោយសារ $g(x) > 0$ (តាមសំណួរ a) និង $x^2 > 0$ ចំពោះគ្រប់ $x > 0$ នាំឱ្យ ៖

$$f'(x) > 0 \quad \text{ចំពោះគ្រប់ } x \in (0, +\infty)$$

ដូចនេះ $f$ ជាអនុគមន៍កើនដាច់ខាតលើ $(0, +\infty)$ ជានិច្ច ។

២. **គណនាលីមីតចុងដែន និងតារាងអថេរភាព ៖**

- $\lim\limits_{x\to 0^+} f(x) = \lim\limits_{x\to 0^+}\left(2x + \frac{\ln x}{x}\right) = 0 + (-\infty) = \boxed{-\infty}$ (ព្រោះ $\lim\limits_{x\to 0^+}\frac{\ln x}{x} = -\infty$) ។
  នាំឱ្យ បន្ទាត់ $\boxed{x = 0}$ (អ័ក្ស $Oy$) ជាអាស៊ីមតូតឈរនៃ $(C)$ ។
- $\lim\limits_{x\to +\infty} f(x) = \lim\limits_{x\to +\infty}\left(2x + \frac{\ln x}{x}\right) = +\infty + 0 = \boxed{+\infty}$ (ព្រោះ $\lim\limits_{x\to +\infty}\frac{\ln x}{x} = 0$) ។

| $x$ | $0$ | $+\infty$ |
|---|---|---|
| $f'(x)$ | ‖ | $+$ |
| $f(x)$ | ‖ $-\infty$ | ↗ $+\infty$ |

៣. **បង្ហាញអាស៊ីមតូតទ្រេត $(D): y = 2x$ និងសិក្សាទីតាំងធៀប ៖**

- ពិនិត្យផលដក ៖

$$\lim_{x\to +\infty}[f(x) - 2x] = \lim_{x\to +\infty}\frac{\ln x}{x} = 0$$

  ដូចនេះ បន្ទាត់ $\boxed{(D): y = 2x}$ ជាអាស៊ីមតូតទ្រេតនៃ $(C)$ ខាង $+\infty$ ។
- ទីតាំងធៀប ៖ $f(x) - 2x = \frac{\ln x}{x}$ មានសញ្ញាដូច $\ln x$ (ព្រោះ $x > 0$) ៖
  - បើ $0 < x < 1 \implies \ln x < 0 \implies (C)$ ស្ថិតនៅខាងក្រោមបន្ទាត់ $(D)$ ។
  - បើ $x = 1 \implies f(1) = 2 = y_D(1) \implies (C)$ កាត់បន្ទាត់ $(D)$ ត្រង់ចំណុច $(1, 2)$ ។
  - បើ $x > 1 \implies \ln x > 0 \implies (C)$ ស្ថិតនៅខាងលើបន្ទាត់ $(D)$ ។

៤. **សមីការបន្ទាត់ប៉ះ $(T)$ ស្របនឹង $(D): y = 2x$ ៖**
បន្ទាត់ $(T) \parallel (D) \iff f'(x_0) = 2$ ៖

$$2 + \frac{1 - \ln x_0}{x_0^2} = 2 \iff \frac{1 - \ln x_0}{x_0^2} = 0 \iff 1 - \ln x_0 = 0 \iff x_0 = e$$

អរដោនេចំណុចប៉ះ ៖ $y_0 = f(e) = 2e + \frac{\ln e}{e} = 2e + \frac{1}{e} \approx 2(2.7) + 0.37 = 5.77$ ។
សមីការបន្ទាត់ប៉ះ $(T)$ គឺ ៖

$$y - \left(2e + \frac{1}{e}\right) = 2(x - e) \iff \boxed{(T): y = 2x + \frac{1}{e} \approx 2x + 0.37}$$

៥. **បង្ហាញឫសក្នុង $[0.5, 0.6]$ គណនាតម្លៃ និងសង់ក្រាប ៖**

- លើចន្លោះ $[0.5, 0.6]$ អនុគមន៍ $f$ ជាប់ និងកើនដាច់ខាត ៖

$$f(0.5) = 2(0.5) + \frac{\ln(1/2)}{0.5} = 1 - 2\ln 2 \approx 1 - 2(0.7) = \mathbf{-0.4} < \mathbf{0}$$

$$f(0.6) = 2(0.6) + \frac{\ln 0.6}{0.6} = 1.2 + \frac{-0.5}{0.6} \approx 1.2 - 0.83 = +\mathbf{0.37} > \mathbf{0}$$

ដោយសារ $f(0.5) \cdot f(0.6) < 0$ តាមទ្រឹស្តីបទតម្លៃកណ្តាល ខ្សែកោង $(C)$ កាត់អ័ក្សអាប់ស៊ីសត្រង់ចំណុចមួយដែលមានអាប់ស៊ីស $\alpha \in [0.5, 0.6]$ ។

- គណនាតម្លៃ ៖

$$f\left(\frac{1}{2}\right) = \mathbf{-0.4}, \quad f(2) = 2(2) + \frac{\ln 2}{2} = 4 + \frac{0.7}{2} = \boxed{4.35}$$




## លំហាត់ទី ៤៤

គេឱ្យអនុគមន៍ $f$ កំណត់ចំពោះគ្រប់ $x > 0$ ដោយ $y = f(x) = \dfrac{x^2 + \ln x + 1}{x}$ ហើយមានក្រាប $(C)$ ។

ក. គណនា $\lim_{x \to +\infty} f(x)$ និង $\lim_{x \to 0^+} f(x)$ រួចរកសមីការអាស៊ីមតូតឈរនៃក្រាប $(C)$ ។

ខ. គណនា $f'(x)$ រួចបង្ហាញថា $f'(x) > 0$ ចំពោះគ្រប់ $x > 0$ ។ សង់តារាងអថេរភាពនៃអនុគមន៍ $f$ ។

គ. បង្ហាញថាបន្ទាត់ $(d): y = x$ ជាអាស៊ីមតូតទ្រេតនៃ $(C)$ ខាង $+\infty$ ។ គណនា $f(2)$ រួចសង់ខ្សែកោង $(C)$ និងបន្ទាត់ $(d)$ (យក $\ln 2 \approx 0.7$) ។

## ដំណោះស្រាយ

ក. **គណនាលីមីត និងរកអាស៊ីមតូតឈរ ៖**

- សរសេរ ៖ $f(x) = x + \dfrac{\ln x + 1}{x}$ ។

មេរៀនទី ៤ ផ្នែកដំណោះស្រាយ

- លីមីតត្រង់ $0^+$ ៖ $\lim\limits_{x\to 0^+} f(x) = 0 + \lim\limits_{x\to 0^+}\left(\frac{1}{x}\cdot(\ln x+1)\right) = (+\infty)(-\infty) = -\infty$ ៖

  ដូច្នេះ $\boxed{x = 0 \text{ (អ័ក្ស } Oy) \text{ ជាអាស៊ីមតូតឈរ}}$ ។

- លីមីតត្រង់ $+\infty$ ៖ $\lim\limits_{x\to+\infty} \frac{\ln x+1}{x} = 0 \implies \lim\limits_{x\to+\infty} f(x) = +\infty + 0 = +\infty$ ។

## ខ. ដេរីវេ និងតារាងអថេរភាព ៖

- ដេរីវេ ៖

$$f'(x) = \frac{(x^2+\ln x+1)'\cdot x - (x^2+\ln x+1)\cdot 1}{x^2} = \frac{\left(2x+\frac{1}{x}\right)x - x^2 - \ln x - 1}{x^2}$$

$$f'(x) = \frac{2x^2+1-x^2-\ln x-1}{x^2} = \boxed{\frac{x^2-\ln x}{x^2}}$$

- ពិនិត្យកន្សោម $x^2 - \ln x$ លើ $(0,+\infty)$ ៖

  តាង $\phi(x) = x^2 - \ln x \implies \phi'(x) = 2x - \frac{1}{x} = \frac{2x^2-1}{x}$ ។

  $\phi'(x) = 0 \iff x = \frac{1}{\sqrt{2}} \implies \phi_{\min} = \phi\left(\frac{1}{\sqrt{2}}\right) = \frac{1}{2} - \ln\left(\frac{1}{\sqrt{2}}\right) = \frac{1}{2} + \frac{1}{2}\ln 2 > 0$ ។

  ដូច្នេះ $x^2 - \ln x > 0$ ចំពោះគ្រប់ $x > 0$ នាំឱ្យ ៖

$$f'(x) > 0 \quad \text{ចំពោះគ្រប់ } x \in (0,+\infty)$$

  ដូចនេះ $f$ ជាអនុគមន៍**កើនដាច់ខាតលើ** $(0,+\infty)$ ។

| $x$ | $0$ | | $+\infty$ |
|---|---|---|---|
| $f'(x)$ | ‖ | $+$ | |
| $f(x)$ | $-\infty$ ‖ $-\infty$ | $\nearrow$ | $+\infty$ |

## គ. អាស៊ីមតូតទ្រេត $(d)$ និងសង់ក្រាប ៖

- $\lim\limits_{x\to+\infty}[f(x)-x] = \lim\limits_{x\to+\infty}\left(\frac{\ln x+1}{x}\right) = 0 \implies \boxed{(d): y = x \text{ ជាអាស៊ីមតូតទ្រេតខាង } +\infty}$ ។

- គណនា $f(2) = \frac{2^2+\ln 2+1}{2} = \frac{5+0.7}{2} = \mathbf{2.85}$ ។




## លំហាត់ទី ៤៥

គេឱ្យអនុគមន៍ $f$ កំណត់ចំពោះ $x>0$ ដោយ $y=f(x)=1-\dfrac{2\ln x}{x}$ ហើយមានក្រាប $(C)$ ។

ក. រក $\lim\limits_{x\to 0^+} f(x)$ និង $\lim\limits_{x\to +\infty} f(x)$ ។ រកអាស៊ីមតូតឈរ និងអាស៊ីមតូតដេកនៃក្រាប $(C)$ ។

ខ. គណនាដេរីវេ $f'(x)$ ហើយសង់តារាងអថេរភាពនៃអនុគមន៍ $f$ ។

គ. សង់ក្រាប $(C)$ ក្នុងតម្រុយតែមួយ (យក $e\approx 2.7, \dfrac{2}{e}\approx 0.7$) ។

ឃ. គណនាផ្ទៃក្រឡាផ្នែកប្លង់កំណត់ដោយក្រាប $(C)$ អាស៊ីមតូតដេក និងបន្ទាត់ឈរ $x=1, x=e$ ។

## ដំណោះស្រាយ

### ក. រកលីមីត និងកំណត់សមីការអាស៊ីមតូត ៖

- ដែនកំណត់នៃអនុគមន៍គឺ $D=(0,+\infty)$ ។
- លីមីតត្រង់ $0^+$ ៖

$$\lim_{x\to 0^+} f(x)=\lim_{x\to 0^+}\left(1-\frac{2\ln x}{x}\right)=1-2\lim_{x\to 0^+}\left(\frac{1}{x}\cdot\ln x\right)$$

ដោយកាលណា $x\to 0^+$ គេបាន $\dfrac{1}{x}\to +\infty$ និង $\ln x\to -\infty \implies \dfrac{\ln x}{x}\to -\infty$ ៖

$$\lim_{x\to 0^+} f(x)=1-2(-\infty)=+\infty \implies \boxed{x=0 \text{ (អ័ក្ស } Oy\text{) ជាអាស៊ីមតូតឈរនៃក្រាប } (C)}$$

- លីមីតត្រង់ $+\infty$ ៖ តាមរូបមន្តលីមីតគ្រឹះ $\lim\limits_{x\to+\infty}\dfrac{\ln x}{x}=0$ ៖

$$\lim_{x\to+\infty}f(x)=\lim_{x\to+\infty}\left(1-\frac{2\ln x}{x}\right)=1-0=\mathbf{1}\implies \boxed{y=1 \text{ ជាអាស៊ីមតូតដេកខាង } +\infty}$$

## ខ. គណនាដេរីវេ និងសង់តារាងអថេរភាព ៖

- គណនាដេរីវេនៃ $f(x)=1-2\left(\dfrac{\ln x}{x}\right)$ ៖

$$f'(x)=0-2\cdot\frac{(\ln x)'\cdot x-(\ln x)(x)'}{x^2}=-2\cdot\frac{\frac{1}{x}\cdot x-\ln x}{x^2}=\frac{2(\ln x-1)}{x^2}$$

- ដោយសារ $x^2>0$ ចំពោះគ្រប់ $x>0$ នោះសញ្ញានៃ $f'(x)$ អាស្រ័យលើកន្សោម $\ln x-1$ ៖

$$f'(x)=0 \iff \ln x-1=0 \iff \ln x=1 \iff x=e$$

  - បើ $0<x<e$ ៖ $\ln x<1 \implies f'(x)<0$ (អនុគមន៍ចុះដាច់ខាត) ។
  - បើ $x>e$ ៖ $\ln x>1 \implies f'(x)>0$ (អនុគមន៍កើនដាច់ខាត) ។

- អនុគមន៍ $f$ មានតម្លៃអប្បបរមាធៀបត្រង់ $x=e$ គឺ ៖

$$f(e)=1-\frac{2\ln e}{e}=\mathbf{1}-\frac{\mathbf{2}}{\mathbf{e}}\approx 1-0.74=\mathbf{0.26}$$

| $x$ | $0$ | | $e$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | ‖ | $-$ | $0$ | $+$ | |
| $f(x)$ | $+\infty$ ‖ $+\infty$ | ↘ | $1-\dfrac{2}{e}$ | ↗ | $1$ |

## គ. សង់ក្រាប $(C)$ ក្នុងតម្រុយតែមួយ ៖



**ឃ. គណនាផ្ទៃក្រឡាផ្នែកប្លង់ ៖**

ចំពោះ $x \in [1,e]$ ក្រាប $(C)$ ស្ថិតនៅខាងក្រោមអាស៊ីមតូតដេក $y=1$ (ព្រោះ $\ln x \geq 0 \implies 1-\frac{2\ln x}{x} \leq 1$) ៖

$$S=\int_1^e [1-f(x)]\,dx=\int_1^e \frac{2\ln x}{x}\,dx=\left[(\ln x)^2\right]_1^e=(\ln e)^2-(\ln 1)^2=1-0=\mathbf{1}$$

ដូច្នេះ $\boxed{S=1 \text{ ឯកតាក្រឡាផ្ទៃ}}$ ។

## លំហាត់ទី ៤៦

គេឱ្យអនុគមន៍ $f$ កំណត់ចំពោះ $x>0$ ដោយ $f(x)=1+2\left(\frac{\ln x}{x}\right)$ ហើយមានក្រាប $(C)$ ។

ក. គណនា $\lim\limits_{x\to 0^+} f(x)$ និង $\lim\limits_{x\to+\infty} f(x)$ រួចកំណត់សមីការអាស៊ីមតូតឈរ និងដេកនៃ $(C)$ ។

ខ. គណនាដេរីវេ $f'(x)$ សិក្សាសញ្ញា $f'(x)$ និងសង់តារាងអថេរភាពនៃ $f$ ។

គ. កំណត់កូអរដោនេចំណុចប្រសព្វ $A$ រវាងក្រាប $(C)$ និងបន្ទាត់ $D: y=1$ រួចរកសមីការបន្ទាត់ $(L)$ ប៉ះក្រាប $(C)$ ត្រង់ $A$ ។

ឃ. គណនា $f\left(\frac{1}{2}\right)$ សង់បន្ទាត់ $(L)$ អាស៊ីមតូត និងក្រាប $(C)$ ក្នុងតម្រុយតែមួយ (យក $e\approx 2.7, \frac{2}{e}\approx 0.7, \ln 2\approx 0.7$) ។

## ដំណោះស្រាយ

**ក. គណនាលីមីត និងកំណត់សមីការអាស៊ីមតូត ៖**

- ដែនកំណត់នៃអនុគមន៍គឺ $D=(0,+\infty)$ ។
- លីមីតត្រង់ $0^+$ ៖

$$\lim_{x\to 0^+} f(x)=\lim_{x\to 0^+}\left[1+2\left(\frac{\ln x}{x}\right)\right]=1+2(-\infty)=-\infty$$

នាំឱ្យ $\boxed{x=0 \text{ (អ័ក្ស } Oy\text{) ជាអាស៊ីមតូតឈរនៃក្រាប } (C)}$ ។

- លីមីតត្រង់ $+\infty$ ៖ តាមរូបមន្តលីមីតគ្រឹះ $\lim\limits_{x\to+\infty}\frac{\ln x}{x}=0$ ៖

$$\lim_{x\to+\infty} f(x)=\lim_{x\to+\infty}\left[1+2\left(\frac{\ln x}{x}\right)\right]=1+2(0)=\mathbf{1}$$

នាំឱ្យ $\boxed{y=1 \text{ ជាអាស៊ីមតូតដេកខាង } +\infty}$ ។

**ខ. គណនាដេរីវេ សិក្សាសញ្ញា និងសង់តារាងអថេរភាព ៖**

- គណនាដេរីវេនៃ $f(x)=1+2\left(\frac{\ln x}{x}\right)$ ៖

$$f'(x)=0+2\cdot\frac{(\ln x)'\cdot x-(\ln x)(x)'}{x^2}=2\cdot\frac{\frac{1}{x}\cdot x-\ln x}{x^2}=\frac{2(1-\ln x)}{x^2}$$

- ដោយសារ $x^2>0$ ចំពោះគ្រប់ $x>0$ នោះសញ្ញានៃ $f'(x)$ ដូចគ្នានឹងសញ្ញានៃ $1-\ln x$ ៖

$$f'(x)=0 \iff 1-\ln x=0 \iff \ln x=1 \iff x=e$$

  – បើ $0<x<e$ ៖ $1-\ln x>0 \implies f'(x)>0$ (អនុគមន៍កើនដាច់ខាត) ។
  – បើ $x>e$ ៖ $1-\ln x<0 \implies f'(x)<0$ (អនុគមន៍ចុះដាច់ខាត) ។

- អនុគមន៍ $f$ មានតម្លៃអតិបរមាធៀបត្រង់ $x=e$ គឺ ៖

$$f(e)=1+2\left(\frac{\ln e}{e}\right)=\mathbf{1}+\frac{\mathbf{2}}{\mathbf{e}}\approx 1+0.74=\mathbf{1.74}$$

| $x$ | $0$ | | $e$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | ‖ | $+$ | $0$ | $-$ | |
| $f(x)$ | $-\infty$ ‖ $-\infty$ | ↗ | $1+\frac{2}{e}$ | ↘ | $1$ |

## គ. ចំណុចប្រសព្វ $A$ និងសមីការបន្ទាត់ប៉ះ $(L)$ ៖

- សមីការអាប់ស៊ីសចំណុចប្រសព្វរវាង $(C)$ និងបន្ទាត់ $D: y=1$ ៖

$$f(x)=1 \iff 1+\frac{2\ln x}{x}=1 \iff \frac{2\ln x}{x}=0 \iff \ln x=0 \iff x=1$$

ដូច្នេះកូអរដោនេចំណុចប្រសព្វគឺ $\boxed{A(1,1)}$ ។

- មេគុណប្រាប់ទិសនៃបន្ទាត់ប៉ះ $(L)$ ត្រង់ $A(1,1)$ ៖

$$f'(1)=\frac{2(1-\ln 1)}{1^2}=2(1-0)=2$$

- សមីការបន្ទាត់ $(L)$ ប៉ះក្រាប $(C)$ ត្រង់ $A$ ៖

$$y-y_A=f'(x_A)(x-x_A) \iff y-1=2(x-1) \iff \boxed{(L): y=2x-1}$$

## ឃ. គណនា $f\left(\frac{1}{2}\right)$ និងសង់បន្ទាត់ $(L)$ ព្រមទាំងក្រាប $(C)$ ៖

- គណនាតម្លៃ $f\left(\frac{1}{2}\right)$ ៖

$$f\left(\frac{1}{2}\right)=1+2\left(\frac{\ln(1/2)}{1/2}\right)=1+4(-\ln 2)=1-4\ln 2\approx 1-4(0.7)=-\mathbf{1.8}$$




## លំហាត់ទី ៤៧

គេឱ្យអនុគមន៍ $f$ កំណត់ចំពោះ $x>0$ ដោយ $f(x)=2\left(1-\dfrac{\ln x}{x}\right)$ ហើយមានក្រាប $(C)$ ។

ក. គណនា $\lim\limits_{x\to 0^+} f(x)$ និង $\lim\limits_{x\to +\infty} f(x)$ ។ កំណត់សមីការអាស៊ីមតូតឈរ និងអាស៊ីមតូតដេកនៃក្រាប $(C)$ ។

ខ. គណនាដេរីវេ $f'(x)$ សិក្សាសញ្ញា $f'(x)$ និងសង់តារាងអថេរភាពនៃ $f$ ។

គ. កំណត់កូអរដោនេចំណុច $M$ រវាងក្រាប $(C)$ និងអាស៊ីមតូតដេក រួចរកសមីការបន្ទាត់ $(L)$ ប៉ះក្រាប $(C)$ ត្រង់ $M$ ។

ឃ. សង់បន្ទាត់ $(L)$ និងក្រាប $(C)$ ក្នុងតម្រុយតែមួយ (យក $e\approx 2.7, \dfrac{2}{e}\approx 0.7$) ។

ង. កំណត់តម្លៃ $k$ ដើម្បីឱ្យសមីការ $2\left(1-\dfrac{\ln x}{x}\right)=k$ មានឫស និងគណនាផ្ទៃក្រឡាកំណត់ដោយ $(C)$ អ័ក្ស $Ox$ បន្ទាត់ $x=1, x=e$ ។

## ដំណោះស្រាយ

### ក. គណនាលីមីត និងកំណត់សមីការអាស៊ីមតូត ៖

- ដែនកំណត់នៃអនុគមន៍គឺ $D=(0,+\infty)$ ។
- លីមីតត្រង់ $0^+$ ៖

$$\lim_{x\to 0^+} f(x)=\lim_{x\to 0^+} 2\left(1-\frac{\ln x}{x}\right)=2(1-(-\infty))=+\infty$$

នាំឱ្យ $x=0$ (អ័ក្ស $Oy$) ជាអាស៊ីមតូតឈរនៃក្រាប $(C)$ ។

- លីមីតត្រង់ $+\infty$ ៖ តាមរូបមន្តលីមីតគ្រឹះ $\lim\limits_{x\to+\infty}\dfrac{\ln x}{x}=0$ ៖

$$\lim_{x\to +\infty} f(x)=\lim_{x\to +\infty} 2\left(1-\frac{\ln x}{x}\right)=2(1-0)=\mathbf{2}$$

នាំឱ្យ $\boxed{y=2 \text{ ជាអាស៊ីមតូតដេកខាង } +\infty}$ ។

**ខ. គណនាដេរីវេ សិក្សាសញ្ញា និងសង់តារាងអថេរភាព ៖**

- ដេរីវេ ៖

$$f'(x)=2\left(-\frac{\frac{1}{x}\cdot x-\ln x}{x^2}\right)=\frac{2(\ln x-1)}{x^2}$$

- ដោយសារ $x^2>0$ ចំពោះគ្រប់ $x>0$ ៖

$$f'(x)=0 \iff \ln x-1=0 \iff \ln x=1 \iff x=e$$

– បើ $0<x<e$ ៖ $\ln x<1 \implies f'(x)<0$ (អនុគមន៍ចុះ) ។
– បើ $x>e$ ៖ $\ln x>1 \implies f'(x)>0$ (អនុគមន៍កើន) ។

- តម្លៃអប្បបរមាធៀបត្រង់ $x=e$ គឺ ៖

$$f(e)=2\left(1-\frac{\ln e}{e}\right)=\mathbf{2-\frac{2}{e}}\approx 2-0.74=\mathbf{1.26}$$

| $x$ | $0$ | | $e$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | ‖ | $-$ | $0$ | $+$ | |
| $f(x)$ | $+\infty$ ‖ $+\infty$ | ↘ | $2-\frac{2}{e}$ | ↗ | $2$ |

**គ. ចំណុចប្រសព្វ $M$ និងសមីការបន្ទាត់ប៉ះ $(L)$ ៖**

- សមីការអាប់ស៊ីសប្រសព្វនឹងអាស៊ីមតូតដេក $y=2$ ៖

$$f(x)=2 \iff 2\left(1-\frac{\ln x}{x}\right)=2 \iff \ln x=0 \iff x=1 \implies \boxed{M(1,2)}$$

- មេគុណប្រាប់ទិសនៃបន្ទាត់ប៉ះ $(L)$ ត្រង់ $M(1,2)$ ៖

$$f'(1)=\frac{2(\ln 1-1)}{1^2}=-2$$

- សមីការបន្ទាត់ $(L)$ ៖

$$y-2=-2(x-1) \iff \boxed{(L): y=-2x+4}$$

**ឃ. សង់បន្ទាត់ $(L)$ និងក្រាប $(C)$ ក្នុងតម្រុយតែមួយ ៖**




ង. កំណត់តម្លៃ $k$ និងគណនាផ្ទៃក្រឡា ៖

- **កំណត់តម្លៃ $k$ ដើម្បីឱ្យសមីការ $2\left(1-\dfrac{\ln x}{x}\right)=k$ មានឫស ៖**

  ផ្អែកតាមតារាងអថេរភាព តម្លៃនៃអនុគមន៍ $f(x)$ លើ $(0,+\infty)$ គឺ $f(x)\geq 2-\dfrac{2}{e}$ ជានិច្ច ។

  ដូច្នេះសមីការ $f(x)=k$ មានឫសលុះត្រាតែ ៖

  $$\boxed{k\geq 2-\frac{2}{e}\approx 1.26}$$

- **គណនាផ្ទៃក្រឡាកំណត់ដោយ $(C)$ អ័ក្ស $Ox$ បន្ទាត់ $x=1, x=e$ ៖**

  លើចន្លោះ $[1,e]$ គេបាន $f(x)\geq 2-\dfrac{2}{e}>0$ នាំឱ្យក្រាបស្ថិតនៅខាងលើអ័ក្ស $Ox$ ៖

  $$S=\int_1^e 2\left(1-\frac{\ln x}{x}\right)dx=2\int_1^e\left(1-\frac{\ln x}{x}\right)dx=2\left[x-\frac{1}{2}(\ln x)^2\right]_1^e$$

  $$S=2\left(\left(e-\frac{1}{2}\right)-(1-0)\right)=2\left(e-\frac{3}{2}\right)=\mathbf{2e-3}$$

  ជំនួស $e\approx 2.718$ គេបាន $\boxed{S=2e-3\approx 2.44 \text{ ឯកតាក្រឡាផ្ទៃ}}$ ។

## លំហាត់ទី ៤៨

គេឱ្យអនុគមន៍ $y=f(x)=\dfrac{e^x-1}{e^x+1}$ មានក្រាប $(C)$ ។

ក. គណនាលីមីតចុងដែនកំណត់ និងរកសមីការអាស៊ីមតូតនៃក្រាប $(C)$ ។

ខ. រកដេរីវេ សិក្សាសញ្ញា $f'(x)$ និងបរមាធៀបនៃ $f$ ។

គ. បង្ហាញថា $f$ ជាអនុគមន៍សេស និងបញ្ជាក់ផ្ចិតឆ្លុះនៃក្រាប $(C)$ ។

ឃ. គូសតារាងអថេរភាពនៃ $f$ រួចរកសមីការបន្ទាត់ប៉ះ $(T)$ ប៉ះក្រាប $(C)$ ត្រង់ផ្ចិតឆ្លុះនោះ ។

ង. សង់ក្រាប $(C)$ (យក $e \approx 2.7, e^{-1} \approx 0.36$) ។

## ដំណោះស្រាយ

### ក. ដែនកំណត់ លីមីត និងអាស៊ីមតូត ៖

- ដោយសារ $e^x + 1 > 0$ ចំពោះគ្រប់ $x \in \mathbb{R}$ នោះដែនកំណត់គឺ $D = \mathbb{R}$ ។
- កាលណា $x \to -\infty$ គេបាន $e^x \to 0$ ៖

$$\lim_{x\to-\infty} f(x) = \frac{0-1}{0+1} = -\mathbf{1} \implies \boxed{y = -1 \text{ ជាអាស៊ីមតូតដេកខាង } -\infty}$$

- កាលណា $x \to +\infty$ គេបាន $\frac{e^x-1}{e^x+1} = \frac{1-e^{-x}}{1+e^{-x}} \to \frac{1-0}{1+0} = 1$ ៖

$$\lim_{x\to+\infty} f(x) = \mathbf{1} \implies \boxed{y = 1 \text{ ជាអាស៊ីមតូតដេកខាង } +\infty}$$

### ខ. ដេរីវេ និងបរមាធៀប ៖

- ដេរីវេ ៖

$$f'(x) = \frac{(e^x-1)'(e^x+1)-(e^x-1)(e^x+1)'}{(e^x+1)^2} = \frac{e^x(e^x+1)-e^x(e^x-1)}{(e^x+1)^2} = \boxed{\frac{2e^x}{(e^x+1)^2}}$$

- ដោយ $e^x > 0$ និង $(e^x+1)^2 > 0$ ចំពោះគ្រប់ $x \in \mathbb{R}$ គេបាន ៖

$$f'(x) > 0 \quad \text{ចំពោះគ្រប់ } x \in \mathbb{R}$$

ដូច្នេះ $f$ ជាអនុគមន៍**កើនដាច់ខាតលើ** $\mathbb{R}$ ហើយ**គ្មានតម្លៃបរមាធៀប**ឡើយ ។

### គ. អនុគមន៍សេស និងផ្ចិតឆ្លុះ ៖

- ចំពោះគ្រប់ $x \in \mathbb{R} \implies -x \in \mathbb{R}$ ៖

$$f(-x) = \frac{e^{-x}-1}{e^{-x}+1} = \frac{\frac{1}{e^x}-1}{\frac{1}{e^x}+1} = \frac{\frac{1-e^x}{e^x}}{\frac{1+e^x}{e^x}} = \frac{1-e^x}{1+e^x} = -\frac{e^x-1}{e^x+1} = -f(x)$$

ដូច្នេះ $f$ **ជាអនុគមន៍សេស** នាំឱ្យគល់កូអរដោនេ $\boxed{O(0,0) \text{ ជាផ្ចិតឆ្លុះ}}$ នៃក្រាប $(C)$ ។

### ឃ. តារាងអថេរភាព និងបន្ទាត់ប៉ះត្រង់ $O(0,0)$ ៖

| $x$ | $-\infty$ | $0$ | $+\infty$ |
|---|---|---|---|
| $f'(x)$ | | $+$ | |
| $f(x)$ | $-1$ | $0$ | $1$ |

- មេគុណប្រាប់ទិសត្រង់ $O(0,0)$ ៖ $f'(0)=\dfrac{2e^0}{(e^0+1)^2}=\dfrac{2(1)}{(1+1)^2}=\dfrac{2}{4}=\dfrac{1}{2}$ ។
- សមីការបន្ទាត់ប៉ះ $(T)$ ត្រង់ $O(0,0)$ ៖

$$y-0=\frac{1}{2}(x-0)\iff \boxed{y=\frac{1}{2}x}$$

ង. **សង់ក្រាប $(C)$ អាស៊ីមតូត និងបន្ទាត់ប៉ះ $(T)$ ៖**




## លំហាត់ទី ៤៩

គេឱ្យអនុគមន៍ $y=f(x)=\dfrac{e^x+1}{e^x-1}$ មានក្រាប $(C)$ ។

ក. រកដែនកំណត់ គណនាលីមីតចុងដែនកំណត់ និងសមីការអាស៊ីមតូតនៃ $(C)$ ។

ខ. រកដេរីវេ សិក្សាសញ្ញា $f'(x)$ និងបរមាធៀបនៃ $f$ ។

គ. បង្ហាញថា $f$ ជាអនុគមន៍សេស និងបញ្ជាក់ផ្ចិតឆ្លុះ ។

ឃ. បន្ទាត់ $(T): y=3$ កាត់ខ្សែកោង $(C)$ ត្រង់ $M$ ។ គណនាកូអរដោនេនៃ $M$ និងសមីការបន្ទាត់ប៉ះខ្សែកោង $(C)$ ត្រង់ចំណុច $M$ ។

ង. គូសតារាងអថេរភាពនៃ $f$ និងសង់ក្រាប $(C)$ (យក $e\approx 2.7, e^{-1}\approx 0.36$) ។

## ដំណោះស្រាយ

ក. **ដែនកំណត់ លីមីត និងអាស៊ីមតូត ៖**

- អនុគមន៍មានន័យកាលណា $e^x-1\neq 0\iff e^x\neq 1\iff x\neq 0$ ៖
  ដែនកំណត់គឺ $\boxed{D=\mathbb{R}\setminus\{0\}=(-\infty,0)\cup(0,+\infty)}$ ។
- លីមីតត្រង់ $\pm\infty$ ៖

- $\lim\limits_{x\to-\infty} f(x)=\dfrac{0+1}{0-1}=-\mathbf{1} \implies$ $\boxed{y=-1 \text{ ជាអាស៊ីមតូតដេកខាង } -\infty}$ ។
- $\lim\limits_{x\to+\infty} f(x)=\lim\limits_{x\to+\infty}\dfrac{1+e^{-x}}{1-e^{-x}}=\dfrac{1+0}{1-0}=\mathbf{1} \implies$ $\boxed{y=1 \text{ ជាអាស៊ីមតូតដេកខាង } +\infty}$ ។

- លីមីតត្រង់ $0$ ៖
  - $\lim\limits_{x\to0^-} f(x)=\dfrac{2}{0^-}=-\infty$ និង $\lim\limits_{x\to0^+} f(x)=\dfrac{2}{0^+}=+\infty$ ៖

  ដូច្នេះ $\boxed{x=0 \text{ (អ័ក្ស } Oy) \text{ ជាអាស៊ីមតូតឈរ}}$ ។

**ខ. ដេរីវេ និងបរមាធៀប ៖**

- ដេរីវេ ៖

$$f'(x)=\frac{(e^x+1)'(e^x-1)-(e^x+1)(e^x-1)'}{(e^x-1)^2}=\frac{e^x(e^x-1)-e^x(e^x+1)}{(e^x-1)^2}=\boxed{-\frac{2e^x}{(e^x-1)^2}}$$

- ដោយ $e^x>0$ និង $(e^x-1)^2>0$ ចំពោះគ្រប់ $x\neq0$ គេបាន ៖

$$f'(x)<0 \quad \text{ចំពោះគ្រប់ } x\in(-\infty,0)\cup(0,+\infty)$$

ដូចនេះ $f$ ជាអនុគមន៍ចុះដាច់ខាតលើ $(-\infty,0)$ និងលើ $(0,+\infty)$ ហើយគ្មានតម្លៃបរមាធៀបឡើយ ។

**គ. អនុគមន៍សេស និងផ្ចិតឆ្លុះ ៖**

- ចំពោះគ្រប់ $x\neq0 \implies -x\neq0$ ៖

$$f(-x)=\frac{e^{-x}+1}{e^{-x}-1}=\frac{\frac{1}{e^x}+1}{\frac{1}{e^x}-1}=\frac{1+e^x}{1-e^x}=-\frac{e^x+1}{e^x-1}=-f(x)$$

ដូច្នេះ $f$ ជា**អនុគមន៍សេស** នាំឱ្យគល់កូអរដោនេ $\boxed{O(0,0) \text{ ជាផ្ចិតឆ្លុះ}}$ នៃក្រាប $(C)$ ។

**ឃ. ចំណុច $M$ និងសមីការបន្ទាត់ប៉ះត្រង់ $M$ ៖**

- រក $M$ ៖ $f(x)=3 \iff \dfrac{e^x+1}{e^x-1}=3 \iff e^x+1=3e^x-3 \iff 2e^x=4 \iff e^x=2 \iff x=\ln2$ ៖

  ដូច្នេះកូអរដោនេចំណុច $M$ គឺ $\boxed{M(\ln2,3)}$ ។
- មេគុណប្រាប់ទិស ៖

$$f'(\ln2)=-\frac{2e^{\ln2}}{(e^{\ln2}-1)^2}=-\frac{2(2)}{(2-1)^2}=-4$$

- សមីការបន្ទាត់ប៉ះត្រង់ $M(\ln2,3)$ ៖

$$y-3=-4(x-\ln2) \iff \boxed{y=-4x+4\ln2+3}$$

(តម្លៃប្រហែល ៖ $y\approx-4x+5.77$) ។

**ង. តារាងអថេរភាព និងសង់ក្រាប $(C)$ ៖**

| $x$ | $-\infty$ | | $0$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | | $-$ | ‖ | $-$ | |
| $f(x)$ | $-1$ | $\longrightarrow$ | $-\infty$ ‖ $+\infty$ | $\searrow$ | $1$ |




## លំហាត់ទី ៥០

គេឱ្យអនុគមន៍ $f$ ដែល $y = f(x) = x^2 e^{-x}$ មានក្រាប $(C)$ ។

ក. រកដែនកំណត់នៃ $f$ ។

ខ. គណនាលីមីតចុងដែនកំណត់ និងរកសមីការអាស៊ីមតូត ។

គ. បង្ហាញថាសមីការបន្ទាត់ $(L)$ ប៉ះខ្សែកោង $(C)$ ត្រង់អាប់ស៊ីស $x = 2$ ស្របនឹងអ័ក្សអាប់ស៊ីស ។

ឃ. រកដេរីវេ សិក្សាសញ្ញា $f'(x)$ និងបរមាធៀបនៃ $f$ ។

ង. គូសតារាងអថេរភាព និងសង់ក្រាប $(C)$ ។

## ដំណោះស្រាយ

ក. **ដែនកំណត់ ៖** $\boxed{D = \mathbb{R}}$ ។

ខ. **គណនាលីមីត និងរកអាស៊ីមតូត ៖**

- $\lim\limits_{x\to-\infty} f(x) = \lim\limits_{x\to-\infty} x^2 e^{-x} = (+\infty)(+\infty) = +\infty$ ។

- $\lim_{x\to+\infty} f(x) = \lim_{x\to+\infty} \frac{x^2}{e^x} = \mathbf{0}$ (តាមលីមីតគ្រឹះ $\lim_{x\to+\infty} \frac{x^n}{e^x} = 0$) ៖
  ដូច្នេះ $\boxed{y = 0 \text{ (អ័ក្ស } Ox) \text{ ជាអាស៊ីមតូតដេកខាង } +\infty}$ ។

**គ. បន្ទាត់ប៉ះ $(L)$ ត្រង់ $x = 2$ ៖**

- ដេរីវេ ៖ $f'(x) = 2xe^{-x} - x^2e^{-x} = x(2-x)e^{-x}$ ។
- ត្រង់ $x = 2$ ៖ $f'(2) = 2(2-2)e^{-2} = \mathbf{0}$ ។
- សមីការបន្ទាត់ប៉ះ $(L)$ គឺ ៖

$$y - f(2) = 0(x-2) \iff \boxed{y = 4e^{-2} = \frac{4}{e^2} \approx 0.54}$$

បន្ទាត់នេះមានទម្រង់ $y =$ ថេរ ដូច្នេះវាស្របនឹងអ័ក្សអាប់ស៊ីស $(Ox)$ ។

**ឃ. ដេរីវេ សញ្ញា និងបរមាធៀប ៖**

- ដោយ $e^{-x} > 0$ ចំពោះគ្រប់ $x \in \mathbb{R}$ នោះសញ្ញា $f'(x)$ ដូចសញ្ញា $x(2-x)$ ៖

$$f'(x) = 0 \iff x = 0 \quad \text{ឬ} \quad x = 2$$

  – បើ $x < 0$ ឬ $x > 2$ ៖ $f'(x) < 0$ (អនុគមន៍ចុះ) ។
  – បើ $0 < x < 2$ ៖ $f'(x) > 0$ (អនុគមន៍កើន) ។
- តម្លៃបរមាធៀប ៖
  – អប្បបរមាធៀបត្រង់ $x = 0$ គឺ $f(0) = 0^2e^0 = \mathbf{0}$ ។
  – អតិបរមាធៀបត្រង់ $x = 2$ គឺ $f(2) = \mathbf{\frac{4}{e^2}} \approx \mathbf{0.54}$ ។

**ង. តារាងអថេរភាព និងសង់ក្រាប $(C)$ ៖**

| $x$ | $-\infty$ | | 0 | | 2 | | $+\infty$ |
|---|---|---|---|---|---|---|---|
| $f'(x)$ | | $-$ | 0 | $+$ | 0 | $-$ | |
| $f(x)$ | $+\infty$ | ↘ | 0 | ↗ | $\frac{4}{e^2}$ | ↘ | 0 |



## លំហាត់ទី ៥១

គេឱ្យអនុគមន៍ $f$ កំណត់ដោយ $y = f(x) = x - 2 + e^{1-x}$ តាងដោយក្រាប $(C)$ ។

ក. រកដែនកំណត់ $D$ គណនាលីមីតចុងដែនកំណត់ រួចបញ្ជាក់សមីការអាស៊ីមតូត ។

ខ. រកដេរីវេ សិក្សាសញ្ញា $f'(x)$ និងបរមាធៀបនៃ $f$ ។

គ. សិក្សាទីតាំងធៀបរវាងខ្សែកោង $(C)$ ជាមួយបន្ទាត់ $(L)$ កាត់តាមគល់តម្រុយ ហើយស្របនឹងអាស៊ីមតូតទ្រេត ។

ឃ. គូសតារាងអថេរភាព និងសង់ក្រាប $(C)$ ។

## ដំណោះស្រាយ

### ក. ដែនកំណត់ លីមីត និងអាស៊ីមតូត ៖

- ដែនកំណត់ ៖ $\boxed{D = \mathbb{R}}$ ។
- $\lim_{x\to-\infty} f(x) = -\infty - 2 + e^{+\infty} = +\infty$ (ព្រោះ $e^{1-x} \to +\infty$) ។
- $\lim_{x\to+\infty} f(x) = +\infty - 2 + e^{-\infty} = +\infty + 0 = +\infty$ ។
- ពិនិត្យ $\lim_{x\to+\infty} [f(x) - (x-2)] = \lim_{x\to+\infty} e^{1-x} = 0$ ៖

  ដូច្នេះបន្ទាត់ $\boxed{(\Delta): y = x - 2 \text{ ជាអាស៊ីមតូតទ្រេតខាង } +\infty}$ ។

### ខ. ដេរីវេ សញ្ញា និងបរមាធៀប ៖

- $f'(x) = 1 - e^{1-x}$ ។
- $f'(x) = 0 \iff e^{1-x} = 1 \iff 1 - x = 0 \iff x = 1$ ។
  - បើ $x < 1$ ៖ $1 - x > 0 \implies e^{1-x} > 1 \implies f'(x) < 0$ (អនុគមន៍ចុះ) ។
  - បើ $x > 1$ ៖ $1 - x < 0 \implies e^{1-x} < 1 \implies f'(x) > 0$ (អនុគមន៍កើន) ។
- អប្បបរមាធៀបត្រង់ $x = 1$ គឺ ៖

$$f(1) = 1 - 2 + e^{1-1} = -1 + 1 = \mathbf{0}$$

### គ. ទីតាំងធៀបរវាង $(C)$ និងបន្ទាត់ $(L)$ ៖

- បន្ទាត់ $(L)$ កាត់តាមគល់ $O(0,0)$ និងស្របនឹងអាស៊ីមតូតទ្រេត $y = x - 2$ (មេគុណប្រាប់ទិស $m = 1$) មានសមីការគឺ $\boxed{(L): y = x}$ ។
- ពិនិត្យផលដក $f(x) - x = -2 + e^{1-x}$ ៖

$$f(x) - x = 0 \iff e^{1-x} = 2 \iff 1 - x = \ln 2 \iff x = 1 - \ln 2 \approx 1 - 0.7 = \mathbf{0.3}$$

  - បើ $x < 1 - \ln 2$ ៖ $e^{1-x} > 2 \implies f(x) - x > 0 \implies (C)$ ស្ថិតនៅ**ខាងលើ** $(L)$ ។
  - បើ $x = 1 - \ln 2$ ៖ $(C)$ **កាត់** $(L)$ ត្រង់ចំណុច $(1 - \ln 2, 1 - \ln 2)$ ។
  - បើ $x > 1 - \ln 2$ ៖ $e^{1-x} < 2 \implies f(x) - x < 0 \implies (C)$ ស្ថិតនៅ**ខាងក្រោម** $(L)$ ។

### ឃ. តារាងអថេរភាព និងសង់ក្រាប $(C)$ ៖

| $x$ | $-\infty$ | | $1$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | | $-$ | $0$ | $+$ | |
| $f(x)$ | $+\infty$ | $\searrow$ | $0$ | $\nearrow$ | $+\infty$ |




## លំហាត់ទី ៥២

គេឱ្យអនុគមន៍ $f$ កំណត់លើ $\mathbb{R}$ ដោយ $f(x)=x+2-\dfrac{4e^x}{1+e^x}$ មានក្រាប $(C)$ ក្នុងតម្រុយ $(O,\vec{i},\vec{j})$ ។

ក. គណនាលីមីត $f(x)$ កាលណា $x\to-\infty$ និង $x\to+\infty$ ។

ខ. បង្ហាញថាបន្ទាត់ $(d_1): y=x+2$ ជាអាស៊ីមតូតទ្រេតនៃ $(C)$ កាលណា $x\to-\infty$ រួចសិក្សាទីតាំងធៀប ។

គ. ផ្ទៀងផ្ទាត់ថាចំពោះគ្រប់ចំនួនពិត $x$ គេបាន $f(x)=x-2+\dfrac{4}{1+e^x}$ ។

ឃ. បង្ហាញថាបន្ទាត់ $(d_2): y=x-2$ ជាអាស៊ីមតូតទ្រេតនៃ $(C)$ កាលណា $x\to+\infty$ រួចសិក្សាទីតាំងធៀប ។

ង. សិក្សាអថេរភាពនៃ $f$ លើ $\mathbb{R}$ ។ សរសេរសមីការបន្ទាត់ $(L)$ ប៉ះក្រាប $(C)$ ត្រង់ចំណុចមានអាប់ស៊ីស $x=0$ ។

ច. សង់ក្រាប $(C)$ បន្ទាត់ $(d_1),(d_2)$ និង $(L)$ ។

## ដំណោះស្រាយ

ក. **គណនាលីមីត ៖**

- $\lim\limits_{x\to-\infty} f(x)=-\infty+2-0=-\infty$ (ព្រោះ $e^x\to 0$) ។
- $\lim\limits_{x\to+\infty} f(x)=+\infty+2-4=+\infty$ (ព្រោះ $\dfrac{4e^x}{1+e^x}\to 4$) ។

ខ. **អាស៊ីមតូតទ្រេត $(d_1)$ ខាង $-\infty$ និងទីតាំងធៀប ៖**

- $\lim\limits_{x\to-\infty}[f(x)-(x+2)] = \lim\limits_{x\to-\infty}\left(-\frac{4e^x}{1+e^x}\right) = 0 \Longrightarrow$ $\boxed{(d_1): y = x+2 \text{ ជាអាស៊ីមតូតទ្រេតខាង } -\infty}$ ។
- ដោយសារ $-\dfrac{4e^x}{1+e^x} < 0$ ចំពោះគ្រប់ $x\in\mathbb{R}$ នោះក្រាប $(C)$ ស្ថិតនៅ**ខាងក្រោម**បន្ទាត់ $(d_1)$ ជានិច្ច ។

**គ. ផ្ទៀងផ្ទាត់កន្សោមនៃ $f(x)$ ៖**

$$f(x) = x+2-\frac{4e^x}{1+e^x} = x+2-\frac{4(e^x+1-1)}{1+e^x} = x+2-4+\frac{4}{1+e^x} = \boxed{x-2+\frac{4}{1+e^x}}$$

**ឃ. អាស៊ីមតូតទ្រេត $(d_2)$ ខាង $+\infty$ និងទីតាំងធៀប ៖**

- $\lim\limits_{x\to+\infty}[f(x)-(x-2)] = \lim\limits_{x\to+\infty}\frac{4}{1+e^x} = 0 \Longrightarrow$ $\boxed{(d_2): y = x-2 \text{ ជាអាស៊ីមតូតទ្រេតខាង } +\infty}$ ។
- ដោយសារ $\dfrac{4}{1+e^x} > 0$ ចំពោះគ្រប់ $x\in\mathbb{R}$ នោះក្រាប $(C)$ ស្ថិតនៅ**ខាងលើ**បន្ទាត់ $(d_2)$ ជានិច្ច ។

**ង. អថេរភាព និងសមីការបន្ទាត់ប៉ះ $(L)$ ត្រង់ $x=0$ ៖**

- ដេរីវេ ៖

$$f'(x) = 1-\frac{4e^x(1+e^x)-4e^{2x}}{(1+e^x)^2} = 1-\frac{4e^x}{(1+e^x)^2} = \frac{(1+e^x)^2-4e^x}{(1+e^x)^2} = \boxed{\frac{(e^x-1)^2}{(e^x+1)^2}}$$

- ដោយសារ $(e^x-1)^2 \geq 0$ និង $(e^x+1)^2 > 0$ នោះ $f'(x) \geq 0$ ចំពោះគ្រប់ $x\in\mathbb{R}$ (ស្មើ $0 \iff x=0$) ។
ដូច្នេះ $f$ ជាអនុគមន៍**កើនដាច់ខាតលើ** $\mathbb{R}$ ។
- ត្រង់ $x=0$ ៖ $f(0) = 0+2-\dfrac{4(1)}{1+1} = 2-2 = \mathbf{0}$ និង $f'(0) = 0$ ។
សមីការបន្ទាត់ប៉ះ $(L)$ គឺ ៖

$$y-0 = 0(x-0) \iff \boxed{y = 0 \text{ (អ័ក្សអាប់ស៊ីស } Ox)}$$

| $x$ | $-\infty$ | | $0$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | | $+$ | $0$ | $+$ | |
| $f(x)$ | $-\infty$ | $\nearrow$ | $0$ | $\nearrow$ | $+\infty$ |

**ច. សង់ក្រាប $(C)$ បន្ទាត់ $(d_1),(d_2)$ និង $(L)$ ៖**

មេរៀនទី ៤ ផ្នែកដំណោះស្រាយ




## លំហាត់ទី ៥៣

គេឱ្យអនុគមន៍ $f$ កំណត់ចំពោះគ្រប់ចំនួនពិត $x$ ដោយ $f(x)=x-\frac{e^x-1}{e^x+1}$ មានក្រាបក្នុងតម្រុយ $(O,\vec{i},\vec{j})$ ។

ក. ១. ផ្ទៀងផ្ទាត់ថា $f(x)=x-1+\frac{2}{1+e^x}=x+1-\frac{2e^x}{1+e^x}$ ។

២. គណនាលីមីត $\lim\limits_{x\to-\infty} f(x)$ និង $\lim\limits_{x\to+\infty} f(x)$ ។

៣. បង្ហាញថាបន្ទាត់ $(d_1): y=x+1$ និង $(d_2): y=x-1$ ជាអាស៊ីមតូតទ្រេតនៃក្រាប $(C)$ ។

៤. សិក្សាទីតាំងធៀបរវាង $(C)$ និងបន្ទាត់ $(d_1),(d_2)$ ។

ខ. បង្ហាញថា $f$ ជាអនុគមន៍សេស និងសិក្សាអថេរភាពនៃ $f$ ។

គ. សរសេរសមីការបន្ទាត់ $(L)$ ប៉ះក្រាបត្រង់ចំណុចមានអាប់ស៊ីស $x=0$ រួចសង់ក្រាប $(C),(d_1),(d_2),(L)$ ក្នុងតម្រុយតែមួយ ។

## ដំណោះស្រាយ

ក. ១. **ផ្ទៀងផ្ទាត់កន្សោម ៖**

$$f(x)=x-\frac{(e^x+1)-2}{e^x+1}=x-1+\frac{2}{1+e^x}$$

$$f(x)=x-\frac{2e^x-(e^x+1)}{e^x+1}=x-\frac{2e^x}{e^x+1}+1=x+1-\frac{2e^x}{1+e^x}$$

សមភាពទាំងពីរត្រូវបានផ្ទៀងផ្ទាត់រួចរាល់ ។

២. **គណនាលីមីត ៖**

- $\lim\limits_{x\to-\infty} f(x)=\lim\limits_{x\to-\infty}\left(x+1-\frac{2e^x}{1+e^x}\right)=-\infty+1-0=-\infty$ ។

- $\lim\limits_{x\to+\infty} f(x) = \lim\limits_{x\to+\infty}\left(x-1+\frac{2}{1+e^x}\right) = +\infty - 1 + 0 = +\infty$ ។

ⓒ. អាស៊ីមតូតទ្រេត ៖

- $\lim\limits_{x\to-\infty}[f(x)-(x+1)] = \lim\limits_{x\to-\infty}\left(-\frac{2e^x}{1+e^x}\right) = 0 \implies \boxed{(d_1): y = x+1 \text{ ខាង } -\infty}$ ។
- ដេរីវេនៃ $h(x)$ ៖ ចំពោះគ្រប់ $x > 0$ ៖

$$h'(x) = -1-\frac{2}{x} = \frac{-x-2}{x} < 0 \quad (\text{ព្រោះ } x>0 \implies -x-2<0)$$

ដូចនេះ អនុគមន៍ $h$ ចុះដាច់ខាតលើ $I = (0, +\infty)$ ។

- ទាញរកសញ្ញានៃ $h(x)$ ៖
  - បើ $0 < x < 1 \implies h(x) > h(1) = 0$ (វិជ្ជមាន) ។
  - បើ $x > 1 \implies h(x) < h(1) = 0$ (អវិជ្ជមាន) ។

### B. សិក្សាអនុគមន៍ $f(x)$ និងសង់ក្រាប ៖

**ក. គណនាលីមីត ៖**

- ត្រង់ $x \to 0^+$ ៖ $\lim\limits_{x\to 0^+}(x+\ln x) = -\infty$ និង $\lim\limits_{x\to 0^+} x^2 = 0^+$ នាំឱ្យ $\boxed{\lim\limits_{x\to 0^+} f(x) = -\infty} \implies \boxed{x=0}$ ជាអាស៊ីមតូតឈរ ។
- ត្រង់ $x \to +\infty$ ៖ $f(x) = \frac{1}{x} + \frac{\ln x}{x^2} \implies \boxed{\lim\limits_{x\to+\infty} f(x) = 0+0 = 0} \implies \boxed{y=0}$ ជាអាស៊ីមតូតដេក ។

**ខ. គណនាដេរីវេ $f'(x)$ ៖ ចំពោះគ្រប់ $x > 0$ ៖**

$$f'(x) = \frac{\left(1+\frac{1}{x}\right)x^2 - (x+\ln x)(2x)}{x^4} = \frac{x^2+x-2x^2-2x\ln x}{x^4} = \frac{x(-x+1-2\ln x)}{x^4} = \boxed{\frac{h(x)}{x^3}}$$

**គ. សញ្ញានៃ $f'(x)$ ៖**

ដោយសារ $x^3 > 0$ ចំពោះគ្រប់ $x \in I$ នាំឱ្យសញ្ញានៃ $f'(x)$ ដូចសញ្ញានៃ $h(x)$ ទាំងស្រុង ៖

- $f'(x) > 0 \iff 0 < x < 1$ (អនុគមន៍ $f$ កើន) ។
- $f'(1) = 0$ ត្រង់ $x = 1$ ។
- $f'(x) < 0 \iff x > 1$ (អនុគមន៍ $f$ ចុះ) ។

ឃ. **តារាងអថេរភាព និងសង់ក្រាប $(C)$ ៖**
តម្លៃអតិបរមាធៀបត្រង់ $x = 1$ គឺ $f(1) = \frac{1+\ln 1}{1^2} = 1$ ។

| $x$ | $0$ | | $1$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | ‖ | $+$ | $0$ | $-$ | |
| $f(x)$ | ‖ $-\infty$ | ↗ | $1$ | ↘ | $0$ |




## លំហាត់ទី ៧០

**A**. គេមានអនុគមន៍ $g$ កំណត់លើ $(0,+\infty)$ ដោយ $g(x) = x^2 + \ln x$ ។

ក. បង្ហាញថា $g$ ជាអនុគមន៍កើនដាច់ខាតលើ $(0,+\infty)$ និងគណនា $g(1)$ ។

ខ. ទាញបញ្ជាក់ថា បើ $x \geq 1$ នោះ $x^2 + \ln x \geq 1$ ហើយបើ $0 < x \leq 1$ នោះ $x^2 + \ln x \leq 1$ ។

គ. កំណត់សញ្ញានៃកន្សោម $x^2 + \ln x - 1$ ចំពោះ $x \in (0,+\infty)$ ។

**B**. គេមានអនុគមន៍ $f$ កំណត់លើ $(0,+\infty)$ ដោយ $f(x) = x + 1 - \dfrac{\ln x}{x}$ ហើយមានក្រាប $(C)$ ក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j})$ ។

ក. សិក្សាលីមីតនៃអនុគមន៍ $f$ ត្រង់ $0$ និង $+\infty$ (ដោយដឹងថា $\lim\limits_{x\to+\infty} \frac{\ln x}{x} = 0$) ។

ខ. បង្ហាញថាដេរីវេនៃអនុគមន៍ $f$ គឺ $f'(x) = \dfrac{x^2 + \ln x - 1}{x^2}$ ។

គ. ប្រើលទ្ធផលផ្នែក $A$ សិក្សាសញ្ញានៃ $f'(x)$ និងសង់តារាងអថេរភាពនៃ $f$ លើ $(0,+\infty)$ ។

ឃ. បង្ហាញថាបន្ទាត់ $(\Delta): y = x + 1$ ជាអាស៊ីមតូតទ្រេតនៃ $(C)$ ត្រង់ $+\infty$ ។ សិក្សាទីតាំងធៀប និងបញ្ជាក់កូអរដោនេចំណុចប្រសព្វ $I$ រវាង $(C)$ និង $(\Delta)$ រួចសង់ $(\Delta)$ និង $(C)$ ។

## ដំណោះស្រាយ

**A**. សិក្សាអនុគមន៍ $g(x)$ ៖

ក. ដេរីវេ ៖ ចំពោះគ្រប់ $x>0$ ៖

$$g'(x) = 2x + \frac{1}{x} = \frac{2x^2+1}{x} > 0 \quad (\text{ព្រោះ } x>0)$$

ដូចនេះ $g$ ជាអនុគមន៍កើនដាច់ខាតលើ $(0,+\infty)$ ។
គណនា $g(1) = 1^2 + \ln 1 = 1 + 0 = \boxed{1}$ ។

ខ. ដោយសារ $g$ កើនដាច់ខាតលើ $(0,+\infty)$ ៖

- បើ $x \geq 1 \implies g(x) \geq g(1) \implies \boxed{x^2+\ln x \geq 1}$ ។
- បើ $0 < x \leq 1 \implies g(x) \leq g(1) \implies \boxed{x^2+\ln x \leq 1}$ ។

គ. សញ្ញានៃកន្សោម $x^2+\ln x - 1 = g(x)-1$ ៖

- បើ $0<x<1 \implies x^2+\ln x-1<0$ (អវិជ្ជមាន) ។
- បើ $x=1 \implies x^2+\ln x-1=0$ ។
- បើ $x>1 \implies x^2+\ln x-1>0$ (វិជ្ជមាន) ។

**B**. សិក្សាអនុគមន៍ $f(x)$ ៖

ក. លីមីតនៃអនុគមន៍ $f$ ៖

- ត្រង់ $x\to 0^+$ ៖ $\lim\limits_{x\to 0^+}\left(-\frac{\ln x}{x}\right) = +\infty \implies \boxed{\lim\limits_{x\to 0^+} f(x) = +\infty} \implies \boxed{x=0}$ ជាអាស៊ីមតូតឈរ ។
- ត្រង់ $x\to+\infty$ ៖ $\lim\limits_{x\to+\infty}\frac{\ln x}{x} = 0 \implies \boxed{\lim\limits_{x\to+\infty} f(x) = +\infty}$ ។

ខ. គណនាដេរីវេ $f'(x)$ ៖ ចំពោះគ្រប់ $x>0$ ៖

$$f'(x) = 1 - \frac{\frac{1}{x}\cdot x - \ln x}{x^2} = 1 - \frac{1-\ln x}{x^2} = \boxed{\frac{x^2+\ln x-1}{x^2}}$$

គ. សញ្ញា $f'(x)$ និងតារាងអថេរភាព ៖
ដោយសារ $x^2>0$ សញ្ញានៃ $f'(x)$ ដូចសញ្ញានៃ $x^2+\ln x-1$ (តាមផ្នែក $A$) ៖

- $f'(x)<0 \iff 0<x<1$ ($f$ ចុះ) ៖ $f'(x)>0 \iff x>1$ ($f$ កើន) ។

តម្លៃអប្បបរមាធៀបត្រង់ $x=1$ គឺ $f(1) = 1+1-\frac{\ln 1}{1} = \boxed{2}$ ។

| $x$ | $0$ | | $1$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | ‖ | $-$ | $0$ | $+$ | |
| $f(x)$ | ‖ $+\infty$ | ↘ | $2$ | ↗ | $+\infty$ |

ឃ. អាស៊ីមតូតទ្រេត ទីតាំងធៀប និងសង់ក្រាប ៖

- ពិនិត្យផលដក ៖ $\lim_{x\to+\infty}[f(x)-(x+1)] = \lim_{x\to+\infty}\left(-\frac{\ln x}{x}\right) = 0$ ។
  ដូចនេះ បន្ទាត់ $\boxed{(\Delta): y = x+1}$ ជាអាស៊ីមតូតទ្រេតខាង $+\infty$ ។
- ទីតាំងធៀប ៖ សញ្ញានៃ $f(x)-(x+1) = -\frac{\ln x}{x}$ ៖
  - លើ $(0,1)$ ៖ $\ln x < 0 \implies -\frac{\ln x}{x} > 0 \implies$ $(\mathbf{C})$ ស្ថិតនៅខាងលើ $(\Delta)$ ។
  - លើ $(1,+\infty)$ ៖ $\ln x > 0 \implies -\frac{\ln x}{x} < 0 \implies$ $(\mathbf{C})$ ស្ថិតនៅខាងក្រោម $(\Delta)$ ។
- ចំណុចប្រសព្វ ៖ $-\frac{\ln x}{x} = 0 \iff \ln x = 0 \iff x = 1 \implies \boxed{I(1,2)}$ ។




## លំហាត់ទី ៧១

គេមានអនុគមន៍ $f$ កំណត់លើ $\mathbb{R}\setminus\{-2,2\}$ ដោយ $f(x) = \dfrac{2x^2}{x^2-4}$ ។

ក. សិក្សាលីមីតនៃអនុគមន៍ $f$ ត្រង់ $-\infty, -2, 2$ និង $+\infty$ ។ បញ្ជាក់អំពីអាស៊ីមតូតដេក និងអាស៊ីមតូតឈរនៃក្រាប $(C)$ ។

ខ. គណនាដេរីវេ $f'(x)$ សិក្សាសញ្ញា $f'(x)$ និងសង់តារាងអថេរភាពនៃ $f$ ។

គ. សង់ក្រាប $(C)$ ក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j})$ ។

## ដំណោះស្រាយ

ក. **គណនាលីមីត និងរកអាស៊ីមតូត ៖**

- លីមីតត្រង់ $\pm\infty$ ៖

$$\lim_{x\to\pm\infty} f(x) = \lim_{x\to\pm\infty}\frac{2x^2}{x^2} = \mathbf{2} \implies \boxed{y = 2 \text{ ជាអាស៊ីមតូតដេកខាង } \pm\infty}$$

- លីមីតត្រង់ $x = 2$ ៖

– $\lim\limits_{x\to 2^-}\dfrac{2x^2}{x^2-4}=\dfrac{8}{0^-}=-\infty$ ។
– $\lim\limits_{x\to 2^+}\dfrac{2x^2}{x^2-4}=\dfrac{8}{0^+}=+\infty$ ។

ដូច្នេះ $\boxed{x=2 \text{ ជាអាស៊ីមតូតឈរ}}$ ។

- លីមីតត្រង់ $x=-2$ ៖

– $\lim\limits_{x\to -2^-}\dfrac{2x^2}{x^2-4}=\dfrac{8}{0^+}=+\infty$ ។
– $\lim\limits_{x\to -2^+}\dfrac{2x^2}{x^2-4}=\dfrac{8}{0^-}=-\infty$ ។

ដូច្នេះ $\boxed{x=-2 \text{ ជាអាស៊ីមតូតឈរ}}$ ។

## ខ. ដេរីវេ និងតារាងអថេរភាព ៖

- អនុវត្តរូបមន្តដេរីវេផលចែក ៖

$$f'(x)=\frac{(2x^2)'(x^2-4)-2x^2(x^2-4)'}{(x^2-4)^2}=\frac{4x(x^2-4)-2x^2(2x)}{(x^2-4)^2}$$

$$f'(x)=\frac{4x^3-16x-4x^3}{(x^2-4)^2}=\boxed{\frac{-16x}{(x^2-4)^2}}$$

- ដោយសារ $(x^2-4)^2>0$ ចំពោះគ្រប់ $x\in D$ នោះសញ្ញា $f'(x)$ ដូចសញ្ញា $-16x$ ៖

$$f'(x)=0 \iff -16x=0 \iff x=0$$

– បើ $x<0$ $(x\neq -2)$ ៖ $-16x>0 \implies f'(x)>0$ (អនុគមន៍កើន) ។
– បើ $x>0$ $(x\neq 2)$ ៖ $-16x<0 \implies f'(x)<0$ (អនុគមន៍ចុះ) ។

- តម្លៃអតិបរមាធៀបត្រង់ $x=0$ គឺ ៖

$$f(0)=\frac{2(0)^2}{0^2-4}=\mathbf{0}$$

| $x$ | $-\infty$ | | $-2$ | | $0$ | | $2$ | | $+\infty$ |
|---|---|---|---|---|---|---|---|---|---|
| $f'(x)$ | | $+$ | ‖ | $+$ | $0$ | $-$ | ‖ | $-$ | |
| $f(x)$ | $2$ | ↗ | $+\infty$ ‖ $-\infty$ | ↘ | $0$ | ↗ | $+\infty$ ‖ $-\infty$ | ↘ | $2$ |

## គ. សង់ក្រាប $(C)$ ៖




## លំហាត់ទី ៧២

គេមានអនុគមន៍ $f$ កំណត់លើ $\mathbb{R}$ ដោយ $f(x)=x+\dfrac{1-3e^x}{1+e^x}$ ហើយមានក្រាប $(C)$ ក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j})$ ។

ក. បង្ហាញថា $f(x)=x+1-\dfrac{4e^x}{1+e^x}$ និងគណនាលីមីតនៃ $f$ ត្រង់ $-\infty$ ។ ស្រាយបំភ្លឺថាបន្ទាត់ $d_1: y=x+1$ ជាអាស៊ីមតូតនៃ $(C)$ ត្រង់ $-\infty$ និងសិក្សាទីតាំងធៀបរវាង $(C)$ និង $d_1$ ។

ខ. គណនាលីមីត $f$ ត្រង់ $+\infty$ ។ ស្រាយបំភ្លឺថាបន្ទាត់ $d_2: y=x-3$ ជាអាស៊ីមតូតនៃ $(C)$ ត្រង់ $+\infty$ និងសិក្សាទីតាំងធៀបរវាង $(C)$ និង $d_2$ ។

គ. ១. គណនាដេរីវេ $f'(x)$ និងបង្ហាញថាចំពោះគ្រប់ចំនួនពិត $x$, $f'(x)=\left(\dfrac{e^x-1}{e^x+1}\right)^2$ ។

២. សិក្សាអថេរភាពនៃ $f$ រួចសង់តារាងអថេរភាពនៃ $f$ ។ សង់ក្រាប $(C)$ និងអាស៊ីមតូត $d_1, d_2$ ។

## ដំណោះស្រាយ

### ក. ទម្រង់នៃ $f(x)$, លីមីត និងអាស៊ីមតូត $d_1$ ខាង $-\infty$ ៖

- បង្ហាញទម្រង់ ៖

$$f(x)=x+\frac{1-3e^x}{1+e^x}=x+\frac{1+e^x-4e^x}{1+e^x}=\boxed{x+1-\frac{4e^x}{1+e^x}}$$

- គណនាលីមីត ៖ កាលណា $x\to-\infty$ នោះ $e^x\to 0$ នាំឱ្យ $\boxed{\lim\limits_{x\to-\infty} f(x)=-\infty}$ ។

- អាស៊ីមតូត $d_1$ ៖ $\lim\limits_{x\to-\infty}[f(x)-(x+1)] = \lim\limits_{x\to-\infty}\left(-\frac{4e^x}{1+e^x}\right) = 0$ ។
  ដូចនេះ បន្ទាត់ $\boxed{d_1 : y = x+1}$ ជាអាស៊ីមតូតទ្រេតនៃ $(C)$ ខាង $-\infty$ ។
- ទីតាំងធៀប ៖ $f(x)-(x+1) = -\frac{4e^x}{1+e^x} < 0$ ចំពោះគ្រប់ $x \in \mathbb{R}$ ។
  ដូចនេះ $(\mathbf{C})$ ស្ថិតនៅខាងក្រោមបន្ទាត់ $\mathbf{d_1}$ ជានិច្ច ។

**ខ. លីមីត និងអាស៊ីមតូត $d_2$ ខាង $+\infty$ ៖**

- សរសេរ ៖ $f(x) = x + \frac{-3(1+e^x)+4}{1+e^x} = x-3+\frac{4}{1+e^x}$ ។
  កាលណា $x \to +\infty$ នោះ $\frac{4}{1+e^x} \to 0$ នាំឱ្យ $\boxed{\lim\limits_{x\to+\infty} f(x) = +\infty}$ ។
- អាស៊ីមតូត $d_2$ ៖ $\lim\limits_{x\to+\infty}[f(x)-(x-3)] = \lim\limits_{x\to+\infty} \frac{4}{1+e^x} = 0$ ។
  ដូចនេះ បន្ទាត់ $\boxed{d_2 : y = x-3}$ ជាអាស៊ីមតូតទ្រេតនៃ $(C)$ ខាង $+\infty$ ។
- ទីតាំងធៀប ៖ $f(x)-(x-3) = \frac{4}{1+e^x} > 0$ ចំពោះគ្រប់ $x \in \mathbb{R}$ ។
  ដូចនេះ $(\mathbf{C})$ ស្ថិតនៅខាងលើបន្ទាត់ $\mathbf{d_2}$ ជានិច្ច ។

**គ. គណនាដេរីវេ តារាងអថេរភាព និងសង់ក្រាប ៖**

១. គណនាដេរីវេ $f'(x)$ ៖ ចំពោះគ្រប់ $x \in \mathbb{R}$ ៖

$$f'(x) = \left[x+1-\frac{4e^x}{1+e^x}\right]' = 1-\frac{4e^x(1+e^x)-4e^x \cdot e^x}{(1+e^x)^2} = 1-\frac{4e^x}{(1+e^x)^2}$$

$$f'(x) = \frac{(1+e^x)^2-4e^x}{(1+e^x)^2} = \frac{e^{2x}-2e^x+1}{(1+e^x)^2} = \boxed{\left(\frac{e^x-1}{e^x+1}\right)^2}$$

២. សិក្សាអថេរភាព និងសង់ក្រាប ៖

ដោយសារ $f'(x) = \left(\frac{e^x-1}{e^x+1}\right)^2 \geq 0$ គ្រប់ $x \in \mathbb{R}$ និង $f'(x) = 0 \iff x = 0$ នាំឱ្យ $f$ ជាអនុគមន៍កើនដាច់ខាតលើ $\mathbb{R}$ ។
ត្រង់ $x = 0 \implies f(0) = 0+1-\frac{4}{2} = -1$ ។

| $x$ | $-\infty$ | | $0$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | | $+$ | $0$ | $+$ | |
| $f(x)$ | $-\infty$ | $\nearrow$ | $-1$ | $\nearrow$ | $+\infty$ |




## លំហាត់ទី ៧៣

គេមានអនុគមន៍ $f$ កំណត់លើ $(1,+\infty)$ ដោយ $f(x)=-x+4+\ln\left(\frac{x+1}{x-1}\right)$ ហើយមានក្រាប $(C)$ ក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j})$ ។

ក. គណនាលីមីតនៃ $f$ ត្រង់ $1$ និងត្រង់ $+\infty$ ។

ខ. ស្រាយបំភ្លឺថានៅលើ $(1,+\infty)$ គេបានដេរីវេនៃ $f$ គឺ $f'(x)=\frac{-(x^2+1)}{(x+1)(x-1)}$ ។ សិក្សាអថេរភាព និងសង់តារាងអថេរភាពនៃ $f$ ។

គ. ១. បង្ហាញថាបន្ទាត់ $d_1: y=-x+4$ ជាអាស៊ីមតូតទ្រេតនៃ $(C)$ ត្រង់ $+\infty$ ។

២. បង្ហាញថាចំពោះគ្រប់ $x\in(1,+\infty)$ គេមាន $\frac{x+1}{x-1}>1$ រួចទាញរកទីតាំងធៀបនៃ $(C)$ ធៀបនឹង $d_1$ ។

ឃ. កំណត់កូអរដោនេនៃចំណុចលើ $(C)$ ដែលបន្ទាត់ប៉ះ $d_2$ មានមេគុណប្រាប់ទិសស្មើ $-\frac{5}{3}$ និងសរសេរសមីការបន្ទាត់ប៉ះ $d_2$ នោះ ។

ង. សង់ក្រាប $(C)$ អាស៊ីមតូត $d_1$ និងបន្ទាត់ប៉ះ $d_2$ (យក $\ln 3\approx 1.1$ និងចំណុចកាត់អ័ក្សអាប់ស៊ីស $(4.5,0)$) ។

## ដំណោះស្រាយ

### ក. គណនាលីមីត ៖

- ត្រង់ $x\to 1^+$ ៖ $\lim\limits_{x\to1^+}\frac{x+1}{x-1}=+\infty \Longrightarrow \lim\limits_{x\to1^+}\ln\left(\frac{x+1}{x-1}\right)=+\infty$ នាំឱ្យ $\boxed{\lim\limits_{x\to1^+}f(x)=+\infty} \Longrightarrow \boxed{x=1}$ ជាអាស៊ីមតូតឈរ ។

- ត្រង់ $x \to +\infty$ ៖ $\lim\limits_{x\to+\infty} \frac{x+1}{x-1} = 1 \implies \lim\limits_{x\to+\infty} \ln\left(\frac{x+1}{x-1}\right) = 0$ នាំឱ្យ $\boxed{\lim\limits_{x\to+\infty} f(x) = -\infty}$ ។

**ខ. គណនាដេរីវេ និងតារាងអថេរភាព ៖**

- ដេរីវេ ៖ ចំពោះគ្រប់ $x > 1$ ៖

$$f'(x) = -1 + \frac{\left(\frac{x+1}{x-1}\right)'}{\frac{x+1}{x-1}} = -1 + \frac{\frac{-2}{(x-1)^2}}{\frac{x+1}{x-1}} = -1 - \frac{2}{(x+1)(x-1)} = \boxed{-\frac{x^2+1}{(x+1)(x-1)}}$$

- សញ្ញា $f'(x)$ ៖ ចំពោះគ្រប់ $x > 1$ គេមាន $x^2+1 > 0$ និង $(x+1)(x-1) > 0$ នាំឱ្យ $f'(x) < 0$ ជានិច្ច ។ ដូចនេះ $f$ ជាអនុគមន៍ចុះដាច់ខាតលើ $(1, +\infty)$ ។
- តារាងអថេរភាព ៖

| $x$ | $1$ $\qquad\qquad$ $+\infty$ |
|---|---|
| $f'(x)$ | ‖ $\quad -$ |
| $f(x)$ | ‖ $+\infty \searrow -\infty$ |

**គ. អាស៊ីមតូតទ្រេត និងទីតាំងធៀប ៖**

① ពិនិត្យផលដក ៖ $\lim\limits_{x\to+\infty} [f(x) - (-x+4)] = \lim\limits_{x\to+\infty} \ln\left(\frac{x+1}{x-1}\right) = 0$ ។
ដូចនេះ បន្ទាត់ $\boxed{d_1 : y = -x+4}$ ជាអាស៊ីមតូតទ្រេតខាង $+\infty$ ។

② ដោយសារ $x > 1 \implies x+1 > x-1 > 0 \implies \dfrac{x+1}{x-1} > 1$ នាំឱ្យ $\ln\left(\frac{x+1}{x-1}\right) > 0$ ។
ដូចនេះ $(\mathbf{C})$ ស្ថិតនៅខាងលើបន្ទាត់ $\mathbf{d_1}$ ចំពោះគ្រប់ $x \in (1, +\infty)$ ។

**ឃ. ចំណុចប៉ះ និងសមីការបន្ទាត់ប៉ះ $d_2$ ៖**

- រកអាប់ស៊ីសនៃចំណុចប៉ះ ៖

$$f'(x) = -\frac{5}{3} \iff \frac{x^2+1}{x^2-1} = \frac{5}{3} \iff 3x^2+3 = 5x^2-5 \iff 2x^2 = 8 \iff x = 2 \quad (\text{ព្រោះ } x > 1)$$

ត្រង់ $x = 2 \implies y = f(2) = -2+4+\ln\left(\frac{3}{1}\right) = 2+\ln 3 \approx 2+1.1 = 3.1$ ។
ដូចនេះ ចំណុចប៉ះគឺ $\boxed{B(2, 2+\ln 3)}$ ។

- សមីការបន្ទាត់ប៉ះ ៖ $y - (2+\ln 3) = -\frac{5}{3}(x-2) \iff \boxed{d_2 : y = -\dfrac{5}{3}x + \dfrac{16}{3} + \ln 3}$ ។

**ង. សង់ក្រាប $(C)$ អាស៊ីមតូត និងបន្ទាត់ប៉ះ ៖**




**លំហាត់ទី ៧៤**

គេមានអនុគមន៍ $f$ កំណត់លើ $\mathbb{R}$ ដោយ $f(x) = x + 2 - \dfrac{4e^x}{e^x + 3}$ ហើយមានក្រាប $(C)$ ក្នុងតម្រុយអរតូណរម៉ាល់ $(O, \vec{i}, \vec{j})$ ។

ក. ១. គណនាលីមីតនៃ $f$ ត្រង់ $-\infty$ និង $+\infty$ ។

២. សិក្សាទីតាំងធៀបនៃក្រាប $(C)$ ធៀបនឹងបន្ទាត់ $d_1 : y = x + 2$ ។

ខ. ១. ស្រាយបំភ្លឺថាចំពោះគ្រប់ចំនួនពិត $x$, $f'(x) = \left(\dfrac{e^x - 3}{e^x + 3}\right)^2$ ។

២. សិក្សាអថេរភាពនៃ $f$ លើ $\mathbb{R}$ និងសង់តារាងអថេរភាពនៃ $f$ ។

គ. ១. បញ្ជាក់លក្ខណៈនៃបន្ទាត់ប៉ះ $d_2$ ទៅនឹង $(C)$ ត្រង់ចំណុច $I$ ដែលមានអាប់ស៊ីស $x = \ln 3$ ។

២. សិក្សាទីតាំងនៃក្រាប $(C)$ ធៀបនឹងបន្ទាត់ប៉ះ $d_2$ ។

ឃ. ១. បង្ហាញថាបន្ទាត់ប៉ះ $d_3$ ទៅនឹង $(C)$ ត្រង់ $x = 0$ មានសមីការ $y = \dfrac{1}{4}x + 1$ ។

២. ដោយសន្មត់ថាចំណុច $I$ ជាផ្ចិតឆ្លុះនៃក្រាប $(C)$ ចូរសង់ក្រាប $(C)$ និងបន្ទាត់ប៉ះ $d_1, d_2, d_3$ ។

## ដំណោះស្រាយ

### ក. លីមីត និងទីតាំងធៀបនឹង $d_1$ ៖

១. $\lim\limits_{x\to-\infty} e^x = 0 \implies \boxed{\lim\limits_{x\to-\infty} f(x) = -\infty}$ ។

$\lim\limits_{x\to+\infty} \frac{4e^x}{e^x+3} = 4 \implies \boxed{\lim\limits_{x\to+\infty} f(x) = +\infty}$ ។

២. ពិនិត្យផលដក ៖ $f(x)-(x+2)=-\frac{4e^x}{e^x+3}<0$ ចំពោះគ្រប់ $x\in\mathbb{R}$ ។
ដូចនេះ $(\mathbf{C})$ ស្ថិតនៅខាងក្រោមបន្ទាត់ $\mathbf{d_1}$ ជានិច្ច ។

**ខ. ដេរីវេ និងតារាងអថេរភាព ៖**

១. ដេរីវេ ៖ ចំពោះគ្រប់ $x\in\mathbb{R}$ ៖

$$f'(x)=1-\frac{4e^x(e^x+3)-4e^x\cdot e^x}{(e^x+3)^2}=1-\frac{12e^x}{(e^x+3)^2}=\frac{(e^x+3)^2-12e^x}{(e^x+3)^2}=\boxed{\left(\frac{e^x-3}{e^x+3}\right)^2}$$

២. សិក្សាអថេរភាព ៖ ដោយសារ $f'(x)\geq 0$ គ្រប់ $x\in\mathbb{R}$ និង $f'(x)=0\iff x=\ln 3$ នាំឱ្យ $f$ ជាអនុគមន៍កើនដាច់ខាតលើ $\mathbb{R}$ ។
តារាងអថេរភាព ៖

| $x$ | $-\infty$ | | $\ln 3$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | | $+$ | $0$ | $+$ | |
| $f(x)$ | $-\infty$ | ↗ | $\ln 3$ | ↗ | $+\infty$ |

**គ. បន្ទាត់ប៉ះ $d_2$ ត្រង់ $I$ និងទីតាំងធៀប ៖**

១. ត្រង់ $x=\ln 3$ គេបាន $f(\ln 3)=\ln 3+2-\frac{4(3)}{3+3}=\ln 3$ និង $f'(\ln 3)=0$ ។
ដូចនេះ បន្ទាត់ប៉ះ $\boxed{d_2:y=\ln 3}$ **ជាបន្ទាត់ដេក**ស្របនឹងអ័ក្សអាប់ស៊ីស ។

២. ដោយសារ $I(\ln 3,\ln 3)$ ជាចំណុចរបត់ ក្រាប $(C)$ កាត់បន្ទាត់ប៉ះ $d_2$ ត្រង់ $I$ ដោយ ៖

- ចំពោះ $x<\ln 3$ ៖ $(C)$ ស្ថិតនៅខាងក្រោម $d_2$ ។
- ចំពោះ $x>\ln 3$ ៖ $(C)$ ស្ថិតនៅខាងលើ $d_2$ ។

**ឃ. បន្ទាត់ប៉ះ $d_3$ និងសង់ក្រាប ៖**

១. ត្រង់ $x=0$ ៖ $f(0)=0+2-\frac{4}{4}=1$ និង $f'(0)=\left(\frac{1-3}{1+3}\right)^2=\frac{1}{4}$ ។
សមីការបន្ទាត់ប៉ះ ៖ $y-1=\frac{1}{4}(x-0)\iff\boxed{d_3:y=\frac{1}{4}x+1}$ ។

២. សង់ក្រាប $(C)$ និងបន្ទាត់ប៉ះ ៖




## លំហាត់ទី ៧៥

មន្ត្រីរាជការម្នាក់មានអាយុ 30 ឆ្នាំបានយកប្រាក់ចំនួន 1000\$ ទៅផ្ញើនៅធនាគារមួយដោយទទួលបានអត្រាការប្រាក់សមាស 11% ក្នុងមួយឆ្នាំ។ ពេលចូលនិវត្តន៍អាយុ 60 ឆ្នាំ តើគាត់បានប្រាក់សរុបទាំងអស់ចំនួនប៉ុន្មាន បើធនាគារទូទាត់ប្រាក់ជាបន្តបន្ទាប់?

## ដំណោះស្រាយ

- **ទិន្នន័យនៃប្រធាន ៖**
  - ប្រាក់ដើមផ្ញើដំបូង ៖ $P = 1000\$$
  - អត្រាការប្រាក់ប្រចាំឆ្នាំ ៖ $r = 11\% = 0.11$
  - រយៈពេលផ្ញើប្រាក់ ពីអាយុ 30 ដល់ 60 ឆ្នាំ ៖ $t = 60 - 30 = 30$ ឆ្នាំ
- **រូបមន្តគណនាការប្រាក់សមាសជាបន្តបន្ទាប់ (Continuous Compounding) ៖**

$$A = P \cdot e^{rt}$$

ដែល $A$ ជាប្រាក់សរុបទាំងអស់ទទួលបានពេលបញ្ចប់កាលកំណត់។

- **គណនាតម្លៃជាក់ស្តែង ៖**

$$A = 1000 \cdot e^{0.11\times 30} = 1000 \cdot e^{3.3}$$

ដោយ $e^{3.3} \approx 27.11263892$ គេបាន ៖

$$A \approx 1000 \times 27.11263892 = 27\,112.63892 \text{ ដុល្លារ} \approx 27\,112.64 \text{ ដុល្លារ}$$

**សេចក្តីសន្និដ្ឋាន ៖** ពេលចូលនិវត្តន៍នៅអាយុ 60 ឆ្នាំ មន្ត្រីរាជការរូបនោះនឹងទទួលបានប្រាក់សរុបទាំងអស់ចំនួន ៖

$A \approx 27\,112.64$ ដុល្លារ

---

**លំហាត់ទី ៧៦**

នៅទីក្រុងមួយកាលពី ២០ ឆ្នាំមុន មានប្រជាជនចំនួន 60000 នាក់ ហើយចំនួនប្រជាជនមានការកើនឡើងដោយអត្រាមួយថេរជារៀងរាល់ឆ្នាំ។ បើបច្ចុប្បន្នមានប្រជាជនចំនួន 150000 នាក់ រកអត្រាកំណើននៃចំនួនប្រជាជនក្នុងទីក្រុងនេះ។

## ដំណោះស្រាយ

- **ទិន្នន័យនៃប្រធាន ៖**
  - ចំនួនប្រជាជនកាលពី ២០ ឆ្នាំមុន (យកជាពេលដើម $t=0$) ៖ $P_0 = 60000$ នាក់
  - ចំនួនប្រជាជនបច្ចុប្បន្ន (ត្រូវនឹង $t = 20$ ឆ្នាំ) ៖ $P(20) = 150000$ នាក់
- **របៀបទី ១ ៖ តាមម៉ូដែលកំណើនអិចស្ប៉ូណង់ស្យែលបន្តបន្ទាប់** $P(t) = P_0 e^{kt}$

  $$P(20) = P_0 e^{20k} \iff 60000e^{20k} = 150000$$

  សម្រួលអង្គទាំងពីរ ៖

  $$e^{20k} = \frac{150000}{60000} = \frac{5}{2} = 2.5$$

  បំពាក់លោការីតនេពែរលើអង្គទាំងពីរ ៖

  $$20k = \ln(2.5) \implies k = \frac{\ln(2.5)}{20}$$

  ដោយ $\ln(2.5) \approx 0.91629$ គេបាន ៖

  $$k \approx \frac{0.91629}{20} \approx 0.04581 = \mathbf{4.58\%} \text{ ក្នុងមួយឆ្នាំ}$$

- **របៀបទី ២ ៖ តាមម៉ូដែលកំណើនប្រចាំឆ្នាំដាច់ដោយឡែក** $P(t) = P_0(1+r)^t$

  $$60000(1+r)^{20} = 150000 \iff (1+r)^{20} = 2.5$$

  នាំឱ្យ ៖

  $$1 + r = (2.5)^{\frac{1}{20}} \approx 1.04689 \implies r \approx 0.04689 = \mathbf{4.69\%} \text{ ក្នុងមួយឆ្នាំ}$$

**សេចក្តីសន្និដ្ឋាន ៖** អត្រាកំណើននៃចំនួនប្រជាជនក្នុងទីក្រុងនេះគឺ ៖

$k \approx 4.58\%$ ក្នុងមួយឆ្នាំ (ម៉ូដែលអិចស្ប៉ូណង់ស្យែល) ឬ $r \approx 4.69\%$ ក្នុងមួយឆ្នាំ (ម៉ូដែលប្រចាំឆ្នាំ)

---

# លំហាត់កិច្ចការផ្ទះ សិក្សាអនុគមន៍ថ្នាក់ទី១២

## ប្រធានលំហាត់ ៖

គេឱ្យអនុគមន៍ $f$ កំណត់ដោយ $f(x)=\dfrac{x^2-8x+11}{x^2-6x+9}$ ។ គេតាង $(C)$ ជាខ្សែកោងតាងអនុគមន៍ $f$ ក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j})$ ។

១. រកដែនកំណត់ $D_f$ នៃអនុគមន៍ $f$ ។

២. រកលីមីត $\lim\limits_{x\to\pm\infty} f(x)$ និង $\lim\limits_{x\to 3} f(x)$ រួចទាញបញ្ជាក់នូវសមីការអាស៊ីមតូតដេក និងសមីការអាស៊ីមតូតឈរនៃក្រាប $(C)$ ។

៣. ក. ចំពោះគ្រប់ $x\in D_f$ បង្ហាញថា $f'(x)=\dfrac{2(x+1)}{(x-3)^3}$ ។

ខ. គូសតារាងអថេរភាពនៃ $f$ ។

៤. ខ្សែកោង $(C)$ កាត់អ័ក្ស $(Ox)$ ត្រង់ពីរចំណុច $A$ និង $B$ និងកាត់អ័ក្ស $(Oy)$ ត្រង់ $C$ ។

ក. គណនាកូអរដោនេនៃចំណុច $A,B$ និង $C$ ។

ខ. ចូរសរសេរសមីការបន្ទាត់ $(T_1),(T_2)$ និង $(T_3)$ ប៉ះនឹងខ្សែកោង $(C)$ រៀងគ្នាត្រង់ចំណុច $A,B$ និង $C$ ។

៥. ចូរសង់ខ្សែកោង $(C)$ និងបន្ទាត់ប៉ះ $(T_1),(T_2)$ និង $(T_3)$ ក្នុងតម្រុយរួមគ្នា ។

## ដំណោះស្រាយលម្អិត

**១. រកដែនកំណត់ $D_f$ នៃអនុគមន៍ $f$ ៖**

អនុគមន៍ $f(x)=\dfrac{x^2-8x+11}{x^2-6x+9}$ មានន័យលុះត្រាតែភាគបែងខុសពីសូន្យ ៖

$$x^2-6x+9\neq 0 \iff (x-3)^2\neq 0 \iff x-3\neq 0 \implies x\neq 3$$

**ដូចនេះ ដែនកំណត់នៃអនុគមន៍គឺ $D_f=\mathbb{R}\setminus\{3\}=(-\infty,3)\cup(3,+\infty)$ ។**

**២. រកលីមីត និងទាញបញ្ជាក់នូវសមីការអាស៊ីមតូតនៃក្រាប $(C)$ ៖**

• លីមីតត្រង់ $\pm\infty$ ៖

$$\lim_{x\to\pm\infty} f(x)=\lim_{x\to\pm\infty}\frac{x^2-8x+11}{x^2-6x+9}=\lim_{x\to\pm\infty}\frac{x^2}{x^2}=1$$

ដោយ $\lim\limits_{x\to\pm\infty} f(x)=1$ នោះបន្ទាត់ដែលមានសមីការ $y=1$ ជាអាស៊ីមតូតដេកនៃក្រាប $(C)$ នៅខាង $\pm\infty$ ។

• លីមីតត្រង់ $x\to 3$ ៖

$$\lim_{x\to 3} f(x)=\lim_{x\to 3}\frac{x^2-8x+11}{(x-3)^2}$$

ដោយ $\lim_{x\to 3}(x^2-8x+11)=3^2-8(3)+11=-4<0$ និង $\lim_{x\to 3}(x-3)^2=0^+$ នោះ ៖

$$\lim_{x\to 3} f(x)=\frac{-4}{0^+}=-\infty$$

**ដោយ $\lim_{x\to 3} f(x)=-\infty$ នោះបន្ទាត់ $x=3$ ជាអាស៊ីមតូតឈរនៃក្រាប $(C)$ ។**

៣. ក. បង្ហាញថា $f'(x)=\dfrac{2(x+1)}{(x-3)^3}$ ៖

យើងមាន $f(x)=\dfrac{x^2-8x+11}{(x-3)^2}$ មានទម្រង់ $\dfrac{u}{v}$ ដែល $u=x^2-8x+11$ និង $v=(x-3)^2$ ។

នាំឱ្យ $u'=2x-8=2(x-4)$ និង $v'=2(x-3)$ ។

តាមរូបមន្តដេរីវេផលចែក $\left(\dfrac{u}{v}\right)'=\dfrac{u'v-uv'}{v^2}$ គេបាន ៖

$$\begin{aligned}
f'(x)&=\frac{(2x-8)(x-3)^2-(x^2-8x+11)\cdot 2(x-3)}{(x-3)^4}\\
&=\frac{(x-3)\left[(2x-8)(x-3)-2(x^2-8x+11)\right]}{(x-3)^4}\\
&=\frac{2x^2-6x-8x+24-2x^2+16x-22}{(x-3)^3}\\
&=\frac{2x+2}{(x-3)^3}=\frac{2(x+1)}{(x-3)^3}
\end{aligned}$$

**ដូចនេះ $f'(x)=\dfrac{2(x+1)}{(x-3)^3}$ ពិតប្រាកដមែនចំពោះគ្រប់ $x\in D_f$ ។**

ខ. គូសតារាងអថេរភាពនៃ $f$ ៖

- ឱ្យ $f'(x)=0 \iff \dfrac{2(x+1)}{(x-3)^3}=0 \iff 2(x+1)=0 \implies x=-1$ ។
- សញ្ញានៃ $f'(x)$ អាស្រ័យនឹងផលគុណ $(x+1)(x-3)$ ព្រោះ $(x-3)^4>0$ ជានិច្ចចំពោះគ្រប់ $x\neq 3$ ៖
  - ចំពោះ $x\in(-\infty,-1)$ ៖ $f'(x)>0 \implies f$ ជាអនុគមន៍កើន ។
  - ចំពោះ $x\in(-1,3)$ ៖ $f'(x)<0 \implies f$ ជាអនុគមន៍ចុះ ។
  - ចំពោះ $x\in(3,+\infty)$ ៖ $f'(x)>0 \implies f$ ជាអនុគមន៍កើន ។
- ត្រង់ $x=-1$ ដេរីវេ $f'(x)$ ប្តូរសញ្ញាពីវិជ្ជមានទៅអវិជ្ជមាន នាំឱ្យអនុគមន៍មានតម្លៃអតិបរមាធៀប ៖

$$f(-1)=\frac{(-1)^2-8(-1)+11}{(-1-3)^2}=\frac{1+8+11}{16}=\frac{20}{16}=\frac{5}{4}$$

- តារាងអថេរភាព ៖

| $x$ | $-\infty$ | | $-1$ | | $3$ | | $+\infty$ |
|---|---|---|---|---|---|---|---|
| $f'(x)$ | | $+$ | $0$ | $-$ | ‖ | $+$ | |
| $f(x)$ | $1$ | ↗ | $\frac{5}{4}$ | ↘ | $-\infty$ ‖ $-\infty$ | ↗ | $1$ |

៤. ក. គណនាកូអរដោនេនៃចំណុច $A, B$ និង $C$ ៖

• ចំណុចប្រសព្វរវាង $(C)$ នឹងអ័ក្ស $(Ox)$ $(y=0)$ ៖

$$f(x)=0 \iff \frac{x^2-8x+11}{(x-3)^2}=0 \iff x^2-8x+11=0$$

$\Delta'=(-4)^2-1(11)=16-11=5>0 \implies x=4\pm\sqrt{5}$ (យកទាំងពីរព្រោះខុសពី $3$) ។

ដូចនេះ $A(4-\sqrt{5},0)$ និង $B(4+\sqrt{5},0)$ ។

• ចំណុចប្រសព្វរវាង $(C)$ នឹងអ័ក្ស $(Oy)$ $(x=0)$ ៖

$$f(0)=\frac{0^2-8(0)+11}{(0-3)^2}=\frac{11}{9}$$

ដូចនេះ $C\left(0,\frac{11}{9}\right)$ ។

ខ. សមីការបន្ទាត់ $(T_1),(T_2)$ និង $(T_3)$ ប៉ះនឹងខ្សែកោង $(C)$ ៖
រូបមន្តទូទៅ ៖ $y=f'(x_0)(x-x_0)+y_0$ ។

• ត្រង់ចំណុច $A(4-\sqrt{5},0)$ ៖ $x_0=4-\sqrt{5}$
$x_0+1=5-\sqrt{5}$ និង $x_0-3=1-\sqrt{5}$ ។
$(1-\sqrt{5})^3=1-3\sqrt{5}+3(5)-5\sqrt{5}=16-8\sqrt{5}=8(2-\sqrt{5})$ ។

$$f'(4-\sqrt{5})=\frac{2(5-\sqrt{5})}{8(2-\sqrt{5})}=\frac{5-\sqrt{5}}{4(2-\sqrt{5})}=\frac{(5-\sqrt{5})(2+\sqrt{5})}{4(4-5)}=-\frac{5+3\sqrt{5}}{4}$$

ដូចនេះ $(T_1): y=-\frac{5+3\sqrt{5}}{4}(x-4+\sqrt{5})$ ឬ $y=-\frac{5+3\sqrt{5}}{4}x+\frac{5+7\sqrt{5}}{4}$ ។

• ត្រង់ចំណុច $B(4+\sqrt{5},0)$ ៖ $x_0=4+\sqrt{5}$
$x_0+1=5+\sqrt{5}$ និង $x_0-3=1+\sqrt{5}$ ។
$(1+\sqrt{5})^3=16+8\sqrt{5}=8(2+\sqrt{5})$ ។

$$f'(4+\sqrt{5})=\frac{2(5+\sqrt{5})}{8(2+\sqrt{5})}=\frac{5+\sqrt{5}}{4(2+\sqrt{5})}=\frac{(5+\sqrt{5})(2-\sqrt{5})}{4(4-5)}=\frac{3\sqrt{5}-5}{4}$$

ដូចនេះ $(T_2): y=\frac{3\sqrt{5}-5}{4}(x-4-\sqrt{5})$ ឬ $y=\frac{3\sqrt{5}-5}{4}x+\frac{5-7\sqrt{5}}{4}$ ។

• ត្រង់ចំណុច $C\left(0,\frac{11}{9}\right)$ ៖ $x_0=0$

$$f'(0)=\frac{2(0+1)}{(0-3)^3}=-\frac{2}{27}$$

ដូចនេះ $(T_3): y=-\frac{2}{27}x+\frac{11}{9}$ ។

៥. សង់ខ្សែកោង $(C)$ និងបន្ទាត់ប៉ះ $(T_1), (T_2)$ និង $(T_3)$ ក្នុងតម្រុយរួមគ្នា ៖




### តារាងតម្លៃពិសេស និងធាតុសំខាន់ៗនៃក្រាប $(C)$ ៖

| ធាតុសំខាន់ៗ | សមីការ / កូអរដោនេ | តម្លៃប្រហែល |
|---|---|---|
| អាស៊ីមតូតដេក | $y = 1$ | $y = 1$ |
| អាស៊ីមតូតឈរ | $x = 3$ | $x = 3$ |
| ចំណុចអតិបរមាធៀប $M$ | $M\left(-1, \frac{5}{4}\right)$ | $(-1, 1.25)$ |
| ប្រសព្វអ័ក្ស $(Ox)$ ត្រង់ $A$ | $A(4-\sqrt{5}, 0)$ | $(1.764, 0)$ |
| ប្រសព្វអ័ក្ស $(Ox)$ ត្រង់ $B$ | $B(4+\sqrt{5}, 0)$ | $(6.236, 0)$ |
| ប្រសព្វអ័ក្ស $(Oy)$ ត្រង់ $C$ | $C\left(0, \frac{11}{9}\right)$ | $(0, 1.222)$ |
| បន្ទាត់ប៉ះ $(T_1)$ ត្រង់ $A$ | $y = -\frac{5+3\sqrt{5}}{4}(x-4+\sqrt{5})$ | $y \approx -2.927x + 5.163$ |
| បន្ទាត់ប៉ះ $(T_2)$ ត្រង់ $B$ | $y = \frac{3\sqrt{5}-5}{4}(x-4-\sqrt{5})$ | $y \approx 0.427x - 2.663$ |
| បន្ទាត់ប៉ះ $(T_3)$ ត្រង់ $C$ | $y = -\frac{2}{27}x + \frac{11}{9}$ | $y \approx -0.074x + 1.222$ |




# ឧបសម្ព័ន្ធ

## ក ៖ តារាងរូបមន្តដេរីវេ (Table of Derivatives)

### ១. រូបមន្តប្រមាណវិធីលើដេរីវេ (Derivative Operations)

ចំពោះអនុគមន៍ $u=u(x)$, $v=v(x)$ ដែលមានដេរីវេ និងចំនួនថេរ $k,c\in\mathbb{R}$ ៖

- $(c)'=0$
- $(u\pm v)'=u'\pm v'$
- $(k\cdot u)'=k\cdot u'$
- $(u\cdot v)'=u'v+uv'$
- $\left(\frac{1}{v}\right)'=-\frac{v'}{v^2}\quad(v\neq 0)$
- $\left(\frac{u}{v}\right)'=\frac{u'v-uv'}{v^2}\quad(v\neq 0)$
- $(f\circ g)'(x)=g'(x)\cdot f'(g(x))$
- $(u^n)'=nu'u^{n-1}\quad(n\in\mathbb{R}^*)$

### ២. និយមន័យ និងអត្ថន័យសំខាន់ៗនៃដេរីវេ (Meaning of Derivatives)

1. និយមន័យចំនួនដេរីវេត្រង់ $x_0$ ៖ $f'(x_0)=\lim\limits_{x\to x_0}\frac{f(x)-f(x_0)}{x-x_0}=\lim\limits_{h\to 0}\frac{f(x_0+h)-f(x_0)}{h}$
2. ដេរីវេឆ្វេង និងដេរីវេស្ដាំត្រង់ $x_0$ ៖ $f'_-(x_0)=\lim\limits_{x\to x_0^-}\frac{f(x)-f(x_0)}{x-x_0}$, $f'_+(x_0)=\lim\limits_{x\to x_0^+}\frac{f(x)-f(x_0)}{x-x_0}$

   $f$ មានដេរីវេត្រង់ $x_0 \iff f'_-(x_0)=f'_+(x_0)=f'(x_0)$។
3. អត្ថន័យធរណីមាត្រ ៖ មេគុណប្រាប់ទិសបន្ទាត់ប៉ះក្រាប $(C)$ ត្រង់ $x_0$ គឺ $m=f'(x_0)=\tan\alpha$។
4. អត្ថន័យរូបវិទ្យា (ចលនាត្រង់) ៖ ល្បឿនខណៈ $v(t)=s'(t)$ និង សំទុះខណៈ $a(t)=v'(t)=s''(t)$។
5. អត្ថន័យសេដ្ឋកិច្ច ៖ ថ្លៃដើម $C'(x)$, ចំណូល $R'(x)$, ចំណេញ $P'(x)=R'(x)-C'(x)$។

## ៣. តារាងរូបមន្តដេរីវេនៃអនុគមន៍បឋម និងអនុគមន៍បណ្ដាក់

| អនុគមន៍បឋម $y=f(x)$ | ដេរីវេ $y'=f'(x)$ | ដេរីវេនៃអនុគមន៍បណ្ដាក់ $u=u(x)$ |
|---|---|---|
| $y=c$ ($c$ ជាចំនួនថេរ) | $y'=0$ | --- |
| $y=x$ | $y'=1$ | $y=u \Longrightarrow y'=u'$ |
| $y=x^n\ (n\in\mathbb{R}^*)$ | $y'=nx^{n-1}$ | $(u^n)'=nu'u^{n-1}$ |
| $y=\sqrt{x}\ (x>0)$ | $y'=\dfrac{1}{2\sqrt{x}}$ | $(\sqrt{u})'=\dfrac{u'}{2\sqrt{u}}\quad (u>0)$ |
| $y=\dfrac{1}{x}\ (x\neq 0)$ | $y'=-\dfrac{1}{x^2}$ | $\left(\dfrac{1}{u}\right)'=-\dfrac{u'}{u^2}\quad (u\neq 0)$ |
| $y=e^x$ | $y'=e^x$ | $(e^u)'=u'e^u$ |
| $y=a^x\ (a>0,a\neq 1)$ | $y'=a^x\ln a$ | $(a^u)'=u'a^u\ln a$ |
| $y=\ln x\ (x>0)$ | $y'=\dfrac{1}{x}$ | $(\ln u)'=\dfrac{u'}{u}\quad (u>0)$ |
| $y=\ln\lvert x\rvert\ (x\neq 0)$ | $y'=\dfrac{1}{x}$ | $(\ln\lvert u\rvert)'=\dfrac{u'}{u}\quad (u\neq 0)$ |
| $y=\log_a x\ (x>0,a>0,a\neq 1)$ | $y'=\dfrac{1}{x\ln a}$ | $(\log_a u)'=\dfrac{u'}{u\ln a}\quad (u>0)$ |
| $y=\sin x$ | $y'=\cos x$ | $(\sin u)'=u'\cos u$ |
| $y=\cos x$ | $y'=-\sin x$ | $(\cos u)'=-u'\sin u$ |
| $y=\tan x$ | $y'=1+\tan^2 x=\dfrac{1}{\cos^2 x}$ | $(\tan u)'=u'(1+\tan^2 u)=\dfrac{u'}{\cos^2 u}$ |
| $y=\cot x$ | $y'=-(1+\cot^2 x)=-\dfrac{1}{\sin^2 x}$ | $(\cot u)'=-u'(1+\cot^2 u)=-\dfrac{u'}{\sin^2 u}$ |

## ៤. រូបមន្តកាត់ដេរីវេសម្រាប់អនុគមន៍សនិទាន (Shortcuts for Rational Functions)

**1.** $y=\dfrac{ax+b}{cx+d} \Longrightarrow y'=\dfrac{\begin{vmatrix} a & b \\ c & d \end{vmatrix}}{(cx+d)^2}=\dfrac{ad-bc}{(cx+d)^2}$

**2.** $y=ax+b+\dfrac{c}{px+q} \Longrightarrow y'=a-\dfrac{cp}{(px+q)^2}$

**3.** $y=\dfrac{ax^2+bx+c}{px+q} \Longrightarrow y'=\dfrac{apx^2+2aqx+(bq-cp)}{(px+q)^2}$

**4.** $y=\dfrac{ax^2+bx+c}{px^2+qx+r} \Longrightarrow y'=\dfrac{\begin{vmatrix} a & b \\ p & q \end{vmatrix}x^2+2\begin{vmatrix} a & c \\ p & r \end{vmatrix}x+\begin{vmatrix} b & c \\ q & r \end{vmatrix}}{(px^2+qx+r)^2}=\dfrac{(aq-bp)x^2+2(ar-cp)x+(br-cq)}{(px^2+qx+r)^2}$

# ខ ៖ តារាងរូបមន្តព្រីមីទីវ និងអាំងតេក្រាលគ្រឹះ (Primitives & Integrals)

## ១. តារាងរូបមន្តព្រីមីទីវគ្រឹះនៃអនុគមន៍ $f(x)$ និងអនុគមន៍បណ្ដាក់ $u(x)$

| ល.រ | ព្រីមីទីវនៃអនុគមន៍អថេរ $x$ | ព្រីមីទីវនៃអនុគមន៍បណ្ដាក់ $u(x)$ |
|---|---|---|
| 1 | $\int 0\,dx = C$ | $\int 0\,du = C$ |
| 2 | $\int k\,dx = kx + C \quad (k$ ថេរ$)$ | $\int k\cdot u'\,dx = ku + C$ |
| 3 | $\int x^n\,dx = \frac{x^{n+1}}{n+1} + C \quad (n \neq -1)$ | $\int u'u^n\,dx = \frac{u^{n+1}}{n+1} + C \quad (n \neq -1)$ |
| 4 | $\int \frac{1}{x}\,dx = \ln\lvert x\rvert + C \quad (x \neq 0)$ | $\int \frac{u'}{u}\,dx = \ln\lvert u\rvert + C \quad (u \neq 0)$ |
| 5 | $\int \frac{1}{\sqrt{x}}\,dx = 2\sqrt{x} + C \quad (x > 0)$ | $\int \frac{u'}{\sqrt{u}}\,dx = 2\sqrt{u} + C \quad (u > 0)$ |
| 6 | $\int e^x\,dx = e^x + C$ | $\int u'e^u\,dx = e^u + C$ |
| 7 | $\int a^x\,dx = \frac{a^x}{\ln a} + C \quad (a > 0, a \neq 1)$ | $\int u'a^u\,dx = \frac{a^u}{\ln a} + C$ |
| 8 | $\int \sin x\,dx = -\cos x + C$ | $\int u'\sin u\,dx = -\cos u + C$ |
| 9 | $\int \cos x\,dx = \sin x + C$ | $\int u'\cos u\,dx = \sin u + C$ |
| 10 | $\int \frac{1}{\cos^2 x}\,dx = \tan x + C$ | $\int \frac{u'}{\cos^2 u}\,dx = \tan u + C$ |
| 11 | $\int \frac{1}{\sin^2 x}\,dx = -\cot x + C$ | $\int \frac{u'}{\sin^2 u}\,dx = -\cot u + C$ |

## ២. រូបមន្តព្រីមីទីវទម្រង់លីនេអ៊ែរ $ax+b$ $(a \neq 0)$

- $\int (ax+b)^n\,dx = \frac{1}{a}\frac{(ax+b)^{n+1}}{n+1} + C \quad (n \neq -1)$
- $\int \frac{1}{ax+b}\,dx = \frac{1}{a}\ln\lvert ax+b\rvert + C$
- $\int \frac{1}{(ax+b)^2}\,dx = -\frac{1}{a(ax+b)} + C$
- $\int e^{ax+b}\,dx = \frac{1}{a}e^{ax+b} + C$
- $\int \sin(ax+b)\,dx = -\frac{1}{a}\cos(ax+b) + C$
- $\int \cos(ax+b)\,dx = \frac{1}{a}\sin(ax+b) + C$
- $\int \frac{1}{\cos^2(ax+b)}\,dx = \frac{1}{a}\tan(ax+b) + C$
- $\int \frac{1}{\sin^2(ax+b)}\,dx = -\frac{1}{a}\cot(ax+b) + C$

## ៣. រូបមន្តព្រីមីទីវនៃអនុគមន៍សនិទានពិសេស ($a>0$)

a. $\int \frac{1}{x^2-a^2}dx = \frac{1}{2a}\ln\left|\frac{x-a}{x+a}\right| + C$

b. $\int \frac{1}{a^2-x^2}dx = \frac{1}{2a}\ln\left|\frac{a+x}{a-x}\right| + C$

c. $\int \frac{1}{x^2+a^2}dx = \frac{1}{a}\arctan\left(\frac{x}{a}\right) + C$

d. $\int \frac{1}{\sqrt{a^2-x^2}}dx = \arcsin\left(\frac{x}{a}\right) + C$

e. $\int \frac{1}{\sqrt{x^2+a^2}}dx = \ln\left|x+\sqrt{x^2+a^2}\right| + C$

f. $\int \frac{1}{\sqrt{x^2-a^2}}dx = \ln\left|x+\sqrt{x^2-a^2}\right| + C$

## ៤. រូបមន្តអាំងតេក្រាលដោយផ្នែក (Integration by Parts)

បើ $u(x)$ និង $v(x)$ ជាអនុគមន៍មានដេរីវេជាប់ គេបានរូបមន្ត ៖

$$\int u\,dv = u\cdot v - \int v\,du \quad \text{ឬ} \quad \int_a^b u(x)v'(x)\,dx = \left[u(x)v(x)\right]_a^b - \int_a^b u'(x)v(x)\,dx$$

ក្បួនអាទិភាពជ្រើសរើស $u$ តាមវិធាន **L-I-A-T-E** ៖

| L | I | A | T | E |
|---|---|---|---|---|
| $\ln x, \log_a x$ | arcsin, arctan | $x^n$, ពហុធា | $\sin x, \cos x$ | $e^x, a^x$ |

## ៥. កម្មវិធីអាំងតេក្រាលក្នុងការគណនាផ្ទៃក្រឡា និងមាឌធរណីមាត្រ

1. ផ្ទៃក្រឡាខណ្ឌដោយ $(C): y=f(x)$ និងអ័ក្ស $Ox$ លើ $[a,b]$ ៖
$S=\int_a^b |f(x)|\,dx \quad$ (បើ $f(x)\geq 0 \implies S=\int_a^b f(x)\,dx$)

2. ផ្ទៃក្រឡាខណ្ឌដោយខ្សែកោងពីរ $(C_1)$ និង $(C_2)$ លើ $[a,b]$ ៖
$S=\int_a^b |f(x)-g(x)|\,dx$

3. មាឌសូលីដបរិវត្តន៍បង្កើតដោយរង្វិលជុំវិញអ័ក្ស $Ox$ លើ $[a,b]$ ៖
$V=\pi\int_a^b [f(x)]^2\,dx \quad$ ឬករណីពីរខ្សែកោង ៖ $V=\pi\int_a^b \left|[f(x)]^2-[g(x)]^2\right|\,dx$

# គ ៖ លីមីតនៃអនុគមន៍ និងវិធីសាស្ត្រគណនារាងមិនកំណត់

## ១. ប្រភេទរាងមិនកំណត់ទាំង ៧ (The 7 Indeterminate Forms)

ក្នុងគណិតវិទ្យាវិភាគ មានរាងមិនកំណត់ចំនួន ៧ ដែលទាមទារឱ្យមានការបំប្លែងកន្សោមមុននឹងគណនាតម្លៃលីមីត ៖

$$\left[\frac{0}{0}\right], \quad \left[\frac{\infty}{\infty}\right], \quad [0\times\infty], \quad [+\infty-\infty], \quad [1^{\infty}], \quad [0^{0}], \quad [\infty^{0}]$$

## ២. វិធីសាស្ត្រគន្លឹះដោះស្រាយរាងមិនកំណត់នីមួយៗ

| រាងមិនកំណត់ | វិធីសាស្ត្រគន្លឹះ | ការពន្យល់ និងបច្ចេកទេស |
|---|---|---|
| $\left[\frac{0}{0}\right]$ | • ដាក់ជាផលគុណកត្តា<br>• គុណកន្សោមឆ្លាស់ (រ៉ាឌីកាល់)<br>• ប្រើរូបមន្តត្រីកោណមាត្រ<br>• ប្រើវិធានឡូពីតាល់ | $\lim_{x\to a}\frac{P(x)}{Q(x)}=\lim_{x\to a}\frac{(x-a)P_1(x)}{(x-a)Q_1(x)}$ រួចសម្រួលកត្តារួម $(x-a)$ ចោល។<br>បើមានរ៉ាឌីកាល់ គុណនឹងកន្សោមឆ្លាស់<br>$(\sqrt{A}-\sqrt{B})(\sqrt{A}+\sqrt{B})=A-B$។ |
| $\left[\frac{\infty}{\infty}\right]$ | • ទាញតួដឺក្រេខ្ពស់បំផុត<br>• ចែកភាគយកនិងភាគបែង<br>• ប្រើវិធានឡូពីតាល់ | ទាញអថេរដែលមានស្វ័យគុណធំបំផុតនៅភាគយក និងភាគបែងជាកត្តារួម រួចសម្រួលចោល។ ប្រើលក្ខណ: $\lim_{x\to\pm\infty}\frac{k}{x^n}=0\ (n>0)$។ |
| $[0\times\infty]$ | • បំប្លែងទៅរាង $\left[\frac{0}{0}\right]$ ឬ $\left[\frac{\infty}{\infty}\right]$ | សរសេរ $f(x)\cdot g(x)=\frac{f(x)}{\frac{1}{g(x)}}$ ឬ $\frac{g(x)}{\frac{1}{f(x)}}$ រួចដោះស្រាយតាមក្បួន $\left[\frac{0}{0}\right]$ ឬ $\left[\frac{\infty}{\infty}\right]$។ |
| $[+\infty-\infty]$ | • គុណកន្សោមឆ្លាស់<br>• ទាញតួធំបំផុតជាកត្តា<br>• តម្រូវភាគបែងរួម | បើជាកន្សោមមានរ៉ាឌីកាល់ គុណនិងចែកនឹងកន្សោមឆ្លាស់។ បើជាកន្សោមពហុធា ទាញតួដែលមានស្វ័យគុណខ្ពស់ជាងគេជាកត្តារួម។ |
| $[1^{\infty}], [0^{0}], [\infty^{0}]$ | • ប្រើលោការីតនេពែរ<br>• រូបមន្ត $y=e^{\ln y}$ | តាង $L=\lim f(x)^{g(x)} \implies \ln L=\lim[g(x)\ln f(x)]$ ដែលនាំឱ្យលីមីតធ្លាក់ចូលរាង $[0\times\infty]$ រួចទាញយក $L=e^{\ln L}$។ |

### ៣. វិធានឡូពីតាល់ (L'Hôpital's Rule)

បើ $\lim_{x\to x_0}\frac{f(x)}{g(x)}$ មានរាងមិនកំណត់ $\left[\frac{0}{0}\right]$ ឬ $\left[\frac{\infty}{\infty}\right]$ ហើយ $f$ និង $g$ មានដេរីវេលើចន្លោះបើកដែលមានផ្ទុក $x_0$ ដោយ $g'(x)\neq 0$ នោះ ៖

$$\lim_{x\to x_0}\frac{f(x)}{g(x)}=\lim_{x\to x_0}\frac{f'(x)}{g'(x)}$$

សម្គាល់ ៖ វិធាននេះក៏នៅតែពិតចំពោះ $x\to\pm\infty$ ផងដែរ។ ប្រសិនបើលទ្ធផលដេរីវេលើកទីមួយនៅតែជាប់រាងមិនកំណត់ $\left[\frac{0}{0}\right]$ ឬ $\left[\frac{\infty}{\infty}\right]$ គេអាចបន្តអនុវត្តវិធានឡូពីតាល់ដេរីវេលើកទីពីរបាន។

### ៤. លីមីតគ្រឹះនៃអនុគមន៍អិចស្ប៉ូណង់ស្យែល និងលោការីតនេពែរ

**a.** $\lim_{x\to 0}\frac{e^x-1}{x}=1$

**b.** $\lim_{x\to 0}\frac{\ln(1+x)}{x}=1$

**c.** $\lim_{x\to\pm\infty}\left(1+\frac{1}{x}\right)^x=e$

**d.** $\lim_{x\to 0}(1+x)^{\frac{1}{x}}=e$

**e.** $\lim_{x\to 0}\frac{a^x-1}{x}=\ln a \quad (a>0, a\neq 1)$

**f.** $\lim_{x\to+\infty}\frac{e^x}{x^n}=+\infty \quad (n>0)$

**g.** $\lim_{x\to+\infty}\frac{x^n}{e^x}=0 \quad (n>0)$

**h.** $\lim_{x\to-\infty}x^n e^x=0 \quad (n\in\mathbb{N}^*)$

**i.** $\lim_{x\to+\infty}\frac{\ln x}{x^n}=0 \quad (n>0)$

**j.** $\lim_{x\to 0^+}x^n\ln x=0 \quad (n>0)$

### ៥. លីមីតគ្រឹះនៃអនុគមន៍ត្រីកោណមាត្រ

**a.** $\lim_{x\to 0}\frac{\sin x}{x}=1 \iff \lim_{u\to 0}\frac{\sin u}{u}=1$

**b.** $\lim_{x\to 0}\frac{\tan x}{x}=1 \iff \lim_{u\to 0}\frac{\tan u}{u}=1$

**c.** $\lim_{x\to 0}\frac{1-\cos x}{x^2}=\frac{1}{2}$

**d.** $\lim_{x\to 0}\frac{1-\cos x}{x}=0$

**e.** $\lim_{x\to 0}\frac{\arcsin x}{x}=1$

**f.** $\lim_{x\to 0}\frac{\arctan x}{x}=1$

# ឃ ៖ ជំហានទាំងស្រុងនៃការសិក្សាអថេរភាព និងសង់ក្រាប (ភាគ ១)

**ជំហានគ្រឹះទាំង ៨ ក្នុងការសិក្សាអថេរភាព និងសង់ក្រាបនៃអនុគមន៍ $y=f(x)$ ៖**

| ជំហាន | ខ្លឹមសារ | សកម្មភាព និងរូបមន្តសំខាន់ៗ |
|---|---|---|
| ជំហានទី ១ | ដែនកំណត់ $(D)$ | • រកសំណុំតម្លៃ $x$ ដែលធ្វើឱ្យកន្សោម $f(x)$ មានន័យ។<br>• ប្រភាគសនិទាន $\frac{P(x)}{Q(x)}$ មានន័យកាលណា $Q(x)\neq 0$។<br>• អនុគមន៍លោការីត $\ln(u)$ មានន័យកាលណា $u>0$។<br>• អនុគមន៍អសនិទាន $\sqrt{u}$ មានន័យកាលណា $u\geq 0$។ |
| ជំហានទី ២ | ទិសដៅអថេរភាព | • គណនាដេរីវេទីមួយ $f'(x)$ ដោយប្រើរូបមន្តដេរីវេត្រឹមត្រូវ។<br>• ដោះស្រាយសមីការ $f'(x)=0$ ដើម្បីរកចំណុចស្ថានីយ។<br>• សិក្សាសញ្ញានៃ $f'(x)$ លើចន្លោះនីមួយៗនៃដែនកំណត់ ៖<br>--- បើ $f'(x)>0$ លើ $I \Longrightarrow f$ ជាអនុគមន៍កើនលើ $I$ $(\nearrow)$។<br>--- បើ $f'(x)<0$ លើ $I \Longrightarrow f$ ជាអនុគមន៍ចុះលើ $I$ $(\searrow)$។ |
| ជំហានទី ៣ | តម្លៃបរមាធៀប | • បើ $f'(x)$ ប្តូរសញ្ញាពី $+$ ទៅ $-$ ត្រង់ $x_0 \Longrightarrow f$ មាន**អតិបរមាធៀប** $M=f(x_0)$។<br>• បើ $f'(x)$ ប្តូរសញ្ញាពី $-$ ទៅ $+$ ត្រង់ $x_0 \Longrightarrow f$ មាន**អប្បបរមាធៀប** $m=f(x_0)$។<br>• ករណី $f'(x_0)=0$ ហើយ $f''(x_0)<0 \Longrightarrow$ អតិបរមាធៀប។<br>• ករណី $f'(x_0)=0$ ហើយ $f''(x_0)>0 \Longrightarrow$ អប្បបរមាធៀប។ |
| ជំហានទី ៤ | លីមីតត្រង់ចុងដែន និងអាស៊ីមតូត | • **អាស៊ីមតូតឈរ ៖** បើ $\lim_{x\to x_0} f(x)=\pm\infty \Longrightarrow (L): x=x_0$ ជាអាស៊ីមតូតឈរ។<br>• **អាស៊ីមតូតដេក ៖** បើ $\lim_{x\to\pm\infty} f(x)=y_0 \Longrightarrow (D): y=y_0$ ជាអាស៊ីមតូតដេក។<br>• **អាស៊ីមតូតទ្រេត ៖** បើ $\lim_{x\to\pm\infty}[f(x)-(ax+b)]=0 \Longrightarrow (\Delta): y=ax+b$ $(a\neq 0)$ ជាអាស៊ីមតូតទ្រេត។ គេអាចរក $a,b$ ដោយចែកពហុធា ឬ $a=\lim_{x\to\pm\infty}\frac{f(x)}{x}$ និង $b=\lim_{x\to\pm\infty}[f(x)-ax]$។ |

# ឃ ៖ ជំហានទាំងស្រុងនៃការសិក្សាអថេរភាព និងសង់ក្រាប (ភាគ ២)

| ជំហាន | ខ្លឹមសារ | សកម្មភាព និងរូបមន្តសំខាន់ៗ |
|---|---|---|
| ជំហានទី ៥ | តារាងអថេរភាព | • រៀបចំជួរដេកចំនួន ៣ ៖ ជួរ $x$, ជួរ $f'(x)$, និងជួរ $f(x)$។<br>• បញ្ចូលដែនកំណត់, ឫសនៃ $f'(x)=0$, សញ្ញា $f'$, និងព្រួញបង្ហាញទិសដៅអថេរភាព ($f$ កើន $\nearrow$, $f$ ចុះ $\searrow$) ព្រមទាំងតម្លៃលីមីត និងតម្លៃបរមាធៀប។<br>• គូសបន្ទាត់ឈរពីរជាន់ ($\|$) ចំពោះតម្លៃ $x$ ដែលធ្វើឱ្យអនុគមន៍គ្មានន័យ។ |
| ជំហានទី ៦ | ភាពប៉ោង ផត និងចំណុចរបត់ | • គណនាដេរីវេទីពីរ $f''(x)$។<br>• បើ $f''(x)>0 \implies$ ក្រាបមានភាព**ផត** (ងើបឡើងលើ $\cup$)។<br>• បើ $f''(x)<0 \implies$ ក្រាបមានភាព**ប៉ោង** (កោងចុះក្រោម $\cap$)។<br>• បើ $f''(x_0)=0$ ហើយ $f''(x)$ ប្ដូរសញ្ញាពេលឆ្លងកាត់ $x_0 \implies I(x_0, f(x_0))$ ជា**ចំណុចរបត់**នៃខ្សែកោង។ |
| ជំហានទី ៧ | ផ្ចិតឆ្លុះ និងអ័ក្សឆ្លុះ | • $I(a,b)$ ជា**ផ្ចិតឆ្លុះ**នៃក្រាប $(C)$ លុះត្រាតែ $\forall x \in D \implies 2a-x \in D$ និង ៖<br>$f(2a-x)+f(x)=2b$<br>• បន្ទាត់ $(d): x=a$ ជា**អ័ក្សឆ្លុះ**នៃក្រាប $(C)$ លុះត្រាតែ $\forall x \in D \implies 2a-x \in D$ និង ៖<br>$f(2a-x)=f(x)$ |
| ជំហានទី ៨ | ចំណុចពិសេស និងការសង់ក្រាប | • រកចំណុចប្រសព្វជាមួយអ័ក្ស $Ox$ $(y=0)$ និងអ័ក្ស $Oy$ $(x=0)$។<br>• សង់តម្រុយអរតូណរម៉េ $(O,\vec{i},\vec{j})$ ឱ្យមានមាត្រដ្ឋានច្បាស់លាស់។<br>• គូសបន្ទាត់អាស៊ីមតូត (បន្ទាត់ដាច់ៗ), ចំណុចបរមា, ចំណុចរបត់, និងចំណុចជំនួយ។<br>• គូសខ្សែកោង $(C)$ ភ្ជាប់ចំណុចទាំងអស់ដោយរលូន ស្របតាមទិសដៅក្នុងតារាងអថេរភាព។ |

## ខ ៖ ធរណីមាត្រវិភាគ និងបន្ទាត់ប៉ះក្រាប (Tangents & Analytic Geometry)

### ១. សមីការបន្ទាត់ប៉ះ និងបន្ទាត់ប្រក្រតីនៃខ្សែកោង $(C): y = f(x)$

1. សមីការបន្ទាត់ប៉ះត្រង់ $M_0(x_0, y_0)$ ៖ $(T): y = f'(x_0)(x - x_0) + y_0$ (ដោយ $y_0 = f(x_0)$)
   មេគុណប្រាប់ទិសនៃបន្ទាត់ប៉ះត្រង់ $x_0$ គឺ $m = f'(x_0) = \tan\alpha$។
2. សមីការបន្ទាត់ប្រក្រតី (កែងនឹងបន្ទាត់ប៉ះត្រង់ $M_0$) ៖ $(N): y = -\dfrac{1}{f'(x_0)}(x - x_0) + y_0$ $(f'(x_0) \neq 0)$
3. បន្ទាត់ប៉ះចេញពីចំណុចក្រៅ $A(x_A, y_A)$ ៖ ដោះស្រាយសមីការ $y_A = f'(x_0)(x_A - x_0) + f(x_0)$ ទាញរក $x_0$។
4. បន្ទាត់ប៉ះស្រប ឬកែងនឹងបន្ទាត់ $(d): y = ax + b$ ៖
   - បើ $(T) \parallel (d) \implies f'(x_0) = a$
   - បើ $(T) \perp (d) \implies f'(x_0) = -\dfrac{1}{a}$ $(a \neq 0)$

### ២. ទីតាំងធៀបរវាងខ្សែកោង $(C): y = f(x)$ និងបន្ទាត់ $(d): y = ax + b$

ដើម្បីសិក្សាទីតាំងធៀបរវាងខ្សែកោង $(C)$ និងបន្ទាត់ $(d)$ គេត្រូវពិនិត្យសញ្ញានៃផលដក $D(x) = f(x) - (ax + b)$ ៖

- បើ $D(x) > 0$ ចំពោះ $x \in I \implies$ ខ្សែកោង $(C)$ ស្ថិតនៅ**ខាងលើ**បន្ទាត់ $(d)$ លើចន្លោះ $I$។
- បើ $D(x) < 0$ ចំពោះ $x \in I \implies$ ខ្សែកោង $(C)$ ស្ថិតនៅ**ខាងក្រោម**បន្ទាត់ $(d)$ លើចន្លោះ $I$។
- បើ $D(x) = 0$ ត្រង់ $x = x_1 \implies$ ខ្សែកោង $(C)$ **កាត់**បន្ទាត់ $(d)$ ត្រង់ចំណុច $M_1(x_1, f(x_1))$។

### ៣. រូបមន្តធរណីមាត្រវិភាគក្នុងប្លង់អរតូណរមេ $(O, \vec{i}, \vec{j})$

ចំពោះចំណុច $A(x_A, y_A)$, $B(x_B, y_B)$ និងបន្ទាត់ $(\Delta): Ax + By + C = 0$ ៖

a. ចម្ងាយរវាងពីរចំណុច $A$ និង $B$ ៖
$AB = \sqrt{(x_B - x_A)^2 + (y_B - y_A)^2}$

b. ចំណុចកណ្តាល $I$ នៃ $[AB]$ ៖
$x_I = \dfrac{x_A + x_B}{2}$, $y_I = \dfrac{y_A + y_B}{2}$

c. ចម្ងាយពីចំណុច $M_0(x_0, y_0)$ ទៅ $(\Delta)$ ៖
$d(M_0, \Delta) = \dfrac{|Ax_0 + By_0 + C|}{\sqrt{A^2 + B^2}}$

d. មេគុណប្រាប់ទិសបន្ទាត់ $(AB)$ ៖
$m = \dfrac{y_B - y_A}{x_B - x_A}$ $(x_A \neq x_B)$

e. សមីការបន្ទាត់កាត់តាម $A$ មាន $m$ ៖
$(d): y - y_A = m(x - x_A)$

f. មុំ $\theta$ រវាងពីរបន្ទាត់មានមេគុណ $m_1, m_2$ ៖
$\tan\theta = \left|\dfrac{m_1 - m_2}{1 + m_1 m_2}\right|$ $(m_1 m_2 \neq -1)$

# ច ៖ រូបមន្តត្រីកោណមាត្រ និងតារាងតម្លៃមុំពិសេស

## ១. រូបមន្តត្រីកោណមាត្រគ្រឹះ

- $\sin^2 x + \cos^2 x = 1$
- $1 + \tan^2 x = \dfrac{1}{\cos^2 x} \quad \left(x \neq \dfrac{\pi}{2} + k\pi\right)$
- $1 + \cot^2 x = \dfrac{1}{\sin^2 x} \quad (x \neq k\pi)$
- $\tan x \cdot \cot x = 1$
- $\tan x = \dfrac{\sin x}{\cos x}, \quad \cot x = \dfrac{\cos x}{\sin x}$
- $-1 \leq \sin x \leq 1, \quad -1 \leq \cos x \leq 1$

## ២. រូបមន្តផលបូក ផលដក មុំឌុប កន្លះមុំ និងបំប្លែងផលគុណ/ផលបូក

a. ផលបូក-ផលដក ៖ $\sin(a \pm b) = \sin a \cos b \pm \sin b \cos a, \quad \cos(a \pm b) = \cos a \cos b \mp \sin a \sin b$

b. មុំឌុប ៖ $\sin 2a = 2 \sin a \cos a, \quad \cos 2a = \cos^2 a - \sin^2 a = 2\cos^2 a - 1 = 1 - 2\sin^2 a$

c. កន្លះមុំ (បញ្ចុះដឺក្រេ) ៖ $\cos^2 a = \dfrac{1 + \cos 2a}{2}, \quad \sin^2 a = \dfrac{1 - \cos 2a}{2}, \quad \tan^2 a = \dfrac{1 - \cos 2a}{1 + \cos 2a}$

d. បំប្លែងផលបូកទៅផលគុណ ៖ $\sin p \pm \sin q = 2 \sin \frac{p \pm q}{2} \cos \frac{p \mp q}{2}, \quad \cos p + \cos q = 2 \cos \frac{p+q}{2} \cos \frac{p-q}{2}$

## ៣. តារាងតម្លៃអនុគមន៍ត្រីកោណមាត្រនៃមុំពិសេស

| មុំជាដឺក្រេ | $0^\circ$ | $30^\circ$ | $45^\circ$ | $60^\circ$ | $90^\circ$ | $120^\circ$ | $135^\circ$ | $150^\circ$ | $180^\circ$ |
|---|---|---|---|---|---|---|---|---|---|
| មុំជារ៉ាដ្យង់ $x$ | $0$ | $\frac{\pi}{6}$ | $\frac{\pi}{4}$ | $\frac{\pi}{3}$ | $\frac{\pi}{2}$ | $\frac{2\pi}{3}$ | $\frac{3\pi}{4}$ | $\frac{5\pi}{6}$ | $\pi$ |
| $\sin x$ | $0$ | $\frac{1}{2}$ | $\frac{\sqrt{2}}{2}$ | $\frac{\sqrt{3}}{2}$ | $1$ | $\frac{\sqrt{3}}{2}$ | $\frac{\sqrt{2}}{2}$ | $\frac{1}{2}$ | $0$ |
| $\cos x$ | $1$ | $\frac{\sqrt{3}}{2}$ | $\frac{\sqrt{2}}{2}$ | $\frac{1}{2}$ | $0$ | $-\frac{1}{2}$ | $-\frac{\sqrt{2}}{2}$ | $-\frac{\sqrt{3}}{2}$ | $-1$ |
| $\tan x$ | $0$ | $\frac{\sqrt{3}}{3}$ | $1$ | $\sqrt{3}$ | ‖ | $-\sqrt{3}$ | $-1$ | $-\frac{\sqrt{3}}{3}$ | $0$ |
| $\cot x$ | ‖ | $\sqrt{3}$ | $1$ | $\frac{\sqrt{3}}{3}$ | $0$ | $-\frac{\sqrt{3}}{3}$ | $-1$ | $-\sqrt{3}$ | ‖ |

**៤. សញ្ញាតាមការ៉ង់ទាំង ៤** (Signs by Quadrants) ៖ **I** $(\sin, \cos, \tan, \cot > 0)$; **II** $(\sin > 0$, ផ្សេងទៀត $< 0)$; **III** $(\tan, \cot > 0$, ផ្សេងទៀត $< 0)$; **IV** $(\cos > 0$, ផ្សេងទៀត $< 0)$

# ឯកសារយោង


1. **ក្រសួងអប់រំ យុវជន និងកីឡា** (២០១០-២០២៥) ៖ សៀវភៅសិក្សាគោល គណិតវិទ្យា ថ្នាក់ទី១២ កម្រិតខ្ពស់, នាយកដ្ឋានអភិវឌ្ឍន៍កម្មវិធីសិក្សា, រាជធានីភ្នំពេញ។

2. **ក្រសួងអប់រំ យុវជន និងកីឡា** (២០១០-២០២៥) ៖ សៀវភៅសិក្សាគោល គណិតវិទ្យា ថ្នាក់ទី១២ កម្រិតមូលដ្ឋាន, នាយកដ្ឋានអភិវឌ្ឍន៍កម្មវិធីសិក្សា, រាជធានីភ្នំពេញ។

3. **ក្រសួងអប់រំ យុវជន និងកីឡា** ៖ សៀវភៅគ្រូ គណិតវិទ្យា ថ្នាក់ទី១២, នាយកដ្ឋានអភិវឌ្ឍន៍កម្មវិធីសិក្សា, រាជធានីភ្នំពេញ។

4. **នាយកដ្ឋានជានាគុណភាពអប់រំ** ៖ កម្រងវិញ្ញាសាប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ (បាក់ឌុប) គណិតវិទ្យា (២០១៤-២០២៥), ក្រសួងអប់រំ យុវជន និងកីឡា។

5. **នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ** ៖ កម្រងវិញ្ញាសាប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេសផ្នែកគណិតវិទ្យា ថ្នាក់ទី១២, រាជធានីភ្នំពេញ។

6. **Stewart, James** (2016) ៖ *Calculus: Early Transcendentals* (8th Edition), Cengage Learning, Boston, USA.

7. **Thomas, George B., Weir, Maurice D., & Hass, Joel** (2018) ៖ *Thomas' Calculus* (14th Edition), Pearson Education, New York, USA.

8. **Larson, Ron, & Edwards, Bruce** (2018) ៖ *Calculus* (11th Edition), Cengage Learning, USA.

9. **Spivak, Michael** (2008) ៖ *Calculus* (4th Edition), Publish or Perish, Houston, Texas.